**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# ប្រាតិភោគចលនវត្ថុតាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា និង ក្រមរដ្ឋប្បវេណី

ស្រាវជ្រាវពីថ្ងៃទី ០១ ខែ មេសា ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១៦

តាក់តែងឡើងដោយ

និស្សិតឈ្មោះ៖ **ហំ សុគុណបុប្ផា**

សាស្ត្រាចារ្យណែនាំ

លោក **ខិន ខណ្ណារ៉ា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១ (**និស្សិតអាហារូបករណ៍**)

ឆ្នាំចូលសិក្សា ២០១២

ឆ្នាំសរសេរសារណា ២០១៦

# **សេចក្តីថ្លែងអំណរគុណ**

នាងខ្ញុំឈ្មោះ **ហាំ សុគុណបុប្ផា** ជានិស្សិតផ្នែកនីតិសាស្ត្រជំនាន់ទី២១ និងជានិស្សិតថ្នាក់អាហារូបករណ៍ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

*ជាបឋមសូមសំដែងនូវភាពកត្តញ្ញូតាធម៌ និងគោរពដឹងគុណដ៏ជ្រាលជ្រៅបំផុតចំពោះ៖*

១. អ្នកម្តាយ **យឹម សុធារី** និងលោកឪពុក **ម៉ែន ធាញ** ដែលបានបង្កើត ចិញ្ចឹមបីបាច់ ថែរក្សាយ៉ាងយកចិត្តទុកដាក់ និងប្រៀនប្រដៅរូបខ្ញុំឲ្យក្លាយជាកូនល្អ សិស្សល្អ និងពលរដ្ឋល្អ ព្រមទាំងជួយទំនុកបម្រុងទាំងថវិកា សម្ភារៈ និងកម្លាំងចិត្ត តាំងពីថ្នាក់កម្រិតបឋមសិក្សា រហូតមកដល់ថ្នាក់ឧត្តមសិក្សា។ បើគ្មានលោកទាំងពីរប្រហែលជារូបខ្ញុំគ្មានលទ្ធភាពបន្តការសិក្សាដូចសព្វថ្ងៃនេះទេ។

២. លោក **ខិន វណ្ណារ៉ា** ជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងជាគ្រូដឹកនាំផ្ទាល់លើប្រធានបទសារណាមួយនេះ។ លោកគ្រូបានជួយណែនាំផ្តល់ដំបូន្មានល្អៗ ចំណេះដឹង និងបទពិសោធន៍ច្រើន ដោយមិនគិតពីភាពនឿយហត់ពីការបង្រៀន ទោះបីជាមានភាពមមាញឹកយ៉ាងណាក៏លោកគ្រូតែងតែឆ្លៀតណែនាំនូវចំណុចដែលខ្វះខាតនានា។

៣. អ្នកស្រីមេធាវី **ទេព បូផល** ដែលតែងតែផ្តល់ឱកាសឲ្យនាងខ្ញុំចូលរួមសិក្សាសិក្ខាសាលានានា ដែលធ្វើរូបខ្ញុំកាន់តែមានសមត្ថភាព និងមានវិចារណកិច្ចគតិយុត្តកាន់តែច្រើនលើវិស័យច្បាប់ កាន់តែភ្លឺថ្លា។ លើសពីនេះ គាត់ក៏ជាអ្នកដែលពិគ្រោះយោបល់ នាពេលនាងខ្ញុំមានចម្ងល់និងបញ្ហាផ្សេងៗ ដែលពិបាកយល់ក្នុងការសរសេរសារណានេះ។

៤. លោក **កែវ បុរិម៉ា** ជាប្រធានការិយាល័យតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានានៅក្រសួងពាណិជ្ជកម្ម ដែលបានជួយសម្រួលដល់រូបនាងខ្ញុំជាច្រើន កំឡុងពេលចុះស្រាវជ្រាវឯកសារនៅទីនោះ។ លោកបានជួយបង្ហាញបន្ថែមនូវចំណុចសំខាន់នៃការស្រាវជ្រាវឲ្យកាន់តែមានប្រសិទ្ធិភាព និងផ្តល់ជាឯកសារទាំងឡាយ ទោះបីជាបងប្រុសមានការរវល់នឹងភារកិច្ចរបស់ខ្លួនយ៉ាងមម៉ាញឹកយ៉ាងណាក៏ដោយ។

គុណបំណាច់ដ៏ថ្លៃថ្លានេះ នាងខ្ញុំសូមលើកហត្ថាទាំងទ្វេរបួងសួងដល់អស់ទេព្តា និងវត្ថុស័ក្តិសិទ្ធិទាំអស់ សូមជួយឃុំគ្រង ថែរក្សា ការពារ អ្នកម្តាយ លោកឪពុក បងប្រុសស្រី លោកគ្រូអ្នកគ្រូសាស្ត្រាចារ្យទាំងអស់ ឲ្យជួបប្រទះតែសេចក្តីសុខ សុខភាពល្អ អាយុយឺនយូរ ទ្រព្យសម្បត្តិបរិបូរ និងជួបនូវពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ៕

# អារម្ភកថា

អត្ថបទសារណាដែលមានចំណងជើង "**ប្រាតិភោគចលនវត្ថុតាមច្បាប់ស្ដីពីប្រតិបត្តិការដែលមានកិច្ចធានា និង ក្រមរដ្ឋប្បវេណី**" នេះគឺជាសមិទ្ធផលដ៏មានសារៈសំខាន់ដែលត្រូវបានរៀបចំ និងចងក្រងដោយនាងខ្ញុំផ្ទាល់តាមរយៈការខិតខំប្រឹងប្រែង និងព្យាយាមឥតមានពេលសម្រាកអស់រយៈពេលប៉ុន្មានខែកន្លងមកនេះ។ ការតាក់តែងសារណាដើម្បីបញ្ចប់ការសិក្សាគឺមានភាពពិបាកច្រើនជាងការប្រលងបញ្ចប់ ប៉ុន្តែក្នុងនាមនាងខ្ញុំជានិស្សិតស្វាធ្យាយមួយរូប ពិតជាចង់ចែករំលែកនូវចំណុចអ្វីថ្មី ដែលរូបខ្ញុំយល់ថាអាចមានភាពពិបាកសម្រាប់អ្នកសិក្សាយកទៅស្រាវជ្រាវ និងអនុវត្តនាពេលបច្ចុប្បន្នក៏ដូចជាអនាគត។

ជាការពិត ការសេរសេរសារណាមួយនេះចេញជារូបរាងឡើង ចំណាយនូវកម្លាំងពលកម្ម ការគិត និងវិភាគគ្រប់ដំណាក់ការនៃការតាក់តែង។ ចំពោះឯកសារវិញនោះ គឺមានជាច្រើនដែលត្រូវអាន និងស្រាវជ្រាវក្នុងទីកន្លែងផ្សេងៗគ្នាដូចជា នៅតាមបណ្ណាល័យ ឯកសារតម្កល់ទុកនៅក្រសួងដែលពាក់ព័ន្ធ នៅតាមបណ្ដាញអ៊ិនធឺណិត ព្រមទាំងត្រូវធ្វើការសាកសួរ និងពិគ្រោះយោបល់ជាមួយអ្នកជំនាញនានាដែលមានចំណេះដឹងខាងផ្នែកនេះ ទើបហ៊ានសម្រេចតាក់តែងនូវឃ្លាឃ្លោងនីមួយៗឡើង។ សរុបមក សារណាបទមួយនេះគឺជាសមិទ្ធិផលថ្មីមួយ ដែលបានឆ្លងកាត់នូវការត្រិះរិះពិចារណា និងការសិក្សាស្រាវជ្រាវអស់រយៈពេលជាច្រើន រហូតឈានដល់ដំណាក់កាលបញ្ចប់ជាស្ថាពរ។ ស្នាដៃនេះមិនមែនកើតចេញពីភាពស្រមើលស្រម៉ៃ ឬភាពស្រពិចស្រពិលនោះទេ គឺកើតចេញពីការខិតខំប្រឹងប្រែងដោយប្រើអស់កម្លាំងកាយចិត្ត និងស្មារតី។

ជាទីបញ្ចប់ ខ្ញុំសង្ឃឹមថា ស្នាដៃដ៏តូចមួយនេះនឹងក្លាយជាឯកសារថ្មី និងប្លែក ដើម្បីផ្ដល់នូវអត្ថប្រយោជន៍ខ្លះៗដល់អ្នកសិក្សាស្រាវជ្រាវដទៃទៀតពាក់ព័ន្ធនឹងប្រាតិភោគចលនវត្ថុ ឲ្យកាន់តែយល់ដឹងស៊ីជម្រៅពីការប្រើប្រាស់ និងការអនុវត្ត។ ទោះបីជាខ្ញុំជានិស្សិតថ្នាក់បញ្ចប់បរិញ្ញាបត្រក៏ប៉ុន្តែ ការបង្កើតនូវកំហុសខុសឆ្គងជាមួយនឹងការប្រើប្រាស់ពាក្យពេចន៍មួយចំនួន ក៏ដូចជាទ្រឹស្ដីប្រាកដជាជៀសមិនផុតនោះទេ ដូច្នេះសូមមេត្តាអភ័យទោសចំពោះបញ្ហាទាំងនេះ។ រូបខ្ញុំសូមស្វាគមន៍នូវរាល់មតិរិះគន់ពីសំណាក់បញ្ញាវ័ន្ត និងអ្នកអានទាំងអស់ចូលរួមកែសម្រួល និងបំពេញបន្ថែមនូវចំណុចខ្វះខាតទាំងឡាយដែលកើតឡើងដោយអចេតនា៕

# មាតិកា

**សេចក្តីផ្តើម** ............ ១

**ជំពូកទី១ របបគតិយុត្តនៃប្រាតិភោគចលនវត្ថុ តាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា**

**១.១. សញ្ញាណទូទៅ** ............ **៧**

១.១.១. ប្រភពនៃប្រតិបត្តិការដែលមានកិច្ចធានា ............ ៧

១.១.២. គោលបំណង នៃការបង្កើត ............ ១០

១.១.៣. ការវិវត្តប្រតិបត្តិការដែលមានកិច្ចធានានៅកម្ពុជា ............ ១១

**១.២. ការបង្កើតប្រតិបត្តិការដែលមានកិច្ចធានា** ............ **១២**

១.២.១. វិសាលភាពនៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ............ ១៣

១.២.១.១.ប្រភេទទ្រព្យធានារូបិយដែលស្ថិតនៅក្រោមវិសាលភាពនៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ............ ១៣

១.២.១.២.ប្រភេទទ្រព្យធានាអរូបិយដែលស្ថិតក្រោមវិសាលភាពនៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ............ ១៥

១.២.១.៣. ប្រតិបត្តិការដែលមិនស្ថិតនៅក្រោមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ............ ១៦

១.២.២. ការបង្កើតកិច្ចព្រមព្រៀងប្រាក់កម្ចី និងកិច្ចព្រមព្រៀងប្រាតិភោគដែលមានសុពលភាព ............ ១៧

១.២.២.១. កិច្ចព្រមព្រៀងប្រាក់កម្ចី ............ ១៧

១.២.២.២. កិច្ចព្រមព្រៀងប្រាតិភោគ ឬការភ្ជាប់សិទ្ធិប្រាតិភោគ ........................... ១៨
ក. លក្ខខណ្ឌទី១៖ អត្ថិភាពនៃកិច្ចព្រមព្រៀងប្រាតិភោគ ................... ១៨
ខ. លក្ខខណ្ឌទី២៖ កូនបំណុលត្រូវទទួលតម្លៃអ្វីមួយ ........................ ១៩
គ. លក្ខខណ្ឌទី៣៖ កូនបំណុលត្រូវមានសិទ្ធិអ្វីមួយលើទ្រព្យធានា ..... ១៩
១.២.២.៣. ប្រសិទ្ធិភាពនៃកិច្ចព្រមព្រៀងប្រាតិភោគ ..................................... ២០
១.២.៣. ការធ្វើសុក្រឹតកម្មលើសិទ្ធិប្រាតិភោគ ......................................................... ២១
១.២.៣.១. មធ្យោបាយនៃការធ្វើសុក្រឹតកម្ម ................................................. ២២
ក. ការតម្កល់លិខិតជូនដំណឹង និងការកាន់កាប់ .............................. ២២
ក.១.ការតម្កល់លិខិតជូនដំណឹង ........................................... ២២
ក.២. ការកាន់កាប់ទ្រព្យធានាដោយម្ចាស់បំណុល .................. ២៤
ខ.សុក្រឹតកម្មដោយស្វ័យប្រវត្តិនៅពេលភ្ជាប់សិទ្ធិប្រាតិភោគលើប្រាក់ខ្ចីទិញទំនិញប្រើប្រាស់ ........................................................... ២៤
ខ.១. សុក្រឹតកម្មដោយស្វ័យប្រវត្តិ ........................................ ២៤
ខ.២.អានុភាពរបស់សិទ្ធិប្រាតិភោគលើប្រាក់ខ្ចីទិញទំនិញប្រើប្រាស់ ..................................................................... ២៥
១.២.៣.២. ការធ្វើសុក្រឹតកម្មលើប្រភេទទ្រព្យធានាផ្សេងៗទៀត .................. ២៥
ក. សុក្រឹតកម្មលើយានយន្តដែលមានលេខស៊េរី ............................. ២៦
ខ. សុក្រឹតកម្មលើឯកសារកម្មសិទ្ធិ ................................................. ២៦
១.២.៣.៣. ការធ្វើសុក្រឹតកម្មលើផលនៃទ្រព្យធានា .................................... ២៧
ក. សុក្រឹតកម្មលើផលដោយស្វ័យប្រវត្តិ ........................................ ២៧
ខ. ការតម្កល់លិខិតជូនដំណឹងទៅលើផលនៃទ្រព្យធានា ................. ២៧

**១.៣. ការអនុវត្តសិទ្ធិរបស់ម្ចាស់បំណុលដែលមានកិច្ចធានា ..... ២៨**

១.៣.១. លក្ខខណ្ឌ និងយន្តការប្រើប្រាស់ដើម្បីអនុវត្តសិទ្ធិ ..... ២៨

១.៣.១.១. លក្ខខណ្ឌដើម្បីអនុវត្តសិទ្ធិ ..... ២៨

១.៣.១.២. យន្តការដែលម្ចាស់បំណុលអាចប្រើប្រាស់ដើម្បីអនុវត្តសិទ្ធិ ..... ២៨

១.៣.២. សិទ្ធិលោះទ្រព្យធានា និងការជម្រះទ្រព្យធានា ..... ២៩

១.៣.២.១. ការអនុវត្តសិទ្ធិលោះមកវិញនូវទ្រព្យធានា ..... ២៩

១.៣.២.២. ការជម្រះទ្រព្យធានា ..... ៣០

១.៣.៣. វិបាកនៃការអនុវត្តសិទ្ធិ ..... ៣១

១.៣.៣.១. វិបាកពាក់ព័ន្ធនឹងអ្នកទិញទ្រព្យធានា និងផលទទួលបានពីទ្រព្យធានា ..... ៣១

១.៣.៣.២.វិបាកទាក់ទងនឹងប្រាតិភោគចំពោះប្រាក់ខ្ចីទិញទំនិញ ឧបករណ៍ និងសារពើភណ្ឌ ..... ៣៣

## ជំពូកទី២ ការសិក្សាប្រៀបធៀបប្រាតិភោគចលនវត្ថុ តាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា និង ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

**២.១. ប្រតិបត្តិការដែលមានកិច្ចធានា និងការបញ្ចាំចលនវត្ថុតាមក្រមរដ្ឋប្បវេណី ...៣៦**

២.១.១. លក្ខណៈរួម ..... ៣៦

២.១.១.១. ប្រភេទនៃទ្រព្យដែលអាចដាក់ប្រាតិភោគ ..... ៣៦

ក.ទ្រព្យរូបិយ ..... ៣៦

ខ. ទ្រព្យអរូបិយ ..... ៣៧

២.១.១.២. លក្ខខណ្ឌសុពលភាពនៃការបង្កើតសិទ្ធិប្រាតិភោគដែលត្រឹមត្រូវ . ៣៨

ក. ការព្រមព្រៀង ..... ៣៨

ខ. សមត្ថភាពភាគី ..... ៣៩

គ. កម្មវត្ថុ ..... ៤០

២.១.១.៣. ការអនុញ្ញាតឲ្យមានតតិយជនធានាដោយវត្ថុ ............................ ៤០
ក. អ្នកធានានៅក្នុងរបបគតិយុត្តនៃការបញ្ចាំ .................................. ៤០
ខ. អ្នកធានានៅក្នុងរបបគតិយុត្តនៃប្រតិបត្តិការដែលមានកិច្ចធានា.... ៤១
២.១.១.៤. វត្ថុមាននូវលក្ខខណ្ឌអានុភាព និងលក្ខខណ្ឌតតាំងដូចគ្នា............ ៤១
ក. លក្ខខណ្ឌអានុភាព .................................................................. ៤១
ខ.លក្ខខណ្ឌតតាំង ........................................................................ ៤២
២.១.១.៥. អានុភាពនៃសិទ្ធិប្រាតិភោគ ..................................................... ៤៣
ក. អានុភាពនៃឃាត់ទុកទៅលើទ្រព្យធានា ..................................... ៤៣
ខ. អានុភាពទៅលើផលដែលកើតចេញមកពីទ្រព្យដែលដាក់ធានា.... ៤៤
២.១.១.៦. ការអនុវត្តសិទ្ធិប្រាតិភោគ ........................................................ ៤៤
ក. ករណីសិទ្ធិលើបំណុលច្រើនមានលើចលនវត្ថុតែមួយ និងលំដាប់
នៃសិទ្ធិ...................................................................................... ៤៤
ខ.លំដាប់នៃការទូទាត់ផលដែលបានមកពីការជម្រះទ្រព្យធានា ........ ៤៦
២.១.១.៧. សិទ្ធិក្នុងការទិញទ្រព្យធានានាពេលជម្រះ និងអានុភាពនៃសិទ្ធិ
ប្រាតិភោគលើអ្នកទិញទ្រព្យធានា ................................................................៤៧
ក. សិទ្ធិក្នុងការទិញទ្រព្យធានានាពេលជម្រះ...................................៤៧
ខ. អានុភាពនៃសិទ្ធិប្រាតិភោគទៅលើអ្នកទិញទ្រព្យធានា ................ ៤៨
២.១.២. លក្ខណៈដោយឡែក .................................................................................. ៤៩
២.១.២.១. បរិបទ និងគោលគំនិតខុសគ្នា ................................................... ៤៩
ក. ប្រាតិភោគចលនវត្ថុតាមសណ្ឋានប្រតិបត្តិការដែលមានកិច្ចធានា... ៤៩
ខ. ប្រាតិភោគចលនវត្ថុតាមសណ្ឋាននៃការបញ្ចាំ .......................... ៤៩
២.១.២.២.លក្ខខណ្ឌនៃការបង្កើតកិច្ចព្រមព្រៀងប្រាតិភោគរបស់ប្រតិបត្តិការ
ដែលមានកិច្ចធានា........................................................................... ៥០

ក.លក្ខខណ្ឌក្នុងការសរសេរជាលាយលក្ខណ៍អក្សរ ......................... ៥០
ខ. ធាតុផ្សំសំខាន់ទាំងបីនៃកិច្ចព្រមព្រៀងប្រាតិភោគ ........................ ៥១
២.១.២.៣. អានុភាពនៃសិទ្ធិប្រាតិភោគទៅលើប្រភេទចលនវត្ថុផ្សេងៗ.......... ៥២
ក. ករណីបង្កើតប្រាតិភោគលើវត្ថុចំណុះ និងវត្ថុចម្រុះ....................... ៥២
ខ. ករណីបង្កើតប្រាតិភោគលើចលនវត្ថុតាំងភ្ជាប់............................ ៥៣
២.១.២.៤. អត្ថិភាពនៃលក្ខខណ្ឌតតាំងសំខាន់ៗផ្សេងគ្នា ............................... ៥៤
ក. លក្ខខណ្ឌតតាំងរបស់សិទ្ធិលើការបញ្ចាំ ...................................... ៥៤
ខ. លក្ខខណ្ឌតតាំងរបស់ប្រតិបត្តិការដែលមានកិច្ចធានា.................. ៥៥
២.១.២.៥. ភាពដោយឡែកពីគ្នានៃការអនុវត្តសិទ្ធិប្រាតិភោគ ........................ ៥៦
ក. ការអនុវត្តសិទ្ធិរបស់ម្ចាស់បំណុលតាមច្បាប់ស្តីពីប្រតិបត្តិការ
ដែលមានកិច្ចធានា ........................................................................... ៥៦
ខ. ការអនុវត្តសិទ្ធិរបស់ម្ចាស់សិទ្ធិលើការបញ្ចាំទៅលើវត្ថុបញ្ចាំ ..........៥៧
ខ.១. ការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប ....................... ៥៨
ខ.២. ការអនុវត្តសិទ្ធិលើការបញ្ចាំតាមរយៈការអនុវត្តដោយ
បង្ខំលើសិទ្ធិប្រាតិភោគចលនវត្ថុ................................................ ៥៩
**២.២. ប្រតិបត្តិការដែលមានកិច្ចធានា និង ប្រាតិភោគដោយអនុប្បទានតាមក្រមរដ្ឋប្បវេណី .............................................................................................៥៩**
២.២.១.លក្ខណៈរួម ...................................................................................... ៦០
២.២.១.១. កម្មវត្ថុនៃការបង្កើត ........................................................... ៦០
ក. ចលនវត្ថុរូបិយ ................................................................... ៦០
ខ.ចលនវត្ថុផ្គុំគ្នា ...................................................................... ៦១
២.២.១.២. អានុភាពលើវត្ថុដែលភ្ជាប់នឹងកម្មវត្ថុនៃប្រាតិភោគ ....................... ៦២
ក. សមាសភាគនៃវត្ថុ .............................................................. ៦២
ខ. ប្រាតិភោគលើវត្ថុចំណុះ និងវត្ថុចម្រុះ.......................................... ៦២

២.២.១.៣. ទំហំសិទ្ធិលើបំណុល និងសិទ្ធិទាមទារឲ្យសងសោហ៊ុយ...............៦៣

ក. ទំហំនៃសិទ្ធិលើបំណុលដែលត្រូវធានា ...................................... ៦៣

ខ. សិទ្ធិទាមទារឲ្យសងសោហ៊ុយ.................................................... ៦៤

២.២.១.៤. វត្តមាននៃអានុភាពចំពោះផលដែលកើតចេញពីទ្រព្យធានា.......... ៦៥

ក. ប្រាតិភោគដោយអនុប្បទាន .................................................... ៦៥

ខ. ប្រតិបត្តិការដែលមានកិច្ចធានា ............................................... ៦៦

២.២.១.៥.ការផ្តល់លទ្ធភាពក្នុងការអនុវត្តសិទ្ធិលោះទ្រព្យធានា..................... ៦៦

២.២.២. លក្ខណៈដោយឡែក .......................................................................៦៧

២.២.២.១. លក្ខខណ្ឌនៃការបង្កើត .............................................................៦៧

ក. ការបង្កើតប្រាតិភោគដោយអនុប្បទាន .......................................៦៧

ខ. ការបង្កើតប្រតិបត្តិការដែលមានកិច្ចធានា .................................... ៦៩

២.២.២.២. អត្ថិភាពនូវសិទ្ធិតតាំងផ្សេងគ្នា .................................................... ៦៩

ក. សិទ្ធិតតាំងរបស់ប្រតិបត្តិការដែលមានកិច្ចធានា........................... ៦៩

ខ. សិទ្ធិតតាំងរបស់ប្រាតិភោគដោយអនុប្បទាន...............................៧០

២.២.២.៣. ការចាត់ចែងកម្មវត្ថុនៃប្រាតិភោគ.................................................៧១

ក.ការចាត់ចែងដោយម្ចាស់សិទ្ធិប្រាតិភោគ.......................................៧១

ខ.ការចាត់ចែងដោយអ្នកបង្កើតសិទ្ធិប្រាតិភោគ...............................៧១

២.២.២.៤. សិទ្ធិ និងដំណោះស្រាយរបស់ម្ចាស់សិទ្ធិករណីមិនសងកាតព្វកិច្ច...៧៣

ក. ការអនុវត្តសិទ្ធិរបស់ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន .........៧៣

ខ. ការអនុវត្តសិទ្ធិរបស់ម្ចាស់បំណុលដែលមានកិច្ចធានា..................៧៣

**២.៣. ការអនុវត្តបញ្ញត្តិរួម និង ការសម្របសម្រួលការអនុវត្តប្រាតិភោគចលនវត្ថុ រវាងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា និង ក្រមរដ្ឋប្បវេណី.................... ៧៥**

២.៣.១. ការអនុវត្តបញ្ញត្តិរួមគ្នាក្នុងការការពារបុគ្គលសុចរិត.................................. ៧៥

២.៣.១.១. អានុភាពតាមនៃសិទ្ធិប្រាតិភោគប្រត្យក្ស និងលទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុដោយតតិយជន.......................................................៧៦

២.៣.១.២. អនុប្បទានសិទ្ធិលើបំណុលដែលសិទ្ធិប្រត្យក្សត្រូវបានបង្កើតដោយម្ចាស់សិទ្ធិប្រាតិភោគទៅលើតតិយជន..................................................៧៧

២.៣.១.៣. ករណីការធ្វើអនុប្បទាននូវវត្ថុលួច ឬវត្ថុបាត់ ...............................៧៨

២.៣.១.៤. ករណីឧបាទេសកម្មលើកម្មវត្ថុនៃសិទ្ធិប្រាតិភោគ.........................៧៩

២.៣.២. ការសម្របសម្រួលការអនុវត្តប្រាតិភោគចលនវត្ថុ...................................... ៨០

២.៣.២.១.អានុភាពនៃប្រតិបត្តិការដែលបង្កើតមុនកាលបរិច្ឆេទចូលជាធរមាននៃក្រមរដ្ឋប្បវេណី ............................................................................................ ៨១

២.៣.២.២.ការផ្លាស់ប្តូររបបគតិយុត្តនៃប្រតិបត្តិការប្រាតិភោគចលនវត្ថុ ......... ៨១

២.៣.២.៣. ការបែងចែកលក្ខណៈសម្គាល់រវាងប្រតិបត្តិការដែលមានកិច្ចធានានិង ប្រតិបត្តិការតាមក្រមរដ្ឋប្បវេណី ............................................................៨២

២.៣.២.៤. អាទិភាពនៃប្រតិបត្តិការពីរដែលបង្កើតលើចលនវត្ថុតែមួយ......... ៨៣

**សេចក្តីសន្និដ្ឋាន...............................................................................................៨៥**

**អនុសាសន៍....................................................................................................................៨៨**

**គន្ថនិទ្ទេស**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ទ្រព្យជាចលនវត្ថុ ត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយដើម្បីធ្វើជាទ្រព្យធានានៅក្នុងប្រទេសឧស្សាហកម្មភាគច្រើន ដូចជានៅសហរដ្ឋអាមេរិក ដែលពាក់កណ្តាលនៃការផ្តល់ឥណទានគឺធានាដោយចលនវត្ថុ ទាំងក្នុងធនាគារ និងស្ថាប័នហិរញ្ញវត្ថុដទៃទៀត។ ចំណែកឯនៅប្រទេសកំពុងអភិវឌ្ឍវិញ ខាងស្ថាប័នផ្តល់ប្រាក់កម្ចីឯកជនមិនសូវផ្តល់ប្រាក់កម្ចីដោយប្រើចលនវត្ថុធ្វើជាទ្រព្យធានានោះទេ លុះត្រាតែលក្ខខណ្ឌពីរត្រូវបានបំពេញដែលលក្ខខណ្ឌទី១គឺ លុះត្រាអ្នកខ្ចីមានអចលនវត្ថុដើម្បីសង និងលក្ខខណ្ឌទី២ គឺអ្នកខ្ចីត្រូវដាក់ចលនវត្ថុនៅក្នុងដៃនៃការកាន់កាប់របស់អ្នកឲ្យខ្ចី។ ក្រៅពីនេះ អ្នកខ្ចីនៅមានជម្រើសផ្សេងទៀតគឺការទទួលប្រាក់កម្ចីដោយមិនចាំបាច់ដាក់ប្រាតិភោគដែលជាប្រភេទការផ្តល់ប្រាក់ដោយគ្មានកិច្ចធានា តែត្រូវជំនួសមកវិញនូវការប្រាក់ខ្ពស់ខ្លាំង និងកំណត់នូវកាលបរិច្ឆេទត្រូវសងក្នុងរយៈពេលខ្លី។ ករណីដែលមិនទទួលយកឧបករណ៍ សារពើភណ្ឌ ឬ ដំណាំ ជាមូលហេតុធ្វើឲ្យមានវិបត្តិហិរញ្ញវត្ថុយ៉ាងខ្លាំងនៅក្នុងការវិនិយោគនៅប្រទេសកំពុងអភិវឌ្ឍ ព្រោះវាបានរាំងនូវការអភិវឌ្ឍផ្នែកឧស្សាហកម្ម និងកសិកម្ម។

ជាក់ស្តែងនៅប្រទេសកម្ពុជា ក៏មិនខុសគ្នាពីបណ្តាប្រទេសកំពុងអភិវឌ្ឍទាំងនោះដែរ ព្រោះថាធនាគារភាគច្រើនបង្កើតគោលនយោបាយសម្រាប់ការផ្តល់ប្រាក់កម្ចី តែទៅលើការដាក់អចលនវត្ថុធ្វើជាទ្រព្យធានាតែប៉ុណ្ណោះ ពីព្រោះតម្លៃអចលនវត្ថុគឺខ្ពស់ជាងចលនវត្ថុ ហេតុដូចនេះហើយអាចធានានូវការសងបានគ្រប់គ្រាន់ជាងចលនវត្ថុ។ ពេលខ្លះការផ្តល់ប្រាក់កម្ចី គឺតម្រូវនូវការប្រាក់ខ្ពស់ ដែលធ្វើឲ្យអ្នកខ្ចីភាគច្រើនមានការរារែកក្នុងការទទួលប្រាក់កម្ចី ដោយសារតែខ្លួនពុំមានអចលនទ្រព្យទៅដាក់ប្រាតិភោគ។ បញ្ហាដែលសង្កេតឃើញមានកន្លងមក ពាក់ព័ន្ធនឹងការបញ្ចាំគឺគេប្រើត្រឹមតែប័ណ្ណសម្គាល់យានយន្ត ជាភាសាសាមញ្ញគេហៅកាតគ្រីម៉ូតូ ទៅដាក់បញ្ចាំដោយមានការយល់ព្រមពីម្ចាស់បំណុលផងដែរ។ តែនេះវាមានភាពប្រថុយប្រថានចំពោះម្ចាស់បំណុល ពីព្រោះទ្រព្យធានានៅនឹងកូនបំណុល ចំណែកកាតគ្រីដែលសម្គាល់ម្ចាស់លើយានយន្ត អាចនឹងធ្វើថ្មីដោយកូនបំណុលបានគ្រប់ពេល។ ការអនុវត្តបែបនេះ បង្កមកពីខ្វះភាពយល់ដឹងពីច្បាប់ និងលក្ខខណ្ឌនៃការអនុវត្ត ដែលធ្វើឲ្យទាំងម្ចាស់បំណុល និងកូនបំណុលអនុវត្តមិនចំប្រភេទនៃរបបគតិយុត្ត ជាហេតុបង្កជាអលទ្ធភាពក្នុងការអនុវត្តសិទ្ធិប្រាតិភោគដែលខ្វះលក្ខខណ្ឌនេះទៅថ្ងៃអនាគត នាពេលជម្លោះកើតមានឡើង។

ដើម្បីបង្កើតជាឧបករណ៍គតិយុត្តគ្រប់គ្រងទៅលើការដាក់ចលនវត្ថុធ្វើជាទ្រព្យធានា និងធានាការអនុវត្តឲ្យមានប្រសិទ្ធិភាព ទើបលេចឡើងនូវវត្តមាននៃច្បាប់ពីរសំខាន់ៗ ក្នុងនោះដែរសង្កេត

ឃើញមានច្បាប់ពាណិជ្ជកម្ម និងក្រមរដ្ឋប្បវេណីដែលបានកំណត់ពីការធានាកាតព្វកិច្ចដោយចលនទ្រព្យ ព្រោះនេះជារឿងធម្មតាកើតឡើងនៅក្នុងសង្គមជាប្រចាំ ដោយសារតែសង្វាក់ផលិតកម្ម និងពាណិជ្ជកម្មកើនឡើង នាំមកនូវតម្រូវការនៃសាច់ប្រាក់ក៏កើនឡើងតាមនោះ។ ក្នុងចំណោមច្បាប់ពាណិជ្ជកម្មជាច្រើន ឃើញមានច្បាប់ពិសេសមួយដែលកំណត់ពីប្រាតិភោគប្រត្យក្សស្រដៀងទៅនឹងរបបគតិយុត្តដែលកំណត់ដោយក្រមរដ្ឋប្បវេណី។ សិទ្ធិប្រាតិភោគប្រត្យក្សនេះបើតាមពាក្យបាលីប្រែមកថាការយកទ្រព្យសម្បត្តិទៅធានាបំណុល ដូចនេះប្រាតិភោគប្រត្យក្សមានកំណើតឡើងដើម្បីធានាសិទ្ធិលើបំណុល ដែលប្រជាពលរដ្ឋធម្មតាតែងតែនិយាយថា យកទ្រព្យទៅដាក់ធានាដើម្បីខ្ចីបំណុល ហើយបើគ្មានលុយសងទេ ម្ចាស់បំណុលនឹងរឹបអូសទ្រព្យធានានោះ។ ដូច្នេះសិទ្ធិប្រាតិភោគប្រត្យក្សគឺ គ្មានអ្វីក្រៅពីសិទ្ធិដែលបានបង្កើតឡើងដើម្បីជាការធានាសិទ្ធិលើបំណុលដែលសន្មតថាមានអត្ថិភាពរួចហើយនោះទេ។ ដោយសារតែលក្ខណៈនៃសិទ្ធិប្រត្យក្សជាសិទ្ធិដែលអាចអះអាងបានទៅនឹងបុគ្គលគ្រប់រូបរួមទាំងតតិយជនផងនោះ ដូចនេះទើបក្រមរដ្ឋប្បវេណីធ្វើការកំណត់នូវប្រភេទនៃសិទ្ធិប្រាតិភោគប្រត្យក្សយ៉ាងច្បាស់លាស់ និងហាមឃាត់ការបង្កើតនូវសិទ្ធិប្រាតិភោគប្រត្យក្សប្រភេទថ្មី លើកលែងតែមានច្បាប់ពិសេស។

សិទ្ធិប្រាតិភោគប្រត្យក្សដែលកំណត់ដោយក្រមរដ្ឋប្បវេណីនេះ បានបង្កើតជាមធ្យោបាយសម្រាប់ការខ្ចីបំណុលដោយការដាក់ទ្រព្យធានា ហើយក្នុងករណីស្ទើតែទាំងអស់ដែលភាគីអ្នកឲ្យខ្ចីនឹងទទួលបានអ្វីមួយធ្វើជាប្រាតិភោគសម្រាប់ការពារករណីដែលអ្នកខ្ចីមិនសងបំណុល ដែលតាមរយៈនោះអ្នកឲ្យខ្ចី អាចធ្វើការលក់ដោយបង្ខំដើម្បីប្តូរជាសាច់ប្រាក់មកសងប្រាក់កម្ចីនោះវិញ។ ក្នុងស្ថានភាពនេះ ដែលកូនបំណុលត្រូវប្រគល់វត្ថុដើម្បីធានាការខ្ចីរបស់ខ្លួន ហើយវត្ថុធានាមិនអាចត្រូវបានប្រើប្រាស់បានទៀតទេ ព្រោះត្រូវប្រគល់ឲ្យម្ចាស់បំណុល។ បើវត្ថុដែលជាកម្មវត្ថុនៃការធានាកាតព្វកិច្ច នៅនឹងដៃម្ចាស់បំណុលជាដរាបដូច្នេះ កូនបំណុលត្រូវអស់សិទ្ធិក្នុងការប្រើប្រាស់វត្ថុនេះជាបណ្តោះអាសន្ន ហើយបើមានបំណងធ្វើអាជីវកម្មដោយប្រើវត្ថុនេះក៏មិនអាចទៅរួច ព្រោះខ្លួនគ្មានសិទ្ធិកាន់កាប់ទ្រព្យនេះទៀតទេ បន្ទាប់ពីយកទៅដាក់បញ្ចាំ។ ដូចនេះវានឹងបង្កជាភាពរាំងស្ទះខាងផ្នែកសេដ្ឋកិច្ច បើសិនជាផ្តល់តែផ្លូវមួយសម្រាប់ធានាការសងកាតព្វកិច្ច ដោយដាក់ចលនវត្ថុជាទ្រព្យធានាជាមួយការផ្ទេរការកាន់កាប់។ ម្យ៉ាងកូនបំណុលត្រូវខាតប្រយោជន៍ច្រើនដោយសារតែខ្លួនអស់លទ្ធភាពនឹងទៅខ្ចីប្រាក់ ព្រោះរកវត្ថុដែលត្រូវប្រគល់ឲ្យម្ចាស់បំណុលមិនបាន។ បញ្ហានឹងចោទឡើង បើកាលណានីតិករអនុម័តច្បាប់ការពារតែផលប្រយោជន៍របស់ម្ចាស់បំណុលជាជាងបុគ្គលទន់ខ្សោយដែលស្គាល់ថាជាភាគីកូនបំណុល។ ចុះបើករណីដែលកូនបំណុលសុចរិតដោយខ្លួនមានបំណងបង្កើតកាតព្វកិច្ច ដើម្បីដំណើរការសកម្មភាពអាជីវកម្មដោយការប្រើប្រាស់

ចលនវត្ថុដែលតម្រូវឲ្យដាក់ធានានោះ ជំនួសឲ្យការប្រគល់ការកាន់កាប់ តើត្រូវធ្វើយ៉ាងណាដើម្បីទទួលបានប្រាក់សម្រាប់អាជីវកម្មបន្តទៅទៀត?

នេះជាមូលហេតុសំខាន់ដែលច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ត្រូវបានបង្កើតឡើងដើម្បីបញ្ចៀសនូវការរបញ្ហាទាំងនេះ។ ការបង្កើតច្បាប់ពិសេសនេះផ្តល់ជាជម្រើសសម្រាប់កូនបំណុលយកទៅអនុវត្ត ហើយដែលកំណត់ពីសិទ្ធិប្រាតិភោគប្រត្យក្សតាមការព្រមព្រៀងដូចក្រមរដ្ឋប្បវេណីផងដែរ។ ប្រតិបត្តិការដែលមានកិច្ចធានាត្រូវបានបង្កើតឡើងមុនក្រមរដ្ឋប្បវេណីថ្មីត្រូវបានប្រកាសឲ្យប្រើទៅទៀត ដើម្បីបង្កើតជាយន្តការគតិយុត្តដ៏សម្បូរបែបសម្រាប់អនុវត្ត។ ទោះបីជាច្បាប់ពិសេសនេះអនុម័តមុនច្បាប់ទូទៅ ក៏របបគតិយុត្តនៃការបញ្ចាំចលនវត្ថុមានកំណើតរួចទៅហើយគឺក្នុង ក្រឹត្យច្បាប់លេខ៣៨។ ការអនុម័តមុនក្រោយបែបនេះ ឈានទៅរកអត្ថិភាពច្បាប់ពីរគ្រប់គ្រងការធានាកាតព្វកិច្ចដោយប្រើចលនវត្ថុដូចគ្នា ខុសតែលក្ខខណ្ឌមួយចំនួន។ ការណ៍នេះហើយទើបបានជាគេមិនថែងនិរាករណ៍នូវច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានានោះទេ ព្រោះខ្លាចនាំឲ្យមានភាពច្របូកច្របល់ និងម្យ៉ាងទៀតដោយយល់ឃើញថាច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាមានតួនាទីសំខាន់ក្នុងការអភិវឌ្ឍប្រទេសជាតិ ដោយសារការផ្តល់លក្ខខណ្ឌពិសេសក្នុងការការធានាសិទ្ធិលើបំណុលដោយមិនចាំបាច់ប្រគល់ទ្រព្យសម្រាប់ដាក់ធានា។

បញ្ហាថ្មីក៏កើតមានឡើង ព្រោះកាលណារបបគតិយុត្តច្រើនគ្រប់គ្រងលើប្រតិបត្តិការប្រាតិភោគចលនវត្ថុដូចគ្នា នាំឲ្យការប្រើប្រាស់អាចមានការភ័ន្តច្រឡំអំពីលក្ខខណ្ឌអានុភាពលក្ខខណ្ឌសុពលភាព គោលគំនិតនៃប្រើប្រាស់ជាពិសេសគឺយន្តការនៃការអនុវត្តសិទ្ធិ។ ការមិនយល់ដឹងពីច្បាប់បែបនេះ អាចបណ្តាលឲ្យប្រជាពលរដ្ឋ អាជីវករ ពាណិជ្ជករ ឬ ឧស្សាហាករដែលជាអ្នកអនុវត្តបាត់បង់លទ្ធភាពក្នុងការអនុវត្ត។ លើសពីនេះ ប្រហែលជាប្រជាពលរដ្ឋធម្មតាមានការពិបាកយល់ថា តើប្រតិបត្តិការនៃប្រាតិភោគចលនវត្ថុដែលខ្លួនកំពុងតែប្រើប្រាស់ស្ថិតនៅក្នុងច្បាប់មួយណាឲ្យប្រាកដ ហើយខ្លួនត្រូវអនុវត្តសិទ្ធិដូចម្តេចខ្លះ? ថាតើទៅតាមផ្លូវតុលាការ ឬ មាននីតិវិធីពិសេសក្នុងការអនុវត្តសិទ្ធិរបស់ខ្លួន។ នេះជាចំណោទបញ្ហាថ្មីដែលអ្នកច្បាប់មួយចំនួនប្រហែលមើលរំលងពីសារៈសំខាន់នៃការធានាកាព្វកិច្ចតាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ក្រៅពីក្រមរដ្ឋប្បវេណីដែលជាស្គាល់ច្បាស់ថាជាច្បាប់ទូទៅ រួមទាំងការកំណត់ឲ្យច្បាស់លាស់នូវរបបគតិយុត្តដែលគ្រប់គ្រងប្រតិបត្តិការប្រាតិភោគចលនវត្ថុ។

ដើម្បីដោះស្រាយបញ្ហាចោទខាងលើ ទើបស្នាដៃមួយនេះត្រូវបានប្រសូត្រឡើងក្នុងគោលបំណងបម្រើអ្នកអានទាំងឡាយនូវខ្លឹមសារសំខាន់ៗ ដោយរំលេចនូវការពន្យល់ពីប្រាតិភោគប្រត្យក្រ

លើចលនវត្ថុតាមច្បាប់ពិសេស និងធ្វើការសិក្សាប្រៀបធៀបនឹងច្បាប់ទូទៅ ដើម្បីចូលរួមចំណែកជួយជម្រុញប្រតិបត្តិការប្រាតិភោគចលនវត្ថុឲ្យកាន់តែមានភាពសកម្មជាងមុន។ ម្យ៉ាងទៀត ក៏មានបំណងឲ្យបុគ្គលទាំងអស់បានសិក្សាស្វែងយល់ និងធ្វើការពិចារណាជ្រើសរើសរបបគតិយុត្តណាខ្លួនមានលទ្ធភាពដើម្បីបំពេញ និងរបបគតិយុត្តណាដែលអាចធានាសិទ្ធិលើបំណុលបានច្រើនជាង។ បន្ថែមលើនេះ មានបំណងធ្វើការរំលេចនូវច្បាប់ពិសេស បង្ហាញដល់អ្នកប្រើប្រាស់ដែលមិនសូវយល់ដឹងពីវត្តមាននៃប្រតិបត្តិការដែលមានកិច្ចធានា និងការតម្កល់លិខិតជូនដំណឹងដែលត្រូវបានបង្កើតឡើងតាំងពីឆ្នាំ២០០៧មកម្ល៉េះ ដែលជាប្រភេទរបបគតិយុត្តមួយផ្សេងទៀតពីប្រាតិភោគប្រត្យក្សក្នុងក្រមរដ្ឋប្បវេណី។ ម្យ៉ាងវិញទៀត ដោយសារសញ្ញាណគតិយុត្តនៃសិទ្ធិប្រត្យក្សមានសារៈសំខាន់ជាងគេ ហើយតែងតែកើតឡើងក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ហេតុដូច្នេះហើយអ្នកច្បាប់ទាំងឡាយចាំបាច់សិក្សាបន្ថែមដើម្បីពង្រីកចំណេះដឹងរបស់ខ្លួនឲ្យបានស៊ីជម្រៅ និងទូលំទូលាយជាងមុន ជាពិសេសជៀសវាងនូវការប្រើប្រាស់ដោយមានការភាន់ច្រឡំ និងមិនចំគោលបំណងនៃការប្រើប្រាស់ដែលអាចឈានទៅរកផលវិបាកទៅថ្ងៃអនាគត និងបាត់បង់ផលប្រយោជន៍។

សារៈប្រយោជន៍ជាសារវន្តមកវិញ ក្នុងការសិក្សាប្រៀបធៀបរបបគតិយុត្តដែលគ្រប់គ្រងការប្រាតិភោគប្រត្យក្សលើចលនវត្ថុក្នុងក្រមរដ្ឋប្បវេណី និងច្បាប់ពិសេសនេះនឹងផ្តល់ជាពុទ្ធិសម្រាប់ការពិចារណា និងយល់កាន់តែច្បាស់ពីប្រតិបត្តិការនៃការធានាសិទ្ធិលើបំណុលដោយដាក់នូវចលនវត្ថុនូវខ្លឹមសារសំខាន់ៗទាំងអស់។ ការស្គាល់នូវសញ្ញាណច្បាស់លាស់នៃរបបគតិយុត្តខាងលើនឹងមានឥទ្ធិពលវិជ្ជមានដោយប្រយោលដល់ការអភិវឌ្ឍវិស័យសេដ្ឋកិច្ចជាតិ ដោយសារតែប្រតិបត្តិការអាជីវកម្មនឹងដំណើរការទៅបានរលូន និងមិនត្រូវបានបង្អាក់ទោះបីជាអាជីវករ ឬ ពលរដ្ឋធម្មតាត្រូវការហិរញ្ញប្បទានសម្រាប់ប្រើប្រាស់ដើម្បីពង្រីកមុខជំនួញរបស់ខ្លួនក៏ដោយ ក៏នៅតែអាចបង្កើតសិទ្ធិប្រាតិភោគបានដែរ ដោយធ្វើការព្រមព្រៀងគ្នាជ្រើសរករបបគតិយុត្តដែលសមស្របទៅនឹងលទ្ធភាពដែលអាចអនុវត្តបាន។

ប្រាតិភោគប្រត្យក្សក្នុងក្រមរដ្ឋប្បវេណីមានសញ្ញាណច្រើន តែសូមធ្វើការកំណត់ត្រឹមតែប្រាតិភោគដែលប្រើប្រាស់ចលនវត្ថុប៉ុណ្ណោះ ដោយដកចេញនូវរបបគតិយុត្តនៃការធានាដោយបុគ្គល ចេញពីកម្មវត្ថុនៃការស្រាវជ្រាវនេះ។ ចំណែកច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាវិញ ក៏ដូចគ្នាព្រោះវិសាលភាពរបស់វា គ្របដណ្តប់ប្រតិបត្តិការផ្សេងៗទៀតក្រៅពីប្រាតិភោគចលនវត្ថុ តែទោះជាយ៉ាងណាក៏ដោយ វិសាលភាពនៃអត្ថបទសារណានេះកំណត់យកការត្រឹមការបញ្ចាំ

ចលនវត្ថុប៉ុណ្ណោះ រីឯក្រមរដ្ឋប្បវេណីវិញនឹងធ្វើការសិក្សាពីសិទ្ធិលើការបញ្ចាំ និងប្រាតិភោគដោយអនុប្បទានដែលជាប្រភេទសិទ្ធិប្រាតិភោគប្រត្យក្សតាមការព្រមព្រៀង ហើយនូវដកចេញសិទ្ធិប្រាតិភោគប្រត្យក្សដែលកំណត់ដោយច្បាប់ដែលរួមមាន ឯកសិទ្ធិ និងឃាត់ទុក។

ដូច្នេះ ដើម្បីងាយស្រួលក្នុងការបង្ហាញពីខ្លឹមសារជាសារវន្តនៃប្រធានបទពាក់ព័ន្ធនឹងការធានាកាតព្វកិច្ចដោយដាក់ចលនវត្ថុ ដែលត្រូវបានបញ្ញត្តក្នុងរបបគតិយុត្តដោយឡែកពីគ្នានេះ ខ្ញុំនឹងធ្វើការបែងចែកប្រធានបទនេះជា ២ជំពូកធំៗដូចខាងក្រោម៖

**ជំពូកទី ១៖** របបគតិយុត្តនៃប្រាតិភោគចលនវត្ថុតាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា

**ជំពូកទី ២៖** ការសិក្សាប្រៀបធៀបប្រាតិភោគចលនវត្ថុ តាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា និង តាមក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

# ជំពូកទី១ របបគតិយុត្តនៃប្រាតិភោគចលនវត្ថុ តាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា

យោងតាមបញ្ញត្តិមាត្រា៧៦៧ នៃក្រមរដ្ឋប្បវេណី បានធ្វើការកម្រិតនូវសិទ្ធិក្នុងការបង្កើតប្រាតិភោគប្រត្យក្ស ត្រឹមសិទ្ធិទាំងឡាយណាដែលកំណត់ដោយក្រមរដ្ឋប្បវេណីតែប៉ុណ្ណោះ ដោយគូភាគីមិនអាចព្រមព្រៀងបង្កើតសិទ្ធិប្រាតិភោគណាផ្សេងបានទេ។ ក្រៅពីសិទ្ធិប្រាតិភោគប្រត្យក្សក្នុងក្រមរដ្ឋប្បវេណី យើងសង្កេតឃើញសិទ្ធិប្រាតិភោគប្រត្យក្សមួយត្រូវបានបង្កើតឡើងក្នុងច្បាប់ពិសេសនៅក្នុងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា។ ជាទូទៅសិទ្ធិប្រាតិភោគប្រត្យក្សមិនអាចបង្កើតតែឯកឯងបានទេ លុះត្រាតែបង្កើតដើម្បីធានាសិទ្ធិលើបំណុល។

រហូតមកដល់ពេលនេះ ប្រាតិភោគចលនវត្ថុនៅក្នុងប្រទេសកម្ពុជា ត្រូវបានបង្កើតឡើងដោយយោងច្បាប់ពីរសំខាន់ៗ ក្នុងនោះមានច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០០៧ និងក្រមរដ្ឋប្បវេណីដែលត្រូវបានប្រកាសឲ្យប្រើដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីនៅឆ្នាំ២០១១។ ការបង្កើតសិទ្ធិប្រាតិភោគផ្សេងៗគ្នាជាមូលហេតុឈានទៅរកការអនុវត្ត និងប្រើប្រាស់របបគតិយុត្តខុសៗគ្នាផងដែរ ដោយហេតុនេះហើយដើម្បីកុំឲ្យមានការយល់ច្រឡំក្នុងការជ្រើសរើសយកប្រតិបត្តិការនីមួយៗមកប្រើប្រាស់ គប្បីសិក្សាពីសញ្ញាណគតិយុត្តនៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឲ្យបានច្បាស់លាស់។

ដោយសារតែសញ្ញាណនៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាជាសញ្ញាណថ្មី តែមានការពិបាកយល់ ព្រមទាំងកង្វះនូវការយល់ដឹងពីការអនុវត្តផងនោះ ដូច្នេះមុននឹងឈានចូលដល់ការបង្ហាញពីភាពដូចគ្នា និងភាពខុសប្លែកនៃប្រតិបត្តិការនីមួយៗ ដែលស្ថិតនៅក្រោមរបបគតិយុត្តដោយឡែកពីគ្នានេះ សូមធ្វើការពន្យល់ពីសញ្ញាណទូទៅដែលជាមូលដ្ឋានគ្រឹះសំខាន់សម្រាប់ធ្វើការប្រៀបធៀប និងដើម្បីងាយយល់ដល់អ្នកសិក្សាស្រាវជ្រាវទាំងឡាយ។ ប្រតិបត្តិការនៃការធានាសិទ្ធិលើបំណុលដោយការយកចលនវត្ថុទៅដាក់ធានា ដែលស្ថិតនៅក្រោមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាត្រូវបានបែងចែកជាបីផ្នែកធំៗគឺ សញ្ញាណទូទៅ(១.១) ការបង្កើតប្រតិបត្តិការដែលមានកិច្ចធានា(១.២) និងចុងក្រោយនឹងបកស្រាយពីការអនុវត្តសិទ្ធិរបស់ម្ចាស់បំណុលដែលមានកិច្ចធានា(១.៣)។

## ១.១. សញ្ញាណទូទៅ

ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា គឺសញ្ញាណថ្មីមួយដែលមានលក្ខណៈទំនើប និងជាប្រភពផ្តល់នូវហិរញ្ញប្បទានសម្រាប់ប្រើប្រាស់ចលនទ្រព្យធ្វើជាទ្រព្យធានា ក្នុងគោលបំណងផ្តល់នូវមូលដ្ឋាននៃហិរញ្ញវត្ថុដើម្បីសម្របសម្រួលដល់ដំណើរការពាណិជ្ជកម្ម។ វាត្រូវបានគេប្រើប្រាស់សម្រាប់ធានាកាតព្វកិច្ច ក្នុងទំនាក់ទំនងអាជីវកម្ម និងដើម្បីផ្តល់ភាពងាយស្រួលដល់ម្ចាស់បំណុល និងកូនបំណុលដោយកាត់បន្ថយចំណាយ និងដំណើរការនានា។ ប្រភពឥណទានពាណិជ្ជកម្មមានមិនច្រើននោះទេ ពោលគឺមានតែមាន ឥណទានដោយការបញ្ចាំអចលនទ្រព្យ កិច្ចធានាដោយបុគ្គល និងឥណទានធានាដោយចលនទ្រព្យតែប៉ុណ្ណោះ។ ម្យ៉ាងវិញទៀត ដោយសារតែនៅប្រទេសកម្ពុជាយើង អ្នកមានកម្មសិទ្ធិលើអចលនទ្រព្យមានតិចតួចពេក ជាហេតុនាំទៅរកអត្ថិភាពនៃច្បាប់នេះ ដើម្បីលើកទឹកចិត្តឲ្យប្រជាពលរដ្ឋដែលពុំមានកម្មសិទ្ធិលើអចលនទ្រព្យមានលទ្ធភាពអាចពង្រីកឥណទានអាជីវកម្មរបស់ខ្លួន និងចូលរួមសកម្មភាពសេដ្ឋកិច្ចកាន់តែច្រើនឡើង។

### ១.១.១. ប្រភពនៃប្រតិបត្តិការដែលមានកិច្ចធានា

អ្នកសិក្សាដែលមិនយល់ពីប្រភពនៃច្បាប់ និងគោលដៅធំក្នុងការបង្កើតច្បាប់ អាចនឹងនាំទៅរកការប្រើប្រាស់ខុសគោលបំណង និងគ្មានប្រសិទ្ធិភាពក្នុងការប្រើប្រាស់ ហេតុដូច្នេះហើយទើបត្រូវសិក្សាទៅលើប្រភពដើម និងគោលបំណងសំខាន់នៃការបង្កើតប្រតិបត្តិការនេះជាមុនសិន ទើបសិក្សាពីរបបគតិយុត្តនៃការបង្កើតប្រតិបត្តិការដែលមានកិច្ចធានាទាំងស្រុង។

មុននឹងការបង្កើតប្រតិបត្តិការដែលមានកិច្ចធានា រូបភាពដំបូងដែលត្រូវបានបង្កើតឡើងនៅប្រទេសនានាក្នុងពិភពលោកគឺ ការបញ្ចាំចលនទ្រព្យតែប៉ុណ្ណោះដែលគេប្រើតាមប្រព័ន្ធច្បាប់រ៉ូម៉ាំង។ តែទោះជាយ៉ាងណាក៏ដោយ ប្រតិបត្តិការនេះមិនបានបំពេញតម្រូវការសេដ្ឋកិច្ចនោះទេ ដោយសារលក្ខខណ្ឌនៃការផ្ទេរការកាន់កាប់ចលនវត្ថុដែលជាទ្រព្យធានា ពីកូនបំណុលទៅម្ចាស់បំណុល នាំឲ្យបង្អាក់នូវសកម្មភាពពាណិជ្ជកម្ម និងមិនអាចសម្របតាមឧស្សាហូបនីយកម្ម និងអន្តរជាតូបនីយកម្មនោះទេ។ ដើម្បីតាមឲ្យទាន់នូវបរិបទទំនើបនៃពាណិជ្ជកម្ម អ្នកច្បាប់រ៉ូម៉ាំង បានប្រកាន់យកនូវរបបគតិយុត្តមួយទៀតគឺអ៊ីប៉ូតែក[1] ដែលមានទម្រង់ជាប្រតិបត្តិការនៃបញ្ចាំចលនវត្ថុនៅឡើយ តែមិនចាំបាច់ប្រើលក្ខខណ្ឌផ្ទេរការកាន់កាប់នៃចលនទ្រព្យដើម្បីធានាកាតព្វកិច្ចនោះទេ។ ទោះជាយ៉ាង

[1] តាមក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ គេប្រើពាក្យហ៊ីប៉ូតែកវិញ តែនៅក្នុងអត្ថបទនេះនឹងរក្សាសញ្ញាណដើមរបស់វាដែលធ្លាប់ត្រូវបានគេហៅគឺ អ៊ីប៉ូតែក ព្រោះច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាបានប្រើប្រាស់ពាក្យនេះជំនួសឲ្យពាក្យហ៊ីប៉ូតែក ដោយសារតែច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាត្រូវបានអនុម័តមុនក្រមរដ្ឋប្បវេណីប្រកាសឲ្យប្រើ។

នេះគឺ សញ្ញាណថ្មីនៃអ៊ីប៉ូតែកបានបង្កើតនូវផលវិបាកពីរសំខាន់ៗដោយសារតែចលនទ្រព្យដែលបានដាក់ធានាដោយកូនបំណុលត្រូវបានលាក់បាំងពីសាធារណៈជន ហើយបង្កើតនូវហានិភ័យដល់អ្នកផ្តល់ឥណទាន និងមិនអាចកំណត់បានថាម្ចាស់បំណុលណាអាចទាមទារសិទ្ធិប្រាតិភោគបាន បើខ្លួនផ្តល់ហិរញ្ញប្បទានដោយមិនបានដឹងថា ទ្រព្យធានាធ្លាប់បានដាក់ប្រាតិភោគពីមុននោះទេ។[2]

ដូចនេះហើយ ការជ្រើសរើសការបញ្ចាំ ឬ អ៊ីប៉ូតែកវានៅតែផ្តល់ផលវិបាកដល់តម្រូវការពាណិជ្ជកម្ម។ ប៉ុន្តែទម្រង់នៃប្រតិបត្តិការទាំងពីរនេះមិនបានផុតរលត់ទេ គេឃើញមានវត្តមានការបញ្ចាំ និងអ៊ីប៉ូតែកនៅក្នុងក្រមរដ្ឋប្បវេណីប្រទេសកម្ពុជាឆ្នាំ១៩២០។ អ្វីដែលជាដំណោះស្រាយថ្មី គឺការបង្កើតនូវច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា នៅពាក់កណ្តាលសតវត្សទី២០ ដែលមានលក្ខណៈសម្រួលច្រើនដល់ការប្រើប្រាស់ចលនទ្រព្យដើម្បីធានាកាតព្វកិច្ច និងមានការទទួលស្គាល់ច្រើនពីបណ្តាប្រទេស ធំ តូចជាហូរហែរនិង ក្រោយមកក៏បង្កើតនូវការិយាល័យចុះបញ្ជីសិទ្ធិប្រាតិភោគ។ ចំពោះក្រមឯកភាពពាណិជ្ជកម្មដែលបានធ្វើការបញ្ញត្ត នូវប្រតិបត្តិការដែលមានកិច្ចធានាវិញត្រូវបានអនុម័តដោយសហរដ្ឋអាមេរិកក្នុងកំឡុងឆ្នាំ១៩៥០ ក្នុងគោលបំណងបញ្ចៀសនូវការប្រើទម្រង់ច្រើន និងចំណាយច្រើនក្នុងការអនុវត្តការផ្តល់ឥណទាន តែធានានូវការបង្កើតនូវវិធានសាមញ្ញក្នុងការផ្សព្វផ្សាយពីអត្ថិភាពនៃសិទ្ធិប្រាតិភោគ និងបន្ថែមឱកាសសម្រាប់ម្ចាស់បំណុល ងាយស្រួលអនុវត្តសិទ្ធិនៅពេលកូនបំណុលមិនសងបំណុល។[3]

នៅប្រទេសកាណាដាវិញដែលប្រកាន់ប្រព័ន្ធ Civil Law ក្នុងឆ្នាំ១៩៩០ បានអនុម័តច្បាប់ស្តីពីសិទ្ធិប្រាតិភោគចលនទ្រព្យ ដោយផ្អែកលើគោលការណ៍ដែលបានប្រើដោយក្រមឯកភាពពាណិជ្ជកម្មរបស់អាមេរិក និងធ្វើការបង្កើតការិយាល័យតម្កល់លិខិតជូនដំណឹង។[4] ចំណែកនៅអឺរ៉ុប និងអាស៊ីបានធ្វើកំណែទម្រង់ជាបន្តបន្ទាប់ ក្រោយពីសិក្សាពីផ្លូវសម្រាប់ការផ្តល់ឥណទានដែលមានប្រសិទ្ធភាពបំផុត និងងាយស្រួលដើម្បីជួយស្តារសេដ្ឋកិច្ចឡើងវិញ ដែលតាមរយៈនោះគេបានបង្កើតនូវសេចក្តីព្រាងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ដោយរួមបញ្ចូលនូវលក្ខខណ្ឌងាយ

---

2 Yoram Keinan, *The Evaluation of Secured Transaction*, p. 9. [ការវិវឌ្ឍន៍នៃប្រតិបត្តិការដែលមានកិច្ចធានា ដោយ យ៉ូរ៉ាម ខៃនណាន, ទំព័រទី៩]

3 Yoram Keinan, *The evaluation of secured transaction*, p. 6 [ការវិវឌ្ឍន៍នៃប្រតិបត្តិការដែលមានកិច្ចធានា ដោយ យ៉ូរ៉ាម ខៃនណាន និងសៀវភៅសេចក្តីពន្យល់ និងឧទាហរណ៍នៃប្រតិបត្តិការដែលមានកិច្ចធានា, ទំព័រ ៨]

4 Ross Cranton, *Security and Debt Recovery: Law's Role in Reform in Asia and the Pacific*, 39 St. Louis University Law Journal 759, in p. 776. [រូស្ស ក្រែនតុន, ប្រាតិភោគ និងការទទួលសិទ្ធិបានសិទ្ធិលើបំណុលមកវិញ: តួនាទីរបស់ច្បាប់ក្នុងការកែប្រែនៅអាស៊ី និងប៉ាស៊ីភិក, បោះពុម្ពដោយអត្ថបទច្បាប់នៃសាកលវិទ្យាល័យ ៧៥៩, ក្នុងទំព័រ ៧៧៦]

ស្រួលក្នុងការអនុវត្តប្រតិបត្តិការនេះដូចជាៈ

- សិទ្ធិប្រាតិភោគលើទ្រព្យធានាអាចដាក់បានទាំងលើទ្រព្យរូបិយ និងអរូបិយ ដើម្បីធានាកាតព្វកិច្ច
- លក្ខខណ្ឌផ្លូវការតិចតួចបំផុតសម្រាប់ការបង្កើតសិទ្ធិប្រាតិភោគ
- លក្ខណៈបត់បែននៃបំណុលដែលមានកិច្ចធានា
- ការតម្កល់ផ្សាយជាសាធារណៈនូវសិទ្ធិប្រាតិភោគ ដើម្បីជៀសវាងនូវសិទ្ធិប្រាតិភោគអាថិកំបាំង
- និងធានានូវសិទ្ធិអនុវត្តមានភាពទូលំទូលាយ។[5]

នៅឆ្នាំ១៩៩៥ ប្រទេសជាច្រើននៅ អឺរ៉ុបខាងកើត និងកណ្តាលមានដូចជា ប្រទេសអ៊ាល់បានី ប៊ុលហ្គារី ហុងហ្គារី ឡាតវី លីតួញ៉ា ស្លូវ៉ាគី និងអ៊ុយក្រែន បានអនុម័តយកច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា។ មួយរយៈចុងក្រោយកំឡុងឆ្នាំ២០០០ ច្បាប់ស្តីពីប្រតិបត្តិការនៃកិច្ចធានា ត្រូវបានចុះផ្សព្វផ្សាយ និងណែនាំដោយធនាគារអភិវឌ្ឍអាស៊ីអំពីគោលការណ៍ និងមុខងាររបស់ការិយាល័យតម្កល់សិទ្ធិប្រាតិភោគ។ នៅឆ្នាំ២០០៣ ធនាគារអភិវឌ្ឍអាស៊ីបានផ្សព្វផ្សាយពីមុខងារនៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា និងការិយាល័យតម្កល់សិទ្ធិប្រាតិភោគ ដែលវាត្រូវបានគេប្រើប្រាស់ស្ទើរគ្រប់ប្រទេសមិនខ្វល់ថាកាលៈទេសៈ ឬប្រព័ន្ធច្បាប់មិនដូចគ្នានោះទេ។ ទើបក្រោយមកប្រទេសមួយចំនួននៅអាស៊ីបានកំពុងពិចារណា លើច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ហើយសម្រាប់ប្រទេសកម្ពុជាជាអាទិ៍បានអនុម័តយកច្បាប់នេះជាច្បាប់ជាតិនៅឆ្នាំ២០០៦។

បច្ចុប្បន្ន គោលការណ៍ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាទំនើប ពាក់ព័ន្ធនឹងចលនទ្រព្យកំពុងក្លាយជាស្តង់ដារពាណិជ្ជកម្ម និងត្រូវបានទទួលស្គាល់ជាវិធានសមស្របមួយសម្រាប់ការធ្វើសុក្រឹតកម្មសិទ្ធិប្រាតិភោគ ដែលអនុលោមទៅនឹងអនុសញ្ញាមួយដែលត្រូវបានអនុម័តដោយគណៈកម្មការអង្គការសហប្រជាជាតិទទួលបន្ទុកច្បាប់ពាណិជ្ជកម្មអន្តរជាតិគឺ "អនុសញ្ញាអនុប្បទានគណនីត្រូវទទួល និងគណនីដែលនឹងត្រូវទទួលនូវពេលអនាគត"។ ជាមួយគ្នានោះ ប្រទេសកម្ពុជាយើងក៏មិនខុសប្លែកពីប្រទេសផ្សេងៗទៀតដែរ ព្រោះប្រទេសកម្ពុជាបានអនុម័តយកសញ្ញាណនៃបទប្បញ្ញត្តិស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ពីក្រមឯកភាពពាណិជ្ជកម្មអាមេរិកនៅត្រង់មាត្រា៩ ដោយសារក្រមឯកភាពពាណិជ្ជកម្មនេះ បានចែងយ៉ាងលម្អិតពីប្រតិបត្តិការដែលមានកិច្ចធានាដូចនេះហើយទើបផ្តល់ជាគម្រូសម្រាប់ប្រទេសនានា យកទៅអភិវឌ្ឍបន្ថែមលើបញ្ញត្តិដែលមាន

[5] សៀវភៅសេចក្តីពន្យល់ និងឧទាហរណ៍នៃមូលដ្ឋានគ្រឹះពាណិជ្ជកម្ម, ទំព័រ ៩០

មានស្រាប់ និងកែលម្អទៅតាមស្ថានភាពជាក់ស្តែង និងបរិបទសង្គមរបស់ប្រទេសនោះមិនថាប្រទេសនោះ។[6]

### ១.១.២. គោលបំណង នៃការបង្កើត

មូលហេតុនៃការបង្កើតច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ក្នុងគោលបំណងបង្កើតទម្រង់សាមញ្ញនៃការប្រើប្រាស់ បង្កើតវិធានដោះស្រាយវិវាទឆាប់រហ័ស និងផ្តល់ជាព័ត៌មានជាសាធារណៈរួមទាំងពង្រឹងការអនុវត្តច្បាប់។ គោលបំណងសំខាន់គឺដើម្បីបង្កើតហិរញ្ញប្បទានជាអតិបរមាធ្វើយ៉ាងណាឲ្យប្រជាពលរដ្ឋ អាចចូលរួមសកម្មភាពសេដ្ឋកិច្ចបានកាន់តែខ្លាំងក្លាតាមរយៈការផ្តល់ដើមទុនច្រើន និងស្ទើរគ្រប់ប្រភេទនៃចលនវត្ថុដល់អ្នកខ្ចីដែលមានទ្រព្យធានាតិចតួចជាពិសេសអ្នកដែលមិនមានកម្មសិទ្ធិលើដីធ្លី។

គោលដៅដែលនីតិនិពន្ធចង់បាន គឺដើម្បីពង្រឹងឥណទានអាជីវកម្មដោយផ្តល់នូវប្រយោជន៍ជាច្រើនដូចជា ទីមួយគឺដើម្បីបង្កើននូវភាពងាយស្រួលក្នុងការបង្កើតសិទ្ធិប្រាតិភោគដោយប្រើប្រាស់រួមមន្តតិចតួច ដោយមិនចាំបាច់ប្រើពាក្យបច្ចេកទេសច្រើន និងទម្រង់ពិសេសណាមួយឡើយ។ គ្រប់បុគ្គលសុទ្ធតែអាចប្រើប្រតិបត្តិការនេះ រួមទាំងធនាគារ អាជីវករតូច ធំ ហើយទ្រព្យធានាទៀតសោតអាចយកមកប្រើបានស្ទើរតែគ្រប់ប្រភេទ លើកលែងតែប្រតិបត្តិការមួយចំនួនដែលត្រូវហាមប្រាមដោយច្បាប់នេះ។ ម្យ៉ាងវិញទៀតកិច្ចព្រមព្រៀងតែមួយអាចត្រូវបានបង្កើតលើទ្រព្យធានាដែលកើតមាននាពេលបច្ចុប្បន្ន និងនាពេលអនាគតផងដែរ។

គោលដៅទីពីរគឺ បង្ការទំនាស់អំពីសិទ្ធិអាទិភាពនៃម្ចាស់បំណុលលើទ្រព្យធានា ដោយផ្តល់នូវការចង្អុលបង្ហាញនូវសិទ្ធិច្បាស់លាស់របស់ម្ចាស់បំណុល ដែលនេះជាមូលហេតុសំខាន់នាំទៅរកលទ្ធភាពខ្ពស់ក្នុងការផ្តល់ឥណទាន។ ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា បញ្ជាក់នូវក្របខណ្ឌច្បាស់លាស់ចំពោះចលនវត្ថុដែលអាចត្រូវបានដាក់ធានា។ វាបង្កើននូវវិធានរួបិយដើម្បីកំណត់អាទិភាពរវាងម្ចាស់បំណុលច្រើន និងដោះស្រាយនូវការទាមទារលើទ្រព្យធានាតែមួយ ព្រមទាំងកាត់បន្ថយហានិភ័យចំពោះម្ចាស់បំណុល និងជម្រុញផ្តល់ឥណទានខ្ពស់ឲ្យកូនបំណុលទៀតផង។

គោលដៅទីបី គឺផ្តល់នូវមធ្យោបាយទំនើបដោយការផ្សាយជាសាធារណៈនូវសិទ្ធិប្រាតិភោគតាមរយៈការិយាល័យតម្កល់ បានផ្តល់ឱកាសឲ្យម្ចាស់បំណុលងាយស្រួលធ្វើការកំណត់ថាអ្នកណាមានសិទ្ធិលើទ្រព្យធានានោះ។ ម្យ៉ាងទៀតវាជួយកាត់បន្ថយភាពការិយាធិបតេយ្យ ការចំណាយច្រើន

---

[6] Yoram Keinan, *The Evaluation of Secured Transaction*, p. 2 [ការវិវត្តនៃប្រតិបត្តិការដែលមានកិច្ចធានា ដោយ យ៉ូរ៉ាម ខៃនណាន, ទំព័រទី២]

និងការខាតបង់ពេលវេលា។ អ្វីដែលពិសេសគឺ ការតម្កល់សិទ្ធិប្រាតិភោគ មានភាពទំនើបកម្មដោយប្រើប្រព័ន្ធអ៊ិនធឺណិតនៃការចុះបញ្ជីហើយមិនចាំបាច់បង់ពន្ធកាត់ទុកទេ។ គោលដៅចុងក្រោយគឺដើម្បីធានាប្រសិទ្ធិភាពក្នុងការអនុវត្តសិទ្ធិនេះឯង។ ជាធម្មតា ហានិភ័យនៃការអនុវត្តសិទ្ធិ គឺជាកត្តាពិចារណាជាសារវន្តរបស់ម្ចាស់បំណុលក្នុងការសម្រេចផ្តល់ឥណទាន ឬ មិនផ្តល់ តែជាសំណាងល្អដែលច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា បានផ្តល់ជាយន្តការអនុវត្តសិទ្ធិមានប្រសិទ្ធិភាព និងឆាប់រហ័ស។

### ១.១.៣. ការវិវត្តប្រតិបត្តិការដែលមានកិច្ចធានានៅកម្ពុជា

ដំបូងឡើយ ប្រតិបត្តិការដែលមានកិច្ចធានានៅកម្ពុជាមិនដែលធ្លាប់អនុម័ត ឬប្រើប្រាស់នៅកម្ពុជាម្តងសោះ។ កម្ពុជាជាប្រទេសខ្វះធនធានមនុស្សផង និងគ្មានមូលដ្ឋានច្បាប់ដែលនៅសេសសល់ផង ណាមួយហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុមានភាពមិនច្បាស់លាស់ ធ្វើឲ្យការផ្តល់ឥណទាននៅកម្ពុជាស្ថិតនៅក្នុងកម្រិតមួយទាប។ មុននឹងបង្កជាកំណើតរបស់ច្បាប់ស្តីពីប្របត្តិការដែលមានកិច្ចធានា មានតែវិស័យធនាគារប៉ុណ្ណោះដែលផ្តល់ហិរញ្ញប្បទានមានកម្រិតសម្រាប់អ្នកខ្ចី ដូចនេះទើបនីតិករយល់ឃើញថាការបង្កើតនូវមធ្យោបាយផ្តល់ហិរញ្ញប្បទានផ្សេងទៀត វានឹងសម្រួលដល់ការទទួលបានឥណទានមួយផ្លូវទៀតសម្រាប់កូនបំណុល។

គំនិតផ្តួចផ្តើមដំបូងគឺចេញពីធនាគារអភិវឌ្ឍអាស៊ី បានពិគ្រោះជាមួយរដ្ឋាភិបាល និងវិស័យឯកជនសំខាន់ៗ ក្នុងការសម្រេចធ្វើសេចក្តីព្រាងផែនការហិរញ្ញវត្ថុអភិវឌ្ឍវិស័យឯកជនសម្រាប់ឆ្នាំ ២០០១-២០១០ ដែលផែនការនេះត្រូវបានអនុម័តនៅខែសីហាឆ្នាំ២០០១។[7] ក្រោយមក ផែនការនេះត្រូវបានគេធ្វើទំនើបកម្មឲ្យក្លាយជាយុទ្ធសាស្ត្រនៃការអភិវឌ្ឍវិស័យឯកជន ឆ្នាំ២០០៦-២០១៥។[8] ផែនការនេះផ្តោតជាសំខាន់ទៅលើ ការកែលម្អវិស័យច្បាប់ហិរញ្ញវត្ថុ ហើយក្នុងនោះដែរការបង្កើតនូវប្រតិបត្តិការដែលមានកិច្ចធានា ជាផ្នែកសំខាន់មួយដែលត្រូវបានយកមកពិចារណានៅកម្ពុជា។ ដោយសារយុទ្ធសាស្ត្រនេះហើយ ទើបសេចក្តីព្រាងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាចេញជារូបរាង ដោយយកគម្រូច្រើនពីក្រមឯកភាពពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិក និងគោល

[7] Financial sector development strategy 2006-2015 & Financial Sector Development Strategy 2011-2020, Royal Government of Cambodia, page 71 [យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០៦-២០០៧ របស់រដ្ឋាភិបាលនៃកម្ពុជា និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០ ទំព័រ៧១]

[8] Financial sector development strategy 2006-2015 & Financial Sector Development Strategy 2011-2020, Royal Government of Cambodia, page 71 [យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០៦-២០០៧ របស់រដ្ឋាភិបាលនៃកម្ពុជា និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០ ទំព័រ៧១]

ការណ៍ណែនាំរបស់ធនាគារអភិវឌ្ឍអាស៊ីស្តីពីការតម្កល់ចលនទ្រព្យ រួមទាំងច្បាប់ស្តីពីប្រាតិភោគចលនទ្រព្យរបស់កាណាដា។ តែទោះជាយ៉ាងណាក៏ដោយ ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានារបស់កម្ពុជា មិនមានភាពស្មុគស្មាញដូចក្រមឯកភាពពាណិជ្ជកម្មនោះទេ ពោលគឺគ្រាន់តែយកបញ្ញត្តិណាដែលអាចយកមកអនុវត្តបាន និងស្របទៅនឹងបរិបទកម្ពុជាតែប៉ុណ្ណោះ។

នៅប្រទេសកម្ពុជា គ្មានបទប្បញ្ញត្តិណាចែងពីការផ្តល់ហិរញ្ញប្បទានចំពោះចលនវត្ថុឲ្យបានច្បាស់លាស់នោះទេ ទោះបីជាមានក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ក៏ដោយ តែវាគ្រាន់តែបញ្ញត្តនូវការផ្តល់ប្រាតិភោគចលនវត្ថុតែមួយផ្នែកតូចតែប៉ុណ្ណោះ។ ក្រមរដ្ឋប្បវេណីប្រទេសកម្ពុជាឆ្នាំ២០០៧ បានចែងតែប្រតិបត្តិការប្រាតិភោគអចលនវត្ថុជាក់លាក់ តែបែរជាទុកចន្លោះប្រហោងច្រើនចំពោះប្រាតិភោគចលនវត្ថុ។ លើសពីនេះ បរិបទរបស់ប្រទេសកម្ពុជាក៏មិនខុសពីប្រទេសផ្សេងៗដែរ ពោលគឺអ្នកមានកម្មសិទ្ធិលើអចលនវត្ថុមានមិនសូវច្រើន ហើយប្រជាពលរដ្ឋត្រូវការទ្រព្យដើម្បីដាក់ធានាកាតព្វកិច្ចពង្រីកអាជីវកម្មផ្សេងៗ នេះដោយសារតែជាទូទៅម្ចាស់បំណុលតែងតែចង់បាន នូវប្រាតិភោគក្នុងរូបភាពទ្រព្យធានាអ្វីមួយធ្វើជាលក្ខខណ្ឌក្នុងការផ្តល់ឥណទាន។

ដូចនេះដើម្បីកាត់បន្ថយអលទ្ធភាពក្នុងការផ្តល់ឥណទាន និងដើម្បីធានាថាគ្រប់ប្រតិបត្តិការក្នុងអាជីវកម្មទាំងអស់ សុទ្ធតែអាចក្លាយទៅជាទ្រព្យធានាបាន ទើបសម្រេចបង្កើតនូវច្បាប់ក្នុងវិស័យហិរញ្ញវត្ថុមួយនេះ ដើម្បីផ្តល់ឥណទានជាតម្រូវការបន្ទាន់នៅក្នុងប្រទេសកម្ពុជា ដោយរួមបញ្ចូលទាំងហិរញ្ញប្បទានឧបករណ៍ថ្មី ហិរញ្ញប្បទានសារពើភណ្ឌ ភាគហ៊ុនក្នុងពាណិជ្ជកម្ម ហិរញ្ញប្បទានគណនីត្រូវទទួល និងការដាក់បញ្ចាំ ការផ្តល់ហិរញ្ញប្បទានកសិកម្មសម្រាប់កសិផល និងសត្វពាហនៈ ហិរញ្ញប្បទានសម្រាប់កែលម្អសំណង់អាគារ និងហិរញ្ញប្បទានទំនិញប្រើប្រាស់ជាអាទិ៍។

## ១.២. ការបង្កើតប្រតិបត្តិការដែលមានកិច្ចធានា

ប្រតិបត្តិការចលនវត្ថុ ចាប់ផ្តើមមានវត្តមាននៅក្នុងច្បាប់ពិសេសដែលត្រូវបានស្គាល់ថាជាច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា និយាយឲ្យចំ នេះជាមូលហេតុឈានទៅរកការប្រើប្រាស់និងការអនុវត្តប្រតិបត្តិការដែលមានលក្ខខណ្ឌខុសពីប្រតិបត្តិការប្រាតិភោគចលនវត្ថុ ដែលមានវត្តមាននៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។ ការយល់ដឹងពីវិសាលភាពនៃការប្រើប្រាស់ និងការអនុវត្តសិទ្ធិឲ្យមានប្រសិទ្ធិភាព ជាពុទ្ធិដែលមិនអាចខ្វះបានសម្រាប់កូនបំណុល និងម្ចាស់បំណុលដើម្បីទទួលបាននូវដំណោះស្រាយដ៏ប្រសើរមួយ ស្របទៅនឹងគោលបំណងនៃការធានាកាតព្វកិច្ចនិងស្ថានភាពជាក់ស្តែង។

### ១.២.១. វិសាលភាពទៅលើទ្រព្យធានា

វិធាននៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ត្រូវបានគ្រប់ដណ្តប់តែចលនវត្ថុតែប៉ុណ្ណោះ ព្រោះបញ្ញត្តិក្នុងមាត្រា២ និងមាត្រា៦ នៃច្បាប់នេះមិនបានកំណត់ពីអចលនវត្ថុធ្វើជាទ្រព្យធានានោះទេ។ ប្រតិបត្តិការប្រាតិភោគអចលនវត្ថុ ទាក់ទងនឹងអាគារ ឬដីត្រូវបានបញ្ញត្តដោយក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ព្រមទាំងច្បាប់ភូមិបាលយ៉ាងលម្អិត និងច្បាស់លាស់។ ដូចនេះការសិក្សាពីប្រតិបត្តិការដែលមានកិច្ចធានានៅក្នុងចំណុចនេះ គឺមានតែប្រាតិភោគចលនវត្ថុតែប៉ុណ្ណោះ។

#### ១.២.១.១. ប្រភេទទ្រព្យធានារូបិយដែលស្ថិតនៅក្រោមវិសាលភាពនៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា

ទ្រព្យធានាជាចំណែកមួយដ៏សំខាន់ក្នុងការផ្តល់ឥណទានអាជីវកម្ម។ វាជាតម្លៃដែលកូនបំណុលប្រគល់ឲ្យម្ចាស់បំណុលដើម្បីទទួលបាននូវឥណទានដែលខ្លួនត្រូវការ។ ប្រតិបត្តិការដែលអនុវត្តជារៀងរាល់ថ្ងៃក្នុងទីផ្សារ ខ្លះត្រូវបានគ្រប់ដណ្តប់ដោយច្បាប់នេះ ក៏ប៉ុន្តែប្រតិបត្តិការខ្លះត្រូវបានគ្រប់គ្រងដោយច្បាប់ផ្សេងៗទៀត ជាពិសេសនៅក្រោមក្រមរដ្ឋប្បវេណីដែលប្រកាសឲ្យប្រើនៅឆ្នាំ២០១១។ តទៅត្រូវធ្វើការកំណត់ឲ្យបានច្បាស់លាស់ថាតើទ្រព្យណាខ្លះអាចប្រើប្រាស់ធ្វើជាទ្រព្យធានានៅក្រោមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា។ នេះដោយយោងតាមមាត្រា៣ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា បានកំណត់យកប្រភេទទ្រព្យដូចខាងក្រោម៖

១). ទំនិញ៖ ចំណុចខាងក្រោម គឺត្រូវចាត់ទុកថាជាទំនិញ ពោលគឺជាវត្ថុដែលសិទ្ធិប្រាតិភោគអាចភ្ជាប់ជាមួយបាន លើកលែងតែគណនី កិច្ចសន្យាលក់ដែលមានកិច្ចធានា រូបិយវត្ថុ ឯកសារ ឬ លិខិតស្នាម មិនចាត់ទុកថាជាទំនិញទេ។[9]

- សារពើភណ្ឌ៖ សំដៅទៅលើទំនិញដែលជាអាចជាផលិតផលសម្រេច ផលិតផលកំពុងស្ថិតក្នុងដំណើរការ វត្ថុធាតុដើម ឬសម្ភារៈដែលបានប្រើប្រាស់សម្រាប់អាជីវកម្ម។ វាអាចជាទំនិញសម្រាប់លក់ ឬជួល ដែលបានដាក់តាំងរួចជាស្រេច។ ឧទាហរណ៍៖ ម៉ូតូដែលផលិតចេញជារូបរាង ដែលបានដាក់តាំងនៅក្នុងរោងចក្រសម្រាប់ការជាវ ឬ ជួលពីសំណាក់អតិថិជន។
- កសិផល៖ ទំនិញដែលកើតឡើងពីការប្រកបរបរកសិកម្ម លើកលែងតែឈើឈរ។[10]

[9] មាត្រា ៣ ចំណុចទី ១៥ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

[10] មាត្រា ៣ (១)នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

- ឧបករណ៍៖ គឺជាទំនិញដែលមិនត្រូវបានរាប់បញ្ចូលនូវកសិផល សារពើភណ្ឌ ទំនិញប្រើប្រាស់ ឬយានយន្តដែលមានលេខស៊េរី។ ឧទាហរណ៍៖ឡរបស់ហាងនំប៉័ង គឺជាឧបករណ៍ មិនមែនសារពើភណ្ឌនោះទេ។
- ទំនិញប្រើប្រាស់៖ ទំនិញគ្រប់ប្រភេទដែលបម្រើតម្រូវការផ្ទាល់ខ្លួន ឬ ក្រុមគ្រួសារតែប៉ុណ្ណោះ លើកលែងតែយានយន្តដែលមានលេខស៊េរីដែលអាចបង្កើតនូវសិទ្ធិប្រាតិភោគបាន។
- ចលនវត្ថុតាំងភ្ជាប់៖ គឺជាទំនិញដែលត្រូវបានភ្ជាប់ទៅនឹងអចលនវត្ថុ ដែលនាំឲ្យកើតឡើងនូវសិទ្ធិប្រត្យក្ស ប៉ុន្តែវានៅតែជាកម្មវត្ថុនៃប្រតិបត្តិការដែលមានកិច្ចធានា។ ឧទាហរណ៍៖ ម៉ាស៊ីនត្រជាក់ដែលភ្ជាប់ទៅនឹងអាគារ។

២). កិច្ចសន្យាលក់ដែលមានកិច្ចធានា៖ កំណត់ត្រាដែលបង្កើតកាតព្វកិច្ចបង់ប្រាក់ ឬ សិទ្ធិប្រាតិភោគ។ ឧទាហរណ៍៖ លោក **ក** បានយកពូជដំណាំពីលោក **ខ** ដោយធ្វើការសន្យាថានឹងបង់ប្រាក់វិញក្នុងរយៈពេល១ខែ ដោយលោក **ក** បានយកសត្វពាហនៈធ្វើជាទ្រព្យធានា។ លោក **ខ** គឺជាអ្នកលក់ មានកិច្ចសន្យាលក់ដែលមានកិច្ចធានា។ ដូចនេះហើយសិទ្ធិប្រាតិភោគត្រូវបានកំណត់នៅក្នុងកំណត់ត្រាជាលាយលក្ខណ៍អក្សរទុកជាឯកសារ។

៣). ឯកសារ៖ សំដៅទៅលើបង្កាន់ដៃដឹកជញ្ជូន បង្កាន់ដៃកាន់ឃ្លាំង ដែលចេញដោយបុគ្គលដែលធ្វើអាជីវកម្មដឹកជញ្ជូន ឬ ស្តុកទំនិញ។ ឧទារហាណ៍៖ បង្កាន់ដៃដឹកជញ្ជូន ត្រូវបានចេញដោយអ្នកដឹកជញ្ជូនទំនិញ ពីចំណុចមួយទៅចំណុចមួយដោយមានតម្លៃជាថ្នូរ។

៤). លិខិតស្នាម៖ ជាកំណត់ត្រាដែលបង្ហាញថា បុគ្គលណាម្នាក់មានសិទ្ធិទទួលបានប្រាក់។

៥). រូបិយវត្ថុ៖ ជាទូទៅតែងតែគិតថាបើបុគ្គលម្នាក់មានប្រាក់ដាក់ជាប្រាតិភោគ គាត់មានលទ្ធភាពអាចផ្តល់ហិរញ្ញប្បទានបានហើយ តែទោះជាយ៉ាងណាក៏ដោយ ដើម្បីជាការកំណត់ពេញលេញ សាច់ប្រាក់ក៏អាចជាប្រភេទមួយនៃទ្រព្យធានាបានដែរ។[11] ឧទាហរណ៍៖ លោក **ក** បានយកសាច់ប្រាក់របស់ខ្លួនចំនួន ៥ម៉ឺនដុល្លារអាមេរិក ដាក់តម្កល់ក្នុងធនាគារមួយនៅអាមេរិក ដើម្បីជានាកូនប្រុសរបស់គាត់បានសិក្សានៅសហរដ្ឋអាមេរិករយៈពេល៣ឆ្នាំ។ ប្រាក់តម្កល់នេះជាលក្ខខណ្ឌតម្រូវរបស់ស្ថានទូតអាមេរិកដែលលោក **ក** មិនអាចដកប្រាក់មកចាយផ្តេសផ្តាសនោះទេ តែគាត់អាចយកទៅធ្វើទ្រព្យធានាបាន។

[11] មាត្រា ៣ (១៥)(២) នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

៦). កិច្ចសន្យាជួលទំនិញក្នុងរយៈពេលវែង៖ គឺជាប្រតិបត្តិការដែលអ្នកជួល (ម្ចាស់វត្ថុជួល) យល់ព្រមឲ្យអ្នកទទួលជួល មានសិទ្ធិកាន់កាប់សម្រាប់រយៈពេលកំណត់មួយជាក់លាក់ ដោយមានការដាក់ទ្រព្យធានា។[12] ការណ៍នេះមានរយៈពេលលើសពី១ឆ្នាំ ឬអាចជាកិច្ចសន្យាដែលមិនកំណត់រយៈពេលច្បាស់លាស់ តែទីបំផុតបែរជារយៈពេលតិចជាង១ឆ្នាំ។ ដូចនេះអនាគតកូនបំណុលអាចប្រគល់ឧបករណ៍ ឬ ទំនិញផ្សេងទៀតធ្វើជាទ្រព្យធានា និងតម្កល់លិខិតជូនដំណឹង។

នៅមានប្រតិបត្តិការផ្សេងទៀត ដែលគ្របដណ្តប់ដោយច្បាប់នេះដែរគឺ បញ្ញើទុកលក់។ តែបើបញ្ញើទុកលក់ចំពោះទំនិញប្រើប្រាស់ ត្រូវបានអនុញ្ញាតនៅក្នុងសហរដ្ឋអាមេរិក។ ក៏ប៉ុន្តែដោយសារតែវិសាលភាពនៃការតាក់តែងសារណាមួយនេះ គ្របដណ្តប់តែប្រាតិភោគចលនវត្ថុតែប៉ុណ្ណោះ ដូច្នេះប្រតិបត្តិការផ្សេងទៀតក្រៅពីប្រាតិភោគចលនវត្ថុ មិនត្រូវបានយកមកពិភាក្សានោះទេ។

### ១.២.១.២.ប្រភេទទ្រព្យធានាអរូបិយដែលស្ថិតក្រោមវិសាលភាពនៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា

ក្រៅពីប្រភេទទ្រព្យធានារូបិយ ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាក៏មានវិសាលភាពទៅលើចលនវត្ថុអរូបិយមួយចំនួនតូចដែលមានក្នុងបច្ចុប្បន្ន ឬនឹងកើតឡើងនាពេលអនាគតជាអាទិ៍ដែលក្នុងនេះគឺសំដៅទៅលើសិទ្ធិត្រូវទទួលបាននូវតម្លៃពីជនទីបី។ វត្ថុអរូបិយត្រូវបានបែងចែកចេញជាពីរគឺ គណនី និងទ្រព្យអរូបិយផ្សេងទៀតដែលរួមមាន៖

១) គណនី គឺជាសិទ្ធិទូទាត់លើទំនិញដែលលក់ ជួល ឬ ផ្តល់សេវាកម្មរួចហើយតែវាមិនមែនជាលិខិតស្នាម ឬ កិច្ចសន្យាលក់ដែលមានកិច្ចធានានោះទេ។ ឧទាហរណ៍៖ កញ្ញា **ក** ទទួលពូជស្រូវពីលោក **ខ** ដោយសន្យាថានឹងទូទាត់នាពេលអនាគតដោយលោក **ខ** គាត់មានគណនីផ្ទាល់ខ្លួន ដូចនេះពួកគេព្រមព្រៀងគ្នាថា នឹងទូទាត់តាមរយៈគណនីរបស់លោក **ខ** ទៅវាប្រសើរជាង។

២) ទ្រព្យអរូបិយផ្សេងទៀត៖ សិទ្ធិ ឬ ចលនវត្ថុដែលមិនមែនជាទំនិញ គណនី កិច្ចសន្យាលក់ដែលមានកិច្ចធានា ឯកសារ លិខិតស្នាម ឬ រូបិយវត្ថុ។

ឧទាហរណ៍បន្ថែមលើករណីខាងលើគឺមានដូចជា កម្មសិទ្ធិបញ្ញា(ប័ណ្ណប៉ាតង់) គណនីឯកសារកម្មសិទ្ធិ សិទ្ធិក្នុងការរុករករ៉ែជាដើម ដែលសុទ្ធតែជាប្រភេទទ្រព្យអរូបិយដែលអាចបង្កើតជាប្រតិបត្តិការដែលមានកិច្ចធានា។

---

[12] មាត្រា ៣(២) នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

### ១.២.១.៣. ប្រតិបត្តិការដែលមិនស្ថិតនៅក្រោមវិសាលភាពនៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា

គួររំលឹកថា ជាមួយនឹងការកំណត់ប្រភេទប្រតិបត្តិការដែលគ្រប់ដណ្តប់ដោយច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាមាត្រា២ ចំណុចទី៤ នៃច្បាប់ដដែលបានកំណត់នូវប្រតិបត្តិការដែលមិនត្រូវបានអនុវត្តដោយយោងច្បាប់នេះ ដែលក្នុងនោះរួមមានដូចជា៖

១). ការផ្ទេរសិទ្ធិទាមទារប្រាក់បៀវត្សរបស់និយោជិត

ប្រាក់បៀវត្សរបស់និយោជិត មិនអាចក្លាយជាកម្មវត្ថុនៃទ្រព្យធានា ឬ ធ្វើការរឹបអូសដើម្បីបង្កើតសិទ្ធិប្រាតិភោគបាននោះទេ ទោះបីជាការផ្ទេរនោះទទួលបានការយល់ព្រមពីនិយោជិតក៏ដោយ ព្រោះច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាពុំមានអានុភាពអនុវត្តលើចំណុចនេះទេ។ ការរឹបអូសប្រាក់ខែដោយមិនស្ម័គ្រចិត្ត ឬ ស្ម័គ្រចិត្ត ត្រូវអនុលោមនៅក្រោមច្បាប់ស្តីពីការងារ។

២). ការបញ្ចាំអចលនវត្ថុ ឬសិទ្ធិដទៃទៀតលើអចលនវត្ថុ

អាគារ ដី កាលណាបើយកទៅប្រើប្រាស់ធ្វើជាទ្រព្យធានា គឺស្ថិតនៅក្រៅវិសាលភាពនៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា។ ផ្ទុយទៅវិញ ប្រតិបត្តិការពាក់ព័ន្ធនឹងអចលនវត្ថុនេះស្ថិតនៅក្រោមវិសាលភាពនៃច្បាប់ភូមិបាលឆ្នាំ២០០១ និង ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។ តែទោះជាយ៉ាងនេះក្តី ចំពោះចលនវត្ថុតាំងភ្ជាប់ដែលជាផ្នែកមួយនៃអចលនទ្រព្យវិញ គឺត្រូវបានយកមកអនុវត្តក្នុងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាវិញ ដែលនឹងធ្វើការពន្យល់នូវខាងក្រោម។

៣). ការលក់គណនី ឬ កិច្ចសន្យាលក់ដែលមានកិច្ចធានាដែលជាផ្នែកនៃការលក់អាជីវកម្មះ ចង់សំដៅទៅលើការលក់កិច្ចសន្យាដែលមានកិច្ចធានា នៅពេលដែលម្ចាស់អាជីវកម្ម បានធ្វើការលក់អាជីវកម្មរបស់ខ្លួន រួមទាំងកិច្ចសន្យាលក់ដែលមានកិច្ចធានាផងនោះទៅអនាគតម្ចាស់អាជីវកម្ម។

៤). អនុប្បទានគណនី កិច្ចសន្យាលក់ដែលមានកិច្ចធានា ឬ លិខិតស្នាមដែលសម្រាប់តែប្រមូលប្រាក់ដែលជំពាក់។

៥). ការប្រាក់លើប្រាក់បញ្ញើ គណនីមូលប្បទានបត្រ គណនីសញ្ជ័យ គណនីសាច់ប្រាក់ដទៃទៀត។

៦) កិច្ចសន្យាជួលទំនិញរយៈពេលខ្លីដែលតិចជាង ១ឆ្នាំដែលមានកំណត់ជាក់លាក់។

### ១.២.២.ការបង្កើតកិច្ចព្រមព្រៀងប្រាក់កម្ចី និងកិច្ចព្រមព្រៀងប្រាតិភោគដែលមានសុពលភាព

គួររំលឹកថា កិច្ចព្រមព្រៀងប្រាក់កម្ចីអាចបង្កើតដាច់ដោយឡែកពីកិច្ចព្រមព្រៀងប្រាតិភោគ តែជួនកាល វាត្រូវបានបង្កើតឡើងរួមគ្នានៅក្នុងកិច្ចព្រមព្រៀងតែមួយ។ តែទោះជាយ៉ាងណាពុំមានច្បាប់តម្រូវឲ្យកិច្ចព្រមព្រៀងទាំងពីរត្រូវធ្វើដាច់ដោយឡែក ឬ ចូលគ្នានោះទេដោយច្បាប់ទុកឲ្យភាគីជាអ្នកសម្រេច។ ប៉ុន្តែការប្រើប្រាស់ពាក្យពេចន៍ គប្បីត្រូវយកចិត្តទុកដាក់ បើកាលណាភាគីបានបង្កើតកិច្ចព្រមព្រៀងប្រាក់កម្ចីផង និងកិច្ចព្រមព្រៀងប្រាតិភោគផង។ ដូចនេះបើសិនជាភាគីបង្កើតកិច្ចព្រមព្រៀងដាច់ដោយឡែកពីគ្នា គប្បីកំណត់ចំណាំនូវលក្ខណៈសម្គាល់ដែលអាចឲ្យបែងចែកដាច់រវាងកិច្ចព្រមព្រៀងទាំងពីរនេះ។

#### ១.២.២.១. កិច្ចព្រមព្រៀងប្រាក់កម្ចី

ខ្លឹមសាររបស់កិច្ចព្រមព្រៀងប្រាក់កម្ចី ត្រូវកំណត់ពីព័ត៌មាននៃប្រាក់កម្ចីឲ្យបានច្បាស់លាស់ និងរយៈពេលសងបំណុល។ ចំណែកក្នុងកិច្ចព្រមព្រៀងប្រាតិភោគ ចាំបាច់ដាក់នូវព័ត៌មានសំខាន់ៗដែលចាំបាច់សម្រាប់គូភាគីក្នុងការអនុវត្តសិទ្ធិប្រាតិភោគ ដើម្បីបំពេញលក្ខខណ្ឌសុពលដូចនេះចាំបាច់ណាស់ដែលត្រូវមានកិច្ចព្រមព្រៀងប្រាតិភោគបន្ថែមលើកិច្ចព្រមព្រៀងប្រាក់កម្ចី។ ជាទូទៅកិច្ចព្រមព្រៀងប្រាក់កម្ចី ត្រូវយោងទៅរកកិច្ចព្រមព្រៀងប្រាតិភោគ ដែលអាចផ្តល់ព័ត៌មានគ្រប់គ្រាន់ថាកិច្ចព្រមព្រៀងប្រាក់កម្ចីមានការពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងប្រាតិភោគ។ ប៉ុន្តែដរាបណាកិច្ចព្រមព្រៀងណាមួយផ្តល់ព័ត៌មានគ្រប់គ្រាន់អាចបង្កើតនូវសុពលភាព ដូចគម្រូខ្លឹមសារនៃកិច្ចព្រមព្រៀងប្រាក់កម្ចី និងប្រាតិភោគបូកចូលគ្នាទៅក្នុងឯកសារតែមួយក៏មិនចោទជាមានបញ្ហាអ្វីដែរ។[13]

ឧទាហរណ៍បើមានកិច្ចព្រមព្រៀងមួយដែលចុះហត្ថលេខាដោយកូនបំណុល និងធនាគារដែលមានបញ្ជាក់ពី ទំហំនៃប្រាក់កម្ចី អត្រាការប្រាក់ និងរយៈពេលសងប្រាក់កម្ចីឲ្យធនាគារ។ កិច្ចព្រមពៀងនេះត្រឹមតែជាកិច្ចព្រមព្រៀងប្រាក់កម្ចីប៉ុណ្ណោះ ពោលគឺវាមិនមែនជាកិច្ចព្រមព្រៀងប្រាតិភោគដែលមានកិច្ចធានានៅឡើយទេ។ ត្រូវចាំថាកិច្ចព្រមព្រៀងប្រាតិភោគត្រូវតែមានការពិពណ៌នាពីទ្រព្យធានា ដែលត្រូវផ្តល់ជាប្រាតិភោគ ចំណែកឯចំណងជើងរបស់វាមិនអាចកំណត់ថាវាជាកិច្ចព្រមព្រៀងប្រាតិភោគបាននោះទេ។ ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាបានចង្អុលបង្ហាញពីលក្ខណៈសម្គាល់ គឺជាខ្លឹមសាររបស់កិច្ចព្រមព្រៀង មិនមែនចំណងជើងនោះទេ។

[13] សៀវភៅពន្យល់ និងឧទាហរណ៍នៃប្រតិបត្តិការដែលមានកិច្ចធានា, ទំព័រ ៦៥

### ១.២.២.២. កិច្ចព្រមព្រៀងប្រាតិភោគ ឬ ការភ្ជាប់សិទ្ធិប្រាតិភោគ

ការបង្កើតកិច្ចព្រមព្រៀងប្រាតិភោគដែលមានសុពលភាព ចាំបាច់ត្រូវធ្វើការភ្ជាប់សិទ្ធិប្រាតិភោគ ទើបម្ចាស់បំណុលអាចអនុវត្តសិទ្ធិបាន។ ការភ្ជាប់សិទ្ធិប្រាតិភោគនេះ តម្រូវលក្ខខណ្ឌ៣សំខាន់ដូចជា អត្ថិភាពកិច្ចព្រមព្រៀងប្រាតិភោគ(ក) តម្លៃដែលកូនបំណុលត្រូវទទួល(ខ) សិទ្ធិដែលកូនបំណុល មានលើទ្រព្យធានា(គ)។

### ក. លក្ខខណ្ឌទី១៖ អត្ថិភាពនៃកិច្ចព្រមព្រៀងប្រាតិភោគ

កិច្ចព្រមព្រៀងប្រាតិភោគ គឺជាកំណត់ត្រាលាយលក្ខណ៍អក្សររវាងកូនបំណុល និងម្ចាស់បំណុលដែលផ្ទេរសិទ្ធិប្រាតិភោគលើទ្រព្យធានាពីកូនបំណុលឲ្យទៅម្ចាស់បំណុល។ កិច្ចព្រមព្រៀងប្រាតិភោគនេះត្រូវអធិប្បាយពីទ្រព្យធានា ហើយវាមិនអាចជាកិច្ចព្រមព្រៀងប្រាតិភោគដែលធ្វើដោយផ្ទាល់មាត់នោះទេ ព្រោះពិបាកក្នុងការបង្ហាញភស្តុតាងពីសិទ្ធិប្រាតិភោគ ហេតុដូច្នេះហើយ អាចនិយាយបានថា លក្ខខណ្ឌកំណត់ថាជាលាយលក្ខណ៍អក្សរនេះគឺជាលក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាដាក់ប្រាតិភោគដែលច្បាប់តម្រូវ។ លើសពីនេះនៅក្នុងកិច្ចព្រមព្រៀងប្រាតិភោគត្រូវមានធាតុផ្សំសំខាន់ចំនួន៣៖

- **ធាតុផ្សំទីមួយ** គឺកិច្ចព្រមព្រៀងត្រូវស្របនឹងច្បាប់កិច្ចសន្យា។ ច្បាប់កិច្ចសន្យានៅទីនេះគឺសំដៅលើក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ដែលកំណត់ពីលក្ខខណ្ឌអានុភាពនៃកិច្ចសន្យាគឺ សំណើរ និងស្ទីការត្រូវគ្នា និងលក្ខខណ្ឌទាំងបីចែងនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ដូចជាកម្មវត្ថុស្របច្បាប់ ការព្រមព្រៀងរបស់ភាគី និងសមត្ថភាពភាគី។
- **ធាតុផ្សំទីពីរ** គឺចាំបាច់មានការបញ្ជាក់ឯកភាព(authenticate) ដែលសំដៅទៅលើការបញ្ជាក់ដោយការចុះហត្ថលេខា ឬការបញ្ជាក់លើឈ្មោះ ឬនិមិត្តសញ្ញាផ្សេងៗដែលធ្វើឡើងដោយផ្ទាល់ដៃរបស់កូនបំណុល មិនមែនតម្រូវហត្ថលេខានៃម្ចាស់បំណុលទេ។ ច្បាប់ក៏ពុំបានតម្រូវការធ្វើកិច្ចព្រមព្រៀងនៅមន្ទីសារការី ឬធ្វើឡើងនៅចំពោះមុខសាក្សីនោះដែរ។
- **ធាតុផ្សំទីបី** គឺកិច្ចព្រមព្រៀងត្រូវតែមានការអធិប្បាយពីទ្រព្យធានា តែមិនចាំបាច់ជាក់លាក់ហួសហេតុពេកទេ គឺធ្វើយ៉ាងណាកុំឲ្យមានការច្រឡំទៅលើអត្តសញ្ញាណនៃទ្រព្យធានានោះចំពោះទ្រព្យធានារបស់ភាគីដទៃទៀតទៅបានហើយ។ ទ្រព្យធានាអាចត្រូវអធិប្បាយទូទៅដោយការសរសេររៀបរាប់ដូចជា "ទ្រព្យសកម្មទាំងអស់" ឬ "រាល់ចលនវត្ថុទាំងអស់"។[14]

[14] សៀវភៅពន្យល់ និងឧទាហរណ៍នៃប្រតិបត្តិការដែលមានកិច្ចធានា, ទំព័រ ៦៣

**ចំណាំ៖** លើកលែងតែយានយន្តដែលមានលេខស៊េរី ដូចជាឡាន ម៉ូតូ កាណូតជាអាទិ៍ ដែលទាមទារតម្រូវឲ្យដាក់លេខស៊េរីដែលភ្ជាប់ទៅនឹងឡាន ម៉ូតូ ឬ កាណូតនោះ។ ចំពោះទំនិញប្រើប្រាស់ក៏ដូចគ្នាដែរ ការពិពណ៌នាគឺមិនគួរប្រើពាក្យ "ទំនិញប្រើប្រាស់" តែមួយមុខនោះទេព្រោះពិបាកក្នុងការវិនិច្ឆ័យនៅពេលអនុវត្ត។ ដូចនេះការពិពណ៌នាពីទំនិញប្រើប្រាស់ គឺត្រូវបញ្ជាក់ពីមុខទំនិញរបស់កូនបំណុលនីមួយៗឲ្យបានច្បាស់លាស់។

## ខ.លក្ខខណ្ឌទី២៖ កូនបំណុលត្រូវទទួលតម្លៃអ្វីមួយ

ម្ចាស់បំណុលត្រូវផ្តល់នូវតម្លៃអ្វីមួយ ជាការតបទៅនឹងទ្រព្យដែលកូនបំណុលបានដាក់ធានា វាអាចជាប្រភេទនៃការសន្យាដើម្បីផ្តល់ជាសាច់ប្រាក់នាពេលអនាគត។ បើយោងតាមនិយមន័យនៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា "តម្លៃ" មានន័យថាជាថ្នូរនឹងការសន្យាក្នុងការផ្តល់ឥណទាន ហើយវាអាចជាទ្រព្យធានា ឬ សិទ្ធិដែលទទួលការប្រគល់អនុលោមតាមកិច្ចសន្យាលក់ទិញ ឬ ក៏សិទ្ធិជាថ្នូរនឹងការសន្យាការដោះដូរ។[15] តាមបញ្ញត្តិដដែលយើងអាចសន្និដ្ឋានបានថា ការបង្កើតសិទ្ធិប្រាតិភោគ អាចអនុវត្តបានទាល់តែម្ចាស់បំណុលដែលមានកិច្ចធានាផ្តល់នូវតម្លៃអ្វីមួយឲ្យទៅកូនបំណុល។ បើសិនជាកិច្ចព្រមព្រៀងប្រាតិភោគបង្កើតឡើង មិនមែនជាការធានាតម្លៃអ្វីមួយដែលម្ចាស់បំណុលនឹងផ្តល់ឲ្យកូនបំណុលទេ ប្រតិបត្តិការនោះមិនមែនជាប្រតិបត្តិការដែលមានកិច្ចធានាទេព្រោះគ្មានកិច្ចណាមួយដែលអាចឲ្យឈ្មោះថាវាជាកិច្ចធានាបាន។

## គ. លក្ខខណ្ឌទី៣៖ កូនបំណុលត្រូវមានសិទ្ធិអ្វីមួយលើទ្រព្យធានា

ការណ៍ដែលមានសិទ្ធិលើទ្រព្យដែលនឹងដាក់ធានា មានសារៈសំខាន់ត្រង់ថាបើកូនបំណុលមិនមានសិទ្ធិលើទ្រព្យធានា នោះម្ចាស់បំណុលនឹងជួបការលំបាក ដូចនេះការទាមទារឲ្យម្ចាស់បំណុលស្វែងរកមូលដ្ឋានជាក់លាក់ អំពីអត្ថិភាពនៃសិទ្ធិកម្មសិទ្ធិរបស់កូនបំណុលលើវត្ថុធានា។ វាអាចជាបន្ទុកធ្ងន់របស់ម្ចាស់បំណុល ក្នុងការស្វែងរកអំណះអំណាងពីកូនបំណុលដើម្បីបញ្ជាក់ថាកូនបំណុលមានសិទ្ធិអំណាចដើម្បីដាក់ទ្រព្យដែលខ្លួនមានទៅបញ្ចាំ។ ទោះបីជាកាទាមទារឲ្យមានសិទ្ធិលើទ្រព្យធានា គឺជាបញ្ហាដែលគួរពិចារណា តែបើសិនជាកូនបំណុលមានសិទ្ធិប្រើប្រាស់ ឬ អាស្រ័យផលតាមកិច្ចសន្យាជួល ផលុបភោគ ឬ កិច្ចព្រមព្រៀងដទៃទៀត ការផ្តល់សិទ្ធិប្រាតិភោគមិនត្រូវបានហាមឃាត់នោះទេ។ នៅក្នុងច្បាប់នេះ "ការមានសិទ្ធិលើទ្រព្យធានា" មិនចាំបាច់ជាសិទ្ធិដែលអាចផ្ទេរទ្រព្យធានានោះទេ ព្រោះក្នុងស្ថានភាពខ្លះ កូនបំណុលមិនមានសិទ្ធិកម្មសិទ្ធលើទ្រព្យ

[15] មាត្រា ៣ (១៩)នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

ធានានោះទេ តែមានសិទ្ធិប្រើប្រាស់ ឬកាន់កាប់ទ្រព្យធានាតាមរយៈកិច្ចសន្យាជួលជាអាទិ៍។[16]

ដូចដែលបានបញ្ជាក់ពីខាងដើមថា កម្មសិទ្ធិលើចលនវត្ថុគឺមានការពិបាកក្នុងការបង្ហាញពីសិទ្ធិពិតប្រាកដរបស់កូនបំណុល ក្នុងករណីមួយចំនួនដូចជា ចិញ្ចៀនពេជ្រជាអាទិ៍ ដែលពេលខ្លះកូនបំណុលពុំមានឯកសារមួយណាដែលអាចបញ្ជាក់ពីកម្មសិទ្ធិលើចិញ្ចៀននេះទេ ព្រោះខ្លួនទទួលនូវប្រទានកម្មពីឪពុកម្ដាយ។ នេះជាមូលហេតុដែលច្បាប់ស្ដីពីប្រតិបត្តិការនៃកិច្ចធានាមិនតម្រូវនូវសិទ្ធិកម្មសិទ្ធិនោះទេ ត្រឹមតែសិទ្ធិអ្វីមួយដែលកូនបំណុលមានគឺគ្រប់គ្រាន់ដើម្បីបង្កើតកិច្ចព្រមព្រៀងប្រាតិភោគមានសុពលភាព និងធ្វើការតម្កល់លិខិតជូនដំណឹង ដោយធានាយ៉ាងណាឲ្យសកម្មភាពអាជីវកម្មមានសន្ទុះលឿនតាមដែលអាចធ្វើបាន។

**ឧទាហរណ៍៖** លោក តារា ចង់ពង្រីកអាជីវកម្មបើកអ៊ិនធឺណិតមួយ ដូចនេះគាត់បានទៅរកលោក សុខ ដើម្បីខ្ចីលុយ២០០០$។ ធនាគារតម្រូវឲ្យគាត់ដាក់កុំព្យូទ័រដែលលោកតារាមានធ្វើជាទ្រព្យធានា លោកតារាក៏យល់ព្រមចុះកិច្ចព្រមព្រៀងប្រាតិភោគ បន្ទាប់មកធនាគាររបស់លោក សុខបានប្រាប់វិញថា ចាំ១០ថ្ងៃសិន។ ក្នុងករណីនេះ កិច្ចព្រមព្រៀងមិនទាន់បង្កើតនោះទេ ព្រោះថាលក្ខខណ្ឌទាំងបីមិនទាន់បំពេញ ពោលគឺលក្ខខណ្ឌទី១ គឺអត្ថិភាពនៃកិច្ចព្រមព្រៀងប្រាតិភោគ និងលក្ខខណ្ឌទី៣ កូនបំណុលមានកម្មសិទ្ធិលើកុំព្យូទ័រទាំងអស់ព្រោះជាឧបករណ៍អាជីវកម្មរបស់គាត់ក៏ប៉ុន្តែខាងធនាគារមិនទាន់ផ្ដល់តម្លៃឲ្យទៅលោកតារានៅឡើយទេ ដែលលក្ខខណ្ឌទី២ មិនទាន់ត្រូវបានបំពេញ។ សកម្មភាពនេះត្រូវចាត់ទុកថាត្រឹមតែជាការពិចារណាឲ្យខ្ចីប្រាក់ប៉ុណ្ណោះ។ ករណីអង្គហេតុដដែល បើសិនជាធនាគារបានយល់ព្រមភ្លាមៗផ្ដល់ប្រាក់កម្ចីដល់លោក តារា ២០០០$ តាមរយៈឥណទានមានកំណត់[17] តែលោកតារាមិនទាន់ដកនោះវិញ ត្រូវចាត់ទុកជាសិទ្ធិប្រាតិភោគបានបង្កើតហើយ ទោះកូនបំណុលមិនទាន់ដកលុយក៏ដោយ។

### ១.២.២.៣. ប្រសិទ្ធភាពនៃកិច្ចព្រមព្រៀងប្រាតិភោគ

ពេលខ្លះកិច្ចព្រមព្រៀងប្រាតិភោគត្រូវបានបង្កើត តែមិនមានប្រសិទ្ធិភាពក្នុងការអនុវត្តដោយច្បាប់មិនទទួលស្គាល់ ដូចនេះចាំបាច់ត្រូវគោរពលក្ខខណ្ឌទាំងអស់ដែលត្រូវបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី ក្រៅពីលក្ខខណ្ឌនៃការភ្ជាប់សិទ្ធិប្រាតិភោគខាងលើ។ យោងតាមក្រមរដ្ឋប្បវេណី សុពលភាពនៃកិច្ចសន្យាដែលតម្រូវឲ្យមានលក្ខខណ្ឌ៣សំខាន់ទៀតគឺ ការបង្ហាញឆន្ទៈគ្មានវិការៈ

[16] សៀវភៅពន្យល់ និងឧទាហរណ៍នៃប្រតិបត្តិការដែលមានកិច្ចធានា, ទំព័រ ៦២

[17] ឥណទានមានកំណត់ គឺជាលិខិតស្នាមដែលមិនតម្រូវឲ្យអ្នកទទួលបានដកប្រាក់ភ្លាមៗទេ ពេលណាដែលគាត់ត្រូវការចាំដកទៅប្រើក៏បាន នេះដើម្បីរក្សាប្រាក់របស់អ្នកទទួលប្រាក់។

សមត្ថភាពភាគី និងកម្មវត្ថុស្របច្បាប់។ ដោយឈរលើបែបគតិយុត្តនៃកិច្ចសន្យា ច្បាប់តម្រូវឲ្យមានលក្ខខណ្ឌអានុភាពមួយទៀត គឺសំណើរ និងស្ទីការត្រូវគ្នា។ លើសពីនេះ កិច្ចព្រមព្រៀងប្រាតិភោគតម្រូវឲ្យសរសេរជាលាយលក្ខណ៍អក្សរ ឬ អាចវាយកុំព្យូទ័រក៏បាន តែបើវាធ្វើដោយផ្ទាល់មាត់គឺមិនអាចទទួលយកបានទេ។ ការសរសេរជាលាយលក្ខណ៍អក្សរ គឺត្រូវគោរពតាមទម្រង់ តែបើសិនមានការដាក់ឈ្មោះខុស ឬចំណងជើងកិច្ចព្រមព្រៀងផ្សេង មិនមានឥទ្ធិពលលើខ្លឹមសារនៃកិច្ចព្រមព្រៀងនេះទេ។ ឧទាហរណ៍៖ នីដា និងមុយឡេង បានព្រមព្រៀងគ្នាផ្ទាល់មាត់ថា នីដា នឹងឲ្យមុយឡេងខ្ចីប្រាក់៥០០$ ហើយមុយឡេងបានយកម៉ូតូឲ្យទៅឲ្យនីដា ដើម្បីធ្វើជាទ្រព្យធានា។ ករណីនេះកិច្ចព្រមព្រៀងមិនមានសុពលភាពនោះទេ ព្រោះមិនបានធ្វើជាលាយលក្ខណ៍អក្សរតាមច្បាប់តម្រូវ។ ម្យ៉ាងការព្រមព្រៀងដោយផ្ទាល់មាត់នេះ មិនបានបង្ហាញពីសក្ខីកម្មនៃសិទ្ធិប្រាតិភោគនោះទេ។

ករណីមួយទៀត គឺអាសយដ្ឋានរបស់ភាគីទោះមាន ឬ មិនមាន មិននាំឲ្យប៉ះពាល់សុពលភាពរបស់កិច្ចព្រមព្រៀងទេ ក៏ប៉ុន្តែវាជាចាំបាច់ក្នុងការស្គាល់អត្តសញ្ញាណរបស់គ្នាទៅវិញទៅមក ដើម្បីប្រាប់ជាដំណឹង ទៅម្ចាស់បំណុលដទៃទៀតអំពីទ្រព្យធានារបស់បុគ្គលមួយណាដែលបានជាប់សិទ្ធិប្រាតិភោគរួចទៅហើយនោះ។ ហេតុដូចនេះ ករណីការដាក់ឈ្មោះកូនបំណុលក្នុងកិច្ចព្រមព្រៀងប្រាតិភោគឲ្យបានត្រឹមត្រូវគឺជារឿងសំខាន់ គប្បីត្រូវពិចារណា ព្រោះខ្លាចប៉ះពាល់ទៅលើបុគ្គលផ្សេងទៀតបើករណីមានឈ្មោះស្រដៀង ឬ ប្រហាក់ប្រហែលគ្នា។ ឧទាហរណ៍ថាភាគីបានសរសេរឈ្មោះខុស ពីឈ្មោះសុភារិន ទៅជាសុភារី។ តុលាការនឹងធ្វើការវិនិច្ឆ័យថា ការសរសេរបែបនេះអាចបង្កភាពសង្ស័យទៅលើអត្តសញ្ញាណរបស់ភាគីដែលឬទេ។ បើមិនដូច្នេះទេ វាអាចបង្កឲ្យកិច្ចព្រមព្រៀងប្រាតិភោគ មោឃភាពដោយសារការច្រឡំលើឈ្មោះបុគ្គល។ បើពិនិត្យមើលទៅ សុភារិនជាឈ្មោះរបស់មនុស្សប្រុស ចំណែកសុភារីជាឈ្មោះរបស់មនុស្សស្រី។ ដូចនេះទោះបីជាកំហុសតិចតួចក៏ដោយ តែវាបង្កដល់ការភ័ន្តច្រឡំលើអត្តសញ្ញាណរបស់កូនបំណុល។

### ១.២.៣. ការធ្វើសុក្រឹតកម្មលើសិទ្ធិប្រាតិភោគ

ការភ្ជាប់សិទ្ធិប្រាតិភោគទៅនឹងទ្រព្យធានា នឹងផ្ដល់ឲ្យម្ចាស់បំណុលនូវសុក្រឹតភាព តែដើម្បីទទួលបានការការពារពេញលេញ ត្រូវបំពេញលក្ខខណ្ឌទៅតាមច្បាប់ ព្រោះការធ្វើសុក្រឹតកម្មធានាបាននូវសិទ្ធិរបស់ម្ចាស់បំណុលអតិបរមាក្នុងការតតាំងទៅនឹងតតិយជន។ ពោលជារួមគោលបំណងក្នុងការធ្វើសុក្រឹតកម្ម គឺដើម្បីតតាំងនឹងតតិយជននេះឯង។

#### ១.២.៣.១. មធ្យោបាយនៃការធ្វើសុក្រឹតកម្ម

ដោយអនុលោមតាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា មធ្យោបាយនៃការធ្វើសុក្រឹតកម្មមាន ៣សំខាន់ៗ៖

#### ក. សុក្រឹតកម្មដោយការតម្កល់លិខិតជូនដំណឹង និងការផ្ទេរការកាន់កាប់

ការតម្កល់លិខិតជូនដំណឹង គឺជាមធ្យោបាយមួយក្នុងការធ្វើសុក្រឹតកម្មលើសិទ្ធិប្រាតិភោគ។ បន្ទាប់ពីម្ចាស់បំណុលតម្កល់លិខិតជូនដំណឹង ម្ចាស់បំណុលដែលមានកិច្ចធានានឹងមានសិទ្ធិទាំងអស់ទៅលើអ្នកកាន់កាប់ទ្រព្យធានាដែលមិនបានធ្វើសុក្រឹតកម្ម ប្រសិនបើលិខិតជូនដំណឹងនេះមិនបានបាត់ប្រសិទ្ធិភាព។[18]

#### ក.១. ការតម្កល់លិខិតជូនដំណឹង

ការតម្កល់លិខិតជូនដំណឹង ត្រូវធ្វើនៅការិយាល័យតម្កល់លិខិតជូនដំណឹងដែលត្រូវបានបង្កើតដោយក្រសួងពាណិជ្ជកម្ម ហើយការិយាល័យតម្កល់នេះស្ថិតនៅក្រោមការត្រួតត្រារបស់នាយកដ្ឋាននីតិកម្ម នៃអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងស្រុក។[19] ប្រយោជន៍នៃការតម្កល់គឺដើម្បីព្រមានអនាគតម្ចាស់បំណុលផ្សេងទៀតពីសិទ្ធិអាទិភាពនៃសិទ្ធិទាមទារលើបំណុល និងដើម្បីបង្កើតកាលបរិច្ឆេទអាទិភាព ពោលគឺអ្នកតម្កល់បានមុន មានសិទ្ធិអាទិភាពមុនទៅលើទ្រព្យធានាតែមួយ។ ករណីដែលម្ចាស់បំណុលពីរនាក់មានសិទ្ធិប្រាតិភោគទៅលើទ្រព្យធានាតែមួយ តែពុំបានតម្កល់ ឬកាន់កាប់ទ្រព្យធានា នោះនឹងនាំឲ្យសិទ្ធិប្រាតិភោគដែលភ្ជាប់នឹងទ្រព្យធានាដែលមានកាលបរិច្ឆេទមុនគេមានអាទិភាពជាងគេ។ ចំណែកឯខ្លឹមសារនៃលិខិតជូនដំណឹងវិញ មានលក្ខណៈសាមញ្ញគឺតម្រូវឲ្យមានតែអត្តសញ្ញាណរបស់ម្ចាស់បំណុល និងអ្នកខ្ចី(កូនបំណុល) ព្រមទាំងការអធិប្បាយទូទៅពីទ្រព្យធានាតែប៉ុណ្ណោះ។ (*សូមមើលឧបសម្ព័ន្ធទី៦*)

រីឯកំណត់ត្រាត្រូវធ្វើជាសាធារណៈ និងអនុញ្ញាតឲ្យសាធារណៈជនចូលសាកសួរដោយមិនរើសអើងនោះទេ។ ប្រភេទនៃលិខិតជូនដំណឹងអំពីសិទ្ធិប្រាតិភោគរួមមាន ៥សំខាន់ៗ៖

- **លិខិតជូនដំណឹងដំបូង៖** មានរយៈពេល ៥ឆ្នាំគិតចាប់ពីកាលបរិច្ឆេទនៃការតម្កល់។ លិខិតជូនដំណឹងត្រូវចុះនូវអត្តសញ្ញាណរបស់អ្នកតម្កល់ ម្ចាស់បំណុលដែលមានកិច្ចធានា ម្ចាស់ឥណទាន កូនបំណុល និងការអធិប្បាយអំពីទ្រព្យធានា។

---

[18] មាត្រា ១០(២) នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

[19] មាត្រា ៥, ១៦, ១៧, និងមាត្រា១៨ នៃអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្មឆ្នាំ ២០១៤

- **លិខិតសុំកែប្រែ៖** អនុញ្ញាតឲ្យមានការផ្លាស់ប្តូរព័ត៌មាននៅក្នុងលិខិតជូនដំណឹងដំបូង ឬនៅក្នុងលិខិតសុំកែប្រែពីមុន។
- **លិខិតសុំបន្ត៖** គឺជាលិខិតដែលត្រូវតម្កល់ក្នុងកំឡុងពេល៦ខែមុនកំណត់នៃលិខិតជូនដំណឹងដំបូង លិខិតសុំបន្តនេះមានអានុភាពបន្តរយៈពេលលិខិតជូនដំណឹងបន្ថែម ០៥ឆ្នាំទៀត។
- **លិខិតសុំកែតម្រូវ៖** ជាលិខិតដែលត្រូវបានបំពេញដើម្បីកែតម្រូវព័ត៌មានដែលខ្លួនយល់ឃើញថាវាលែងជាព័ត៌មានត្រឹមត្រូវ។ (*សូមមើលឧបសម្ព័ន្ធទី៤*)
- **លិខិតសុំបញ្ចប់៖** គឺជាលិខិតដែលបញ្ចប់នូវលិខិតជូនដំណឹងទាក់ទងនឹងបុគ្គលដែលបានតម្កល់លិខិតជូនដំណឹងនោះ។

ចំណែកឯអាជ្ញាធរមានសមត្ថកិច្ចលើកិច្ចការរបស់រដ្ឋបាលនេះ ត្រូវបានបង្កើតឡើងដើម្បីទទួលការតម្កល់ និងរក្សាគណនីសម្រាប់អតិថិជន។ ការិយាល័យនេះត្រូវចេញនូវលិខិត និងទិន្នន័យនានាបន្ទាប់ពីមានការសុំស្រាវជ្រាវពីសាធារណៈជន នូវការតម្កល់លិខិតជូនដំណឹងលើសិទ្ធិប្រាតិភោគផ្សេងៗ (*សូមមើលឧបសម្ព័ន្ធទី៣*)។ ការិយាល័យធ្វើការប្រមូលទិន្នន័យប្រាតិភោគ និងទិន្នន័យនានាពាក់ព័ន្ធនឹងការតម្កល់ផងដែរ បើនិយាយទៅ ករណីយកិច្ចរបស់ការិយាល័យនេះ មិនសូវជាសំបូរបែបនោះទេ។ ករណីយកិច្ចសំខាន់របស់ការិយាល័យគឺ ត្រូវចុះលេខពិសេសលើលិខិតជូនដំណឹងនីមួយៗ កំណត់ពីកាលបរិច្ឆេទ ពេលវេលានៃការតម្កល់ កំណត់កាលបរិច្ឆេទកន្លងផុតរបស់លិខិតជូនដំណឹងដំបូង រក្សាកំណត់ត្រាបើសិនមានការសុំកែប្រែ និងការតម្កល់ដទៃទៀតដែលពាក់ព័ន្ធនឹងលិខិតជូនដំណឹងដើមដំបូងដែលមិនត្រឹមត្រូវ។ ក្រៅពីនេះ ត្រូវរក្សាទុកបញ្ជីរាយនាមតាមអក្ខរក្រមនៃឈ្មោះកូនបំណុល។ ការិយាល័យនេះមានករណីយកិច្ចរក្សាទុកលិខិតជូនដំណឹងរយៈពេល ១០ឆ្នាំក្រោយកាលបរិច្ឆេទផុតរយៈពេលរបស់លិខិតជូនដំណឹង។[20]

លក្ខណៈជាសាមញ្ញនៃការតម្កល់លិខិតជូនដំណឹង គឺមិនតម្រូវឲ្យមានព័ត៌មានច្រើនពីព្រោះមិនចង់ឲ្យមានឧបសគ្គ និងឥទ្ធិពលមិនសមរម្យដល់ប្រតិបត្តិការដែលមានកិច្ចធានា តែធ្វើយ៉ាងណាជំរុញការផ្តល់ហិរញ្ញប្បទានបានឆាប់រហ័សនោះទេ។

(*សូមមើលឧបសម្ព័ន្ធ ទី៤ និងទី៦*)

[20] មាត្រា 42 នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា

### ក.២. ការផ្ទេរការកាន់កាប់ទ្រព្យធានាទៅម្ចាស់បំណុល

ការផ្ទេរការកាន់កាប់ទ្រព្យធានាទៅឲ្យម្ចាស់បំណុល ក៏ជាមធ្យោបាយមួយទៀតនៃការធ្វើសុក្រឹតកម្មផងដែរ។ ការកាន់កាប់នេះវាមានលក្ខណៈស្រដៀងទៅនឹងវិធានរបស់ការបញ្ចាំចលនវត្ថុ ដែលតម្រូវឲ្យម្ចាស់បំណុលកាន់កាប់ទ្រព្យធានាដើម្បីតតាំងនឹងតតិយជន។ ការកាន់កាប់អាចធ្វើទៅបានប្រសិនបើទ្រព្យធានានោះជា ទំនិញ លិខិតស្នាម ឯកសារ ប័ណ្ណភាគហ៊ុនជាអាទិ៍។ ប៉ុន្តែចូរចាំថា ប្រសិនបើម្ចាស់បំណុលជ្រើសរើសវិធីកាន់កាប់ដើម្បីធ្វើសុក្រឹតកម្ម នោះសុក្រឹតភាពមានតែខណៈពេលកាន់កាប់ប៉ុណ្ណោះ តែបើកាលណាម្ចាស់បំណុលលែងកាន់កាប់ហើយ សុក្រឹតភាពនឹងបញ្ឈប់។[21] ដូចនេះហើយ ម្ចាស់បំណុលគប្បីពិចារណាធ្វើការតម្កល់លិខិតជូនដំណឹង ដែលអាចធានាសុក្រឹតភាពបានគ្រប់ពេល ដរាបណាលិខិតជូនដំណឹងនេះនៅមានប្រសិទ្ធិភាព។

## ខ.សុក្រឹតកម្មដោយស្វ័យប្រវត្តិនៅពេលភ្ជាប់សិទ្ធិប្រាតិភោគលើប្រាក់ខ្ចីទិញទំនិញប្រើប្រាស់

### ខ.១. សុក្រឹតកម្មដោយស្វ័យប្រវត្តិ

ក្រៅពីមធ្យោបាយនៃការធ្វើសុក្រឹតកម្មតាមរយៈការតម្កល់លិខិតជូនដំណឹង និងការកាន់កាប់ សុក្រឹតកម្មនឹងកើតដោយស្វ័យប្រវត្តិ ក្នុងករណីដែលសិទ្ធិប្រាតិភោគធ្វើទៅលើទំនិញប្រើប្រាស់។ "**ទំនិញប្រើប្រាស់**" ត្រូវបានគេឲ្យនិយមន័យថាជាចលនវត្ថុដែលប្រើជាចំបងក្នុងលក្ខណៈបុគ្គល គ្រួសារ ឬ គោលបំណងផ្ទះសំបែងច្រើនជាងសម្រាប់ការងារនៅក្នុងក្រុមហ៊ុន រោងចក្រ សិប្បកម្មជាអាទិ៍។ ផ្ទុយទៅវិញ ករណីមួយទៀតគឺ កុំព្យូទ័រត្រូវបានដាក់នៅក្នុងផ្ទះ ក្នុងបន្ទប់គេងផ្ទាល់ខ្លួន តែហាមមិនឲ្យមានអ្នកប្រើប្រាស់ ដូច្នេះចំណាត់ថ្នាក់ទ្រព្យធានានេះគឺជា"**ឧបករណ៍**" មិនមែនជាឧបករណ៍ប្រើប្រាស់ទៀតទេ។ ចូរចំណាំថា ការធ្វើសុក្រឹតកម្មលើទំនិញប្រើប្រាស់តែម្តងត្រូវបានហាមឃាត់ ក៏ប៉ុន្តសិទ្ធិលើប្រាតិភោគលើទំនិញប្រើប្រាស់ត្រូវបានអនុញ្ញាត ហើយម្ចាស់បំណុលមិនចាំបាច់តម្កល់លិខិតជូនដំណឹងទៅការិយាល័យតម្កល់លិខិតជូនដំណឹងនោះទេ តែសិទ្ធិប្រាតិភោគត្រូវបានភ្ជាប់ដោយឯកឯង។[22] នេះដោយសារតែតម្លៃនៃទំនិញប្រើប្រាស់មិនមានតម្លៃខ្ពស់ ម្យ៉ាងព្រោះតែនីតិនីពន្ធគិតថា ការផ្តល់ប្រាតិភោគលើទំនិញប្រើប្រាស់ជាប្រតិបត្តិការដែលអាចនឹងកើតមានច្រើនញឹកញាប់ ដូចនេះបើតម្រូវឲ្យធ្វើការតម្កល់នូវរាល់ពេលម្ចាស់បំណុលផ្តល់ប្រាក់ខ្ចី

[21] មាត្រា ១០(៥) នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

[22] មាត្រា ១០(៣) នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

ទិញទំនិញប្រើប្រាស់ទៅកូនបំណុល វានឹងអាចក្លាយជាការបន្ថែមបន្ទុកដល់ម្ចាស់បំណុល ក្នុងការចំណាយពេលវេលា និងការចំណាយច្រើនទៅលើការបង្កើតប្រតិបត្តិការនីមួយៗ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ច្បាប់ពុំបានហាមឃាត់ម្ចាស់បំណុលពីការតម្កល់លិខិតជូនដំណឹងចំពោះសិទ្ធិប្រាតិភោគបង្កើតលើទំនិញប្រើប្រាស់នោះទេ នេះគឺដោយហេតុថាបើសិនជាអ្នកទិញចង់ទិញទំនិញប្រើប្រាស់ពីកូនបំណុល ហើយសិទ្ធិប្រាតិភោគលើទំនិញប្រើប្រាស់របស់កូនបំណុលពុំមានការតម្កល់ប្រហែលជាវាផ្តល់នូវហានិភ័យចំពោះអ្នកទិញទំនិញប្រើប្រាស់ដែលជាប់សិទ្ធិប្រាតិភោគនោះ ព្រោះមិនបានដឹងថាទំនិញនោះបានជាប់សិទ្ធិប្រាតិភោគពីមុន។ ទោះបីជាច្បាប់កំណត់យ៉ាងនេះក៏ដោយ ការធ្វើសុក្រឹតកម្មលើទំនិញប្រើប្រាស់ដោយការតម្កល់លិខិតជូនដំណឹង ផ្តល់នូវការធានាខ្ពស់ជាងការមិនតម្កល់។

### ខ.២. អានុភាពរបស់សិទ្ធិប្រាតិភោគលើប្រាក់ខ្ចីទិញទំនិញប្រើប្រាស់

ជាគោលការណ៍ ការភ្ជាប់សិទ្ធិប្រាតិភោគលើទ្រព្យធានា ដោយការតម្កល់លិខិតជូនដំណឹងមុនគេគឺបញ្ជាក់នូវអាទិភាពលើសិទ្ធិផ្សេងទៀតដែលតម្កល់ក្រោយ ដែលអនុវត្តចំពោះប្រតិបត្តិការទាំងឡាយណាដែលគ្រប់ដណ្តប់ដោយច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា។ ករណីតម្កល់មុននេះហើយនាំឲ្យសិទ្ធិប្រាតិភោគនៅភ្ជាប់នឹងទំនិញប្រើប្រាស់គ្រប់ទីកន្លែង មិនថាទ្រព្យធានាដែលជាទំនិញប្រើប្រាស់នេះនៅក្នុងដៃអ្នកណានោះទេ។ ដោយសារតែការបង្កើតសិទ្ធិប្រាតិភោគលើប្រាក់ខ្ចីទិញទំនិញប្រើប្រាស់ ដែលត្រូវបានស្គាល់ថាជាការលក់ទិញជឿនេះ ធ្វើឲ្យអ្នកទិញក្នុងអាជីវកម្មធម្មតាពិបាកវិនិច្ឆ័យបានថា ទំនិញនេះមានជាប់សិទ្ធិប្រាតិភោគ ឬ អត់ ដោយសារតែសុក្រឹតកម្មដោយស្វ័យប្រវត្តិដូចបានពន្យល់ពីខាងដើមនេះ។ ហេតុដូច្នេះហើយ ករណីនេះអនុញ្ញាតឲ្យអ្នកទិញទំនិញប្រើប្រាស់ដែលជាអ្នកទិញទំនិញអាជីវកម្មធម្មតាពីកូនបំណុល មិនមានជាប់សិទ្ធិប្រាតិភោគនោះទេពោលគឺទោះបីជាទំនិញនេះនៅក្នុងដៃជនទីបីទៅហើយក៏ដោយ។[23]

### ១.២.៣.២. ការធ្វើសុក្រឹតកម្មលើប្រភេទទ្រព្យធានាផ្សេងៗទៀត

ការធ្វើសុក្រឹតកម្ម គឺជាការអនុវត្តជាធម្មតាជាមួយទ្រព្យធានាដូចមានការរៀបរាប់ក្នុងចំណុច ១.២.៣.១. (មធ្យោបាយនៃការធ្វើសុក្រឹតកម្ម) ដែលបានកំណត់ក្នុងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាដើម្បីការធានាកាតព្វកិច្ច ក៏ប៉ុន្តែសុក្រឹតកម្មលើយានយន្តដែលមានលេខស៊េរី និងឯកសារកម្មសិទ្ធិមានការខុសប្លែកបន្តិច។

[23] មាត្រា ១០(៣) នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

## ក. សុក្រឹតកម្មលើយានយន្តដែលមានលេខស៊េរី

ការធ្វើសុក្រឹតកម្មលើយានយន្តដែលមានលេខស៊េរី តាមរយៈការតម្កល់លិខិតជូនដំណឹងនេះតម្រូវឲ្យម្ចាស់បំណុល ធ្វើការអធិប្បាយពីលេខស៊េរីរបស់យានយន្តនោះប៉ុណ្ណោះ។ វាមានគុណប្រយោជន៍ដល់អ្នកទិញ ក្នុងការស្រាវជ្រាវនៅការិយាល័យតម្កល់លិខិតជូនដំណឹងពីលេខស៊េរីរបស់យានយន្តនានា ដូចជាម៉ូតូ ឡាន កាណូតជាដើម ថាតើវាមានជាប់សិទ្ធិប្រាតិភោគដែរឬទេ មុននឹងអ្នកទិញសម្រេចចិត្តទិញ។

ចំណុចដែលខុសប្លែក គឺថាយានយន្តដែលមានលេខស៊េរី មិនត្រូវបានគ្របដណ្តប់ដោយសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុល ទៅលើសារពើភណ្ឌជាយានយន្តនោះទេ។ ក្នុងករណីខាងលើនេះ ម្ចាស់បំណុលមិនតម្រូវឲ្យតម្កល់លិខិតជូនដំណឹង ដោយធ្វើការរៀបរាប់ពីលេខស៊េរីនីមួយៗរបស់កូនបំណុលដើម្បីធ្វើសុក្រឹតកម្មសិទ្ធិប្រាតិភោគរបស់ខ្លួនទេ ដោយយល់ឃើញវានឹងបង្កការលំបាក និងចំណាយពេលសម្រាប់ម្ចាស់បំណុលក្នុងការលុបចោលលេខស៊េរី ឬ បន្ថែមលេខស៊េរីរបស់យានយន្តនីមួយៗ នៅរាល់ពេលកូនបំណុលធ្វើការលក់ ឬទិញរថយន្តថ្មីចូលឃ្លាំងម្តងៗ។ ករណីកូនបំណុលជាម្ចាស់កន្លែងលក់ឡានច្រើន នៅពេលតម្កល់លិខិតជូនដំណឹងនៃកិច្ចព្រមព្រៀងប្រាតិភោគ ម្ចាស់បំណុលគ្រាន់តែពណ៌នាពីទ្រព្យធានាថា*"រាល់ឡានទាំងអស់ដែលមាននៅក្នុងឃ្លាំង"*។ ការបញ្ជាក់ប៉ុណ្ណោះ គឺគ្រប់គ្រាន់សម្រាប់ការយល់បានថា ឡាននេះសំដៅទៅលើឡានដាក់តាំង រួមទាំងឡានដែលទិញមកថ្មីផងដែរ។ ប៉ុន្តែបើឃ្លាំងលក់ឡានរបស់កូនបំណុលមានច្រើន ត្រូវបញ្ជាក់ពីឈ្មោះរបស់ឃ្លាំងនោះផង។

## ខ. សុក្រឹតកម្មលើឯកសារកម្មសិទ្ធិ

ជាទូទៅទំនិញដែលត្រូវបានគេដឹកជញ្ជូន ឬ ផ្ញើទុកដោយស្តុកក្នុងឃ្លាំង តែងតែមានបង្កាន់ដៃ ប័ណ្ណផ្ទុកទំនិញ ឬ ឯកសារដទៃទៀតបញ្ជាក់ពីកម្មសិទ្ធិរបស់ម្ចាស់ទំនិញ។ ឯកសារដែលចែងពីទំនិញនេះជាចលនវត្ថុ ដូចនេះវាមានអានុភាពដើម្បីបង្កើតសិទ្ធិប្រាតិភោគដែលតម្រូវឲ្យមានការធ្វើសុក្រឹតកម្មដូចគ្នានៅពេលបង្កើតសិទ្ធិប្រាតិភោគ។[24] ទោះបីជាទំនិញនៅក្នុងដៃរបស់អ្នកទទួលទុកទំនិញ ឬ ក្នុងដំណាក់កាលដឹកជញ្ជូនក៏ដោយ បើសិនជាឯកសារកម្មសិទ្ធិអំពីទំនិញទាំងនេះត្រូវបានចេញមក នាំឲ្យសិទ្ធិប្រាតិភោគដែលបានធ្វើសុក្រឹតភាពលើឯកសារកម្មសិទ្ធិ មានតម្លៃជាងសិទ្ធិប្រាតិភោគដែលបានធ្វើសុក្រឹតភាពលើទំនិញ មានន័យថាការប្រើប្រាស់ឯកសារធ្វើជាប្រាតិភោគ

[24] មាត្រា ១០(៤) នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

មានតម្លៃខ្ពស់ជាងសិទ្ធិប្រាតិភោគលើទំនិញដែលមានចែងក្នុងឯកសារ។ វិធាននេះមានគោលបំណងរក្សា និងផ្តល់ទំនុកចិត្តជាអតិបរមាដល់ការប្រើប្រាស់ឯកសារកម្មសិទ្ធិ។

### ១.២.៣.៣. សុក្រឹតកម្មលើផលនៃទ្រព្យធានា

#### ក. សុក្រឹតកម្មស្វ័យប្រវត្តិ

យោងតាមបទប្បញ្ញត្តិច្បាប់ "ផល" សំដៅទៅលើអ្វីដែលទទួលបានពេល លក់ ជួល ឬ ការផ្តល់អាជ្ញាប័ណ្ណពីទ្រព្យធានា សូម្បីតែការធានារ៉ាប់រងលើទ្រព្យធានានោះក៏ត្រូវចាត់ទុកជាផលនៃទ្រព្យធានាដែរ។[25] សិទ្ធិប្រាតិភោគភ្ជាប់ទៅនឹងទ្រព្យធានា វាក៏ត្រូវបានភ្ជាប់ដោយស្វ័យប្រវត្តិទៅនឹងផលនៃទ្រព្យធានាផងដែរ ដោយម្ចាស់បំណុលមិនចាំបាច់ធ្វើការតម្កល់លិខិតជូនដំណឹងពីសិទ្ធិប្រាតិភោគលើផលកើតចេញពីទ្រព្យធានានោះទេ។ ទោះបីកិច្ចព្រមព្រៀងមិនបានបញ្ជាក់ថាសិទ្ធិប្រាតិភោគគ្របដណ្តប់លើផលក៏ដោយ ក៏វាមានអនុភាពលើផលដោយស្វ័យប្រវត្តិ។ វាជាលក្ខណៈពិសេសមួយ សម្រាប់ករណីម្ចាស់បំណុលមិនបានដឹងថាខ្លួនមានសិទ្ធិលើផលនៃទ្រព្យធានានោះ ម្ចាស់បំណុលនៅតែត្រូវបានអនុញ្ញាតឲ្យយកផលលើទ្រព្យធានានោះយកមកសងបំណុល។

#### ខ. ការតម្កល់លិខិតជូនដំណឹងលើផល

គោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន តែងតែយកមកប្រើប្រាស់នៅក្នុងដំណាក់កាលការធ្វើសកម្មភាពអ្វីមួយលើកលែងតែច្បាប់ចែងរិតត្បិត។ បើមើលទៅលើមាត្រា៣ ចំណុច២២ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាមិនបានហាមឃាត់គូភាគីឲ្យបង្កើតនូវការយល់ព្រមផ្សេងនោះទេ។ ដូចនេះកូនបំណុល និងម្ចាស់បំណុលអាចព្រមព្រៀងបានថា ផលនៃទ្រព្យធានាមិនត្រូវបានគ្របដណ្តប់ដោយសិទ្ធិប្រាតិភោគនោះទេ។[26] ច្បាប់នៅតែទុកសិទ្ធិលើការបង្ហាញឆន្ទៈរបស់ភាគីបង្កើតកិច្ចព្រមព្រៀងគ្នាផ្សេងពីបញ្ញត្តិច្បាប់នៅក្នុងការធ្វើសុក្រឹតកម្មលើផលនេះ។

លក្ខណៈពិសេសនៃប្រតិបត្តិការដែលបង្កើតតាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាផ្តល់ឲ្យម្ចាស់បំណុលនូវផលនៃទ្រព្យធានា[27] មានន័យថាគ្រប់កាលៈទេសៈនៃការជម្រះចោលទ្រព្យធានា សិទ្ធិប្រាតិភោគត្រូវបានភ្ជាប់ទៅនឹងផលនៃទ្រព្យធានានោះ ទោះបីជាម្ចាស់បំណុលដែលមានកិច្ចធានាបានធ្វើការតម្កល់លិខិតជូនដំណឹង ដោយមិនបានបញ្ជាក់ពីអានុភាពនៃសិទ្ធិប្រាតិភោគទៅ

[25] មាត្រា ៣(២២) នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

[26] មាត្រា ៩(២) នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

[27] ផលនៃទ្រព្យធានា គឺជាអ្វីដែលទទួលបានពីការលក់ ឬដោះដូរទ្រព្យធានាគ្រប់រូបភាព។

លើផលនៃទ្រព្យធានាក៏ដោយ។ ម្ចាស់បំណុលអាចធ្វើការជ្រើសរើសការតម្កល់លិខិតជូនដំណឹងជាមួយនឹងការអធិប្បាយពីផលដែលកើតចេញពីទ្រព្យធានាដែលបានធ្វើសុក្រឹតកម្ម។

## ១.៣. ការអនុវត្តសិទ្ធិរបស់ម្ចាស់បំណុលដែលមានកិច្ចធានា

កិច្ចព្រមព្រៀងប្រាតិភោគ នឹងត្រូវបានបញ្ចប់បើសិនជាកូនបំណុលបានបំពេញកាតព្វកិច្ចដូចកំណត់ក្នុងកិច្ចព្រមព្រៀង បន្ទាប់មកកូនបំណុល ឬម្ចាស់បំណុលនឹងធ្វើការតម្កល់លិខិតសុំបញ្ចប់។ កិច្ចព្រមព្រៀងក៏ត្រូវរំលត់ផងដែរ ករណីដែលកូនបំណុលមិនសង ហើយម្ចាស់បំណុលបានអនុវត្តសិទ្ធិដោយការជម្រះចោលទ្រព្យធានា។ ក្នុងការអនុវត្តសិទ្ធិ ម្ចាស់បំណុលដែលមានកិច្ចធានាមានសិទ្ធិក្នុងការកាន់កាប់ទ្រព្យធានា ឬត្រួតត្រាលើទ្រព្យធានា។ សិទ្ធិនេះគឺជាការបន្ថែមទៅលើសិទ្ធិក្នុងការអនុវត្តដទៃទៀត ដែលកំណត់ដោយច្បាប់ផ្សេង។

### ១.៣.១. លក្ខខណ្ឌ និងយន្តការប្រើប្រាស់ដើម្បីអនុវត្តសិទ្ធិ

#### ១.៣.១.១. លក្ខខណ្ឌដើម្បីអនុវត្តសិទ្ធិ

ពាក់ព័ន្ធនឹងការកាន់កាប់ទ្រព្យធានា ប្រសិនបើម្ចាស់បំណុលដែលមានកិច្ចធានាទទួលបាននូវការជំទាស់ក្នុងកំឡុងពេល២០ថ្ងៃ[28] ពេលនេះម្ចាស់បំណុលដែលមានកិច្ចធានាមិនអាចរក្សាទុកទ្រព្យធានាដើម្បីទូទាត់កាតព្វកិច្ចបានទេ។ ដូចនេះម្ចាស់បំណុលដែលមានកិច្ចធានាត្រូវជម្រះចោលទ្រព្យធានា តាមរយៈមធ្យោបាយដទៃទៀតដែលច្បាប់នេះបានចែង។ ប្រសិនម្ចាស់បំណុល មិនទទួលបានការជំទាស់ក្នុងកំឡុងពេល២០ថ្ងៃទេ ច្បាប់តម្រូវឲ្យគាត់អាចរក្សាទ្រព្យធានានោះដើម្បីទូទាត់កាតព្វកិច្ចបំណុលបាន។ ម្យ៉ាងវិញទៀត វិធានទូទៅនៃអាទិភាពនៃសិទ្ធិប្រាតិភោគលើទ្រព្យធានាតែមួយ កំណត់ឲ្យការអនុវត្តសិទ្ធិរបស់ម្ចាស់បំណុលអាស្រ័យទៅលើការតម្កល់មុន មានសិទ្ធិអាទិភាពមុនគេដោយអាស្រ័យទៅលើកាលបរិច្ឆេទនៃការតម្កល់នោះ។

#### ១.៣.១.២. យន្តការដែលម្ចាស់បំណុលអាចប្រើប្រាស់ដើម្បីអនុវត្តសិទ្ធិ

បន្ទាប់ពីកូនបំណុលមិនសងបំណុល ម្ចាស់បំណុលមិនចាំបាច់ដាក់ពាក្យសុំទៅតុលាការដើម្បីធ្វើការកាន់កាប់ ឬ ត្រួតត្រាលើទ្រព្យធានានោះទេ ប្រសិនបើកូនបំណុលយល់ព្រមឲ្យម្ចាស់បំណុលកាន់កាប់។[29] ការយល់ព្រមនេះត្រូវតែធ្វើជាលាយលក្ខណ៍អក្សរ[30] និងយកមកអនុវត្តនៅ

---

[28] មាត្រា ៤៩ ចំណុចទី៤ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា

[29] មាត្រា ៤៨ ចំណុចទី១ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា

ពេលកូនបំណុលមិនសងបំណុល។ ក៏ប៉ុន្តែជាទូទៅកម្រណាស់ដែលកូនបំណុលយល់ព្រមផ្ទេរការកាន់កាប់ឲ្យម្ចាស់បំណុល។ បើពេលកំណត់ត្រូវសងបានមកដល់ ហើយម្ចាស់បំណុលជូនដំណឹងពីពេលវេលាដែលត្រូវសងទៅកូនបំណុល ហើយកូនបំណុលយល់ព្រមអនុវត្តកាតព្វកិច្ចដោយស្ម័គ្រចិត្ត នោះបញ្ហានឹងមិនកើតឡើងទេ តែបើកូនបំណុលមិនសុខចិត្តសងបំណុល នោះម្ចាស់បំណុលត្រូវចាត់វិធានការដែលច្បាប់បានផ្តល់ឲ្យ។

បន្ទាប់ពីមិនសងបំណុល បើកូនបំណុលមិនព្រមផ្តល់ការយល់ព្រមឲ្យម្ចាស់បំណុលធ្វើការកាន់កាប់ទ្រព្យធានា នោះនឹងតម្រូវឲ្យមានដំណើរការរឿងក្តីដើម្បីទទួលការកាន់កាប់។ ដូចនេះម្ចាស់បំណុលដែលមានកិច្ចធានាត្រូវដាក់ពាក្យទៅតុលាការសុំសេចក្តីសម្រេចកិច្ចការប្រញាប់ ឬការបញ្ជាពិសេសពីតុលាការ។[31] តុលាការត្រូវចេញដីកាកិច្ចការប្រញាប់ ដែលអនុញ្ញាតឲ្យម្ចាស់បំណុលទទួលបានការកាន់កាប់ទ្រព្យដែលដាក់ធានា។ ក្នុងករណីនេះតុលាការត្រូវពិចារណាពីរករណីគឺ តើមានកិច្ចព្រមព្រៀងប្រាតិភោគរវាងកូនបំណុល និងម្ចាស់បំណុលដែរឬទេ? និងទីពីរពិចារណា ថាតើកូនបំណុលពិតជាមិនសងបំណុលពិតមែនឬទេ?[32] បន្ទាប់មកទៀត តុលាការនឹងចេញដីកាមួយបង្គាប់ឲ្យកាន់កាប់ ឬត្រួតត្រាទៅតាមជម្រើសដែលម្ចាស់បំណុលមានកិច្ចធានាចង់បាន។

### ១.៣.២. សិទ្ធិលោះទ្រព្យធានា និងការជម្រះទ្រព្យធានា

#### ១.៣.២.១. ការអនុវត្តសិទ្ធិលោះមកវិញនូវទ្រព្យធានា

ទោះបីជាទ្រព្យធានា ត្រូវបានម្ចាស់បំណុលដែលមានកិច្ចធានាបានរឹបអូសយកមកដើម្បីធ្វើការជម្រះចោលក៏ដោយ បទប្បញ្ញត្តិនៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា អនុញ្ញាតឲ្យកូនបំណុលមានសិទ្ធិលោះមកវិញនូវទ្រព្យធានានោះ តែកូនបំណុលត្រូវតែបំពេញកាតព្វកិច្ចទាំងអស់ដែលត្រូវបានធានាដោយទ្រព្យធានា ដូចជាការចំណាយផ្សេងៗក្នុងការកាន់កាប់ ការជួសជុល និងក្នុងការរៀបចំធ្វើការជម្រះទ្រព្យធានាបានទូទាត់ដោយកូនបំណុល។[33] ជាពិសេស ការលោះនេះត្រូវធ្វើឡើងមុនពេលម្ចាស់បំណុលដែលមានកិច្ចធានា ជម្រះចោលនូវទ្រព្យធានា ឬចុះកិច្ចសន្យាជម្រះចោលនូវទ្រព្យធានា ឬមុនកាតព្វកិច្ចរបស់កូនបំណុលត្រូវបានរលត់។

---

[30] មាត្រា ៥១ ចំណុចទី៣ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

[31] មាត្រា ៤៨ ចំណុចទី២ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

[32] មាត្រា ៤៨(១) នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

[33] មាត្រា ៥២ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

ក្នុងការលក់ទ្រព្យធានានេះទៀតសោត ម្ចាស់បំណុលត្រូវគោរពតាម "ភាពសមស្របនៃគោលការណ៍ពាណិជ្ជកម្ម"[34] ពោលគឺស្របទៅនឹងការប្រព្រឹត្តដែលវិចារណបុគ្គលក្នុងអាជីវកម្មធម្មតានៃការលក់ប្រភេទដូចគ្នានៃទ្រព្យ នឹងជ្រើសរើសយកមកអនុវត្ត។ កូនបំណុលមិនអាចអះអាងប្រឆាំងដោយយកភ័ស្តុតាងថាការលក់ទ្រព្យធានានៅកន្លែងផ្សេង ឬពេលវេលាផ្សេងនាំឲ្យទទួលបានតម្លៃដែលប្រសើរជាងមុននោះទេ។[35] ក៏ប៉ុន្តែបើសិនជាម្ចាស់បំណុល មិនគោរពតាមពេលវេលាពិសេសដោយការធ្វេសប្រហែស ឬ លក់ខុសពីតម្លៃទីផ្សារជាអាទិ៍ នោះនឹងត្រូវចាត់ទុកថាម្ចាស់បំណុលរំលោភកាតព្វកិច្ចរបស់ខ្លួន។

### ១.៣.២.២. ការជម្រះទ្រព្យធានា

ម្ចាស់បំណុលអាចជ្រើសរើសវិធីណាមួយក្នុងការជម្រះចោលនូវទ្រព្យធានា ដើម្បីយកប្រាក់មកសងបំណុលដែលបានជំពាក់ នេះជាសិទ្ធិរបស់ម្ចាស់បំណុលក្នុងការជម្រះចោលទ្រព្យធានា។ ការជម្រះចោលអាចធ្វើក្នុងរូបភាព ការលក់ ជួលជាអាទិ៍។[36] ការលក់អាចធ្វើមួយផ្នែក ឬទាំងស្រុង និងអាចជ្រើសរើសពេលវេលាក្នុងការជម្រះ។ ការជម្រះអាចធ្វើក្នុងវេទិកាសាធារណៈ ឬឯកជន ហើយម្ចាស់បំណុលសុទ្ធតែអាចមានសិទ្ធិទិញទ្រព្យធានាបាន។[37] ម្ចាស់បំណុលដែលមានកិច្ចធានាត្រូវជូនដំណឹងសមស្របអំពីពេលវេលា និងទីកន្លែងដែលប្រព្រឹត្តទៅនៃការជម្រះ លើកលែងតែទ្រព្យដែលត្រូវជម្រះងាយផុយរលួយ ឬ ឆាប់ធ្លាក់ថ្លៃ ដែលមិនតម្រូវឲ្យម្ចាស់បំណុលជូនដំណឹងកូនបំណុលនោះទេ។[38]

ប្រសិនបើទ្រព្យធានាមួយជាកម្មវត្ថុនៃការធានាដែលមានម្ចាស់បំណុលច្រើន ហើយដែលម្ចាស់បំណុលដទៃទៀតធ្វើលិខិតជូនដំណឹងពីសិទ្ធិរបស់ខ្លួន នោះម្ចាស់បំណុលដែលមានបំណងធ្វើការជម្រះ ត្រូវជូនដំណឹងដល់ម្ចាស់បំណុលដទៃនោះពីមុននឹងការជម្រះចោលទ្រព្យធានា។ នៅពេលការជម្រះចោលត្រូវបានបញ្ចប់ ផលនៃការជម្រះនេះ[39] ត្រូវប្រើជាដំបូងសម្រាប់ការចំណាយផ្សេងៗដែលប្រើប្រាស់លើការជម្រះចោលទ្រព្យធានា ដូចជាចំណាយលើការរក្សាទុកទ្រព្យធានា

[34] មាត្រា ៥៣ ចំណុចទី២ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

[35] មាត្រា ៥៣ ចំណុចទី៤ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

[36] មាត្រា ៥៩(១) នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

[37] មាត្រា ៥៩(៦) នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

[38] មាត្រា ៥៩(៤) នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

[39] គឺជាសាច់ប្រាក់ ដែលទទួលបានពីការជម្រះទ្រព្យធានា

ការរៀបចំទ្រព្យធានាសម្រាប់ជម្រះចោល និងការចំណាយលើឯកសារច្បាប់របស់ម្ចាស់បំណុល។[40] បន្ទាប់មកផលពីទ្រព្យធានានោះ យកទៅប្រើសម្រាប់សងបំណុលដែលមានកិច្ចធានាហើយប្រសិនបើទ្រព្យធានាមិនគ្រប់សងបំណុលទេ កូនបំណុលត្រូវទទួលខុសត្រូវចំនួនដែលខ្វះ។[41]

ចំណែកទ្រព្យធានាដែលនៅសល់ ម្ចាស់បំណុលត្រូវប្រគល់ជូនកូនបំណុលវិញ តែបើមានម្ចាស់បំណុលដទៃទៀត ត្រូវយកផលទៅទូទាត់ បើសិនជាម្ចាស់បំណុលដទៃទៀតបានធ្វើលិខិតជូនដំណឹងដល់ម្ចាស់បំណុលដែលមានកិច្ចធានាតាំងពីដំបូងនៃដំណើរការជម្រះនេះ ឬទទួលលិខិតជូនដំណឹងពីម្ចាស់បំណុលដែលមានកិច្ចធានាដទៃទៀត។ ចំពោះអ្នកទិញទ្រព្យធានាវិញករណីការជម្រះចោលនេះ មិនជាប់សិទ្ធិប្រាតិភោគទេ។ ការណ៍នេះដើម្បីការពារការខាតបង់ដែលកើតឡើងលើអ្នកទិញទ្រព្យធានា និងដើម្បីធានាថាតម្លៃនៃទ្រព្យធានានឹងមិនធ្លាក់ចុះ។

### ១.៣.៣. វិបាកនៃការអនុវត្តសិទ្ធិ

#### ១.៣.៣.១. វិបាកពាក់ព័ន្ធនឹងអ្នកទិញទ្រព្យធានា និងផលទទួលបានពីទ្រព្យធានា

ជាទូទៅ សិទ្ធិប្រាតិភោគនៅជាប់នឹងទ្រព្យធានាបន្ទាប់ពីបានធ្វើសុក្រឹតកម្ម ទោះបីជាទ្រព្យធានាត្រូវបានគេលក់ ឬដោះដូរក៏ដោយ។ ដូចនេះហើយអ្នកទិញទ្រព្យធានាត្រូវមានការប្រុងប្រយ័ត្ន បើមិនដូច្នោះទេ អ្នកទិញត្រូវចាត់ទុកថាទិញទ្រព្យធានាដែលជាប់ទាំងសិទ្ធិប្រាតិភោគ។ ក៏ប៉ុន្តែតាមអំណាននៃមាត្រា១៥ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា បើសិនអ្នកទិញមិនបានដឹងថាទ្រព្យធានាជាប់សិទ្ធិប្រាតិភោគ ហើយទ្រព្យធានានោះទៀតសោតមិនបានធ្វើសុក្រឹតកម្ម នោះអ្នកទិញនឹងទទួលបានទ្រព្យធានាដោយមិនជាប់សិទ្ធិប្រាតិភោគ។ ដោយឡែកចំពោះទំនិញប្រើប្រាស់ បើសិនជាម្ចាស់បំណុលបានធ្វើការតម្កល់លិខិតជូនដំណឹង ជំនួសឲ្យការជឿទុកចិត្តទៅលើសុក្រឹតកម្មដោយស្វ័យប្រវត្តិ នោះម្ចាស់បំណុលដែលមានកិច្ចធានាមានអាទិភាពលើអ្នកទិញទំនិញប្រើប្រាស់ និយាយម្យ៉ាងទៀតថាសិទ្ធិប្រាតិភោគត្រូវបានភ្ជាប់ទៅនឹងទំនិញប្រើប្រាស់ដែលអ្នកទិញបានជាវពីកូនបំណុល។ សុក្រឹតកម្មដោយស្វ័យប្រវត្តិ ដែលកើតឡើងពីប្រតិបត្តិការនៃប្រាតិភោគដែលមានលើទំនិញប្រើប្រាស់ ពុំមានអាទិភាពលើអ្នកទិញទំនិញប្រើប្រាស់ឡើយ បើមិនបានតម្កល់លិខិតជូនដំណឹង។[42]

---

[40] មាត្រា ៥០(១) នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

[41] មាត្រា ៥០(២) នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

[42] មាត្រា ១៤(៣) នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

ដូចបានបញ្ជាក់ពីខាងដើម ជាទូទៅអ្នកជួលទ្រព្យធានាត្រូវបានភ្ជាប់សិទ្ធិប្រាតិភោគកាលបើខ្លួនបានដឹងថាទ្រព្យធានាមានជាប់សិទ្ធិប្រាតិភោគ និងក្រោយពេលដែលទ្រព្យធានាមានសុក្រឹតភាព។ តែទោះជាយ៉ាងនេះក្តី ជាអញ្ញត្រកម្មចំពោះអ្នកជួលក្នុងអាជីវកម្មធម្មតា ទោះបីជាគាត់បានដឹងថាសិទ្ធិលើការជួលនោះជាប់សិទ្ធិប្រាតិភោគ ឬ បានដឹងពីសុក្រឹតភាពនៃសិទ្ធិនោះក៏ដោយ ក៏សិទ្ធិលើការជួលនោះមិនជាប់សិទ្ធិប្រាតិភោគដែរ។ ចំណែកឯយានយន្តដែលមានលេខស៊េរីវិញក៏ដូចគ្នា គឺម្ចាស់បំណុលដែលមានកិច្ចធានានឹងមានអាទិភាពលើអ្នកទិញយានយន្ត ប្រសិនបើខ្លួនបានតម្កល់លិខិតជូនដំណឹងដោយការអធិប្បាយពីលេខស៊េរីនៃយានយន្តនោះ។[43] ការណ៍នេះនឹងនាំម្ចាស់បំណុលដែលមានកិច្ចធានាអាចអនុវត្តសិទ្ធិប្រាតិភោគលើយានយន្តដែលមានលេខស៊េរី ប្រឆាំងនឹងអ្នកទិញបាន។ ឧទាហរណ៍ថា ម្ចាស់បំណុល **ក** បានធ្វើសុក្រឹតកម្មតាមរយៈការតម្កល់លិខិតជូនដំណឹងអំពីសិទ្ធិប្រាតិភោគលើឡានម៉ាក Porche មួយគ្រឿងដោយមិនបានអធិប្បាយពីលេខស៊េរីនោះទេ។ ក្រោយមក កូនបំណុលដែលជាម្ចាស់ឡាន បានលក់ឡាននេះទៅអ្នកប្រើប្រាស់ ដូចនេះនាំឲ្យឡានដែលត្រូវបានទិញដោយអ្នកប្រើប្រាស់ មិនបានជាប់សិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុល **ក** ទេ ពីព្រោះការពិនិត្យមើលក្នុងការិយាល័យតម្កល់ពីលេខស៊េរីរបស់ឡានម៉ាក Porche នេះមិនត្រូវបានលាតត្រដាងទេហើយអ្នកទិញមានការពិបាកក្នុងការដឹងថាឡាននេះជាប់សិទ្ធិប្រាតិភោគ។ ម្យ៉ាងទៀតម្ចាស់បំណុលក៏មិនអាចអនុវត្តសិទ្ធិប្រាតិភោគប្រឆាំងនឹងអ្នកទិញបានដែរ។

ចំណែកឯវិបាកទាក់ទងនឹងផលវិញ របបគតិយុត្តនៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាបានកំណត់ថា អ្នកលក់ទំនិញដែលស្គាល់ថាជាម្ចាស់បំណុលដែលមានកិច្ចធានា អាចធ្វើការទាមទារយកបាននូវផលដែលកើតពីទ្រព្យធានាក្នុងរូបភាពណាក៏ដោយ មិនខ្វល់ថាកូនបំណុលបានលក់ទ្រព្យធានាទៅជនទី៣ ហើយជនទី៣ បានលក់ទ្រព្យធានាទៅជនទី៤ ក៏ម្ចាស់បំណុលដែលមានកិច្ចធានានៅតែអាចទាមទារមកបាននូវផលជាសាច់ប្រាក់ ដែលកើតចេញពីការលក់ទ្រព្យធានាដែលបានធ្វើសុក្រឹតកម្ម។ និយាយឲ្យចំ ដោយសារតែផលរបស់ទ្រព្យធានាភ្ជាប់ទៅនឹងទ្រព្យធានានៅពេលបង្កើតសិទ្ធិប្រាតិភោគ ដូចនេះវាអនុញ្ញាតឲ្យម្ចាស់បំណុលដែលមានកិច្ចធានា មានសិទ្ធិទាមទារផលទាំងនោះ លើកលែងតែម្ចាស់បំណុល និងកូនបំណុលបានបង្កើតកិច្ចព្រមព្រៀងថាផលនៃទ្រព្យធានាមិនជាប់សិទ្ធិប្រាតិភោគនោះទេ។ នេះជាការផ្តល់លទ្ធភាពដល់គូភាគីនៃកិច្ចព្រមព្រៀងឲ្យធ្វើការសម្រេចទៅលើអានុភាពនៃសិទ្ធិប្រាតិភោគទៅលើផល។

[43] មាត្រា ១៤(៤) នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

### ១.៣.៣.២. វិបាកទាក់ទងនឹងប្រាតិភោគចំពោះប្រាក់ខ្ចីទិញទំនិញ ឧបករណ៍ និង សារពើភណ្ឌ

ការបង្កើតសិទ្ធិប្រាតិភោគលើប្រាក់ខ្ចីទិញទំនិញ ឧបករណ៍ និងសារពើភណ្ឌ គឺជាការលក់ទិញជឿតែមានការតម្កល់លិខិតជូនដំណឹងលើប្រតិបត្តិការទាំងអស់នេះ។ ត្រូវចាំថានេះជាករណីពិសេសដែលវិធានច្បាប់បានផ្តល់ឲ្យនូវអាទិភាពរបស់វា ទោះបីជាការតម្កល់លិខិតជូនដំណឹងលើប្រភេទទ្រព្យធានាពាក់ព័ន្ធនឹងប្រាតិភោគលើប្រាក់ខ្ចីទិញទំនិញទាំងបីប្រភេទនេះ ត្រូវបានធ្វើឡើងក្រោយម្ចាស់បំណុលដទៃទៀតក៏ដោយ តែនៅតែមានអាទិភាពមុនគេ។ នេះគេហៅថា "តម្កល់លំដាប់ទី២ មានអាទិភាពមុនគេ"។ ករណីនេះប្លែកបន្តិចដែលតោងទាមអ្នកអនុវត្តត្រូវមានការប្រុងប្រយ័ត្នលើចំណុចនេះ។ ដូចនេះត្រូវចាំថា ការតម្កល់លិខិតជូនដំណឹងចំពោះប្រភេទទ្រព្យធានាជាទំនិញ ឧបករណ៍ ឬសារពើភណ្ឌ គឺតម្កល់ក្រោយតែទទួលអាទិភាពមុន។

ឧទាហរណ៍ថា ធនាគារបានភ្ជាប់សិទ្ធិប្រាតិភោគដោយការធ្វើសុក្រឹតកម្ម និងពិពណ៌នានៅក្នុងកិច្ចព្រមព្រៀងប្រាតិភោគថា "គ្រប់ចលនទ្រព្យរបស់កូនបំណុល" ហើយ៣ខែក្រោយមកកូនបំណុលបានទិញទំនិញជឿពីម្ចាស់ហាងលក់ម៉ូតូហង់ដា ដោយហាងលក់ម៉ូតូបានធ្វើសុក្រឹតកម្មក្នុងរយៈពេល ៥ថ្ងៃបន្ទាប់ពីប្រគល់ម៉ូតូឲ្យទៅកូនបំណុល។ ករណីនេះ សិទ្ធិប្រាតិភោគរបស់ម្ចាស់ហាងហង់ដា ត្រូវមានអាទិភាពលើសិទ្ធិប្រាតិភោគដែលបានតម្កល់មុនរបស់ធនាគារ។[44]

បន្ទាប់ពីបញ្ចប់សញ្ញាណទូទៅនៃប្រតិបត្តិការដែលមានកិច្ចធានា ចំណុចដែលនឹងត្រូវយកមកបង្ហាញជាបន្ទាប់ គឺធ្វើការសិក្សាប្រៀបធៀបប្រតិបត្តិការដែលមានកិច្ចធានា និងប្រាតិភោគចលនវត្ថុដទៃទៀតក្នុងក្រមរដ្ឋប្បវេណី។ ដូចដែលបានបញ្ជាក់បង្ហាញនូវខាងក្រោម ក្រៅពីប្រាតិភោគចលនវត្ថុដែលត្រូវបានបង្កើតតាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ប្រាតិភោគចលនវត្ថុក៏អាចត្រូវបានបង្កើតតាមរូបភាពផ្សេងទៀតដែលបញ្ញត្តដោយច្បាប់ទូទៅ។ ពោលគឺមានមូលដ្ឋានគតិយុត្តិពីរដែលយកមកប្រើប្រាស់ សម្រាប់ធានាកាតព្វកិច្ចដោយដាក់នូវចលនវត្ថុជាទ្រព្យធានាដែលក្នុងនោះមានសិទ្ធិលើការបញ្ចាំ និងប្រាតិភោគដោយអនុប្បទានដែលគ្រប់គ្រងដោយក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

កូនបំណុល ឬម្ចាស់បំណុល មានសិទ្ធិក្នុងការជ្រើសរើសរបបគតិយុត្តមួយណាដើម្បីធ្វើការគ្រប់គ្រងកាតព្វកិច្ចរបស់ខ្លួន។ សេរីភាពរបស់កូនបំណុល ឬ ម្ចាស់បំណុលក្នុងការជ្រើសរើសសញ្ញានប្រាតិភោគចលនវត្ថុណាមួយក៏ដោយ ត្រូវគោរពតាមលក្ខខណ្ឌដែលកំណត់ដោយច្បាប់

[44] មាត្រា ១៨(១) នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

ដើម្បីធ្វើការអនុវត្តសិទ្ធិមានប្រសិទ្ធិភាព។ តទៅទៀតនេះ នឹងធ្វើការពិភាក្សាលម្អិតពីលក្ខខណ្ឌនីមួយៗ មុននឹងធ្វើការជ្រើសរើស របបគតិយុត្តណាដែលមានសារៈប្រយោជន៍ដល់ប្រតិបត្តិការនៃប្រាតិភោគចលវត្ថុ។ នៅក្នុងជំពូកទី១នេះ សូមមិនធ្វើការបកស្រាយពីរបបគតិយុត្តនៃសិទ្ធិលើការបញ្ចាំ និងប្រាតិភោគដោយអនុប្បទានទេ ព្រោះវាជាសញ្ញាណដែលអ្នកអនុវត្តស្គាល់ច្រើន និងមានស្នាដៃមួយចំនួនហើយដែលបានសរសេរពីសញ្ញាណការបញ្ចាំចលនវត្ថុតាមក្រមរដ្ឋប្បវេណី។

# ជំពូកទី២ ការសិក្សាប្រៀបធៀបប្រាតិភោគចលនវត្ថុ តាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា និង តាមក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ប្រាតិភោគប្រត្យក្ស គឺជាប្រភេទមួយនៃសិទ្ធិប្រត្យក្សដែលត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រងទំនាក់ទំនងគតិយុត្តពាក់ព័ន្ធនឹងប្រតិបត្តិការធានាបំណុលដោយយកវត្ថុទៅដាក់ធានា ព្រោះថាបើថ្ងៃក្រោយមកកូនបំណុលមិនបំពេញកាតព្វកិច្ច ម្ចាស់បំណុលមានសិទ្ធិរឹបអូសទ្រព្យធានាដើម្បីសងសិទ្ធិលើបំណុលដែលមានអាទិភាពជាងម្ចាស់បំណុលធម្មតា។ ប្រាតិភោគដែលនឹងយកមកពិភាក្សាប្រៀបធៀបខាងក្រោម គឺយកត្រឹមតែប្រាតិភោគចលនវត្ថុតាមការព្រមព្រៀងប៉ុណ្ណោះ ចំពោះឯកសិទ្ធិ និងសិទ្ធិឃាត់ទុកដែលជាប្រភេទសិទ្ធិប្រាតិភោគប្រត្យក្សដែលច្បាប់កំណត់ មិនត្រូវបានយកមកធ្វើការប្រៀបធៀបនៅទីនេះនោះទេ។ ក្រៅពីប្រាតិភោគប្រត្យក្សដែលបង្កើតដោយក្រមរដ្ឋប្បវេណី ភាគីនៅតែអាចជ្រើសរើសយកការបង្កើតសិទ្ធិប្រាតិភោគប្រត្យក្សតាមច្បាប់ពិសេសបាន។ ប៉ុន្តែរហូតមកដល់ឥលូវ គឺមានតែច្បាប់ស្តីពីប្រតិបត្តិដែលមានកិច្ចធានាតែមួយគត់ដែលបានបង្ហាញវត្តមាននូវសិទ្ធិប្រាតិភោគប្រត្យក្ស តែធ្វើការកំណត់យកត្រឹមតែការធានាដោយដាក់នូវចលនវត្ថុតែប៉ុណ្ណោះ។

របបគតិយុត្តនៃប្រតិបត្តិការដែលមានកិច្ចធានាមានភាពដូចគ្នា និងប្លែកគ្នាពីប្រាតិភោគចលនវត្ថុតាមក្រមរដ្ឋប្បវេណី ទាំងការបង្កើត ការរំលាយ និងការអនុវត្តសិទ្ធិ ដែលសម្រាប់អ្នកប្រើប្រាស់ វាហាក់ដូចជាមានភាពស្រពិចស្រពិល និងពិបាកក្នុងការបែងចែកបន្តិចប្រសិនបើមិនស្គាល់ពីរបបគតិយុត្តនីមួយៗច្បាស់លាស់។ ដូចនេះ ដើម្បីកំចាត់ចោលនូវភាពមន្ទិលចំពោះសញ្ញាណនៃប្រាតិភោគចលនវត្ថុទាំងបីខុសគ្នានេះ គប្បីធ្វើការប្រៀបធៀបរបបគតិយុត្តនីមួយៗដាច់ដោយឡែកពីគ្នា ដោយពិភាក្សាប្រៀបធៀបលើប្រតិបត្តិការដែលមានកិច្ចធានា និងការបញ្ចាំតាមក្រមរដ្ឋប្បវេណី **(២.១)** ជាមុន បន្ទាប់មកធ្វើការប្រៀបធៀបប្រតិបត្តិការដែលមានកិច្ចធានា និងប្រាតិភោគដោយអនុប្បទានតាមក្រមរដ្ឋប្បវេណី**(២.២)**។ ចំណុចសំខាន់ជាចុងក្រោយ នឹងធ្វើការលើកយកនូវបញ្ញត្តិសម្របសម្រួលប្រាតិភោគចលនវត្ថុរវាងប្រតិបត្តិការដែលមានកិច្ចធានា និងក្រមរដ្ឋប្បវេណី **(២.៣.)**មួយទៀត ដែលសម្គាល់ឃើញជាកំណត់ដោយបញ្ញត្តក្នុងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១ ក្នុងគោលបំណងធ្វើការគ្រប់គ្រងរបបគតិយុត្តនេះឲ្យដំណើរការទៅបានរលូន។

## ២.១. ប្រតិបត្តិការដែលមានកិច្ចធានា និង ការបញ្ចាំចលនវត្ថុតាមក្រមរដ្ឋប្បវេណី

ជាជំហានដំបូងសូមធ្វើការប្រៀបធៀប ប្រតិបត្តិការដែលមានកិច្ចធានា និងការបញ្ចាំដែលនៅក្រោមរបបនេះយើងធ្វើការប្រៀបធៀបលក្ខណៈដូចគ្នា(២.១.១) និងលក្ខណៈខុសគ្នា(២.១.២) នូវចំណុចមួយចំនួនគួរឲ្យកត់សម្គាល់ និងមានខ្លឹមសារជាសារវន្តសម្រាប់ការធ្វើការសិក្សាពិភាក្សា។

### ២.១.១. លក្ខណៈរួម

ដោយស្ថិតនៅក្នុងរបបគតិយុត្តនៃសិទ្ធិប្រាតិភោគប្រត្យក្សលើចលនវត្ថុដូចគ្នា ប្រតិបត្តិការដែលមានកិច្ចធានា និងសិទ្ធិលើការបញ្ចាំមានលក្ខណៈដូចគ្នាមួយចំនួនគួរឲ្យកត់សម្គាល់ដូចខាងក្រោម។

#### ២.១.១.១. ប្រភេទនៃទ្រព្យដែលអាចដាក់ប្រាតិភោគ

គេធ្វើការបែងចែកចលនវត្ថុដែលអាចដាក់ជាប្រាតិភោគជា ២ប្រភេទដែលយកជាកម្មវត្ថុនៃការបញ្ចាំ និងការបង្កើតប្រតិបត្តិការដែលមានកិច្ចធានាដែលនឹងត្រូវពិភាក្សារួមមាន ទ្រព្យរូបិយ និងទ្រព្យអរូបិយ។ ការកំណត់បែបនេះ ដើម្បីឲ្យការបង្កើតប្រតិបត្តិការដាក់ធានាអាចបង្កើតឡើងតាមច្រើនរូបភាព និងមិនមានការរំខានដល់អាជីវកម្មក្នុងការប្រើប្រាស់ចលនវត្ថុសម្រាប់ធានាសិទ្ធិលើបំណុល។

##### ក. ចលនទ្រព្យរូបិយ

តាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា និងការបញ្ចាំតាមក្រមរដ្ឋប្បវេណី ការប្រើប្រាស់ចលនវត្ថុជាវត្ថុរូបិយ ដើម្បីធ្វើជាទ្រព្យធានាជាទូទៅត្រូវបានអនុញ្ញាត។ តែបើតាមការសង្កេតមើលទៅនៅក្នុងប្រតិបត្តិការដែលមានកិច្ចធានា បានកំណត់ច្បាស់លាស់ពីប្រភេទទ្រព្យដែលអាចប្រើប្រាស់ដើម្បីដាក់ប្រាតិភោគមានច្រើនប្រភេទដូចជាទំនិញ រួមមាន សារពើភណ្ឌ កសិផល ឧបករណ៍ ចំណែកទំនិញប្រើប្រាស់ មានដូចជា កង់ ម៉ូតូ ទូរស័ព្ទ រថយន្តជាអាទ៍។ ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាបើកទូលាយដល់អាជីវករទាំងអស់ ប្រើប្រាស់សិទ្ធិទាំងអស់ដែមានលើចលនវត្ថុគ្រប់ប្រភេទ។[45]

ប្រតិបត្តិការខាងលើនេះ ក៏មិនខុសគ្នាពីសិទ្ធិលើការបញ្ចាំដែរព្រោះបើតាមការបកស្រាយនៅក្នុងក្រមរដ្ឋប្បវេណី មិនមានបទប្បញ្ញត្តិណាដែលហាមឃាត់ការបញ្ចាំនូវចលនវត្ថុដែលបាន

[45] មាត្រា៦ នៃច្បាប់ស្តីពីប្របត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

រៀបរាប់ខាងលើនេះទេ ពោលគឺឲ្យតែចលនវត្ថុដែលជាវត្ថុរូបិយសុទ្ធតែអាចជាក្លាយជាកម្មវត្ថុនៃការបញ្ចាំឲ្យតែទ្រព្យនោះអាចផ្លាស់ប្តូរទីតាំងបាន។ ដូចនេះអ្នកបង្កើតប្រតិបត្តិការដើម្បីធានាសិទ្ធិលើបំណុលមិនចាំបាច់ព្រួយបារម្ភនោះទេ ទោះជានៅក្រោមប្រតិបត្តិការដែលមានកិច្ចធានាក្តី តាមការបញ្ចាំក្តី សុទ្ធតែអាចប្រើចលនវត្ថុបានច្រើនប្រភេទ លើកលែងតែចលនវត្ថុមួយចំនួនដូចជា ឯកសារកម្មសិទ្ធិ ឬប័ណ្ណកម្មសិទ្ធិចលនវត្ថុរូបិយប័ណ្ណជាអាទិ៍ (ឧបករណ៍ដែលអាចជួញដូរបាន) អាចដាក់ធ្វើជាប្រតិបត្តិការដែលមានកិច្ចធានាបាន តែវាមិនត្រូវបានអនុញ្ញាតក្នុងរបបគតិយុត្តនៃការបញ្ចាំនោះទេ។ នេះក៏ព្រោះថា ការបញ្ចាំតម្រូវនូវការកាន់កាប់ទ្រព្យធានា មិនមែនជាការកាន់កាប់លិខិតបញ្ជាក់កម្មសិទ្ធិដូចរាប់រាប់នេះទេ ព្រោះបង្ការការបាត់បង់ប្រយោជន៍របស់ម្ចាស់បំណុលបើសិនកូនបំណុលចាត់ចែងកម្មវត្ថុធានាបាត់ទៅ។ ប៉ុន្តែប្រសិនបើម្ចាស់បំណុលយល់ព្រមទទួលលិខិតបញ្ជាក់កម្មសិទ្ធិលើចលនវត្ថុ ម្ចាស់បំណុលនេះគ្រាន់តែជាម្ចាស់បំណុលធម្មតាប៉ុណ្ណោះ ដោយមិនទទួលបាននូវលក្ខខណ្ឌតតាំងដូចម្ចាស់បំណុលអាទិភាពនោះទេ នេះជាភាពខុសគ្នានៃសិទ្ធិលើបំណុលធម្មតា និងសិទ្ធិប្រាតិភោគប្រត្យក្ស។ (*សូមមើលឧបសម្ព័ន្ធទី ៧*)

### ខ. ទ្រព្យអរូបិយ

ក្រៅពីការបង្កើតប្រាតិភោគលើចលនវត្ថុជាទ្រព្យរូបិយ ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាក៏បានអនុញ្ញាតនូវការបង្កើតប្រាតិភោគលើទ្រព្យអរូបិយផងដែរមានដូចជា សិទ្ធិរុករករ៉ែ មូលប្បទានបត្រ ភាគហ៊ុនជាអាទិ៍។ បើសិនជាកូនបំណុលអាចបង្ហាញលិខិតស្នាមដែលអាចបញ្ជាក់សិទ្ធិរបស់ខ្លួនបាន គាត់អាចបង្កើតសិទ្ធិប្រាតិភោគដោយការតម្កល់លិខិតជូនដំណឹង។ មធ្យោបាយប្រសើរបំផុតដែលម្ចាស់បំណុលអាចធានាស្ថានភាពជាម្ចាស់បំណុលដែលមានកិច្ចធានា គឺត្រូវសុំយកឯកសារដែលជាភស្តុតាងនៃកម្មសិទ្ធិ ដូចជាវិក័យបត្រ ឬ ទម្រង់ដទៃទៀតនៃលិខិតជូនដំណឹងជាផ្លូវការ ដែលបញ្ជាក់ថាកូនបំណុលមានសិទ្ធិអំណាចផ្ទេរទ្រព្យសម្បត្តិនោះមានតាមផ្លូវច្បាប់ជាទ្រព្យធានាមកទុកនៅម្ចាស់បំណុលនៃកិច្ចធានា។

ចំណែករបបគតិយុត្តលើការបញ្ចាំវិញ ក៏ផ្តល់ផ្លូវសម្រាប់ការបង្កើតសិទ្ធិលើការបញ្ចាំទៅលើវត្ថុអរូបិយផងដែរដោយសង្កេតឃើញតែការបញ្ចាំសិទ្ធិមួយប៉ុណ្ណោះ ដែលសិទ្ធិនៅទីនេះគ្មានអ្វីក្រៅពីសិទ្ធិលើបំណុលនោះទេ។ សិទ្ធិលើបំណុលគ្មានរូបរាងទេ តែម្ចាស់សិទ្ធិលើការបញ្ចាំអាចយកសិទ្ធិដែលខ្លួនមានទៅលើអ្នកបង្កើតសិទ្ធិលើការបញ្ចាំទៅបញ្ចាំឲ្យទៅភាគីទី៣បាន។ នេះហើយជារូបភាពនៃការដាក់ទ្រព្យអរូបិយបាន ទោះអ្នកអនុវត្តចង់ប្រើប្រាស់របបគតិយុត្តមួយណាដើម្បីគ្រប់គ្រងក៏ដោយ។ ក្រៅពីនេះយោងតាមក្រមរដ្ឋប្បវេណីបានកំណត់និយមន័យ "ចលនវត្ថុអរូបិយ" ថាជា

ទ្រព្យសម្បត្តិដែលគ្មានរូបរាងដែលអាចគ្រប់គ្រងបានដូចជា អគ្គិសនី និងថាមពល ដែលតាមក្រមរដ្ឋប្បវេណីជាគោលការណ៍ ត្រូវយកមកប្រើប្រាស់ និងចាត់ចែងដូចចលនវត្ថុដែរ និងអាចបង្កើតសិទ្ធិប្រត្យក្សបានដូចគ្នា។[46] នាំឲ្យបកស្រាយបានថាទ្រព្យអរូបិយក៏ជាកម្មវត្ថុនៃការដាក់បញ្ចាំតាមរបបគតិយុត្តនៃការដាក់បញ្ចាំដូចគ្នា។

*(សូមមើលឧបសម្ព័ន្ធទី ៧ ប្រកាសលេខ ០២៨)*

### ២.១.១.២. លក្ខខណ្ឌសុពលភាពនៃការបង្កើតសិទ្ធិប្រាតិភោគដែលត្រឹមត្រូវ

ធាតុសំខាន់នៃប្រតិបត្តិការដែលមានកិច្ចធានា គឺកិច្ចព្រមព្រៀងប្រាតិភោគរវាងម្ចាស់បំណុល និងកូនបំណុលដែលត្រូវបានគ្របដណ្តប់ដោយច្បាប់កិច្ចសន្យាកម្ពុជា ដែលក្នុងរយៈពេលនោះគឺក្រឹត្យច្បាប់លេខ៣៨ ក្រ.ច ស្តីអំពី "កិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា" ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៨៨។ ប៉ុន្តែដោយសាតែក្រឹត្យច្បាប់លេខ៣៨ ត្រូវបាននិរាករណ៍ដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ដូចនេះច្បាប់កិច្ចសន្យាដែលគ្រប់គ្រងលើកិច្ចព្រមព្រៀងប្រាតិភោគគឺក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ដែលប្រកាសដោយព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១។[47] ត្រង់នេះបញ្ជាក់ថា លក្ខខណ្ឌសុពលភាពដែលប្រើប្រាស់ដោយកិច្ចសន្យាបញ្ចាំចលនវត្ថុ មិនខុសគ្នាពីលក្ខខណ្ឌសុពលភាពដែលនឹងត្រូវអនុវត្តចំពោះកិច្ចព្រមព្រៀងប្រាតិភោគដែលស្ថិតនៅក្រោមច្បាប់ប្រតិបត្តិការដែលមានកិច្ចធានានោះទេ។ លក្ខខណ្ឌទាំងនោះមានដូចជា៖

#### ក. ការព្រមព្រៀង

ការព្រៀងព្រៀងដែលកើតចេញពីឆន្ទៈ ជាលក្ខខណ្ឌដែលចាំបាច់ក្នុងការបង្កើតកិច្ចសន្យា។ បើសិនជាបុគ្គលបង្កើតកិច្ចសន្យាដោយមិនកើតពីឆន្ទៈខ្លួនទេ ផ្ទុយទៅវិញមានការបង្ខិតបង្ខំពីតតិយជនដើម្បីបង្កើតកិច្ចសន្យា នោះច្បាប់មិនទទួលស្គាល់អានុភាពបែបនេះទេ ប៉ុន្តែលុះត្រាតែមានការទាមទារពីភាគីនៃកិច្ចសន្យា ដើម្បីលុបចោលកិច្ចសន្យាដែលកើតចេញមកពីកម្លាំងជំរុញក្រៅខ្លួនរបស់ភាគីនោះ ហើយមានតែភាគីទេដែលអាចទាមទារលុបចោល។ ជាការពិត អាចមានករណីដែលការបង្កើតសិទ្ធិលើបំណុល ឬ ដោយមានវិការៈក្នុងការបង្ហាញឆន្ទៈ ដែលបង្កើតជាមោឃភាព ឬ ត្រូវបានលុបចោល នោះសិទ្ធិប្រាតិភោគប្រត្យក្សក៏មិនត្រូវមានអានុភាពឡើយ។[48]

---

[46] មាត្រា១២០(៤) នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[47] មាត្រា១ នៃច្បាប់ស្តីពីប្របត្តិការដែលមានកិច្ចធានា ឆ្នាំ២០០៦

[48] មាត្រា៧៦៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

ឧទាហរណ៍៖ លោក លីហួរ បានបង្ខំលោក តារា ដែលជាម្ចាស់លក់គុ-ទូ ទៅចុះកិច្ចសន្យាខ្ចីប្រាក់ពីអ្នកស្រី ពៅដោយសន្យាដាក់ទំនិញទាំងអស់ដែលមាននៅក្នុងហាងលក់គ្រឿងសង្ហារិមរបស់លោកតារា។ ករណីនេះ បើក្រោយមកលោកតារាអាចបង្ហាញឆន្ទៈដោយប្ដឹងសុំលុបចោលកិច្ចសន្យានេះបាន ដោយសារតែពេលចុះកិច្ចសន្យាជាមួយអ្នកស្រីពៅ ខ្លួនធ្វើដោយសារតែលោកលីហួរគម្រាមសម្លាប់កូនរបស់គាត់។

និយាយជារួម ការបង្ហាញឆន្ទៈដែលមានវិការៈដូចជាការឆបោក ការគម្រាម ការកេងចំណេញហួសហេតុជាអាទិ៍ សុទ្ធតែអាចក្លាយជាមូលហេតុក្នុងការលុបចោលកិច្ចសន្យា មិនថាកិច្ចព្រមព្រៀងប្រាតិភោគបង្កើតតាមច្បាប់ស្ដីពីប្រតិបត្តិការដែលមានកិច្ចធានា[49] ឬ ក្រមរដ្ឋប្បវេណីនោះទេ។

### ខ. សមត្ថភាពភាគី

តាមក្រមរដ្ឋប្បវេណី សមត្ថភាពជាលក្ខខណ្ឌមួយដើម្បីបង្កើតកិច្ចសន្យាមួយឲ្យមានសុពលភាព និងអានុភាព ទៅបំពេញលក្ខខណ្ឌគ្រឹះគឺ សមត្ថភាពរបស់គូភាគីនៃកិច្ចសន្យា។ សមត្ថភាពដែលចាំបាច់ដើម្បីឲ្យគូភាគីនៃកិច្ចសន្យាត្រូវតែគោរពតាមរួមមាន សមត្ថភាពក្នុងការបង្ហាញឆន្ទៈ និងសមត្ថភាពក្នុងការធ្វើសកម្មភាព។ មានន័យថាក្នុងការធ្វើកិច្ចសន្យាគូភាគីត្រូវតែបង្ហាញឆន្ទៈក្នុងស្ថានភាពដែលខ្លួនអាចយល់ដឹងអំពីខ្លឹមសារនៃកិច្ចសន្យាដែលខ្លួននឹងត្រូវអនុវត្ត និងត្រូវមានសមត្ថភាពគ្រប់គ្រាន់តាមផ្លូវច្បាប់។ ក្នុងន័យនេះមានន័យថាភាគីមិនមែនជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ ឬ ជននៅក្រោមហិតូបត្ថម្ភកៈនោះឡើយ។

កាលណាគូភាគីបានគោរពនូវលក្ខខណ្ឌសមត្ថភាពនេះ នោះកិច្ចសន្យាដែលបានធ្វើឡើងនឹងមានសុពលភាព។ ប៉ុន្តែប្រសិនបើលក្ខខណ្ឌសមត្ថភាពមិនត្រូវបានគោរពទេ វានឹងផ្ដល់នូវវិបាកដែលនាំឲ្យកិច្ចសន្យានោះត្រូវបានលុបចោល ដោយអ្នកមានសិទ្ធិលុបចោល។ លើកលែងតែករណីអនីតិជនទទួលបានអត្តាធីនភាពដែលត្រូវបានប្រកាសពីតុលាការ ហើយទោះបីជាជននោះមានអាយុត្រឹម១៦ឆ្នាំក៏ដោយ តែសកម្មភាពរបស់គាត់ត្រូវបានច្បាប់ចាត់ទុកថាមានអានុភាពដូចនីតិជនដែលមានសមត្ថភាពពេញលេញ។ ទោះជាយ៉ាងនេះក្ដី នៅតែមានការការពារភាគីម្ខាងទៀតនៃជនដែលត្រូវបានកម្រិតសមត្ថភាពនៅក្នុងសកម្មភាពអាជីវកម្មប្រចាំថ្ងៃ ដោយអនុញ្ញាតឲ្យសកម្មភាពដែលបង្កើតដោយអសមត្ថជននៅតែមានសុពលភាព រហូតដល់បើអ្នកមានសិទ្ធិលុបចោលបង្ហាញឆន្ទៈលុបចោល មិនដូច្នោះទេ សកម្មភាពនោះនឹងត្រូវបានសន្មតថានៅតែមានសុពលភាព

[49] មាត្រា ២ នៃច្បាប់ស្ដីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

ដដែល។[50] ជាមួយគ្នានេះដែរ ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ក៏បានចង្អុលបង្ហាញនូវសមត្ថកិច្ចរបស់ក្រមរដ្ឋប្បវេណីចូលអន្តរាគមន៍លើកិច្ចសន្យាប្រាតិភោគ[51] មានន័យថាលក្ខខណ្ឌសមត្ថភាពនៃការបង្កើតកិច្ចសន្យាបញ្ចាំត្រូវយកមកអនុវត្តដូចគ្នា ទៅលើការបង្កើតកិច្ចព្រមព្រៀងប្រាតិភោគក្នុងប្រតិបត្តិការដែលមានកិច្ចធានាផងដែរ ទើបបង្កើតឲ្យកិច្ចនោះមានសុពលភាពសម្រាប់ការអនុវត្ត។

### គ. កម្មវត្ថុ

ការបង្កើតកិច្ចព្រមព្រៀងប្រាតិភោគនៅក្រោមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាក្តី ឬក្រមរដ្ឋប្បវេណីក្តី ត្រូវគោរពទៅតាមមាត្រា៣៥៤ ចំពោះចលនវត្ថុដែលជាកម្មនៃការដាក់ធានាដែលតម្រូវឲ្យជាកម្មវត្ថុស្របច្បាប់[52] មិនដូច្នេះទេកិច្ចសន្យានេះមិនអាចអនុវត្តបានឡើយ ថែមទាំងត្រូវចាត់ទុកជាមោឃៈទៀតផង។ ឧទាហរណ៍៖ នៅក្រោមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាកញ្ញានីដា បានបង្កើតកិច្ចព្រមព្រៀងប្រាតិភោគដោយដាក់គ្រឿងញៀនដែលនាងមាន ដើម្បីធានាសិទ្ធិលើបំណុលរបស់ខ្លួន ដើម្បីយកប្រាក់ទៅទិញគ្រឿងញៀនបន្ថែមទៀត និងលក់ទៅឲ្យអ្នកប្រើប្រាស់បានទាន់ពេលវេលា។ ករណីនេះកិច្ចព្រមព្រៀងប្រាតិភោគ ត្រូវបានមោឃៈ ដោយសារគ្រឿងញៀនគឺជាកម្មវត្ថុខុសច្បាប់ និងមិនទទួលស្គាល់ដោយច្បាប់កម្ពុជានោះទេ។

(*សូមមើលមើលគម្រូកិច្ចព្រមព្រៀងប្រាក់កម្ចី និងដាក់បញ្ចាំក្នុង ឧបសម្ព័ន្ធទី ២*)

## ២.១.១.៣. ការអនុញ្ញាតឲ្យមានតតិយជនធានាដោយវត្ថុ

### ក. អ្នកធានានៅក្នុងរបបគតិយុត្តនៃការបញ្ចាំ

ការធានាដោយវត្ថុត្រូវបានគេយកមកប្រើប្រាស់ក្នុងរបបគតិយុត្តនៃការបញ្ចាំ ដើម្បីធានាសិទ្ធិលើបំណុលរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ ទោះបីជាកូនបំណុលមិនមានសិទ្ធិលើចលនវត្ថុណាមួយដែលអាចដាក់បញ្ចាំបានក្តី ក៏ក្រមរដ្ឋប្បវេណីអនុញ្ញាតឲ្យតតិយជនជាអ្នកធានា យកចលនវត្ថុរបស់ខ្លួនទៅធានាសិទ្ធិលើបំណុលរបស់កូនបំណុលបានដែរ។[53] អ្វីដែលគួរឲ្យកត់សម្គាល់ គឺក្នុងរបបគតិយុត្តនៃការបញ្ចាំ មិនមានបញ្ញត្តិណាតម្រូវឲ្យកូនបំណុលមានសិទ្ធិលើចលនវត្ថុដែលជា

---

[50] មាត្រា៣៥៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[51] មាត្រា ២(៣) នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

[52] កម្មវត្ថុមិនស្របច្បាប់ សំដៅដល់អត្ថន័យនៃកិច្ចសន្យា ដែមានភាពផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ ឬ ភាពខុសច្បាប់ និងទំនៀមទម្លាប់ល្អ។

[53] មាត្រា ៨២៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

កម្មវត្ថុនៃការបញ្ចាំនោះទេ។ ហេតុដូច្នេះហើយ ទើបអ្នកបង្កើតសិទ្ធិលើការបញ្ចាំអាចប្រើប្រាស់របប គតិយុត្តអ្នកធានាដោយវត្ថុបាន តាមរយៈតតិយជនធានាដោយវត្ថុតាមការព្រមព្រៀង។

**ខ. អ្នកធានានៅក្នុងរបបគតិយុត្តនៃប្រតិបត្តិការដែលមានកិច្ចធានា**

ចំណែកអ្នកធានា នៅក្នុងរបបគតិយុត្តនៃប្រតិបត្តិការដែលមានកិច្ចធានាតាមច្បាប់ស្តីពី ប្រតិបត្តិការដែលមានកិច្ចធានាក៏ដូចគ្នា គឺអនុញ្ញាតឲ្យមានការធានាដោយវត្ថុដែរ ទោះបីជាច្បាប់ស្តី ពីប្រតិបត្តិការដែលមានកិច្ចធានា មិនបានចែងច្បាស់ដូចរបបគតិយុត្តនៃសិទ្ធិលើការបញ្ចាំថា អនុញ្ញាតឲ្យមានអ្នកធានាដោយវត្ថុក៏ដោយ ក៏ប៉ុន្តែបើសង្កេតទៅលើមាត្រា៩ នៃច្បាប់ស្តីពីប្រតិបត្តិការ ដែលមានកិច្ចធានានៅត្រង់កថាខណ្ឌទី១ បានសរសេរថា "សិទ្ធិប្រាតិភោគដែលភ្ជាប់ទៅនឹងទ្រព្យ ធានា អាចបង្ខំឲ្យកូនបំណុល និងភាគីទីបីប្រតិបត្តិតាមបានចំពោះទ្រព្យធានានោះ"។ ត្រង់នេះ ហើយដែលអាចបកស្រាយបានថា ការបង្កើតសិទ្ធិប្រាតិភោគដោយយកទ្រព្យរបស់អ្នកធានាទៅ តម្កល់លិខិតជូនដំណឹងត្រូវបានអនុញ្ញាត ដែលអ្នកធានានៅក្នុងច្បាប់ស្តីពីប្រតិបត្តិការដែលមាន កិច្ចធានា គឺប្រើពាក្យភាគីទីបីនេះឯង។ ចំណែកការអនុវត្តជាក់ស្តែង ក៏ពិតជាមានអ្នកធានាដោយវត្ថុ ផងដែរ បើតាមការសាកសួរមន្ត្រីជំនាញនៅក្នុងការិយាល័យតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការ ដែលមានកិច្ចធានា ដោយស្ថានភាពគេប្រើជាទូទៅក្នុងប្រតិបត្តិការអាជីវកម្មធំៗ។

**២.១.១.៤. វត្តមាននូវលក្ខខណ្ឌអានុភាព និងលក្ខខណ្ឌតតាំងដូចគ្នា**

**ក.លក្ខខណ្ឌអានុភាព**

មាត្រា១៣៣ នៃក្រមរដ្ឋប្បវេណីបញ្ញត្តពី ការបង្កើត ការផ្ទេរ និងការកែប្រែសិទ្ធិប្រត្យក្សដែល មានអនុភាព មិនតម្រូវលក្ខខណ្ឌច្រើននោះទេ ឲ្យតែភាគីធ្វើការព្រមព្រៀងគ្នានោះនឹងបង្កើតនូវ អានុភាព។ ការព្រមព្រៀងនៅទីនេះ គឺសំដៅលើសំណើរ និងស្វីការត្រូវគ្នា ស្របគ្នាទៅលើខ្លឹមសារ នៃកិច្ចសន្យា។ ដូចនេះលក្ខខណ្ឌអានុភាព គឺជាលក្ខខណ្ឌដែលដែលត្រូវបំពេញដើម្បីឲ្យការបង្កើត ការផ្ទេរ និងការកែប្រែនូវសិទ្ធិប្រត្យក្ស មានអានុភាពតាមផ្លូវច្បាប់ដែលជាលក្ខខណ្ឌមិនអាចខ្វះបាន។

ចំពោះការបង្កើតសិទ្ធិលើការបញ្ចាំ ឬការបង្កើតប្រតិបត្តិការដែលមានកិច្ចធានា គឺជា សកម្មភាពនៃការបង្កើតសិទ្ធិប្រត្យក្សដែលស្ថិតនៅក្នុងប្រភេទសិទ្ធិប្រាតិភោគប្រត្យក្ស ដូចនេះបើ គ្មានវត្តមាននូវការព្រមព្រៀងរបស់ភាគីទេ នោះនឹងការបង្កើតប្រតិបត្តិការគ្មានអានុភាព និងមិន អាចយកទៅអនុវត្តបាននោះទេ។ លក្ខខណ្ឌសាមញ្ញបំផុតក្នុងការបង្កើតនូវអានុភាពនៃសិទ្ធិប្រាតិភោគ គឺការព្រមព្រៀងរបស់ភាគីជាចម្បង។ ចំណែកចំពោះរបបគតិយុត្តនៃការបញ្ចាំវិញ បានកំណត់

បន្ថែមថាសិទ្ធិលើការបញ្ចាំមិនមាននូវអានុភាពទេ បើគោរពលក្ខខណ្ឌនៃការប្រគល់វត្ថុទៅម្ចាស់សិទ្ធិនៃការបញ្ចាំ ហើយការផ្ទេរសិទ្ធិនេះទៀតសោត មិនចាំបាច់ចុះកិច្ចព្រមព្រៀងផ្ទេរសិទ្ធិកាន់កាប់នោះទេ ដោយសារតែការប្រើប្រាស់បញ្ញត្តិសន្មតពាក់ព័ន្ធនឹងចលនវត្ថុថា ចលនវត្ថុនៅដៃអ្នកណាអ្នកនោះជាម្ចាស់កម្មសិទ្ធិ[54] ដូចនេះត្រឹមតែការព្រមព្រៀងគឺគ្រប់គ្រាន់។ ជាកំណត់ចំណាំ បើគ្មានវត្ថុមានការផ្ទេរការកាន់កាប់ទេ ការបង្កើតសិទ្ធិលើការបញ្ចាំមិនមានអានុភាពទេ ដោយបន្ថែមពីលើលក្ខខណ្ឌនៃការព្រមព្រៀងតែមួយមុខ ប៉ុន្តែលក្ខខណ្ឌនៃការព្រមព្រៀងគឺលក្ខខណ្ឌរួមនៃការបង្កើតសិទ្ធិលើការបញ្ចាំ និងការបង្កើតប្រតិបត្តិការដែលមានកិច្ចធានា។

### ខ.លក្ខខណ្ឌតតាំង

ចំពោះលក្ខខណ្ឌតតាំងវិញ គឺជាលក្ខខណ្ឌសម្រាប់ធ្វើការអះអាងអំពីអានុភាពចំពោះតតិយជន ឬ អាចនិយាយម្យ៉ាងទៀតគឺលក្ខខណ្ឌដែលធ្វើឲ្យការបង្កើត ការផ្ទេរ និងការកែប្រែនូវសិទ្ធិប្រត្យក្សឲ្យមានអានុភាពចំពោះតតិយជន។ ការបង្កើត ការផ្ទេរ និងការកែប្រែសិទ្ធិប្រត្យក្សទៅលើអចលនវត្ថុគេតម្រូវឲ្យមានការចុះបញ្ជី ចំណែកលក្ខខណ្ឌតតាំងនៃសិទ្ធិប្រត្យក្សលើចលនវត្ថុ គឺតម្រូវឲ្យមានការផ្ទេរការកាន់កាប់។ លក្ខខណ្ឌនៃការផ្ទេរការកាន់កាប់នេះ ជាលក្ខខណ្ឌរួមមួយរវាងប្រតិបត្តិការដែលមានកិច្ចធានា និងសិទ្ធិលើការបញ្ចាំដូចគ្នា សម្រាប់យកទៅប្រឆាំងទៅនឹងតតិយជនគ្រប់រូបដូចគ្នា ព្រោះនៅពេលម្ចាស់បំណុល និងកូនបំណុលព្រមព្រៀងបង្កើតប្រាតិភោគប្រត្យក្សលើចលនវត្ថុ ចាំបាច់ត្រូវផ្ទេរការកាន់កាប់ទ្រព្យធានាទៀតទើបមានអានុភាពតតាំងនឹងតតិយជន។

ចំណែកឯការធ្វើសុក្រឹតកម្មលើសិទ្ធិប្រាតិភោគ នៅក្នុងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ម្ចាស់បំណុលអាចជ្រើសរើសការធ្វើសុក្រឹតកម្ម តាមរយៈការទទួលកាន់កាប់ទ្រព្យធានារបស់កូនបំណុលដោយការព្រមព្រៀងគ្នា។ ការប្រើសិទ្ធិតតាំងចំពោះតតិយជនក្នុងករណីការកាន់កាប់នេះ គឺជាលក្ខខណ្ឌមួយក្នុងចំណោមការធ្វើសុក្រឹតកម្មផ្សេងទៀត។ ម្ចាស់បំណុលនៃកិច្ចធានាជាទូទៅមិនកាន់កាប់ទ្រព្យធានាទេ តែបើកូនបំណុលដែលមានកិច្ចធានាប្រគល់ទ្រព្យធានាឲ្យទៅម្ចាស់បំណុល គឺអាចចាត់ទុកថាជាការធ្វើសុក្រឹតកម្មដោយស្របច្បាប់ទោះជាមិនតម្កល់លិខិតជូនដំណឹងក៏ដោយ[55] តែត្រូវចាំថាការកាន់កាប់មិនមានអានុភាពពេញលេញដូចការធ្វើសុក្រឹតកម្មតាមរយៈការតម្កល់លិខិតជូនដំណឹងនោះទេ។ ករណីនេះអាចមានភាពប្រទាំងប្រទឹស ដោយសារតែការផ្ទេរការកាន់តាមប្រតិបត្តិការដែលមានកិច្ចធានា ស្រដៀងនឹងលក្ខខណ្ឌតាមក្រមរដ្ឋប្បវេណី។

---

[54] មាត្រា២៥៩(៤) នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[55] មាត្រា ៤៨ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

ចំណែករបបគតិយុត្តនៃការបញ្ចាំក៏ជាប្រភេទមួយក្នុងចំណោមសិទ្ធិប្រត្យក្សផងដែរ ដូចនេះ លក្ខខណ្ឌនៃការផ្ទេរការកាន់កាប់ក៏ត្រូវយកមកអនុវត្តដូចគ្នា ពោលលក្ខខណ្ឌអានុភាពរបស់ការបញ្ចាំ គឺការប្រគល់វត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំទៅម្ចាស់សិទ្ធិលើការបញ្ចាំ។ បន្ថែមលើនេះ របបគតិយុត្តនៃការបញ្ចាំបញ្ញត្តបន្ថែមទៀតថា បើមិនមានការកាន់កាប់ជានិរន្តន៍ដោយម្ចាស់សិទ្ធិលើការបញ្ចាំទេលើវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំទេ នោះការបង្កើតសិទ្ធិលើការបញ្ចាំគ្មានអានុភាពតតាំងទៅនឹងតតិយជននោះទេ[56] ព្រោះច្បាប់មិនអនុញ្ញាតឲ្យអ្នកបង្កើតសិទ្ធិលើការបញ្ចាំកាន់កាប់ដោយផ្ទាល់លើវត្ថុបញ្ចាំឡើយ។[57] មិនចាំបាច់មានន័យថា ទាល់តែមានម្ចាស់បំណុលជាអ្នកកាន់កាប់ទ្រព្យធានាកាតព្វកិច្ចដោយផ្ទាល់នោះទេ ព្រោះថាការកាន់កាប់ក៏អាចធ្វើតាមរយៈអ្នកតំណាងរបស់ម្ចាស់សិទ្ធិលើការបញ្ចាំបានដែរ គឺការកាន់កាប់ដោយប្រយោល ក៏បំពេញលក្ខណ្ឌការកាន់កាប់ផងដែរ។ ឧទាហរណ៍៖ កូនបំណុលA បង្កើតសិទ្ធិលើការបញ្ចាំលើឡានរបស់ខ្លួនជាមួយម្ចាស់បំណុលB ហើយម្ចាស់បំណុល B បានឲ្យតតិយជាអ្នកតំណាងរបស់គាត់ទុកព្រោះដោយសារតែខ្លួនគ្មានទីកន្លែងគ្រប់គ្រាន់សម្រាប់រក្សាទុកវត្ថុបញ្ចាំដែលជា ឡានធុនធំមួយគ្រឿងនេះ។

### ២.១.១.៥. អានុភាពនៃសិទ្ធិប្រាតិភោគ

#### ក. អានុភាពនៃការឃាត់ទុកទៅលើទ្រព្យធានា

បន្ទាប់ពីការមិនសងបំណុល ម្ចាស់បំណុលដែលមានកិច្ចធានា មានសិទ្ធិក្នុងការរក្សាទុកទ្រព្យធានាដើម្បីសងបំណុល ដូចជាការស្នើឃាត់ទុកនូវកម្មវត្ថុដែលជាទ្រព្យធានាជាដើម ដើម្បីធ្វើការទូទាត់។[58] បើសិនជាមិនមានការផ្តល់សិទ្ធិនេះទេ នោះម្ចាស់បំណុលនឹងមានភាពពិបាកក្នុងការអនុវត្តសិទ្ធិប្រាតិភោគរបស់ខ្លួនឲ្យកាន់តែមានប្រសិទ្ធិភាព។ ការឃាត់ទុកនេះ ម្ចាស់បំណុលដែលមានកិច្ចធានាត្រូវធ្វើការស្នើសុំការឃាត់ទុកនេះ ទៅកាន់កូនបំណុល ឬម្ចាស់បំណុលដទៃទៀត។ កូនបំណុល និងម្ចាស់បំណុលដែលមានកិច្ចធានាដទៃទៀតនេះ មានសិទ្ធិជំទាស់ក្នុងកំឡុងពេល ២០ថ្ងៃ ចាប់ពីពេលទទួលបានលិខិតជូនដំណឹង។ ចំណែកសិទ្ធិលើការបញ្ចាំ អានុភាពនៃការឃាត់ទុកក៏អាចយកមកអនុវត្តបានដែរ ដោយម្ចាស់បំណុលក៏មានសិទ្ធិក្នុងការឃាត់ទុកវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ រហូតដល់ខ្លួនបានទទួលការសងដើម្បីធ្វើការអនុវត្តសិទ្ធិរបស់ខ្លួនដែលមានលើវត្ថុនេះ។ ដោយហេតុថា ប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំមានតែសិទ្ធិកាន់កាប់តែគ្មានសិទ្ធិឃាត់ទុក នោះជា

[56] មាត្រា៨១៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[57] មាត្រា៨១៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[58] មាត្រា ៥១ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

លទ្ធផលនាំឲ្យការបង្កើតសិទ្ធិលើការបញ្ចាំដោយមានការប្រគល់វត្ថុនឹងក្លាយជាឥតន័យ ដូច្នេះម្ចាស់សិទ្ធិនឹងមិនទទួលបាននូវការសងដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀតនោះទេ។[59]

### ខ. អានុភាពទៅលើផលដែលកើតចេញមកពីទ្រព្យដែលដាក់ធានា

សិទ្ធិប្រាតិភោគភ្ជាប់ទៅនឹងទ្រព្យធានា វាក៏ត្រូវបានភ្ជាប់ដោយស្វ័យប្រវត្តិទៅនឹងផលនៃទ្រព្យធានាផងដែរ។ ទោះបីកិច្ចព្រមព្រៀងមិនបានបញ្ជាក់ថាសិទ្ធិប្រាតិភោគគ្របដណ្តប់លើផលក៏ដោយ ក៏វាមានអនុភាពលើផលដោយស្វ័យប្រវត្តិ ក៏ប៉ុន្តែគូភាគីអាចយល់ព្រមថាផលនៃទ្រព្យធានាមិនត្រូវបានគ្រប់ដណ្តប់ដោយសិទ្ធិប្រាតិភោគ។ នេះជាការអនុវត្តប្រាតិភោគចលនវត្ថុដែលបង្កើតតាមប្រតិបត្តិការដែលមានកិច្ចធានា។

ចំណែកសិទ្ធិលើការបញ្ចាំក៏មិនខុសគ្នាដែរ សិទ្ធិលើការបញ្ចាំក៏មានអានុភាពលើផលដែរ តែភាគីអាចព្រមព្រៀងគ្នាថា ទំហំនៃសិទ្ធិលើបំណុលគ្មានទៅលើផលនៃទ្រព្យធានា[60] ព្រោះជាទូទៅគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន តែងតែយកមកប្រើប្រាស់នៅក្នុងក្រមរដ្ឋប្បវេណី ព្រោះនីតិករមិនចង់រិតត្បិតសកម្មភាពនៃការបង្កើតសិទ្ធិលើការបញ្ចាំហួសហេតុពេកទេ មិនដូច្នេះទេច្បាប់នឹងត្រូវវិសោធនកម្មជាញឹកញាប់ ព្រមទាំងមិនសមស្របនឹងស្ថានភាពរបស់ប្រជាពលរដ្ឋ។ សិទ្ធិដែលទទួលបានផលកើតចេញពីវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ ត្រូវយកទៅទូទាត់ការប្រាក់នៃសិទ្ធិលើបំណុលជាមុន បន្ទាប់មកយកទៅទូទាត់នឹងប្រាក់ដើម ហើយបើនៅសល់ត្រូវប្រគល់ជូនអ្នកបង្កើតសិទ្ធិលើការបញ្ចាំ ឬ ម្ចាស់បំណុលដទៃទៀត។[61] ទោះជាយ៉ាងណាក៏ដោយ ការយកផលនៃវត្ថុដែលដាក់ធានាមកសងសិទ្ធិលើបំណុលតាមរបបគតិយុត្តនៃការបញ្ចាំ គឺជាបញ្ញត្តិតាមការព្រមព្រៀងតែប៉ុណ្ណោះ។ ប៉ុន្តែចូរចាំថាបើយកផលមកសង ម្ចាស់បំណុលត្រូវតែយកមកកាត់ការប្រាក់នៃសិទ្ធិលើបំណុលជាមុន សល់ប៉ុន្មានយកទៅកាត់ប្រាក់ដើម ដោយមិនអាចទទួលផលទទេៗបានទេ។

## ២.១.១.៦. ការអនុវត្តសិទ្ធិប្រាតិភោគ

### ក. ករណីសិទ្ធិលើបំណុលច្រើនលើចលនវត្ថុតែមួយ និងលំដាប់នៃសិទ្ធិ

ភាគីដែលមានបំណងបង្កើតសិទ្ធិប្រាតិភោគ គឺអាចធ្វើបានលើចលនវត្ថុតែមួយ ទោះបីជាភាគីជ្រើសរើសយក ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ឬក្រមរដ្ឋប្បវេណីក៏ដោយ។ ដោយហេតុ

59 មាត្រា ៨២១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

60 មាត្រា៨២០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

61 មាត្រា ៨២២នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ថាច្បាប់ទុកសិទ្ធិឲ្យមានការបង្កើតប្រាតិភោគបានច្រើនដងលើចលវត្ថុតែមួយ ដើម្បីប្រើឲ្យអស់លទ្ធភាពនៃតម្លៃក្នុងចលនវត្ថុនោះ ធ្វើយ៉ាងណាជៀសវាងមានការខាតបង់លើអ្នកបង្កើតសិទ្ធិប្រាតិភោគដែលជាភាគីទន់ខ្សោយជាងម្ចាស់សិទ្ធិប្រាតិភោគ។ ហេតុដូច្នេះហើយ ទើបចែងពីលំដាប់នៃសិទ្ធិក្នុងការអនុវត្តសិទ្ធិប្រាតិភោគរបស់ខ្លួន។ នៅក្នុងការបង្កើតសិទ្ធិប្រាតិភោគច្រើនលើចលនវត្ថុតែមួយ កិច្ចព្រមព្រៀងប្រាតិភោគនៅក្រោមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា អាចត្រូវបង្កើតឡើងបានច្រើនដងជាមួយម្ចាស់បំណុលតែមួយ ឬ ផ្សេងៗគ្នា[62] ដោយមើលទៅលើលំដាប់ពេលវេលានៃការតម្កល់លិខិតជូនដំណឹង គឺការតម្កល់មុនមានអាទិភាពជាង។[63]

ចំណែកឯការបញ្ចាំវិញ មតិទី១យល់ថា ករណីនៃការបញ្ចាំច្រើនដងទៅលើចលនវត្ថុតែមួយក៏អាចកើតឡើងផងដែរ ដោយសារថាវាអាចបង្កើតសិទ្ធិលើបំណុលច្រើន ដែលត្រូវចាំថាបានចំពោះម្ចាស់បំណុលតែម្នាក់ប៉ុណ្ណោះ បើបង្កើតសិទ្ធិលើបំណុលច្រើនចំពោះម្ចាស់បំណុលច្រើនផ្សេងគ្នាមិនអាចទៅរួចទេ ព្រោះយើងដឹងហើយថាសិទ្ធិលើការបញ្ចាំមានអនុភាពលុះត្រាតែផ្ទេរការកាន់កាប់ទៅម្ចាស់បំណុលទើបមានអនុភាព។ ការបង្កើតសិទ្ធិលើបំណុលច្រើន គឺកើតមានករណីដែលកូនបំណុលយកកម្មវត្ថុនៃការបញ្ចាំទៅបង្កើតសិទ្ធិលើបំណុលច្រើនដង ចំពោះម្ចាស់បំណុលតែម្នាក់ ព្រោះការដាក់បញ្ចាំលើកទីមួយ អ្នកបង្កើតសិទ្ធិយល់ថាអត់គ្រប់សម្រាប់ទឹកប្រាក់យកទៅប្រើប្រាស់ និងម្យ៉ាងទ្រព្យធានារបស់ខ្លួនហាក់ដូចជាមានតម្លៃសេដ្ឋកិច្ចច្រើន ដូច្នេះអ្នកបង្កើតអាចសុំខ្ចីថែម ដោយដាក់ប្រាតិភោគលើវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំដដែលនេះទៅម្ចាស់សិទ្ធិលើការបញ្ចាំដដែលម្តងទៀត។ សកម្មភាពបែបនេះ ក៏បំពេញលក្ខខណ្ឌសម្រាប់ការបង្កើតសិទ្ធិលើការបញ្ចាំផងដែរ ហើយលំដាប់នៃសិទ្ធិត្រូវ អនុលោមតាមពេលវេលាដូចគ្នា។[64] មានន័យថា បើសិនជាសិទ្ធិលើបំណុលមួយណាដល់កំណត់សងមុន គឺយកកម្មវត្ថុដែលដាក់ប្រាតិភោគទៅអនុវត្តមុន។

ឧទាហរណ៍៖ លោក សុធា ខ្ចីប្រាក់ពីលោក ម៉ូនីន លើកទីមួយចំនួន$២០០ ដោយដាក់ម៉ូតូ **ស្កូបពី** ជាទ្រព្យធានានៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៦ និងកំណត់បរិច្ឆេទសងនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧។ ក្រោយមក នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៦ លោកសុធា ដដែលបានបង្កើតសិទ្ធិលើការបញ្ចាំម្តងទៀតដោយខ្ចី$៥០០ តែកាលបរិច្ឆេទនៃការសង គឺនៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦។ ករណីនេះ លំដាប់នៃសិទ្ធិគឺគេមើលទៅលើកាលបរិច្ឆេទនៃការសង មួយណាដល់មុនយកទៅអនុវត្ត

[62] មាត្រា ៧ (៣) នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

[63] មាត្រា ១២ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

[64] មាត្រា ៨៣៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

មុន ហេតុដូចនេះលោក ម៉ូនីន អាចអនុវត្តសិទ្ធិលើការបញ្ចាំចំពោះកាលកំណត់សងទី២ ទៅលើទឹកប្រាក់ខ្ចីចំនួន $៥០០ មុនចំនួនទឹកប្រាក់ខ្ចីលើកទី១ ដោយសារតែកាលបរិច្ឆេទសងបានដល់មុន។

នៅតែមានភាពចម្រូងចម្រាសចំពោះការបកស្រាយ មាត្រា៨៣៣ (លំដាប់សិទ្ធិនៃការបញ្ចាំចលនវត្ថុ) ដោយមតិទីពីរ លើកឡើងថាការបង្កើតសិទ្ធិលើបំណុលច្រើនក្នុងរបបគតិយុត្តនៃការបញ្ចាំកើតមានឡើងនៅពេលដែល កូនបំណុលបង្កើតសិទ្ធិលើការបញ្ចាំពីរដង ទៅលើម្ចាស់បំណុលផ្សេងពីគ្នា ដោយធ្វើការព្រមព្រៀងថាអ្នកណាជាអ្នកកាន់កាប់ទ្រព្យធានារបស់កូនបំណុល។ ឧទាហរណ៍៖ **ក** បានដាក់វត្ថុបញ្ចាំឲ្យ **ខ** ហើយបន្ទាប់មកយកទៅបញ្ចាំឲ្យ **គ** ទៀត។ ករណីនេះ បើសិន **ក** បានជូនដំណឹងទៅ **ខ** ថាខ្លួនបានដាក់វត្ថុដែលខ្លួនយកទៅបញ្ចាំនៅនឹង **ខ** នោះទៅបញ្ចាំឲ្យ **គ** ម្នាក់ទៀត ហើយបើ **ខ** យល់ព្រម **គ** ក៏អាចក្លាយទៅជាម្ចាស់សិទ្ធិលើការបញ្ចាំលើវត្ថុនេះដែរ។ ប៉ុន្តែ **ខ** ក៏អាចយកសិទ្ធិរបស់ខ្លួនទៅតតាំងនឹង **គ** បានដែរដោយផ្អែកលើការព្រមព្រៀងរវាង **ក** និង **ខ្លួន** នាពេលដែរ **គ** ទាមទារការកាន់កាប់លើវត្ថុ។

### ខ. លំដាប់នៃការទូទាត់ផលដែលបានមកពីការជម្រះទ្រព្យធានា

ម្យ៉ាងទៀត ពាក់ព័ន្ធនឹងប្រតិបត្តិការដែលមានកិច្ចធានា ផលនៃការជម្រះទ្រព្យធានា[65] ត្រូវប្រើប្រាស់តាមលំដាប់ជាកំណត់ដូចជា៖

- ដំបូងត្រូវសងថ្លៃចំណាយផ្សេងៗដូចជា ការរៀបចំជម្រះទ្រព្យធានា ចំណាយសម្រាប់មេធាវី ថ្លៃចំណាយរឿងក្តីដែលម្ចាស់បំណុលបានចំណាយ
- បន្ទាប់មកយកទៅទូទាត់បំណុលដែលធានាដោយសិទ្ធិប្រាតិភោគ
- ទូទាត់ទៅលើបំណុលរបស់ម្ចាស់បំណុលដែលមានកិច្ចធានាដទៃទៀត បើមានការទាមទារជាលាយលក្ខណ៍អក្សរ មុនពេលម្ចាស់បំណុលអាទិភាពធ្វើការបែងចែកផលនៃទ្រព្យធានា តែត្រូវផ្តល់ភស្តុតាងពីផលប្រយោជន៍លើទ្រព្យធានា
- ទូទាត់បំណុលគ្មានទ្រព្យធានាដែលបានទទួលស្គាល់ (សិទ្ធិលើបំណុលធម្មតាបើកាលណាដល់កំណត់ត្រូវសងដែរ)
- ទឹកប្រាក់ដែលនៅសល់ត្រូវប្រគល់ឲ្យកូនបំណុល តែបើទឹកប្រាក់ខ្វះ ម្ចាស់បំណុលអាចទាមទារសំណងថែមនូវទឹកប្រាក់ដែលខ្វះនោះ។

[65] តម្លៃដែលបានមកពីការលក់ទ្រព្យធានា

ចំណែកឯការបញ្ចាំតាមក្រមរដ្ឋប្បវេណីក៏មិនខុសប្លែកប៉ុន្មានដែរ តែរបបគតិយុត្តនៃការបញ្ចាំ បានធ្វើការកំណត់ពីទំហំនៃសិទ្ធិលើបំណុលដែលត្រូវធានា តែមិនបានបញ្ជាក់ពាក្យលំដាប់ដែលត្រូវសងនៅពេលអនុវត្តសិទ្ធិលើការបញ្ចាំនោះទេ។ ទោះជាយ៉ាងណាយើងអាចបកស្រាយបញ្ញត្តិនៃមាត្រា៨២០ បានថាបន្ទាប់ពីម្ចាស់សិទ្ធិលើការបញ្ចាំទទួលបានផលពីការជម្រះទ្រព្យធានា ទឹកប្រាក់ដែលបាននោះត្រូវយកទៅសងប្រាក់ដើមជាមុន បន្ទាប់មកការប្រាក់ ប្រាក់ធានាសងក្នុងករណីមិនគោរពកិច្ចសន្យា សោហ៊ុយដើម្បីអនុវត្តសិទ្ធិលើការបញ្ចាំ ដូចជាការជួលមេធាវី និងនីតិវិធីតុលាការជាអាទិ៍ សោហ៊ុយដើម្បីថែរក្សាវត្ថុបញ្ចាំ ព្រមទាំងសំណងនៃការខូតខាតដែលកើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ច ឬ វិការៈកំបាំងនៃវត្ថុបញ្ចាំ។ ទោះជាយ៉ាងណាភាគីអាចព្រមព្រៀងគ្នាផ្សេងដោយចែងផ្ទុយពីបញ្ញត្តិនៃមាត្រា៨២០ ក្នុងសកម្មភាពនៃការបង្កើតសិទ្ធិលើការបញ្ចាំ។[66]

បន្ទាប់ពីសងចំណាយខាងលើ ចំនួនទឹកប្រាក់សល់ពីការលក់វត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំចលនវត្ថុ ម្ចាស់សិទ្ធិលើការបញ្ចាំត្រូវប្រគល់ទឹកប្រាក់ឲ្យកូនបំណុល ឬ ម្ចាស់បំណុលផ្សេងទៀត ហើយម្ចាស់បំណុលផ្សេងទៀតនោះត្រូវទទួលការសងសិទ្ធិលើការបញ្ចាំតាមសមាមាត្រនៃចំនួនទឹកប្រាក់ដែលមានលើកម្មវត្ថុនេះ។ តែបើករណីដែលកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំចលនវត្ថុនោះមិនគ្រប់គ្រាន់ដើម្បីសងសិទ្ធិលើបំណុលទេ កូនបំណុលត្រូវសងកាតព្វកិច្ចដែលនៅសល់តទៅទៀតទៅម្ចាស់សិទ្ធិលើការបញ្ចាំ។

### ២.១.១.៧. សិទ្ធិក្នុងការទិញទ្រព្យធានានាពេលជម្រះ និងអានុភាពនៃសិទ្ធិប្រាតិភោគលើអ្នកទិញទ្រព្យធានា

#### ក.សិទ្ធិក្នុងការទិញទ្រព្យធានានាពេលជម្រះ

បើកូនបំណុលមិនអនុវត្តកាតព្វកិច្ចទៅហើយ នោះម្ចាស់បំណុលមានសិទ្ធិក្នុងការទទួលយកនូវតម្លៃដែលបានមកពីការលក់ទ្រព្យធានា តាមរយៈការព្រមព្រៀងគ្នាដាក់ប្រាតិភោគតាំងពីកិច្ចសន្យាលើកដំបូងត្រូវបានបង្កើតរវាងម្ចាស់សិទ្ធិ និងអ្នកបង្កើតសិទ្ធិ។ ក្នុងការលក់ឡាយឡុងនូវទ្រព្យធានានេះ បើតាមតាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ម្ចាស់បំណុលមានសិទ្ធិក្នុងការទិញវត្ថុដែលដាក់ធានា[67] នៅពេលអនុវត្តសិទ្ធិរបស់ខ្លួន។ ចំណែកការបញ្ចាំវិញក៏មិនខុសគ្នា ព្រោះពុំមានបញ្ញត្តិណាស្ថិតក្នុងរបបគតិយុត្តនេះ ចែងនូវការហាមឃាត់ការទិញដោយម្ចាស់សិទ្ធិលើការបញ្ចាំនោះដែរទេ។ បើសង្កេតមើលលើមាត្រា៥២៤ និងមាត្រា៥២៥ នៃក្រមរដ្ឋប្បវេណីវិញ មិនបានធ្វើការ

[66] មាត្រា ៨២០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[67] មាត្រា ៤៩ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

ហាមឃាត់ម្ចាស់សិទ្ធិលើការបញ្ចាំ ក្នុងការទិញវត្ថុធានានៅពេលអនុវត្តដោយបង្ខំនោះទេ ដូចនេះ មិនមានភាពខុសប្លែកទេដែលថាម្ចាស់សិទ្ធិលើការបញ្ចាំ មានសិទ្ធិក្នុងការទិញវត្ថុធានា ព្រោះមិនមានការខាតបង់ប្រយោជន៍ណាទៅលើកូនបំណុលចំពោះការទិញកម្មវត្ថុនៃការបញ្ចាំនោះទេ។

គួរតែពិចារណាករណីមួយចំនួនតូច ប្រសិនបើអនុញ្ញាតឲ្យម្ចាស់សិទ្ធិទិញទ្រព្យធានាដែលលក់ឡាយឡុង ប្រហែលជាអាចប៉ះពាល់ផលប្រយោជន៍របស់កូនបំណុល ដោយហេតុថា ប្រសិនបើទ្រព្យធានាដែលកូនបំណុលយកទៅដាក់ធានាមានតម្លៃថ្លៃ តែម្ចាស់បំណុលផ្តល់នូវប្រាក់កម្ចីតិច និងកំណត់ថ្ងៃបរិច្ឆេទក្នុងការសងមានរយៈពេលខ្លី ព្រោះម្ចាស់បំណុលចង់បានទ្រព្យធានាដែលជាវត្ថុមានតម្លៃខ្ពស់នេះមកធ្វើជាកម្មសិទ្ធិ។ ដូចនេះការអនុញ្ញាតឲ្យម្ចាស់បំណុលទិញទ្រព្យធានាប្រហែលជាអាចនឹងឈានទៅរកការបង្កជាគំនិតទុច្ចរិតដល់ម្ចាស់បំណុល។ ទីមួយ គឺការវាយតម្លៃទ្រព្យធានាក្នុងតម្លៃទាបក្នុងការឲ្យខ្ចីប្រាក់ និងទីពីរ មិនអនុគ្រោះដល់កូនបំណុលទោះជាបីជារូបភាពនៃការមិនអនុវត្តកាតព្វកិច្ចទើបតែម្តងជាអាទិ៍។ នេះគ្រាន់តែគំនិតពិចារណាមួយផ្នែកតូចប៉ុណ្ណោះពាក់ព័ន្ធនឹងការអនុញ្ញាតឲ្យម្ចាស់បំណុលមានសិទ្ធិទិញទ្រព្យធានា។

## ខ.អានុភាពនៃសិទ្ធិប្រាតិភោគទៅលើអ្នកទិញទ្រព្យធានា

អ្នកទិញទ្រព្យធានានាពេលជម្រះ ជាស្ថានភាពខុសពីអ្នកទិញទ្រព្យធានាមុនកាលបរិច្ឆេទដែលកូនបំណុលត្រូវអនុវត្តកាតព្វកិច្ច ដោយច្បាប់មិនការពារអ្នកទិញទាំងនោះទេបើសិនជាមានគំនិតទុច្ចរិត និងមានកំហុសក្នុងការទិញទ្រព្យធានាដែលជាប់សិទ្ធិប្រាតិភោគ។ ជាធម្មតាបន្ទាប់ពីការអនុវត្តសិទ្ធិរបស់ម្ចាស់បំណុលដែលមានទ្រព្យធានា ទ្រព្យនោះនឹងទៅដល់ដៃជនទីពដែលបានទិញទ្រព្យធានានាពេលលក់ឡាយឡុង។ ដើម្បីសម្រួលដល់ការលក់ ច្បាប់បានធ្វើការការពារផលប្រយោជន៍អ្នកទិញជាពិសេសពាក់ព័ន្ធនឹងការជម្រះចោលនូវទ្រព្យធានា ព្រោះបើសិនជាមិនកំណត់ដូច្នេះ ប្រហែលជាគ្មានអ្នកណាហ៊ានទិញទ្រព្យធានានាពេលធ្វើការលក់នោះទេ ព្រោះខ្លាចមានអានុភាពតាមនៃសិទ្ធិលើបំណុល។ ដូចនេះទើបកំណត់ថា ការជម្រះចោលនូវទ្រព្យធានានាពេលកូនបំណុលមិនអនុវត្តកាតព្វកិច្ច គឺជាការផ្ទេរសិទ្ធិទាំងអស់ដល់អ្នកទិញ ដោយមិនមានជាប់សិទ្ធិប្រាតិភោគនោះទេ។ ចំណែកខាងមន្ត្រីការិយាល័យចុះបញ្ជីវិញត្រូវជួយសម្របសម្រួលក្នុងករណីនេះ ដោយការចេញប័ណ្ណសម្គាល់ម្ចាស់សិទ្ធិថ្មីចំពោះយានយន្តដែលមានលេខស៊េរីជាអាទិ៍។ បើសិនជាមិនទុកចិត្តពីអត្ថិភាពនៃការមិនសងបំណុលរបស់កូនបំណុល មន្ត្រីចុះបញ្ជីអាចធ្វើការស្នើសុំពីម្ចាស់បំណុល នូវសេចក្តីសម្រេចរបស់តុលាការដែលបង្គាប់ឲ្យម្ចាស់បំណុលកាន់កាប់ ឬអាចជាកិច្ចព្រមព្រៀងលាយលក្ខណ៍អក្សររបស់កូនបំណុលដែលព្រមប្រគល់ទ្រព្យធានា ឲ្យម្ចាស់បំណុល

កាន់កាប់ និងធ្វើការជម្រុះបន្ទាប់ពីខ្លួនមិនសងបំណុល។[68]

### ២.១.២. លក្ខណៈដោយឡែក

ក្រៅពីចំណុចរួមនៃរបបគតិយុត្តទាំងពីរ ជាមួយគ្នានោះក៏ឃើញមាននូវលក្ខណៈផ្សេងគ្នាមួយចំនួនឲ្យកត់សម្គាល់ នេះក៏ព្រោះរបបមួយហាក់ដូចជាប្រើនៅក្នុងបរិបទទំនាក់ទំនងរវាងបុគ្គល និងបុគ្គលធម្មតា និងមួយទៀតហាក់ដូចជាប្រើក្នុងទំនាក់ទំនងរវាងពាណិជ្ជករ និងពាណិជ្ជករ ហេតុដូច្នេះវាអាចឈានទៅរកការអនុវត្តខុសប្លែកគ្នាខ្លះៗ ទៅតាមគោលដៅ និងគោលគំនិតនៃការបង្កើតច្បាប់នីមួយៗ។

#### ២.១.២.១. បរិបទ និងគោលគំនិតខុសគ្នា

##### ក. ប្រាតិភោគចលនវត្ថុតាមសណ្ឋាននៃប្រតិបត្តិការដែលមានកិច្ចធានា

ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ដែលកំណត់ក្នុងច្បាប់ពិសេស ផ្តោតសំខាន់តែលើសកម្មភាពអាជីវកម្មធំៗតែប៉ុណ្ណោះ។ គំនិតនេះចង់លើកឡើងថាប្រតិបត្តិការដែលមានកិច្ចធានាបង្កើតឡើង គឺដើម្បីផ្តល់ហិរញ្ញប្បទានសម្រាប់ការប្រកបអាជីវកម្ម និងផ្តោតសំខាន់ទៅលើការលើកស្ទួយវិស័យពាណិជ្ជកម្ម ដែលរួមមានក្រុមហ៊ុន សហគ្រាសធំ តូច និងមធ្យមជ សុទ្ធតែអាចប្រើប្រាស់នូវប្រតិបត្តិការដែលមានកិច្ចធានា។ ការប្រើប្រាស់នូវប្រតិបត្តិការនេះផ្តល់នូវសារៈសំខាន់ច្រើនក្នុងការដំណើរការអាជីវកម្ម ជាពិសេសជៀងវាងបាននូវការរក្សាទុក ឬ បង្កក់ទុកនូវសារពើភណ្ឌ ឬ ឧបករណ៍ដែលជាដំណើរការសំខាន់នៅក្នុងវិស័យអាជីវកម្ម រោងចក្រ។ បើសិនជាកំណត់ឲ្យមានការប្រគល់វត្ថុនៃការបញ្ចាំ នោះអាជីវកម្មរបស់កូនបំណុលដែលមានកិច្ចធានានឹងមានការរាំងស្ទះដែលអាចជាហេតុបង្កឲ្យវិស័យសេដ្ឋកិច្ចជួបភាពលំបាក។ ហេតុដូច្នេះហើយ ទើបច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា មិនតម្រូវឲ្យមានរូបភាពនៃការប្រគល់ទ្រព្យធានាជាចាំបាច់នោះទេ តែបើភាគីព្រមព្រៀងគ្នា នោះច្បាប់ក៏មិនហាមឃាត់ករណីនេះដែរ។

##### ខ. ប្រាតិភោគចលនវត្ថុតាមសណ្ឋាននៃការបញ្ចាំ

ចំណែកការបញ្ចាំតាមក្រមរដ្ឋប្បវេណីវិញ មានគោលបំណងបម្រើឲ្យវិស័យឯកជន និយាយឲ្យចំ ប្រធាននៃការបញ្ចាំគឺជាប្រជាពលរដ្ឋធម្មតាក្នុងទំនាក់ទំនាងរវាងបុគ្គល និងបុគ្គលធម្មតា។ ដោយហេតុថា បញ្ញត្តិនៅក្នុងរបបគតិយុត្តនៃការបញ្ចាំ សំដៅលក្ខខណ្ឌអានុភាពនៃការប្រគល់ទ្រព្យ

---

[68] មាត្រា ៥០ (៣) (ខ) នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

ធានា ម្យ៉ាងដោយសារតែវាស្ថិតនៅក្នុងច្បាប់ទូទៅផង ទើបបានជាសន្មតថា ការប្រើប្រាស់សញ្ញាណនៃការបញ្ចាំយកមកអនុវត្តភាគច្រើនក្នុងទំនាក់ទំនងបុគ្គលក្នុងជីវភាពប្រចាំថ្ងៃ ដែលមានភាពខ្វះខាតផ្នែកហិរញ្ញវត្ថុបន្តិចបន្តួច និងជ្រើសរើសយកសិទ្ធិលើការបញ្ចាំចលនវត្ថុមកអនុវត្ត។

ម្យ៉ាងវិញទៀត បើសិនជាការបញ្ចាំចលនវត្ថុ ត្រូវបានប្រើប្រាស់នៅក្នុងប្រតិបត្តិការអាជីវកម្មធំៗ ដោយអនុវត្តការប្រគល់សារពើភណ្ឌ ឬ ឧបករណ៍ជា វាជាការខាតបង់មួយផ្នែកធំសម្រាប់អ្នកបង្កើតសិទ្ធិលើការបញ្ចាំ ដែលសុខចិត្តជ្រើសរើសប្រតិបត្តិការនៃប្រាតិភោគចលនវត្ថុនៅក្រោមក្រមរដ្ឋប្បវេណី ជំនួសឲ្យការប្រើប្រាស់ប្រតិបត្តិការដែលមានកិច្ចធានា។ នេះក៏ព្រោះថាអ្នកបង្កើតសិទ្ធិលើការបញ្ចាំអាចរក្សាទុកទ្រព្យធានានៅក្នុងឃ្លាំងរបស់ខ្លួន និងរង់ចាំអតិថិជនមកជាវដើម្បីបានជាឥណទានបន្តអាជីវកម្មទៅមុខ ប្រសើរជាជាងប្រគល់ចលនវត្ថុជាប្រភេទទំនិញសម្រាប់លក់ទៅម្ចាស់សិទ្ធិនៃការបញ្ចាំ ដោយសុខចិត្តបញ្ឈប់សកម្មភាពពាណិជ្ជកម្មទិញដូរនៃទ្រព្យធានានោះទេ។ តែទោះជាយ៉ាងណាក៏ដោយ បុគ្គលដែលមានបំណងប្រើប្រាស់ប្រាតិភោគចលនវត្ថុ មានសិទ្ធិក្នុងការជ្រើសរើសប្រតិបត្តិការណាមួយតាមតែខ្លួនចង់បាន តែក្នុងនាមជាពាណិជ្ជករ គប្បីតែមានការពិចារណាខ្ពស់ក្នុងការជ្រើសរើសរបបគតិយុត្តណាដែលផ្តល់អត្ថប្រយោជន៍ច្រើនដល់ខ្លួន។

### ២.១.២.២. លក្ខខណ្ឌនៃបង្កើតកិច្ចព្រមព្រៀងប្រាតិភោគតាមប្រតិបត្តិការដែលមានកិច្ចធានា

#### ក. លក្ខខណ្ឌក្នុងការសរសេរជាលាយលក្ខណ៍អក្សរ

បន្ថែមលើចំណុចខុសប្លែកដូចបានបញ្ជាក់ខាងលើ កិច្ចព្រមព្រៀងប្រាតិភោគធ្វើនៅក្រោមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ត្រូវធ្វើជាលាយលក្ខណ៍អក្សរ[69] ចំណែកសិទ្ធិលើការបញ្ចាំវិញមានភាពស្ងៀមស្ងាត់នៅត្រង់ចំណុចការបង្កើតកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ តែប្រហែលជាទុកសិទ្ធិដល់ភាគីក្នុងការជ្រើសរើសការកត់ត្រាជាលាយលក្ខណ៍អក្សរ ឬ មិនកត់ត្រាមួយណាងាយជាង។ បន្ថែមលើនេះ កិច្ចព្រមព្រៀងប្រាតិភោគនៅក្រោមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានានេះ អាចកើតចេញកំណត់ត្រាច្រើនដែលដាក់បញ្ចូលគ្នា ឧទាហរណ៍ដូចជាក្នុងការបង្កើតប្រាតិភោគចលនវត្ថុមួយអាចមានកិច្ចសន្យាខ្ចីប្រាក់ផ្សេង និងកិច្ចព្រមព្រៀងប្រាតិភោគមួយទៀត តែទោះជាយ៉ាងណាក៏ដោយ កិច្ចព្រមព្រៀងនីមួយៗត្រូវមានបញ្ជាក់នូវលក្ខណៈដែលទាក់ទងគ្នា និងអាចត្រូវបញ្ជាក់ពីចំនួនទឹកប្រាក់ខ្ចី រួមទាំងវត្ថុដែលនឹងក្លាយជាកម្មវត្ថុនៃការធានាកាតព្វកិច្ច។

[69] មាត្រា ៦ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ ២០០៦

កិច្ចព្រមព្រៀងប្រាតិភោគ មិនតម្រូវរូបមន្តនៃលិខិតបញ្ជាក់យថាភូតអ្វីនោះទេ តែហត្ថលេខារបស់កូនបំណុលជាលក្ខខណ្ឌចាំបាច់។ ក្រៅពីនេះការសរសេរឈ្មោះរបស់កូនបំណុល ក៏មានសារៈសំខាន់សម្រាប់ម្ចាស់បំណុលដែលមានកិច្ចធានាក្នុងការធានាថាព័ត៌មានទាំងនេះគឺត្រឹមត្រូវ និងមិនច្រឡំជាមួយជនដទៃនោះទេ។ ចំណែកកិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំ តាមក្រមរដ្ឋប្បវេណី មិនតម្រូវឲ្យមានទម្រង់ណាមួយជាកំណត់ដូចជា លិខិតយថាភូតដែលត្រូវមានសេចក្តីបញ្ជាក់ដោយស្ថាប័នសាធារណៈ ឬជាលិខិតឯកជននោះទេ ពោលគឺតម្រូវតែការព្រមព្រៀងរបស់ភាគីតែប៉ុណ្ណោះគឺគ្រប់គ្រាន់ហើយ។[70] តែទោះជាយ៉ាងណាភាគីអាចព្រមព្រៀងបង្កើតកិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំជាលាយលក្ខណ៍អក្សរ ហើយវាជាការល្អប្រសើរសម្រាប់ដាក់ជាភស្តុតាងនៅពេលអនុវត្តសិទ្ធិ។ ដូចនេះភាគីគួរតែបង្កើតកិច្ចព្រមព្រៀងការបញ្ចាំជាលាយលក្ខណ៍អក្សរ ដើម្បីបានជាសក្ខីភាពអះអាងប្រឆាំងនឹងភាគីដែលទុច្ចរិតក្នុងការអនុវត្តកាតព្វកិច្ច។

## ខ. ធាតុផ្សំសំខាន់ទាំងបីនៃកិច្ចព្រមព្រៀងប្រាតិភោគ

ខុសពីការបង្កើតសិទ្ធិលើការបញ្ចាំ ដែលតម្រូវត្រឹមតែការព្រមព្រៀងរបស់ភាគីតែប៉ុណ្ណោះ ចំណែកប្រសិទ្ធិភាពនៃកិច្ចព្រមព្រៀងប្រាតិភោគ តាមប្រតិបត្តិការដែលមានកិច្ចធានាកើតឡើងនៅពេលដែលលក្ខខណ្ឌបីទៀតត្រូវបានបំពេញតាមបញ្ញត្តិនៃមាត្រា៩ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាដូចខាងក្រោម ហើយលក្ខខណ្ឌទាំង៣ មិនចាំបាច់ត្រូវគោរពតាមលំដាប់នោះទេ គឺមួយណាមកមុនក៏បានដែរ។[71] លក្ខខណ្ឌទាំង៣នេះមានដូចជាៈ

- ***កូនបំណុលត្រូវមានសិទ្ធិលើកម្មវត្ថុនៃទ្រព្យធានាៈ*** អាចជាសិទ្ធិក្នុងការផ្ទេរ ឬ សិទ្ធិកម្មសិទ្ធិរបស់កូនបំណុលក្នុងការផ្ទេរទ្រព្យធានាទៅម្ចាស់បំណុល ឬអាចជាសិទ្ធិជួល។ ដើម្បីធានាបានថា កូនបំណុលមានសិទ្ធិអ្វីមួយលើទ្រព្យធានា ម្ចាស់បំណុលដែលមានកិច្ចធានា អាចស្នើសុំឯកសារកម្មសិទ្ធិ ឬវិក្កយបត្រលក់ កិច្ចសន្យាជួល ឬទម្រង់លិខិតផ្លូវការដទៃទៀត ដែលអាចបញ្ជាក់បានថាកូនបំណុលពិតជាមានសិទ្ធិអំណាចក្នុងការផ្ទេរទ្រព្យធានាតាមផ្លូវច្បាប់។[72]

---

[70] មាត្រា៨១៨ នៃសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៥: គន្ថីទី៦

[71] មាត្រា ៩ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

[72] សៀវភៅស្តីពីការពន្យល់ និងឧទាហរណ៍លើប្រតិបត្តិការដែលមានកិច្ចធានា, ទំព័រ ៦៦

- *អត្ថិភាពនៃកិច្ចព្រមព្រៀងប្រាតិភោគដោយមានការយល់ព្រមពីកូនបំណុល៖* ការយល់ព្រមពីកូនបំណុល ដោយការតាក់តែងក្នុងកិច្ចសន្យាលាយលក្ខណ៍អក្សរគឺសំខាន់ នឹងត្រូវតែមានការបញ្ជាក់ដោយហត្ថលេខារបស់កូនបំណុល។[73]
- *កូនបំណុលត្រូវទទួលតម្លៃអ្វីមួយពីម្ចាស់បំណុល៖* តម្លៃនេះអាចជាសាច់ប្រាក់ ឬជាការសន្យាដើម្បីផ្តល់សាច់ប្រាក់ជាមុននៅពេលអនាគត ក៏ប៉ុន្តែការអនុវត្តសិទ្ធិប្រាតិភោគបាន ទាល់តែម្ចាស់បំណុលដែលមានកិច្ចធានាផ្តល់តម្លៃអ្វីមួយទៅឲ្យកូនបំណុល។[74]

### ២.១.២.៣.អានុភាពនៃសិទ្ធិប្រាតិភោគលើប្រភេទចលនវត្ថុផ្សេងៗ

#### ក. ករណីការបង្កើតប្រាតិភោគលើវត្ថុចំណុះ និងវត្ថុចម្បង

ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ មិនបានបញ្ញត្តអំពីនិយមន័យនៃវត្ថុចម្បងនោះទេ ប៉ុន្តែយើងអាចធ្វើការស្វែងយល់អំពីអត្ថន័យនៃវត្ថុចម្បងបានតាមរយៈនិយមន័យនៃវត្ថុចំណុះបានថា វត្ថុចំណុះជាវត្ថុដែលមិនមែនជាសមាសភាគនៃវត្ថុចម្បង ហើយដែលកម្មសិទ្ធិករនៃវត្ថុចំណុះបានភ្ជាប់ទៅនឹងវត្ថុចម្បងក្នុងគោលបំណងសេដ្ឋកិច្ចនៃវត្ថុចម្បង។ ការបង្កើត និងការផ្ទេរសិទ្ធិចំពោះវត្ថុចម្បង ត្រូវមានអានុភាពចំពោះវត្ថុចំណុះផងដែរ លើកលែងតែមានការសន្យាពិសេស។[75] នេះមានន័យថា ការបង្កើតសិទ្ធិប្រាតិភោគលើវត្ថុចម្បង អាចនឹងមិនមានអានុភាពដល់វត្ថុចំណុះ លើកលែងតែភាគីធ្វើការព្រមព្រៀងផ្សេង។ ករណីដែលបង្កើតសិទ្ធិលើការបញ្ចាំលើវត្ថុចម្បង ហើយក្រោយមកវត្ថុចម្បងភ្ជាប់ទៅនឹងវត្ថុចំណុះដោយសារការកែច្នៃ និងការលម្អជាអាទិ៍ ប្រហែលជាមិនអាចកើតឡើងទេ ដោយយើងដឹងហើយថា ការបញ្ចាំមានលក្ខខណ្ឌអានុភាពនៃការប្រគល់វត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំទៅម្ចាស់សិទ្ធិ ដូចនេះគ្មានករណីណាដែលវត្ថុចម្បងត្រូវបានភ្ជាប់នឹងវត្ថុចំណុះដើម្បីបង្កើតតម្លៃសេដ្ឋកិច្ចអ្វីទេ ព្រោះវត្ថុនេះមិននៅក្នុងដៃអ្នកបង្កើតសិទ្ធិលើការបញ្ចាំនោះទេ។

ចំណែកតាមប្រតិបត្តិការដែលមានកិច្ចធានាវិញបានឲ្យនិយមន័យវត្ថុចំណុះថា ជាចលនវត្ថុដែលបានផ្គុំបញ្ចូលជាមួយចលនវត្ថុផ្សេង តាមរបៀបដែលមិនឲ្យបាត់បង់អត្តសញ្ញាណនៃចលនវត្ថុចំបងនោះទេ។ ក៏ប៉ុន្តែការបង្កើតសិទ្ធិប្រាតិភោគលើវត្ថុចម្បង នឹងមិនមានអានុភាពដល់វត្ថុចំណុះនោះទេ ប្រសិនបើវត្ថុចំណុះនោះត្រូវបានគោរពការធ្វើសុក្រឹតកម្ម មុននឹងវត្ថុចម្បងត្រូវបានបង្កើត

---

[73] សៀវភៅស្តីពីការពន្យល់ និងឧទាហរណ៍លើប្រតិបត្តិការដែលមានកិច្ចធានា, ទំព័រ ៦២

[74] សៀវភៅស្តីពីការពន្យល់ និងឧទាហរណ៍លើប្រតិបត្តិការដែលមានកិច្ចធានា, ទំព័រ ៦៦

[75] មាត្រា១២៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

សិទ្ធិប្រាតិភោគ និងតម្កល់លិខិតជូនដំណឹង។ ឧទាហរណ៍ ប្រដាប់ចាក់បទចម្រៀងតំឡើងនៅក្នុងរថយន្ត គឺជាវត្ថុចំណុះពីព្រោះអត្តសញ្ញាណនៃរថយន្តដើមនៅតែមានលក្ខណៈច្បាស់លាស់ដដែល។ ចំពោះប្រដាប់ចាក់ចម្រៀងថ្មី អាចនឹងត្រូវភ្ជាប់ទៅនឹងរថយន្តដែលត្រូវបានដាក់ប្រាតិភោគ និងធ្វើសុក្រឹតកម្មរួចទៅហើយ ទៅដាក់ធានាសិទ្ធិលើបំណុលឲ្យម្ចាស់បំណុលទី១ ហើយប្រដាប់ចាក់ចម្រៀងនេះក៏បានធ្វើសុក្រឹតកម្មរួចហើយដែរ។ តែមួយរយៈក្រោយមកម្ចាស់រថយន្តមិនសងបំណុលទៅម្ចាស់បំណុលទី១ ដូចនេះម្ចាស់បំណុលទី១ បានរឹបអូសយករថយន្តទៅលក់ដើម្បីយកប្រាក់ធានាបំណុលខ្លួន តែទោះជាយ៉ាងណាក៏ដោយ ដោយសារតែម៉ាស៊ីនចាក់ចម្រៀងថ្មីដែលបានភ្ជាប់នឹងរថយន្តបានជាប់សិទ្ធិប្រាតិភោគ ដូចនេះម្ចាស់បំណុលទី១ ត្រូវយកលុយទៅសងកាតព្វកិច្ចរបស់ម្ចាស់បំណុលទី ២ផងដែរ។

## ខ. ករណីបង្កើតប្រាតិភោគលើចលនវត្ថុតាំងភ្ជាប់

ជាទូទៅ ចលនវត្ថុតាំងភ្ជាប់នឹងក្លាយជាសមាសភាគនៃវត្ថុ បើកាលណាចង់ធ្វើការផ្លាស់ប្តូរទីតាំង ឬ យកចេញពីអចលនវត្ថុនោះនឹងនាំឲ្យខូចរូបរាងដែលប៉ះពាល់ផលប្រយោជន៍សេដ្ឋកិច្ច។ បើបង្កើតសិទ្ធិប្រាតិភោគលើចលនវត្ថុតាំងភ្ជាប់ ត្រូវតម្កល់នៅការិយាល័យសុរិយោដីដែលបានបង្កើតឡើងតាមច្បាប់ភូមិបាល។

ក៏ប៉ុន្តែ តាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ចលនវត្ថុតាំងភ្ជាប់អាចជាកម្មវត្ថុនៃការបង្កើតសិទ្ធិប្រាតិភោគ ដោយច្បាប់នេះបានឲ្យនិយមន័យនៃពាក្យចលនវត្ថុតាំងភ្ជាប់ថា "ជាទំនិញដែលបានភ្ជាប់ទៅនឹងអចលនវត្ថុ ឬ មានគោលបំណងតាំងភ្ជាប់ទៅនឹងអចលនវត្ថុតាមរបៀបមួយដែលនាំឲ្យមានសិទ្ធិប្រត្យក្សកើតឡើង"។[76] តាមន័យនេះនាំឲ្យយល់បានថាវាគឺជាប្រភេទចលនវត្ថុដែលពិបាកក្នុងការយកចេញពីអចលនវត្ថុ ឬ បើវាយកវាចេញពីអចលនវត្ថុនឹងបង្កឲ្យខូចខាតអចលនវត្ថុនោះ ឬ បាត់បង់នូវតម្លៃអ្វីមួយ។ ឧទាហរណ៍៖ អណ្តូងស្នប់ដែលបានបង្កើតសិទ្ធិប្រាតិភោគដាក់នៅក្រោមប្រតិបត្តិការដែលមានកិច្ចធានា តែក្រោយមកត្រូវបានម្ចាស់ទ្រព្យធានា យកវាទៅភ្ជាប់ទៅនឹងដីរបស់ខ្លួនដែលបានភ្ជាប់បន្ទុកអ៊ីប៉ូតែករួចទៅហើយ។ ករណីនេះបើយោលតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា បានអនុញ្ញាតឲ្យបង្កើតប្រតិបត្តិការប្រភេទនេះ[77] ពោលគឺកូនបំណុលដែលមានកិច្ចធានាអាចបង្កើតសិទ្ធិប្រាតិភោគលើអណ្តូងស្នប់បាន ដោយធ្វើការព្រមព្រៀងជាមួយម្ចាស់បំណុលថាខ្លួនសុំកាន់កាប់ទ្រព្យធានា។

---

[76] មាត្រា១៣ នៃច្បាប់ស្តីពីប្របត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

[77] មាត្រា៦(៣) នៃច្បាប់ស្តីពីប្របត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

ចំពោះសិទ្ធិប្រាតិភោគលើប្រាក់ខ្ចីទិញទំនិញ ដែលបានធ្វើសុក្រឹតកម្មរួចលើចលនវត្ថុតាំងភ្ជាប់មានអាទិភាពលើអ៊ីប៉ូតែក និងការទាមទារដទៃទៀតទោះបីអ៊ីប៉ូតែកមានមុនក្តី។ គោលបំណងនៃការផ្តល់អាទិភាពខ្ពស់បែបនេះគឺ ដើម្បីជំរុញការលើកទឹកចិត្តលើប្រាតិភោគខ្ចីទិញទំនិញប្រើប្រាស់ និងបង្កើនដំណើរការកែលម្អលើអចលនវត្ថុ។ ឧទាហរណ៍ទី១៖ ធនាគារ ១ ធ្វើសុក្រឹតកម្មលើសិទ្ធិប្រាតិភោគលើសំភារៈអណ្តូងទឹកដែលត្រូវដំឡើងលើដី បន្ទាប់មកធនាគារ២ ទទួលបានអ៊ីប៉ូតែកលើដីនោះក្រោយសិទ្ធិប្រាតិភោគត្រូវបានធ្វើសុក្រឹតកម្ម។ ករណីនេះសិទ្ធិប្រាតិភោគរបស់ធនាគារលេខ១ មានអាទិភាពលើអ៊ីប៉ូតែក តែមានអានុភាពត្រឹមតែតម្លៃសម្ភារៈប៉ុណ្ណោះ។ ឧទាហរណ៍ទី២៖ ធនាគារមានកិច្ចសន្យាអ៊ីប៉ូតែកជាមួយម្ចាស់រោងចក្រទៅលើដី។ ក្រោយមកក្រុមហ៊ុនមួយបានផ្តល់ហិរញ្ញប្បទានលើប្រាក់ទិញម៉ាស៊ីនដេរថ្មីសម្រាប់ម្ចាស់រោងចក្រ ដោយធ្វើសុក្រឹតកម្មលើម៉ាស៊ីនថ្មីទាំងនោះមុនពេលវាត្រូវបានដំឡើងនៅក្នុងរោងចក្រ។ ស្ថានភាពនេះ សិទ្ធិអាទិភាពរបស់ក្រុមហ៊ុនមានទៅលើធនាគារ ពីព្រោះម៉ាស៊ីនជាចលនវត្ថុតាំងភ្ជាប់ដែលអាចយកចេញពីរោងចក្របានដោយងាយស្រួល។

ផ្ទុយទៅវិញចំពោះការបញ្ចាំតាមក្រមរដ្ឋប្បវេណី មិនអាចធ្វើបានទេលើចលនវត្ថុតាំងភ្ជាប់ ព្រោះវាបានក្លាយជាសមាភាគនៃវត្ថុ ដូចជាកង្ហារភ្ជាប់ទៅនឹងផ្ទះអ្នកបង្កើតសិទ្ធិលើការបញ្ចាំ។ អ្វីដែលគួរឲ្យកត់សម្គាល់ថាសិទ្ធិលើការបញ្ចាំមិនអាចបង្កើតបានលើចលនវត្ថុតាំងភ្ជាប់ ព្រោះអ្នកបង្កើតសិទ្ធិគ្មានលទ្ធភាពក្នុងការប្រគល់វត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ ទៅម្ចាស់សិទ្ធិលើការបញ្ចាំនោះទេ និងម្យ៉ាងទៀត លក្ខខណ្ឌអានុភាពរបស់របបគតិយុត្តនៃការបញ្ចាំគឺការប្រគល់វត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ។ បើភាគីព្រមព្រៀងថាមិនចាំបាច់ប្រគល់ ការបញ្ចាំនៅតែអាចធ្វើបានតែគ្មានអានុភាពការពារតាមផ្លូវច្បាប់នោះទេ។

### ២.១.២.៤. អត្ថិភាពនៃលក្ខខណ្ឌតតាំងសំខាន់ៗផ្សេងគ្នា

ទោះបីជាមានការពិពណ៌នាពីលក្ខខណ្ឌតតាំងនៅផ្នែកខាងលើ ពីលក្ខខណ្ឌតតាំងធម្មតាដែលកំណត់ដោយបញ្ញត្តិរួមនៃក្រមរដ្ឋប្បវេណី អំពីអានុភាពនៃសិទ្ធិប្រាតិភោគប្រត្យក្សលើចលនវត្ថុដោយផ្ទេរការកាន់កាប់ដែលជាចំណុចដូចគ្នា តែស្ថិតនៅក្នុងចំណុចនេះនឹងធ្វើការបង្ហាញពីលក្ខខណ្ឌតតាំងសំខាន់ក្រៅពីការផ្ទេរការកាន់កាប់តែមួយមុខ។

### ក. លក្ខខណ្ឌតតាំងរបស់ប្រតិបត្តិការដែលមានកិច្ចធានា

ការតម្កល់លិខិតជូនដំណឹង ជាលក្ខខណ្ឌសំខាន់នៃការបង្កើតប្រតិបត្តិការដែលមានកិច្ចធានាទោះបីជាមិនមានផ្ទេរការកាន់កាប់ក៏ដោយ។ ការជ្រើសរើសរបស់ម្ចាស់បំណុលក្នុងការតម្កល់លិខិតជូនដំណឹងជាជាងទទួលការកាន់កាប់ទ្រព្យធានាគឺ អាចតតាំងបានគ្រប់រូបភាពទោះបីជាវត្ថុដែលជា

កម្មវត្ថុនៃការដាក់ធានា ត្រូវបានកូនបំណុលផ្ទេរការកាន់ទៅម្ចាស់បំណុលទីពីរ ឬ ទីបីក៏ដោយក៏ការតម្កល់លិខិតជូនដំណឹង នៅតែមានអានុភាពជាជាងការផ្ទេរការកាន់កាប់ក្នុងការធ្វើសុក្រឹតភាពលើសិទ្ធិប្រាតិភោគដែលមានលើវត្ថុដែលជាកម្មវត្ថុនៃការធានានោះ។ សូមចំណាំថា ការប្រើសិទ្ធិតតាំងចំពោះតតិយជនក្នុងករណីផ្ទេរកាន់កាប់នេះ គឺជាលក្ខខណ្ឌមួយក្នុងចំណោមការធ្វើសុក្រឹតកម្មផ្សេងទៀត តែការកាន់កាប់មិនមានអានុភាពពេញលេញដូចការធ្វើសុក្រឹតកម្មតាមរយៈការតម្កល់លិខិតជូនដំណឹងនៅការិយាល័យតម្កល់លិខិតជូនដំណឹងនោះទេ។ បើកាលណាការកាន់កាប់ដោយម្ចាស់បំណុលដែលមានកិច្ចធានាលើទ្រព្យធានា ត្រូវបានបញ្ឈប់ដោយការប្រគល់វត្ថុនៃការធានាឲ្យកូនបំណុលកាន់កាប់វិញ នោះសុក្រឹតភាពនឹងបានបង់អានុភាព ហើយម្ចាស់បំណុលមិនអាចតតាំងនឹងតតិយជនបាននោះទេ ចំណែកសិទ្ធិរបស់ខ្លួនក៏ក្លាយទៅជាសិទ្ធិលើបំណុលធម្មតា មិនមែនជាសិទ្ធិលើបំណុលដែលមានកិច្ចធានាទៀតទេ។[78]

## ខ. លក្ខខណ្ឌតតាំងរបស់សិទ្ធិលើការបញ្ចាំ

ចំណែកការបញ្ចាំវិញ លក្ខខណ្ឌដើម្បីតតាំងនឹងតតិយជន គឺការការកាន់ចលនវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំជានិរន្តរ៍ ព្រោះតាមក្រមរដ្ឋប្បវេណី ម្ចាស់សិទ្ធិលើការបញ្ចាំមិនអាចតតាំងសិទ្ធិលើការបញ្ចាំនោះចំពោះតតិយជនបានឡើយ ប្រសិនបើខ្លួនមិនបានកាន់កាប់វត្ថុជានិរន្តរ៍។ ដូចនេះហើយ លុះត្រាតែថាម្ចាស់សិទ្ធិលើការបញ្ចាំនៅតែបន្តការកាន់កាប់វត្ថុបញ្ចាំ ដើម្បីតតាំងសិទ្ធិលើការបញ្ចាំនោះចំពោះតតិយជនគ្រប់រូប។[79] ម្យ៉ាងទៀតបើមិនមានការកាន់កាប់ជានិរន្តន៍ដោយម្ចាស់សិទ្ធិលើការបញ្ចាំទេ នោះការបង្កើតសិទ្ធិលើការបញ្ចាំគ្មានអានុភាពនោះទេ[80] ព្រោះច្បាប់មិនអនុញ្ញាតឲ្យអ្នកបង្កើតសិទ្ធិលើការបញ្ចាំកាន់កាប់ដោយផ្ទាល់លើវត្ថុបញ្ចាំនោះទេ។[81] មិនចាំបាច់មានន័យថាទាល់តែមានម្ចាស់បំណុលជាអ្នកកាន់កាប់ខ្លួននោះទេ ព្រោះថាការកាន់កាប់ក៏អាចធ្វើតាមរយៈអ្នកតំណាងបានដែរ គឺការកាន់កាប់ដោយប្រយោល ក៏បំពេញលក្ខណ្ឌការកាន់កាប់ផងដែរ។ ឧទាហរណ៍៖ កូនបំណុល A បានបង្កើតសិទ្ធិលើការបញ្ចាំលើឡានរបស់ខ្លួនជាមួយម្ចាស់បំណុល B ហើយម្ចាស់បំណុល B បានឲ្យតតិយជាអ្នកតំណាងរបស់គាត់ទុកព្រោះដោយសារតែខ្លួនគ្មានទីកន្លែងគ្រប់គ្រាន់សម្រាប់រក្សាទុកវត្ថុបញ្ចាំ។ ករណីនេះក៏បង្កើតនូវលក្ខខណ្ឌតតាំងសម្រាប់ម្ចាស់

---

[78] មាត្រា១០(៥) នៃច្បាប់ស្ដីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

[79] មាត្រា ៨២៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[80] មាត្រា៨១៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[81] មាត្រា៨១៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

សិទ្ធិលើការបញ្ចាំផងដែរ ទោះជាទ្រព្យធានាមិននៅនឹងខ្លួនកាន់កាប់ដោយផ្ទាល់ក៏ដោយ។

នេះជាលក្ខខណ្ឌតតាំងសំខាន់ៗរបស់របបគតិយុត្តទាំងពីរដែលខុសគ្នា ដោយមួយតម្រូវឲ្យតម្កល់លិខិតជូនដំណឹងនៅក្រសួងពាណិជ្ជកម្ម និងម្ខាងទៀតតម្រូវការបន្តការកាន់កាប់ជានិរន្តរ៍ដោយម្ចាស់សិទ្ធិលើការបញ្ចាំជាកំណត់ ដើម្បីតាំងនឹងតតិយជនដែលមកអះអាងពីសិទ្ធិផ្សេងៗ។

### ២.១.២.៥. ភាពដោយឡែកពីគ្នានៃការអនុវត្តសិទ្ធិប្រាតិភោគ

ទោះជាស្ថិតនៅក្នុងរបបគតិយុត្តខុសគ្នា តែពេលខ្លះសិទ្ធិប្រាតិភោគមានការអនុវត្តសិទ្ធិដូចគ្នា ដូចជាការប្រើប្រាស់ការអនុវត្តដោយបង្ខំ ឬ ការរក្សារការពារ។ តែទោះជាយ៉ាងណា បើយើងក្រឡេកមើលរបបនៃការដាក់ចលនវត្ថុជាប្រាតិភោគទាំងពីរនេះ មានការអនុវត្តសិទ្ធិខុសគ្នាច្រើន។ ដូចនេះដើម្បីដឹងច្បាស់ សូមធ្វើការបកស្រាយជាបន្តដូចខាងក្រោម។

#### ក. ការអនុវត្តសិទ្ធិតាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា

តាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ភាគីអាចធ្វើការព្រមព្រៀង បានថាតើការមិនសងបំណុលរបស់កូនបំណុលត្រូវមានរូបភាពដូចម្តេច ដូច្នេះហើយរូបភាពរបស់ភាគីកំណត់នោះហើយដែលត្រូវចាត់ទុកថាជាការមិនសងបំណុល។[82] ភាគីអាចព្រមព្រៀងបានថាករណីដែលកំណត់សងបានមកដល់ ហើយកូនបំណុលនៅតែមិនអនុវត្តកាព្វកិច្ច បើម្ចាស់បំណុលដាស់តឿន៣ដង ហើយមិនអនុវត្ត នោះត្រូវចាត់ទុកថាជាការមិនសងបំណុល ដែលនាំលទ្ធភាពទៅរកការអនុវត្តសិទ្ធិរបស់ម្ចាស់បំណុល។ ពាក់ព័ន្ធទៅនឹងទ្រព្យអរូបិយ ម្ចាស់បំណុលអនុវត្តតែម្តងដោយមិនចាំបាច់ប្តឹងទៅតុលាការនោះទេ ហើយបើទ្រព្យធានាជាឯកសារ ម្ចាស់បំណុលដែលមានកិច្ចធានាអាចប្រើសិទ្ធិលើឯកសារ ឬចំពោះទំនិញដែលបានចែងក្នុងឯកសារនេះ ដោយមិនចាំបាច់តុលាការទេ។[83]

ក្រៅពីនេះ ម្ចាស់បំណុលនៃកិច្ចធានា មានសិទ្ធិប្តឹងសុំសេចក្តីសម្រេចកិច្ចការប្រញាប់ ឬការបញ្ជាពិសេសពីតុលាការដើម្បីឲ្យម្ចាស់បំណុលធ្វើការកាន់កាប់ និងគ្រប់គ្រងទ្រព្យធានាបើសិនជាទ្រព្យធានានៅក្នុងដៃកូនបំណុល។[84] ប៉ុន្តែរហូតមកដល់ពេលនេះ មិនមានការកំណត់មួយណាច្បាស់លាស់ពីដីកាសម្រេចកិច្ចការប្រញាប់ ថាចេញក្នុងរយៈពេលប៉ុន្មាន ប្រើនីតិវិធីច្បាស់លាស់ដូចម្តេចនៅឡើយទេ។ តែអនុលោមតាមមាត្រា៤៨ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាបាន

[82] មាត្រា ៤៦(១) នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

[83] មាត្រា ៤៦(៥) នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

[84] មាត្រា ៤៦(៦) & ៤៨(២) នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

កំណត់បន្ថែមថា ពាក់ព័ន្ធនឹងសវនាការត្រូវផ្តោតតែទៅលើបញ្ហាដែលពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងប្រាតិភោគដែលកំណត់ពីទ្រព្យធានាតែប៉ុណ្ណោះ និងទាល់តែមានការខកខានមិនបានសងបំណុលយ៉ាងតិចមួយលើក របស់កូនបំណុលទើបម្ចាស់បំណុល អាចអនុវត្តសិទ្ធិប្រាតិភោគលើទ្រព្យធានាបាន។

បន្ទាប់ពីទទួលបានដីកាសម្រេចកិច្ចការប្រញាប់ពីតុលាការហើយ ម្ចាស់បំណុលដែលមានកិច្ចធានា អាចនឹងត្រូវការសេវាកម្មរបស់អាជ្ញាសាលា ឬមន្ត្រីដទៃទៀតជាចាំបាច់ដើម្បីដកហូតទ្រព្យធានាពីកូនបំណុល។ បន្ទាប់មកម្ចាស់បំណុលអាចទុកដាក់កម្មវត្ថុធានាមករក្សាទុក ឬទុកនៅលំនៅស្ថានរបស់កូនបំណុល ឬទីកន្លែងផ្សេងទៀតដែលរកឃើញទ្រព្យធានាតែម្តង ហើយធ្វើការជម្រះដោយមិនចាំបាច់ដីកាសម្រេចអនុញ្ញាតការអនុវត្តដោយបង្ខំ ដូចការអនុវត្តសិទ្ធិលើការបញ្ចាំនោះទេ។[85] ដូចច្នេះអាចទាញបានថា ការអនុវត្តនេះគឺប្រើប្រាស់នីតិវិធីរក្សាការពារ ក្នុងការគ្រប់គ្រងថែរក្សាវត្ថុធានាមុននឹងការធ្វើការចាត់ចែងដោយម្ចាស់បំណុលខ្លួនឯង ដោយមិនប្រើប្រាស់រូបភាពនីតិវិធីនៃការអនុវត្តដោយបង្ខំនោះទេ ព្រោះថាការអនុវត្តដោយបង្ខំគឺអាជ្ញាធរដែលមានសមត្ថកិច្ចជាអ្នកអនុវត្តលក់ឡាយឡុង តែករណីនេះគឺម្ចាស់បំណុលជាអ្នកធ្វើការលក់ឡាយឡុងខ្លួនឯង។

បន្ទាប់មកទៀត ម្ចាស់បំណុលដែលមានកិច្ចធានា ត្រូវប្រគល់ទឹកប្រាក់ដែលជាផលនៃការជម្រះទ្រព្យធានា ដែលលើសទៅឲ្យកូនបំណុលវិញ ហើយកូនបំណុលក៏ត្រូវមានទំនួលខុសត្រូវសងនូវទឹកប្រាក់ដែលខ្វះផងដែរ លើកលែងតែមានការព្រមព្រៀងផ្សេង។[86] លើសពីនេះ ច្បាប់ពិសេសនេះមិនអនុញ្ញាតឲ្យម្ចាស់បំណុលមានសិទ្ធិធ្វើជាម្ចាស់កម្មសិទ្ធិលើទ្រព្យធានា ដើម្បីកាត់កងសិទ្ធិលើបំណុលដូចការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប ដែលត្រូវបានអនុញ្ញាតដោយរបបគតិយុត្តនៃការបញ្ចាំនោះទេ តែម្ចាស់បំណុលដែលមានកិច្ចធានាមានសិទ្ធិធ្វើការជម្រះដោយជ្រើសរើសវិធីណាមួយ ដូចជាការលក់ ជួល ឬ ការជម្រះតាមការចង់បានរបស់ខ្លួន។[87]

## ខ. ការអនុវត្តសិទ្ធិលើការបញ្ចាំទៅលើវត្ថុបញ្ចាំ

ម្ចាស់សិទ្ធិលើការបញ្ចាំ អាចជ្រើសរើសវិធីណាមួយក្នុងចំណោមវិធីពីរគឺ ការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប(ខ.១) និងការអនុវត្តដោយបង្ខំលើសិទ្ធិប្រាតិភោគចលនវត្ថុ(ខ.២) ដើម្បីធ្វើការអនុវត្តសិទ្ធិរបស់ខ្លួន ករណីដែលកូនបំណុលមិនសងបំណុលដោយស្ម័គ្រចិត្ត។

---

[85] មាត្រា ៤៨ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

[86] មាត្រា ៥០ (២) នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

[87] មាត្រា ៤៩ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

### ខ.១. ការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប

ដោយមិនចាំបាច់ប្រើប្រាស់ការអនុវត្តដោយបង្ខំ ម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រើប្រាស់ការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប តាមការចង្អុលបង្ហាញដោយមាត្រា៨៣២ នៃក្រមរដ្ឋប្បវេណី និងអនុវត្តតាមមាត្រា៥០៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប សំដៅលើការអនុវត្តសិទ្ធិរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ ក្នុងការទទួលបានវត្ថុបញ្ចាំមកធ្វើជាកម្មសិទ្ធិរបស់ខ្លួនតាមរយៈតុលាការតែម្តង ដោយមិនបាំបាច់ឆ្លងកាត់នីតិវិធីនៃការអនុវត្តដោយបង្ខំទេ។ នៅពេលដល់កំណត់សងសិទ្ធិលើបំណុលហើយ បើម្ចាស់សិទ្ធិលើការបញ្ចាំមិនបានទទួលការសងទេ ម្ចាស់សិទ្ធិលើការបញ្ចាំអាចទាមទារឲ្យតុលាការយកវត្ថុបញ្ចាំនោះ មកសងខ្លួនផ្ទាល់តែម្តងដើម្បីកាត់សិទ្ធិលើបំណុល។[88]

ករណីខាងលើនេះ តុលាការត្រូវជ្រើសតាំងអ្នកវាយតម្លៃឲ្យវាយតម្លៃនូវវត្ថុបញ្ចាំជាមុន មុនពេលចេញដីកាសម្រេច ប៉ុន្តែប្រសិនបើម្ចាស់បំណុល និងកូនបំណុល បានព្រមព្រៀងគ្នារួចហើយ អំពីតម្លៃដោយបានសរសេរក្នុងពាក្យសុំ តុលាការមិនចាំបាច់ជ្រើសតាំងអ្នកវាយតម្លៃទៀតទេ។ តុលាការត្រូវប្រកាសអនុញ្ញាតឲ្យយកវត្ថុបញ្ចាំមកសងដោយផ្ទាល់ ក្នុងចំនួនទឹកប្រាក់ដែលបានវាយតម្លៃ ឬ បានយល់ព្រមក្នុងពាក្យសុំនោះ ប៉ុន្តែប្រសិនបើតម្លៃនោះលើសពីចំនួនទឹកប្រាក់សរុបនៃកាតព្វកិច្ចដែលត្រូវសង តុលាការត្រូវបង្គាប់ឲ្យសងចំនួនលើសនោះទៅឲ្យកម្មសិទ្ធិករនៃវត្ថុបញ្ចាំវិញ។ ទោះជាយ៉ាងនេះក្តី ការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេបត្រូវគោរពនីតិវិធីតឹងរឹងចំនួន ៤ គឺត្រូវធ្វើតាមរយៈតុលាការ មានការអនុញ្ញាតពីតុលាការ មានការវាយតម្លៃត្រឹមត្រូវ មានការជូនដំណឹងទៅកូនបំណុលជាមុន។[89] លក្ខខណ្ឌដែលតឹងរឹងនេះ ធ្វើឡើងដើម្បីការពារអ្នកបង្កើតសិទ្ធិលើការបញ្ចាំ និងអ្នកធានាដោយវត្ថុ។

### ខ.២. ការអនុវត្តសិទ្ធិលើការបញ្ចាំតាមរយៈការអនុវត្តដោយបង្ខំលើសិទ្ធិប្រាតិភោគចលនវត្ថុ

ម្ចាស់សិទ្ធិលើការបញ្ចាំអាចមានជម្រើសផ្សេងទៀត ក្រៅពីការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប។ នៅពេលដែលអ្នកបង្កើតសិទ្ធិលើការបញ្ចាំមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន តាមការកំណត់សងដោយការស្ម័គ្រចិត្តទេ ទោះបីម្ចាស់សិទ្ធិលើការបញ្ចាំបានទាមទារឲ្យសងយ៉ាងណាក៏ដោយ នោះម្ចាស់សិទ្ធិលើការបញ្ចាំអាចទាមទារឲ្យអ្នកបង្កើតសិទ្ធិលើការបញ្ចាំអនុវត្តកាតព្វកិច្ច

[88] មាត្រា ៨៣២ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[89] មាត្រា៨៣២ នៃសេចក្តីកំណត់ក្រមរដ្ឋប្បវេណីភាគ៤ គន្លឹះទី ៦

របស់ខ្លួនតាម រយៈការអនុវត្តដោយបង្ខំបានដោយប្រើប្រាស់មាត្រា៥០០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ម្ចាស់បំណុលអាចដាក់ពាក្យសុំ ដើម្បីអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុទៅអាជ្ញាសាលា។[90] តាមរយៈនោះអាជ្ញាសាលាត្រូវលក់ចលនវត្ថុនោះតាមវិធីលក់ឡាយឡុង។ ទោះបីជាគ្មានលិខិតអនុវត្តដើម្បីដាក់ទៅអាជ្ញាសាលាក៏ដោយ បើម្ចាស់បំណុលបានដាក់កម្មវត្ថុនៃសិទ្ធិប្រាតិភោគ ឬ ក៏ម្ចាស់បំណុលមានឯកសារណា ដែលអាចបញ្ជាក់បានថាអ្នកកាន់កាប់ចលវត្ថុបានយល់ព្រមចំពោះការរឹបអូស នេះក៏ការអនុវត្តសិទ្ធិប្រាតិភោគលើចលនវត្ថុអាចចាប់ផ្តើមបានដែរ។

## ២.២. ប្រតិបត្តិការដែលមានកិច្ចធានា និងប្រាតិភោគដោយអនុប្បទានតាមក្រមរដ្ឋប្បវេណី

ប្រាតិភោគ គឺជាមធ្យោបាយមួយដែលធានាដល់ម្ចាស់សិទ្ធិប្រាតិភោគ ក្នុងការប្រមូលនូវសិទ្ធិលើបំណុលរបស់ខ្លួនត្រលប់មកវិញដោយមានលទ្ធភាពខ្ពស់ ដោយយកចលនវត្ថុមកដាក់ប្រាតិភោគ។ ក្រៅពីមធ្យោបាយនៃការដាក់ប្រាតិភោគតាមរូបភាពនៃការបញ្ចាំ ក្រមរដ្ឋប្បវេណីបានបញ្ញត្តប្រាតិភោគមួយផ្សេងទៀតគឺ ប្រាតិភោគដោយអនុប្បទាន។ នេះដោយសារតែ ការបញ្ចាំទាមទារឲ្យកូនបំណុលប្រគល់វត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ ដូចនេះវាពិបាកសម្រាប់កូនបំណុលក្នុងការប្រើប្រាស់ទ្រព្យធានាឲ្យអស់លទ្ធភាព ហេតុដូច្នេះហើយ ទើបមានរបបគតិយុត្តមួយទៀតតម្រូវត្រឹមតែការផ្ទេរកម្មសិទ្ធិនៃទ្រព្យធានាតាមរយៈការព្រមព្រៀងតែប៉ុណ្ណោះ ដោយអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានអាចរក្សាទ្រព្យនៅនឹងខ្លួនសម្រាប់បន្តការធ្វើអាជីវកម្ម ឬប្រើប្រាស់បន្តទៅទៀត។ ក្រៅពីបញ្ញត្តិច្បាប់ទូទៅ អំពីប្រាតិភោគដោយអនុប្បទាន នៅមានច្បាប់ពិសេសដែលកំណត់ពីប្រាតិភោគចលនវត្ថុ ដែលរបបគតិយុត្តនេះគឺត្រូវបានគេហៅឈ្មោះថា ប្រតិបត្តិការដែលមានកិច្ចធានា។ របបគតិយុត្តនៃប្រាតិភោគដោយអនុប្បទាន ដែលមិនទាមទារនូវការផ្ទេរការកាប់ជាក់ស្តែងទៅម្ចាស់សិទ្ធិនេះ លេចនូវសញ្ញាណមួយរិតតែប្រហាក់ប្រហែលនឹងប្រតិបត្តិការដែលមានកិច្ចធានានៅក្នុងច្បាប់ពិសេសដែលកំណត់ពីសិទ្ធិប្រាតិភោគប្រត្យក្សផ្សេងទៀតលើចលនវត្ថុ។

តែទោះជាយ៉ាងណា គោលបំណងនៃការបង្កើតរបបគតិយុត្តច្រើន គឺដើម្បីសម្របសម្រួលដល់តម្រូវការនៃសាច់ប្រាក់ និងអនុញ្ញាតឲ្យបង្កើតឡើងតាមការព្រមព្រៀងរបស់ភាគី តាមរយៈការបន្ថែមនូវវិស័យគតិយុត្តផ្សេងទៀត ដើម្បីជាកាតាលីករសម្រាប់ជម្រុញប្រព័ន្ធនៃការផ្តល់ឥណទានឲ្យមានដំណើរការល្អ។ ការប្រើប្រាស់ប្រតិបត្តិការនៃការធានាកាតព្វកិច្ច អាចជ្រើសរើសដោយភាគីបានដោយសេរី យោងតាមគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន តែបើសិនជាមិនគោរពតាម

[90] មាត្រា ៣៩៩ (១) នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

លក្ខខណ្ឌនៃរបបគតិយុត្តនីមួយៗដែលបានកំណត់ទេ វាអាចបង្កឲ្យបាត់បង់ផលប្រយោជន៍សេដ្ឋកិច្ច។ អាស្រ័យហេតុនេះ ការបែងចែកពីលក្ខណៈរួមគ្នា (២.២.១) និងលក្ខណៈខុសគ្នា(២.២.២) នៃប្រាតិភោគដោយអនុប្បទាន និងប្រតិបត្តិការដែលមានកិច្ចធានា នឹងបង្កភាពងាយស្រួលដល់ការអនុវត្តសិទ្ធិរបស់ម្ចាស់បំណុល និងកូនបំណុលឲ្យកាន់តែមានភាពប្រសើរជាងមុន។

### ២.២.១.លក្ខណៈរួម

ប្រតិបត្តិការដែលមានកិច្ចធានា និងប្រាតិភោគដោយអនុប្បទានស្ថិតនៅក្រោមរបបគតិយុត្តខុសគ្នា តែក៏នៅមានលក្ខណៈមួយចំនួនដូចគ្នា ដោយសារតែគោលបំណងនៃការបង្កើតឡើងគឺដើម្បីផ្តល់ជាសិទ្ធិអាទិភាពដល់ម្ចាស់បំណុលដែលជ្រើសរើស មានលទ្ធភាពក្នុងការទទួលបានការសងខ្ពស់ជាងម្ចាស់បំណុលធម្មតា។ ម្យ៉ាងវិញទៀត ការសិក្សាពីភាពដូចគ្នានៃរបបគតិយុត្តទាំងពីរនេះ នឹងផ្តល់ជាពុទ្ធិដ៏មានសារៈសំខាន់ក្នុងការស្គាល់នូវធាតុដែលដូចគ្នាទាំងឡាយ ដែលនឹងបង្កជាភាពងាយស្រួលក្នុងការបែងចែករបបគតិយុត្តនីមួយៗ។

#### ២.២.១.១. កម្មវត្ថុនៃការបង្កើត

##### ក.ចលនវត្ថុរូបិយ

សិទ្ធិប្រត្យក្ស គឺជាសិទ្ធិដែលមានលើវត្ថុ មិនមែនមានលើមនុស្សនោះទេ ហើយពាក្យវត្ថុនៅទីនេះ សំដៅទៅលើកម្មវត្ថុនៃសិទ្ធិប្រត្យក្ស។ ចំណែកប្រភេទចលនវត្ថុដែលជាកម្មវត្ថុនៃការបង្កើតសិទ្ធិប្រត្យក្សបានគឺចលនវត្ថុរូបិយទូទៅ ដែលច្បាប់មិនបានបញ្ញត្តហាមឃាត់តឹងរឹងនោះទេ។ ចលនវត្ថុរូបិយនេះ សំដៅទៅលើវត្ថុដែលមិនមែនជាអចលនវត្ថុ ដែលអាចរំកិលបាន និងផ្លាស់ទីតាំងបាន មានដូចជាគ្រឿងសង្ហារិម សម្ភារៈការិយាល័យ នាឡិកា ចិញ្ចៀនពេជ្រ ទំនិញ របស់របរប្រើប្រាស់នានា សុទ្ធតែជាកម្មវត្ថុនៃការបង្កើតសិទ្ធិប្រត្យក្សបានទាំងអស់ ដែលមានតម្លៃសេដ្ឋកិច្ចធ្វូនល្មមនឹងបង្កើតសិទ្ធិប្រាតិភោគទៅតាមការវាយតម្លៃរបស់ម្ចាស់សិទ្ធិប្រាតិភោគ។ ដោយសារសម័យនេះជាសម័យបច្ចេកវិទ្យាខ្ពស់ មិនត្រឹមតែអចលនវត្ថុនោះទេដែលគេឲ្យតម្លៃ ចលនវត្ថុនាពេលបច្ចុប្បន្នក៏មានចរាចរយ៉ាងសកម្មផងដែរ ព្រមទាំងបង្កើតនូវប្រតិបត្តិការស្ទើររាប់មិនអស់ក្នុងមួយថ្ងៃៗ។ ទោះជាយ៉ាងណា ការចាត់ចែងចលនវត្ថុមានផលប៉ះពាល់ទៅលើសុវត្ថិភាពខាងជំនួយព្រោះពិបាកវិនិច្ឆ័យពីអ្នកដែលជាម្ចាស់សិទ្ធិពិតប្រាកដ។

### ខ.ចលនវត្ថុផ្តុំគ្នា

គោលបំណងនៃការប្រើប្រាតិភោគដោយអនុប្បទាន គឺដើម្បីជម្រុញការផ្តល់ហិរញ្ញប្បទានដោយមានការដាក់ចលនវត្ថុធ្វើជាទ្រព្យធានា ហើយទ្រព្យនៃការដាក់ធានាមិនអាចជាអចលនវត្ថុទេ ព្រោះការផ្តល់ទ្រព្យធានាជាអចលនវត្ថុដោយមិនប្រគល់ការកាន់កាប់ អាចធ្វើបានដោយប្រើប្រាស់របបគតិយុត្តហ៊ីប៉ូតែក[91]។ ដូចនេះក្រៅពីចលនវត្ថុរូបិយដែលពិពណ៌នាខាងលើ តើមានប្រភេទចលនវត្ថុផ្សេងដែលអាចដាក់ធានាបានឬទេ?

យោលតាមមាត្រា៨៨៨ នៃក្រមរដ្ឋប្បវេណីបានបញ្ញត្តថា *"ចលនវត្ថុច្រើន ដែលត្រូវបានកំណត់ទំហំតាមមាត្រដ្ឋាន ដូចជាប្រភេទ ឬកន្លែងស្ថិតនៅនៃចលនវត្ថុ"* ក៏ជាកម្មវត្ថុនៃការដាក់ប្រាតិភោគដោយអនុប្បទានបានដែរ។ អំណានបទប្បញ្ញត្តិនេះនាំឲ្យយល់បានថា កម្មវត្ថុនៃការដាក់ប្រាតិភោគដោយអនុប្បទាន ក្រៅពីចលនវត្ថុរូបិយធម្មតា គេក៏អាចបង្កើតទៅលើចលនវត្ថុរួមផ្តុំតែមួយ ដូចជាក្នុងរូបភាពការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានដោយដាក់ចលនវត្ថុទាំងអស់នៅក្នុងឃ្លាំង ឬ ដាក់មាន់ទាំងអស់នៅក្នុងកសិដ្ឋានជាអាទិ៍។

មិនខុសគ្នាពី ការដាក់ទ្រព្យធានាធ្វើជាកម្មវត្ថុនៃប្រតិបត្តិការដែលមានកិច្ចធានានោះទេ ព្រោះតាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា អនុញ្ញាតចំពោះការដាក់ប្រាតិភោគចំពោះគ្រប់ប្រភេទនៃទ្រព្យធានាទាំងអស់ រួមបញ្ចូលទាំងទ្រព្យដែលមាននាពេលបច្ចុប្បន្ន និងទ្រព្យដែលកើតមាននៅពេលអនាគតទៀតផង។[92] ឧទាហរណ៍នៃការបង្កើតប្រាតិភោគដោយចលនវត្ថុរួមផ្តុំគ្នាតែមួយគឺៈ លោក សុខ ចង់ពង្រីកកសិដ្ឋានចិញ្ចឹមមាន់របស់គាត់ ដូច្នេះគាត់បានខ្ចីប្រាក់ពីលោក សៅរ៍ ដោយយល់ព្រមបង្កើតសិទ្ធិប្រាតិភោគ លើមាន់ទាំងអស់ដែលមាននៅក្នុងកសិដ្ឋានចំនួន១០០ក្បាល។ ដូចនេះទោះបីជាមាន់ខ្លះត្រូវបានលក់ចេញក៏ដោយ តែចំនួនមាន់ថ្មីដែលទិញចូលមកក៏ជាផ្នែកមួយនៃប្រាតិភោគផងដែរ។

### ២.២.១.២. អានុភាពលើវត្ថុដែលភ្ជាប់នឹងកម្មវត្ថុនៃប្រាតិភោគ

អានុភាពនៃប្រាតិភោគក៏មានទៅលើវត្ថុភ្ជាប់ ដែលកំណត់ដោយក្រមរដ្ឋប្បវេណី និងចលនវត្ថុតាំងភ្ជាប់ដែលប្រើប្រាស់ដោយច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាដែរ។ ជាទូទៅវត្ថុដែលភ្ជាប់ទៅនឹងកម្មវត្ថុនៃការដាក់ប្រាតិភោគ ឬ ជាផ្នែកមួយនៃវត្ថុដែលជាកម្មវត្ថុសុទ្ធតែបង្កើតនូវ

---

[91] មកដល់ត្រង់នេះ សូមប្តូរមកប្រើហ៊ីប៉ូតែកវិញ ដោយសារតែការពិភាក្សាទៅលើក្រមរដ្ឋប្បវេណីថ្មីឆ្នាំ២០០៧

[92] មាត្រា ៦ (១), (៨) នៃប្រតិបត្តិការដែលមានកិច្ចធានា២០០៦

អានុភាពនៃសិទ្ធិប្រាតិភោគនោះ។[93] វត្ថុភ្ជាប់នេះត្រូវបានបែងចែកជាពីរគឺ សមាសភាគនៃវត្ថុ និង វត្ថុចំណុះ។

### ក. សមាសភាគនៃវត្ថុ

សមាសភាគនៃវត្ថុ សំដៅទៅលើសមាសភាគដែលមិនអាចបំបែកបានដោយមិនប្តូរលក្ខណៈដើមនៃវត្ថុ[94] ដូចជា កញ្ចក់ ឬ បំពង់ស៊ីម៉ាំងនៃរថយន្តជាអាទិ៍។ ប្រាតិភោគដោយអនុប្បទាន បានផ្តល់អានុភាពរបស់ខ្លួនទៅលើវត្ថុទាំងអស់ដែលភ្ជាប់នឹងកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន ដែលជាផ្នែកមួយនៃកម្មវត្ថុនោះ នៅពេលបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន។[95] មានន័យថាបើសិនជាម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានទទួលបានសិទ្ធិប្រាតិភោគលើរថយន្ត នោះនាំឲ្យគាត់មានសិទ្ធិទៅលើចំណែកផ្សេងៗនៃរថយន្តនោះ ទាំងកញ្ចក់ ទាំងម៉ាស៊ីនរបស់រថយន្ត។ ដោយសារវត្ថុទាំងអស់នេះមិនអាចដកចេញពីរថយន្តបានទេ ប្រសិនបើបំបែកវត្ថុនេះចេញនឹងនាំឲ្យរថយន្តដំណើរការលែងកើត ឬ នាំឲ្យមានការផ្លាស់ប្តូរលក្ខណៈដើមនៃរថយន្តជាមិនខាន។

ចំពោះបញ្ញត្តិនៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ក៏អនុវត្តដូចគ្នាចំពោះសមាសភាគនៃវត្ថុផងដែរ។[96] បើមិនកំណត់អានុភាពបែបនេះទេ ម្ចាស់បំណុលអាចនឹងបាត់ប្រយោជន៍ បើកូនបំណុលទុច្ចរិតដោះយកសមាសភាគនៃវត្ថុទៅលក់ ឬ បង្កើតប្រាតិភោគតាមតែចិត្តចង់បាន។ នេះជាមូលហេតុដែល ច្បាប់មិនអនុញ្ញាតឲ្យភាគីធ្វើកិច្ចព្រមព្រៀង ដកចេញនូវសមាសភាគនៃវត្ថុពីអានុភាពនៃសិទ្ធិប្រាតិភោគនោះទេ ពោលគឺចំណុចនេះត្រូវបានរិតត្បិតដោយមាត្រា១២១ នៃក្រមរដ្ឋប្បវេណីបញ្ញត្តថាករណីនេះជាបញ្ញត្តិដែលត្រូវអនុវត្តដោយបង្ខំ។

### ខ. ប្រាតិភោគលើវត្ថុះចំណុះ និងវត្ថុចម្បង

វិសាលភាពនៃប្រតិបត្តិការដែលមានកិច្ចធានា ក៏អាចបង្កើតលើវត្ថុចំណុះផងដែរ ករណីដូចជាការតម្កល់លិខិតជូនដំណឹងលើត្បូងពេជ្រដែលភ្ជាប់ទៅនឹងដងចិញ្ចៀន ដែលជាតម្លៃទាំងអស់ដែលកូនបំណុលមាន។[97] ជាធម្មតា ត្បូងពេជ្រមានតម្លៃខាងសេដ្ឋកិច្ចខ្ពស់លុះត្រាតែវាភ្ជាប់ទៅនឹងដងចិញ្ចៀន ឬ ខ្សែករ។ បើសិនជាមានករណីនេះកើតឡើង អានុភាពនៃប្រតិបត្តិការដែលមានកិច្ច

[93] មាត្រា ៦(៣) នៃប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧ និង មាត្រា ៨៩១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[94] មាត្រា ១២១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[95] មាត្រា ៨៩១(១) នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[96] មាត្រា ២៣ នៃប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

[97] មាត្រា ២០ នៃប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

ធានាអាចអនុញ្ញាតឲ្យម្ចាស់បំណុលមានសិទ្ធិដកហូតយកវត្ថុចំណុះនោះ ចេញពីចលនវត្ថុផ្សេងនោះបានលុះត្រាតែខ្លួនមានសិទ្ធិអាទិភាពជាងបុគ្គលផ្សេងទៀត[98] ក៏ប៉ុន្តែម្ចាស់បំណុលមានកាតព្វកិច្ចសងនូវថ្លៃចំណាយជួសជុល ឬ ការខូចខាតដែលកើតមានដោយសារការដកចេញនូវវត្ថុចំណុះនោះ។

ឯអានុភាពប្រាតិភោគដោយអនុប្បទានវិញ ក៏មានទៅលើចលនវត្ថុតាំងភ្ជាប់ផងដែរ ក្នុងរូបភាពជា *"វត្ថុដែលភ្ជាប់នឹងវត្ថុដែលជាកម្មវត្ថុ និងជាផ្នែកមួយនៃវត្ថុដែលជាកម្មវត្ថុនោះ នៅពេលបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន"* ។[99] វាក៏អាចបង្កើតលើវត្ថុចំណុះផងដែរ ដែលភ្ជាប់ទៅនឹងវត្ថុចម្បងដែលបង្កើតតម្លៃលើវត្ថុចម្បងនោះ។ ភាគីអាចធ្វើកិច្ចព្រមព្រៀងដកចេញនូវវត្ថុចំណុះពីអានុភាពនៃប្រាតិភោគដោយអនុប្បទានបាន បើសិនជាមានការព្រមព្រៀងថាបង្កើតសិទ្ធិប្រាតិភោគតែទៅលើវត្ថុចម្បងតែប៉ុណ្ណោះ។[100] ដូច្នេះនៅពេលកូនបំណុលមិនសងបំណុល ម្ចាស់បំណុលអាចដករុះរើយកវត្ថុចំណុះនោះចេញពីចលនវត្ថុជាវត្ថុចម្បងនោះ។

តាមការពិតទៅ វាមានភាពពិបាកបន្តិចក្នុងការកំណត់ថា មួយណាជាវត្ថុចំណុះ មួយណាជាវត្ថុចម្បង ព្រោះបើយើងមើលទៅលើតម្លៃប្រហែលជាអាចសម្គាល់ដឹង តែវាអាស្រ័យតាមការព្រមព្រៀងរបស់ភាគីក្នុងការកំណត់តែប៉ុណ្ណោះ។ ឧទាហរណ៍ខ្លះដូចជា ទូក និងម៉ាស៊ីនដែលភ្ជាប់ទៅនឹងទូកនេះ តើមួយណាជាវត្ថុចំណុះ មួយណាជាវត្ថុចម្បង? បើមើលលើស្ថានភាពជាក់ស្ដែងទូកធម្មតាមានតម្លៃតិចតួចប៉ុណ្ណោះ ចំណែកម៉ាស៊ីនដែលត្រូវបានគេភ្ជាប់នឹងទូកវិញគឺមានតម្លៃថ្លៃជាង។ ចំពោះចិញ្ចៀនមាស និងត្បូងពេជ្រក៏ដូចគ្នា ពេលខ្លះតម្លៃរបស់វាសឹងតែអាចស្មើគ្នាអាស្រ័យដោយទំហំ និងតម្លៃសេដ្ឋកិច្ចជាក់ស្ដែង។

### ២.២.១.៣. ទំហំនៃសិទ្ធិលើបំណុល និងសិទ្ធិទាមទារឲ្យសងសោហ៊ុយ

#### ក. ទំហំនៃសិទ្ធិលើបំណុលដែលត្រូវធានា

ភាគីនៃកិច្ចព្រមព្រៀងអាចបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ដោយកំណត់ពីទំហំនៃសិទ្ធិលើបំណុលដែលត្រូវធានាបាន តែបើមិនបានកំណត់ក្នុងកិច្ចព្រមព្រៀងទេ សិទ្ធិលើបំណុលត្រូវមានទៅលើ ប្រាក់ដើម ការប្រាក់ ប្រាក់ធានាសងក្នុងករណីមិនគោរពកិច្ចសន្យា សោហ៊ុយដើម្បីអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន សោហ៊ុយដើម្បីរក្សាវត្ថុដែលជាកម្មវត្ថុ ព្រមទាំងសំណង

[98] មាត្រា ២២(១), (២) នៃប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

[99] មាត្រា ៨៩១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[100] មាត្រា ៨៩១(២) នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

នៃការខូចខាតដែលកើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ច ឬ វិការៈកំបាំងនៃវត្ថុដែលជាកម្មវត្ថុ។[101]

ចំណែកច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា មិនបានកំណត់ច្បាស់លាស់ពីទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានការពារនោះទេ តែបើយោងបញ្ញត្តិនៃមាត្រា៥០ នៃច្បាប់ដដែលនេះនាំឲ្យយល់បានថា មានការចង្អុលបង្ហាញពីកម្រិតនៃសិទ្ធិលើបំណុលដែលត្រូវសងនៅពេលម្ចាស់បំណុលធ្វើការអនុវត្តសិទ្ធិលើទ្រព្យធានា ដែលទំហំសិទ្ធិលើបំណុលដែលត្រូវចេញមានដូចជា ការសងថ្លៃចំណាយសមស្របដែលកើតឡើងពីការកាន់កាប់ គ្រប់គ្រង និងថែរក្សា ការចំណាយក្នុងការជម្រះទ្រព្យធានា និងការជម្រះទ្រព្យធានា ដោយបញ្ចូលទាំងថ្លៃមេធាវី ចំណាយរឿងក្តីដែលម្ចាស់បំណុលដែលមានកិច្ចធានាបានរ៉ាប់រងចំណាយ។[102]

## ខ. សិទ្ធិទាមទារឲ្យសងសោហ៊ុយ

ដូចគ្នាទៅនឹងលក្ខណៈសារធាតុនៃការបញ្ចាំដែរ នៅត្រង់ថាបើសិនជាក្នុងកំឡុងពេលកាន់កាប់ទ្រព្យធានាដោយម្ចាស់សិទ្ធិនៃប្រាតិភោគ ត្រូវមានកាតព្វកិច្ចមើលថែរក្សា និងឃុំគ្រងទ្រព្យធានាឲ្យបានល្អក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត។[103] បើម្ចាស់សិទ្ធិប្រាតិភោគបានចំណាយជាចាំបាច់សម្រាប់ការគ្រប់គ្រង និងថែរក្សា ឬ ចេញចំណាយបង្កើនតម្លៃវត្ថុដែលជាកម្មវត្ថុនៃការដាក់ប្រាតិភោគ នោះម្ចាស់សិទ្ធិអាចទាមទារឲ្យកម្មសិទ្ធិករនៃវត្ថុនោះសងនូវចំណាយនោះទាំងអស់ ឬ សងនូវតម្លៃប្រាក់ដែលកើននោះ បើសិនជាតម្លៃនោះនៅតែមានអត្ថិភាព។[104]

ដូចគ្នានេះដែរ នៅក្នុងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាត្រង់មាត្រា៨ បានកំណត់ជាក់ជាកំណត់ថា ម្ចាស់បំណុលដែលមានកិច្ចធានាត្រូវយកចិត្តទុកដាក់ក្នុងការថែរក្សា ឃុំគ្រងទ្រព្យធានាឲ្យបានល្អ ឲ្យដូចខ្លួនជាម្ចាស់កម្មសិទ្ធិពិតប្រាកដ។ បើសិនជាភាគីមិនបានព្រមព្រៀងផ្សេងនោះទេ ម្ចាស់បំណុលដែលមានកិច្ចធានា មានសិទ្ធិទាមទារនូវចំណាយសមស្របដែលខ្លួនបានចេញឲ្យកូនបំណុលដែលមានកិច្ចធានា រួមបញ្ចូលទាំងថ្លៃធានារ៉ាប់រង ពន្ធអាករ និងចំណាយផ្សេងៗទៀតលើទ្រព្យធានានោះ។

---

[101] មាត្រា ៨៩៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[102] មាត្រា ៥០ នៃប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

[103]មាត្រា ៨២៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[104] មាត្រា ៨៩៦ និង ៨២៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

### ២.២.១.៤. វត្តមាននៃអានុភាពចំពោះផលដែលកើតចេញពីទ្រព្យធានា

#### ក. ប្រាតិភោគដោយអនុប្បទាន

នៅក្រោមរបបគតិយុត្តនៃប្រាតិភោគដោយអនុប្បទាន អានុភាពចំពោះផលត្រូវបានបែងចែកជាពីរករណី៖

- *ករណីទី១៖ អ្នកបង្កើតប្រាតិភោគដោយអនុប្បទាន ឬតតិយជនដែលទទួលការបញ្ជាពីអ្នកបង្កើត កាន់កាប់វត្ថុដោយចំពោះ*

ករណីដែលវត្ថុដែលជាកម្មវត្ថុ នៅក្នុងដៃកូនបំណុល ឬ តតិយជនដែលទទួលការបញ្ជា ដូច្នេះអានុភាពនៃផលមិនភ្ជាប់សិទ្ធិប្រាតិភោគដោយអនុប្បទានទេ មានន័យថាកូនបំណុលអាចប្រើប្រាស់ និងអាស្រ័យផលពីវត្ថុដែលជាកម្មវត្ថុ។ ប៉ុន្តែផលត្រូវទទួលបាននូវអានុភាព ករណីដែលពេលកំណត់ត្រូវសងបានមកដល់ (ផុតអំឡុងពេលប្រាតិភោគ ឬនៅពេលម្ចាស់បំណុលទាមទារនៅពេលក្រោយ ) ហើយម្ចាស់បំណុលបានទាមទារ ដោយធ្វើការចាត់ចែងប្តូរជាប្រាក់ ឬ អនុប្បទានជាស្ថាពរ នោះកូនបំណុលលែងមានសិទ្ធិប្រើប្រាស់ និងអាស្រ័យផលពីវត្ថុនោះទៀតហើយ។[105]

- *ករណីទី២៖ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ឬ តតិយជនដែលទទួលការបញ្ជាពីម្ចាស់សិទ្ធិ កាន់កាប់វត្ថុដោយចំពោះ*

ករណីដែលម្ចាស់បំណុល ឬ តតិយជនដែលទទួលការបញ្ជា កាន់កាប់វត្ថុដែលកម្មវត្ថុដោយចំពោះ គាត់មានសិទ្ធិទទួលផលដែលកើតឡើងពីវត្ថុនោះ ហើយត្រូវកាត់សិទ្ធិលើបំណុលដោយយកផលទៅកាត់ការប្រាក់ជាមុនសិន ហើយប្រសិនបើមានសល់ត្រូវយកកាត់ប្រាក់ដើម។[106] ម្ចាស់បំណុលមិនចាំបាច់ យកផលមកកាត់សិទ្ធិលើបំណុលទេ ក្នុងករណីដែលម្ចាស់បំណុលមិនអាចទាមទារការប្រាក់ពីកូនបំណុលបាន និយាយឲ្យចំគឺមិនចាំបាច់យកផលនេះទៅទូទាត់នឹងការប្រាក់ដែលខ្លួនអាចទទួលបាន។ ផ្ទុយទៅវិញ បើសិនជាកូនបំណុលបង្កើតកិច្ចព្រមព្រៀងពិសេសដើម្បីបង្កើតកិច្ចសន្យាប្រាតិភោគដោយមានការប្រាក់ ដូចជាកិច្ចសន្យាខ្ចីបរិភោគជាអាទិ៍ នោះម្ចាស់បំណុលចាំបាច់ត្រូវយកផលដែលខ្លួនទទួលបានពីវត្ថុដែលជាកម្មវត្ថុ ទៅកាត់សិទ្ធិលើបំណុលនេះដោយសារតែខ្លួនបានទទួលការប្រាក់ទៅហើយ មិនគួរអាស្រ័យផលថែមទៀតទេ។[107]

---

105 មាត្រា ៨៩២(១) នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

106 មាត្រា ៨២២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

107 មាត្រា ៨៩២(២) នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

### ខ. ប្រតិបត្តិការដែលមានកិច្ចធានា

ចំណែកតាមប្រតិបត្តិការដែលមានកិច្ចធានាក៏អនុញ្ញាតឲ្យសិទ្ធិប្រាតិភោគ មានលើផលនៃទ្រព្យធានាផងដែរ ដោយមិនចាំបាច់តម្កល់លិខិតជូនដំណឹង ដើម្បីធ្វើសុក្រឹតកម្មសិទ្ធិប្រាតិភោគលើផលនៃទ្រព្យធានានោះទេ។[108] បើទ្រព្យធានានៅក្នុងដៃម្ចាស់បំណុលដែលមានកិច្ចធានាគាត់អាចធ្វើការរក្សាទុកផលជារូបិយវត្ថុដែលកើតចេញពីទ្រព្យធានា តែត្រូវយកទៅទូទាត់កាតព្វកិច្ចប្រាតិភោគ។[109] ជាទូទៅ ការភ្ជាប់សិទ្ធិប្រាតិភោគទៅនឹងទ្រព្យធានា ផ្តល់ឲ្យនូវម្ចាស់បំណុលដែលមានកិច្ចធានានូវសិទ្ធិលើផលនៃទ្រព្យធានា លើកលែងតែភាគីបានព្រមព្រៀងមិនបង្កើតអានុភាពនៃប្រាតិភោគលើផលនៃទ្រព្យធានា។[110] តែក្នុងករណីដែលផលនៅក្នុងដៃកូនបំណុលដែលមានកិច្ចធានា ជាទូទៅកូនបំណុលមានសិទ្ធិទទួលផលលើទ្រព្យដែលនៅក្នុងដៃរបស់ខ្លួន ព្រោះគោលបំណងនៃការតម្កល់លិខិតជូនដំណឹងចំពោះសិទ្ធិប្រាតិភោគ ដើម្បីទុកទ្រព្យធានានៅនឹងដៃកូនបំណុលក្នុងការធ្វើអាជីវកម្មបន្តទៅទៀត រួមទាំងប្រើប្រាស់ និងទទួលផលពីទ្រព្យធានានោះ។

### ២.២.១.៥. ការផ្តល់លទ្ធភាពក្នុងការអនុវត្តសិទ្ធិលោះទ្រព្យធានា

បើរយៈពេលដែលត្រូវអនុវត្តកាតព្វកិច្ចត្រូវបានផុតរយៈពេល ហើយកូនបំណុលនៅមិនសងបំណុល នេះគឺថេរវេលាដែលម្ចាស់បំណុលអាចអនុវត្តសិទ្ធិរបស់ខ្លួន។ មុននឹងម្ចាស់បំណុលចាប់ផ្តើមអនុវត្តសិទ្ធិជម្រះទៅលើទ្រព្យធានា ច្បាប់បានផ្តល់សិទ្ធិដល់កូនបំណុល ក្នុងការអនុវត្តសិទ្ធិលោះទ្រព្យធានារបស់ខ្លួនវិញ។ របបគតិយុត្តប្រាតិភោគដោយអនុប្បទាន បានកំណត់ឲ្យអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន អាចទទួលបាននូវកម្មវត្ថុប្រាតិភោគវិញ កាលណាបានផ្តល់នូវកាតព្វកិច្ចគ្រប់ចំនួន ទៅម្ចាស់សិទ្ធិសិទ្ធិប្រាតិភោគដោយអនុប្បទាន នៅមុនពេលមានការផ្តល់ប្រាក់ជម្រះ។ ការអនុវត្តសិទ្ធិលោះនេះ ធ្វើបានលុះត្រាតែចំនួនទឹកប្រាក់នៃកាតព្វកិច្ចដែលត្រូវសងមានចំនួនតិចជាង តម្លៃកម្មវត្ថុនៃប្រាតិភោគ បន្ទាប់ពីពេលដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានបានជូនដំណឹងអំពីចំនួនដែលលើសនោះទៅឲ្យអ្នកបង្កើត។[111] ត្រង់នេះចង់បញ្ជាក់ថា បើកាតព្វកិច្ចរបស់កូនបំណុលតិចជាងតម្លៃនៃកម្មវត្ថុដែលដាក់ប្រាតិភោគ នោះកូនបំណុលមិនមានសិទ្ធិក្នុងការលោះទ្រព្យធានាមកវិញទេ។

---

[108] មាត្រា ១០ (៩) នៃប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

[109] មាត្រា ៨(២)(គ) នៃប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

[110] មាត្រា ៩(២) នៃប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

[111] មាត្រា ៨៩៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ចំពោះប្រតិបត្តិការដែលមានកិច្ចធានាក៏ដូចគ្នា ដោយនីតិករទុកសិទ្ធិចុងក្រោយឲ្យកូនបំណុលដែលមានកិច្ចធានាមានឱកាសទទួលបាននូវទ្រព្យធានារបស់ខ្លួនមកវិញ មុននឹងម្ចាស់បំណុលដែលមានកិច្ចធានាអនុវត្តសិទ្ធិក្នុងការជម្រះ។ បន្ទាប់ពីការមិនសងបំណុល កូនបំណុលអាចលោះយកទ្រព្យធានាដោយអនុវត្តកាតព្វកិច្ចទាំងអស់ ដែលខ្លួនបានធានាចំពោះម្ចាស់បំណុលដែលមានកិច្ចធានា ក្រៅពីនេះកូនបំណុលត្រូវចេញសោហុយថ្លៃចំណាយដែលម្ចាស់បំណុលបានចាយក្នុងការកាន់កាប់ និងជួសជុលទ្រព្យធានាសម្រាប់ធ្វើការជម្រះ ថ្លៃសេវាមេធាវី និងចំណាយផ្សេងៗក្នុងរឿងក្តីឲ្យបានមុនម្ចាស់បំណុលនៃទ្រព្យធានាធ្វើការជម្រះចោលនូវទ្រព្យធានា ឬ ចុះកិច្ចសន្យាជម្រះចោល។ ការអនុវត្តសិទ្ធិលោះក៏អាចធ្វើបានដែរ នៅមុនពេលដែលកាតព្វកិច្ចរបស់កូនបំណុលដែលត្រូវសងម្ចាស់បំណុលរលត់។[112]

ក្រៅពីលក្ខណៈដូចគ្នានៃប្រតិបត្តិការដែលមានកិច្ចធានា និងប្រាតិភោគដោយអនុប្បទាន ដូចមានការពន្យល់ និងបកស្រាយខាងលើ នៅមានលក្ខណៈខុសគ្នាមួយចំនួនគួរឲ្យកត់សម្គាល់ដែលនឹងអធិប្បាយបន្តទៅទៀត។

### ២.២.២. លក្ខណៈដោយឡែក

ទោះបីជាស្ថិតនៅក្នុងប្រភេទនៃសិទ្ធិប្រាតិភោគប្រត្យក្សដូចគ្នាក៏ដោយ តែលក្ខខណ្ឌ និងការអនុវត្តមិនដូចគ្នាទាំងស្រុងនោះទេ ដោយសារតែបទប្បញ្ញត្តិច្បាប់បង្កើតប្រាតិភោគច្រើនទម្រង់ដើម្បីឲ្យភាគីអាចជ្រើសរើសមូលដ្ឋានគតិយុត្តណាដែលមានភាពងាយស្រួលជាង តាមដែលចិត្តចង់តែគោរពលក្ខខណ្ឌផ្សេងៗដើម្បីមានអានុភាពតាមផ្លូវច្បាប់។

#### ២.២.២.១. លក្ខខណ្ឌនៃការបង្កើត

##### ក. ការបង្កើតប្រាតិភោគដោយអនុប្បទាន

ប្រាតិភោគដោយអនុប្បទាន គឺជាឧបករណ៍ថ្មីមួយដែលអនុញ្ញាតឲ្យអ្នកបង្កើតសិទ្ធិប្រាតិភោគបន្តការកាន់កាប់ និងអាចប្រើប្រាស់ចលនវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគ តាមទម្រង់នៃការផ្ទេរកម្មសិទ្ធិ។[113] នេះជាបញ្ញត្តិបង្កើតឡើងដើម្បីដោះស្រាយនូវផលវិបាកតាមរូបភាពនៃសិទ្ធិលើការបញ្ចាំដែលតម្រូវឲ្យអ្នកបង្កើតសិទ្ធិលើការបញ្ចាំ ធ្វើការប្រគល់វត្ថុបញ្ចាំឲ្យម្ចាស់សិទ្ធិនៃការបញ្ចាំ ដោយមិនត្រូវបានអនុញ្ញាតឲ្យអ្នកបង្កើតសិទ្ធិលើការបញ្ចាំ នៅបន្តការកាន់កាប់ចលនវត្ថុនោះឡើយ។[114]

---

[112] មាត្រា ៥២ នៃប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

[113] មាត្រា ៨៨៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[114] មាត្រា ៨១៨ និង ៨១៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ចំណែកឯការបង្កើតវិញ សិទ្ធិប្រាតិភោគដោយអនុប្បទានគ្រាន់តែធ្វើឡើងតាមការព្រមព្រៀងរបស់ភាគីតែប៉ុណ្ណោះ ដោយឯកសារជាលាយលក្ខណ៍អក្សរមិនត្រូវបានទាមទារនោះទេ។[115] យោងតាមមាត្រា៨៨៨ នៃក្រមរដ្ឋប្បវេណីកំណត់ថា *"ប្រាតិភោគដោយអនុប្បទាន សំដៅទៅលើការណ៍ដែលកូនបំណុល ឬ តតិយជនធ្វើអនុប្បទាន*[116]*នូវចលនវត្ថុរបស់ខ្លួនជាកំណាត់ទៅឲ្យម្ចាស់បំណុលដើម្បីធានាកាតព្វកិច្ច"*។ ដោយឈរលើបញ្ញត្តិនេះនាំឲ្យបកស្រាយបានថា ភាគីអាចធ្វើការព្រមព្រៀងក្នុងការផ្ទេរ ឬ មិនផ្ទេរកម្មសិទ្ធិនូវកម្មវត្ថុនៃប្រាតិភោគ។

គួរកត់សម្គាល់ផងដែរថា អ្នកបង្កើតប្រាតិភោគដោយអនុប្បទានអាចធ្វើការផ្ទេរកម្មសិទ្ធិនូវចលនវត្ថុរបស់ខ្លួនជាកំណាត់ ទៅម្ចាស់សិទ្ធិលើប្រាតិភោគ។[117] ប៉ុន្តែវាមិនមែនជាការផ្ទេរកម្មសិទ្ធិលើទ្រព្យធានាទាំងស្រុងទេ ដោយគេធ្វើការផ្ទេរតែសិទ្ធិមួយពិសេសដែលគេហៅថា "សិទ្ធិប្រាតិភោគ" ក្នុងគោលបំណងធានាកាតព្វកិច្ចតែប៉ុណ្ណោះ។ គេអាចនិយាយបានថា កម្មសិទ្ធិនៃវត្ថុគឺផ្នែកខ្លះត្រូវបន្តការកាន់កាប់ដោយអ្នកបង្កើតប្រាតិភោគ ហើយផ្នែកខ្លះត្រូវបានផ្ទេរទៅឲ្យអ្នកមានសិទ្ធិប្រាតិភោគ។ ការបកស្រាយបែបនេះ គឺឈរលើកថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃមាត្រា៨៨៨ ដែលបញ្ញត្តថា បើកាតព្វកិច្ចត្រូវបានសងដោយអ្នកបង្កើតសិទ្ធិប្រាតិភោគរួចហើយ *"កម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុត្រូវផ្ទេរទៅអ្នកបង្កើត"*។

តាមរយៈកិច្ចព្រមព្រៀងរវាងភាគី ទ្រព្យធានាអាចត្រូវបានកាន់កាប់ដោយអ្នកបង្កើតសិទ្ធិប្រាតិភោគ ម្ចាស់សិទ្ធិប្រាតិភោគ តតិយជនដែលបានទទួលការបញ្ជាពីអ្នកបង្កើតសិទ្ធិប្រាតិភោគ ឬ អាចជាតតិយជនដែលទទួលបានការបញ្ជាពីម្ចាស់សិទ្ធិប្រាតិភោគ។ ម្យ៉ាងវិញទៀត រូបភាពនៃការបង្កើតកិច្ចព្រមព្រៀងផ្ទេរកម្មសិទ្ធិនេះកើតឡើងក្នុងរូបភាពពីរសំខាន់ គឺទីមួយ អាចជាកិច្ចព្រមព្រៀងផ្ទេរកម្មសិទ្ធិ តាមរយៈការផ្ទេរការកាន់កាប់ដោយផ្ទាល់ទៅម្ចាស់សិទ្ធិប្រាតិភោគ និងទីពីរ ក្នុងរូបភាពជាកិច្ចព្រមព្រៀងផ្ទេរកម្មសិទ្ធិ តាមរយៈការផ្ទេរកាន់កាប់ដោយការព្រមព្រៀង គឺជាការផ្ទេរការកាន់កាប់ដោយប្រយោល (ម្ចាស់សិទ្ធិប្រាតិភោគកាន់កាប់ដោយប្រយោល រីឯអ្នកបង្កើតសិទ្ធិកាន់កាប់ដោយចំពោះ)។

---

[115] មាត្រា ៨៨៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[116] យោងតាមសន្ទានុក្រមផ្នែករដ្ឋប្បវេណី *អនុប្បទាន*៖ គឺជាការផ្ទេរសិទ្ធិ ឬទ្រព្យសម្បត្តិរបស់បុគ្គលណាម្នាក់ ដែលជាអនុប្បទាយីទៅឲ្យបុគ្គលម្នាក់ទៀតដែលជាអនុប្បទានិក។

[117] មាត្រា ៨៨៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

### ខ. ការបង្កើតប្រតិបត្តិការដែលមានកិច្ចធានា

ខុសពីលក្ខខណ្ឌនៃការបង្កើតប្រាតិភោគដោយអនុប្បទាន ការបង្កើតប្រាតិភោគយោងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ត្រូវធ្វើជាកំណត់ត្រាលាយលក្ខណ៍អក្សររវាងកូនបំណុល និងម្ចាស់បំណុលដែលផ្ទេរសិទ្ធិប្រាតិភោគលើទ្រព្យធានាពីកូនបំណុលឲ្យទៅម្ចាស់បំណុល។ កិច្ចព្រមព្រៀងប្រាតិភោគនេះត្រូវអធិប្បាយពីទ្រព្យធានា ហើយវាមិនអាចជាកិច្ចព្រមព្រៀងប្រាតិភោគដែលធ្វើដោយផ្ទាល់មាត់នោះទេ ហេតុដូច្នេះហើយ អាចនិយាយបានថាលក្ខខណ្ឌដែលកំណត់ថាត្រូវធ្វើជាលាយលក្ខណ៍អក្សរនេះ គឺជាលក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាដែលច្បាប់តម្រូវ។

លើសពីនេះ មានភាពចាំបាច់ត្រូវមានលក្ខខណ្ឌ៣សំខាន់ទៀត ដើម្បីបង្កើតនូវប្រសិទ្ធភាព។[118] លក្ខខណ្ឌទី១ គឺភាគីត្រូវបង្កើតកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ ហើយកូនបំណុលដែលមានកិច្ចធានាត្រូវចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ។ លក្ខខណ្ឌទី២ គឺម្ចាស់បំណុលត្រូវផ្តល់តម្លៃឲ្យទៅកូនបំណុល ដាក់ចងនូវកាតព្វកិច្ចរបស់កូនបំណុលដែលមានកិច្ចធានាត្រូវដាក់ប្រាតិភោគរបស់ខ្លួនហើយតម្លៃនេះអាចជាកាតព្វកិច្ចអ្វីមួយ ឬ ជាប្រាក់។ លក្ខខណ្ឌចុងក្រោយ គឺកូនបំណុលត្រូវមានសិទ្ធិលើទ្រព្យធានា ឬ អំណាចផ្ទេរសិទ្ធិលើទ្រព្យធានាឲ្យទៅម្ចាស់បំណុល។[119] បើកាលណាលក្ខខណ្ឌទាំងអស់នេះបានបំពេញ ទើបកិច្ចព្រមព្រៀងប្រាតិភោគមានប្រសិទ្ធិភាពអាចអនុវត្តបាន។

#### ២.២.២.២. អត្ថិភាពនូវសិទ្ធិតតាំងផ្សេងគ្នា

### ក. សិទ្ធិតតាំងរបស់ប្រតិបត្តិការដែលមានកិច្ចធានា

ដើម្បីម្ចាស់បំណុលទទួលបាននូវសិទ្ធិតតាំង ចាំបាច់ត្រូវធ្វើសុក្រឹតកម្ម ដោយការតម្កល់លិខិតជូនដំណឹង។[120] ការតម្កល់លិខិតជូនដំណឹងអាចធ្វើទៅលើ ទំនិញ លិខិតស្នាម ឬ ឯកសារ។ ម្ចាស់បំណុលនៃកិច្ចធានា អាចធ្វើការកាន់កាប់ទ្រព្យធានាក៏បាន ដោយមិនចាំបាច់តម្កល់លិខិតជូនដំណឹង ព្រោះនេះក៏ជាការធ្វើសុក្រឹតកម្មផងដែរ។ ប៉ុន្តែត្រូវចាំថា អានុភាពរវាងការកាន់កាប់ និងការតម្កល់លិខិតជូនដំណឹង គឺការតម្កល់លិខិតជូនដំណឹងមានសុក្រឹតភាពជាង។ ចំណែកឯសិទ្ធិប្រាតិភោគលើប្រាក់ខ្ចីទិញទំនិញប្រើប្រាស់វិញ គឺមានសុក្រឹតកម្មដោយស្វ័យប្រវត្តិ ដោយមិនចាំបាច់តម្កល់លិខិតជូនដំណឹងនោះទេ តែបើមានការតម្កល់លិខិតជូនដំណឹងទៀតកាន់តែប្រសើរ និងអាចតតាំងនឹងតតិយជនកាន់តែមានប្រសិទ្ធិភាព។

---

118 មាត្រា ៩ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

119 មាត្រា ៩ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

120 មាត្រា ១២(៣), (៤) នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

## ខ. សិទ្ធិតតាំងរបស់ប្រាតិភោគដោយអនុប្បទាន

ដើម្បីទទួលបានអានុភាពតតាំងគឺ ម្ចាស់សិទ្ធិប្រាតិភោគត្រូវទទួលបានកាន់កាប់ ចំពោះវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគ បើមិនដូច្នោះទេម្ចាស់បំណុលមិនអាចតតាំងនឹងតតិយជនបាននោះទេ។[121] យោងតាមក្រមរដ្ឋប្បវេណី ការផ្ទេរការកាន់កាប់នូវកម្មវត្ថុប្រាតិភោគ ដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានអាចធ្វើបានតាមវិធីណាមួយដូចខាងក្រោម៖

- ***វិធីទី១៖*** ការប្រគល់ដោយជាក់ស្តែង គឺជាការផ្ទេរតាមរយៈការប្រគល់វត្ថុកាន់កាប់។
- ***វិធីទី២៖*** ការប្តូរលក្ខណៈនៃការកាន់កាប់ សំដៅទៅលើការកាន់កាប់ដែលអាចធ្វើការផ្ទេរតាមការព្រមព្រៀងរបស់ភាគី ដោយមិនចាំបាច់ធ្វើការប្រគល់ជាក់ស្តែងនោះទេ។ ឧទាហរណ៍៖ លោក **ក** បានទិញរថយន្តពី **ខ** បន្ទាប់ពីចុះកិច្ចសន្យាលក់ទិញរួចលោក **ខ** ចង់ជួលរថយន្តពី **ក** ដូចនេះលោក **ក** ជាអ្នកកាន់កាប់ដោយប្រយោល ចំណែកលោក **ខ** ជាអ្នកកាន់កាប់ដោយផ្ទាល់។ បើមើលទៅហាក់ដូចជាការកាន់កាប់មិនបានផ្ទេរទេ តែជាក់ស្តែងការកាន់កាប់ត្រូវបានផ្ទេរតាមការព្រមព្រៀងពីលោក **ខ** ទៅលោក **ក**។ មើលទៅរូបភាពនេះលោក **ក** មិនទាន់បានកាន់កាប់ដោយចំពោះម្តងណាទេ។
- ***វិធីទី៣៖*** ការប្រគល់ដោយសង្ខេប គឺជាការផ្ទេរការកាន់កាប់តាមរយៈការព្រមព្រៀងរបស់ភាគី ក្នុងករណីដែលអនុប្បទានិកបានក្តាប់ទុកវត្ថុដែលជាកម្មវត្ថុនៃការកាន់កាប់ នោះនៅក្នុងដៃតាមការជាក់ស្តែង ហើយអនុប្បទាយីបានបាត់បង់ការកាន់កាប់ដោយប្រយោលរបស់ខ្លួនធ្លាប់មាន។ ឧទាហរណ៍៖ លោក សុខ ជួលរថយន្តពីលោក សុធី តែក្រោយមកលោក សុខ បានទិញរថយន្តពីលោក សុធី។ ក្នុងករណីនេះលោក សុធី បានបាត់បង់ការកាន់កាប់ដោយប្រយោលដែលខ្លួនធ្លាប់មាន ព្រោះលោក សុធី បានបាត់បង់ការកាន់កាប់លើវត្ថុដោយចំពោះតាំងពីដើមមកម្ល៉េះដោយសារតែកិច្ចសន្យាជួល លុះដល់ពេលកិច្ចសន្យាលក់ទិញកើតឡើងលោក សុធី មិនមានវត្ថុដែលត្រូវប្រគល់ឲ្យលោក សុខ ទេ ព្រោះវត្ថុនៅនឹងដៃលោក សុខ ស្រាប់ទៅហើយ នេះជាការរូបភាពនៃប្រគល់ដោយសង្ខេប។
- ***វិធីទី៤៖*** ការផ្ទេរកាន់កាប់ដោយការបញ្ជា សំដៅលើម្ចាស់សិទ្ធិដែលកាន់កាប់ដោយប្រយោលលើវត្ថុ បានបង្កើតកិច្ចព្រមព្រៀងថា ផ្ទេរការកាន់កាប់ទៅតតិយជន ហើយក្នុងករណីនេះម្ចាស់សិទ្ធិមានករណីយកិច្ចជូនដំណឹងអំពីហេតុនោះ ទៅអ្នកកាន់កាប់ដោយចំពោះលើវត្ថុនោះដើម្បីគាត់ធ្វើការផ្ទេរទៅតតិយជន។ ឧទាហរណ៍៖ លោក **ក** ជួលផ្ទះឲ្យលោក **ខ** ហើយកំឡុងពេលជួល

[121] មាត្រា ៨៩០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

នេះលោក **ក** បានលក់ផ្ទះនេះទៅលោក **គ** ដែលជាតតិយជន។ ដូចនេះលោក **ក** មានករណីយកិច្ចជូនដំណឹងទៅលោក **ខ** ដើម្បីឲ្យដឹងថាលោក **គ** កំពុងកាន់កាប់ដោយចំពោះលើទ្រព្យរបស់លោក **ខ** តាមរយៈអត្ថិភាពនៃកិច្ចសន្យាជួលដែលបានបង្កើត។

### ២.២.២.៣. ការចាត់ចែងកម្មវត្ថុនៃប្រាតិភោគ

#### ក. ការចាត់ចែងតាមរបបគតិយុត្តនៃប្រាតិភោគដោយអនុប្បទាន

ដោយហេតុថាប្រាតិភោគដោយអនុប្បទាន ផ្តល់នូវលទ្ធភាពប្រគល់ការកាន់កាប់ដោយចំពោះ ឬ អាចគ្រាន់តែផ្ទេរការកាន់កាប់ដោយការព្រមព្រៀង ដូចនេះហើយវាអាចនឹងមានករណីដែលម្ចាស់សិទ្ធិប្រាតិភោគ ឬ អ្នកបង្កើតសិទ្ធិប្រាតិភោគ ឬក៏អ្នកធានាដោយវត្ថុធ្វើការចាត់ចែងនូវវត្ថុដែលជាកម្មវត្ថុប្រាតិភោគ។

ការចាត់ចែងអាចនឹងកើតមានលើចលនវត្ថុរូបិយ ឬចលនវត្ថុដែលផ្គុំគ្នាដែលជាកម្មវត្ថុនៃការដាក់ប្រាតិភោគដោយអនុប្បទាន។ ចំពោះចលនវត្ថុ បើការចាត់ចែងត្រូវបានធ្វើឡើង ហើយបុគ្គលដែលធ្វើលទ្ធកម្មលើវត្ថុនេះជាបុគ្គលសុចរិត និងគ្មានកំហុសក្នុងការដឹង ដូចនេះតតិយជនដែលធ្វើលទ្ធកម្មនេះអាចលើកឡើងនូវលក្ខខណ្ឌតតាំងនឹងម្ចាស់សិទ្ធិប្រាតិភោគបាន។[122] ផ្ទុយទៅវិញ បើមានការចាត់ចែងទៅលើចលនវត្ថុផ្គុំគ្នា ទោះជាតតិយជនដឹង ឬ មិនដឹងពីអត្ថិភាពនៃសិទ្ធិប្រាតិភោគក៏ដោយ តតិយជននោះនៅតែអាចធ្វើលទ្ធកម្មលើចលនវត្ថុផ្គុំគ្នាបាន[123] ដែលមានន័យថាសិទ្ធិរបស់ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានត្រូវរលត់ ព្រោះទំនិញត្រូវបានគេលក់ទៅបាត់ វានឹងលែងជាចលនវត្ថុផ្គុំគ្នាទៀតហើយ។

#### ខ. ការចាត់ចែងតាមរបបគតិយុត្តនៃប្រតិបត្តិការដែលមានកិច្ចធានា

ចំណែកឯប្រតិបត្តិការដែលមានកិច្ចធានា មិនបានធ្វើការបែងចែកការចាត់ចែងចលនវត្ថុរូបិយ ឬ ចលនវត្ថុផ្គុំគ្នានោះទេ ដោយសារការចាត់ចែងក្នុងស្ថានភាពលក់ ការផ្តល់អាជ្ញាប័ណ្ណ ឬការដូរជាអាទិ៍ ជាគោលការណ៍ សុទ្ធតែត្រូវបានបន្តជាប់នូវសិទ្ធិប្រាតិភោគ លុះត្រាតែភាគីអាចព្រមព្រៀងគ្នាផ្ទុយពីនេះ។[124] ក៏ប៉ុន្តែ មានអញ្ញត្រកម្មមួយចំនួនដូចខាងក្រោម៖

[122] មាត្រា ៨៨៨(១) នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[123] មាត្រា ៨៨៨(២) នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[124] មាត្រា ១៧ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

- **ករណីទ្រព្យធានាធម្មតា ឬទ្រព្យរូបិយ៖** បើបុគ្គលនោះទទួលទិញទ្រព្យធានា និងបានផ្តល់តម្លៃមុនពេលដែលសិទ្ធិប្រាតិភោគមានសុក្រឹតភាព បុគ្គលនោះនឹងទទួលបានទ្រព្យនោះដោយគ្មានជាប់សិទ្ធិប្រាតិភោគ។[125]
- **ករណីអ្នកទិញទំនិញប្រើប្រាស់៖** មិនគិតពីទំនិញនោះមាន ឬ គ្មានសុក្រឹតភាពនោះទេ បើអ្នកទិញមិនបានដឹងថាមានជាប់សិទ្ធិប្រាតិភោគ នៅមុនពេលមានការតម្កល់លិខិតជូនដំណឹង ជននោះនឹងទទួលបានទំនិញប្រើប្រាស់ដោយមិនមានជាប់សិទ្ធិប្រាតិភោគ។[126]
- **ករណីអ្នកទិញក្នុងអាជីវកម្មធម្មតា៖** អ្នកទិញត្រូវទទួលកម្មសិទ្ធិដោយគ្មានជាប់សិទ្ធិប្រាតិភោគលើទំនិញនោះ ទោះបីសិទ្ធិប្រាតិភោគត្រូវបានភ្ជាប់ទៅនឹងទ្រព្យធានាហើយក៏ដោយ និងទោះជាខ្លួនបានដឹងពីអត្ថិភាពនោះក៏ដោយ។[127]
- **ករណីអ្នកទិញយានយន្តដែលមានលេខស៊េរី៖** អ្នកទិញនោះត្រូវទទួលយានយន្តមានលេខស៊េរីដោយគ្មានជាប់សិទ្ធិប្រាតិភោគ បើអ្នកទិញមិនបានដឹងថាមានសិទ្ធិប្រាតិភោគ និងលិខិតជូនដំណឹងដែលតម្កល់នោះមិនបានពិពណ៌នាពីយានយន្តមានលេខស៊េរី ឬ ក៏ចុះលេខមិនបានត្រឹមត្រូវ។[128]
- **ករណីការទិញកសិផល៖** អ្នកទិញដែលបានទិញកសិផលដែលជាប់សិទ្ធិប្រាតិភោគ ក្នុងគោលបំណងយកទៅប្រើជាទំនិញប្រើប្រាស់ ដោយមិនបានដឹងថាមានសិទ្ធិប្រាតិភោគ និងមុនពេលសិទ្ធិប្រាតិភោគមានសុក្រឹតភាព នោះអ្នកទិញកសិផលនោះមិនជាប់សិទ្ធិប្រាតិភោគនោះទេ។[129]

### ២.២.២.៤. សិទ្ធិ និងដំណោះស្រាយរបស់ម្ចាស់សិទ្ធិករណីមិនអនុវត្តកាតព្វកិច្ច

### ក. ការអនុវត្តសិទ្ធិរបស់ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន

ក្នុងរបបប្រាតិភោគដោយអនុប្បទាន អាចមានករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានជាអ្នកកាន់កាប់ទ្រព្យធានា ឬ អាចជាអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានធ្វើការកាន់កាប់ទ្រព្យធានា ដូចនេះចាំបាច់ត្រូវបែងចែកការអនុវត្តសិទ្ធិប្រាតិភោគជាពីរករណីដូចខាងក្រោម៖

---

[125] មាត្រា ១៩(១) នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

[126] មាត្រា ១៩(៣) នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

[127] មាត្រា ១៩(២) នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

[128] មាត្រា ១៩(៤) នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

[129] មាត្រា ១៩(៥) នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

*ករណីទី១៖ វត្ថុស្ថិតនៅក្រោមការកាន់កាប់របស់ម្ចាស់សិទ្ធិប្រាតិភោគ ឬតតិយជនដែលទទួលការបញ្ជា*

នៅពេលដែលកំណត់សងបានមកដល់ បើសិនជាកាតព្វកិច្ចពុំត្រូវបានអនុវត្ត ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានតម្រូវឲ្យជូនដំណឹងទៅអ្នកបង្កើតសិទ្ធិប្រាតិភោគជាមុន បន្ទាប់មកទើបអនុវត្តសិទ្ធិរបស់ខ្លួនដោយការប្តូរវត្ថុដែលជាកម្មវត្ថុនោះជាប្រាក់ដោយផ្ទាល់ខ្លួន តាមរយៈការលក់ជាអាទិ៍ ឬ ធ្វើលទ្ធកម្មកម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនៃការដាក់ធានាកាតព្វកិច្ចជាស្ថាពរបាន។[130] បើតម្លៃនៃវត្ថុ ដែលជាកម្មវត្ថុមានចំនួនលើសពីចំនួនទឹកប្រាក់នៃកាតព្វកិច្ចដែលត្រូវសងម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន នោះម្ចាស់សិទ្ធិត្រូវបង់ចំនួនទឹកប្រាក់ដែលលើសនោះទៅឲ្យកូនបំណុលដោយចាត់ទុកជាប្រាក់ជម្រះ។[131]

*ករណីទី២ ៖ វត្ថុស្ថិតនៅដៃអ្នកបង្កើតសិទ្ធិប្រាតិភោគ ឬ តតិយជនដែលទទួលការបញ្ជា*

បើកូនបំណុលខកខានក្នុងការសងកាតព្វកិច្ច ជាដំបូងម្ចាស់សិទ្ធិប្រាតិភោគត្រូវទាមទារជននោះប្រគល់វត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគជាមុនសិន ហើយទើបអាចចាត់ចែងប្តូរវត្ថុដែលជាកម្មវត្ថុនោះជាប្រាក់ដោយផ្ទាល់ខ្លួន ឬ ធ្វើលទ្ធកម្មកម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុប្រាតិភោគជាស្ថាពរបានតាមធម្មតា។[132] បើតម្លៃនៃវត្ថុដែលជាកម្មវត្ថុមានចំនួនលើសពីចំនួនទឹកប្រាក់នៃកាតព្វកិច្ចដែលត្រូវសងម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន នោះម្ចាស់សិទ្ធិត្រូវបង់ចំនួនប្រាក់ដែលលើសនោះទៅឲ្យកូនបំណុលដោយចាត់ទុកជាប្រាក់ជម្រះ ដើម្បីជៀសវាងនូវការចំណេញហួសហេតុទៅលើអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន។[133]

### ខ. ការអនុវត្តសិទ្ធិរបស់ម្ចាស់បំណុលដែលមានកិច្ចធានា

ពាក់ព័ន្ធនឹងទ្រព្យអរូបិយ ម្ចាស់បំណុលអនុវត្តតែម្តងដោយមិនចាំបាច់ប្តឹងទៅតុលាការនោះទេ ហើយបើទ្រព្យធានាជាឯកសារ ម្ចាស់បំណុលដែលមានកិច្ចធានាអាចប្រើសិទ្ធិលើឯកសារ ឬ ចំពោះទំនិញដែលបានចែងក្នុងឯកសារនេះ ដោយមិនចាំបាច់ទៅតុលាការទេ។[134] ប៉ុន្តែក្រៅពីករណីនេះ ម្ចាស់បំណុលនៃកិច្ចធានាមានសិទ្ធិប្តឹងសុំសេចក្តីសម្រេចកិច្ចការប្រញាប់ ឬ ការបញ្ជា

[130] មាត្រា ៨៩៨ (១)នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[131] មាត្រា ៨៩៨ (៣) នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[132] មាត្រា ៨៩៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[133] មាត្រា ៨៩៨ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[134] មាត្រា ៥៦(៥) នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

ពិសេសពីតុលាការដើម្បីធ្វើការកាន់កាប់ និងគ្រប់គ្រងទ្រព្យធានា។[135] តែអនុលោមតាមមាត្រា៥៨ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាបានកំណត់ថា ពាក់ព័ន្ធនឹងសវនាការត្រូវផ្តោតតែលើបញ្ហាដែលពាក់ព័ន្ធ និងកិច្ចព្រមព្រៀងប្រាតិភោគដែលកំណត់ពីទ្រព្យធានាតែប៉ុណ្ណោះ លើសពីនេះ ទាល់តែមានការខកខានមិនបានសងបំណុល យ៉ាងតិចមួយលើករបស់កូនបំណុលទើបតុលាការ អាចចេញដីកាដែលម្ចាស់បំណុលដែលទាមទារបាន។ ការអនុវត្តនេះ គឺហាក់ដូចជាការប្រើប្រាស់នីតិវិធីរក្សាការពារ ក្នុងការគ្រប់គ្រង និងថែរក្សាវត្ថុធានា មុននឹងធ្វើការចាត់ចែង។ ចំណែកឯរូបភាពនៃនីតិវិធីនៃការអនុវត្តដោយបង្ខំមិនត្រូវបានប្រើប្រាស់នោះទេ ព្រោះក្នុងរបបកិច្ចប្រតិបត្តិការដែលមានកិច្ចធានា ម្ចាស់បំណុលជាអ្នកគ្រប់គ្រងទ្រព្យធានា និងធ្វើការចាត់ចែងតែម្តង ដោយមិនចាំបាច់អាជ្ញាធរមានសមត្ថកិច្ចជាអ្នកអនុវត្តនោះទេ។

ការចាត់ចែងបែបណាក៏ដោយ ម្ចាស់បំណុលដែលមានកិច្ចធានា ត្រូវប្រគល់ទឹកប្រាក់ដែលជាផលនៃការជម្រះទ្រព្យធានាដែលលើសទៅឲ្យកូនបំណុល ហើយកូនបំណុលវិញ ក៏ត្រូវមានទំនួលខុសត្រូវសងនូវទឹកប្រាក់ដែលខ្វះផងដែរ លើកលែងតែមានការព្រមព្រៀងផ្សេង។[136] ច្បាប់ស្តីប្រតិបត្តិការដែលមានកិច្ចធានា មិនអនុញ្ញាតឲ្យម្ចាស់បំណុលមានសិទ្ធិធ្វើជាម្ចាស់កម្មសិទ្ធិលើទ្រព្យធានាដើម្បីកាត់កងសិទ្ធិលើបំណុលដូចការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន ហើយដោយមិនឆ្លងកាត់ផ្លូវតុលាការទាល់តែសោះនោះទេ។

*(សូមមើលឧបសម្ព័ន្ធទី ១ តារាងប្រៀបធៀប)*

## ២.៣. ការអនុវត្តបញ្ញត្តិរួម និងការសម្របសម្រួលការអនុវត្តប្រាតិភោគចលនវត្ថុ រវាងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា និង ក្រមរដ្ឋប្បវេណី

ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីនៅឆ្នាំ២០១១ បានបញ្ញត្តជាពិសេសនូវមធ្យោបាយក្នុងការអនុវត្តជាក់ស្តែងនៅត្រង់ជំពូកទី៦ ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ដើម្បីធ្វើការកំណត់ពីអានុភាពអនុវត្តនៃប្រតិបត្តិការប្រាតិភោគចលនវត្ថុមុន និងក្រោយចូលជាធរមាននៃក្រមរដ្ឋប្បវេណី ក៏ដូចជាការទទួលស្គាល់នូវប្រតិបត្តិការដែលធ្វើនៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត ជៀសវាងការធ្វើវិសោធនកម្មច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា។ លើសពីនេះ នីតិករចង់សម្របសម្រួលនូវភាពមិនព្រមព្រៀងគ្នា រវាងប្រតិបត្តិការដែលត្រូវបានធ្វើឡើងនៅក្រោមរបបគតិយុត្តក្រមរដ្ឋប្បវេណីផង និងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាផង។

---

[135] មាត្រា ៥៦(៦) & ៥៨(២) នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

[136] មាត្រា ៥០(២) នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

ចំណែកឯបញ្ញត្តិរួមនៃការអនុវត្ត ចង្អុលបង្ហាញពីការអនុវត្តនូវបញ្ញត្តិដូចគ្នាទោះជាប្រតិបត្តិការនៃប្រាតិភោគបង្កើតឡើងដោយយោងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ឬក្រមរដ្ឋប្បវេណីក៏ដោយ។ ភាគច្រើននៃបញ្ញត្តិរួម គឺបង្កើតឡើងដើម្បីការពារតតិយជនដែលជាជនសុចរិត និងការពារបុគ្គលសុចរិតដែលសំដៅទៅលើម្ចាស់សិទ្ធិប្រាតិភោគផងដែរ ព្រោះបើមិនកំណត់ដូច្នេះទេសកម្មភាពសេដ្ឋកិច្ចនឹងត្រូវបានបង្អង់ ដោយសារតែសកម្មភាពលក់ទិញ ដោះដូរជាអាទិ៍ ត្រូវបានបង្អាក់ដំណើរការបណ្តាលមកពីភាពភ័យខ្លាចរបស់តតិយជន ក្នុងការធ្វើលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុ ដែលនេះនឹងបង្កជាផលពិបាកសម្រាប់សកម្មភាពអាជីវកម្មទាំងឡាយ។ ដូច្នេះដើម្បីបង្ការបញ្ហាលើកឡើងខាងលើនេះ ការអនុវត្តបញ្ញត្តិរួមក្នុងការពារបុគ្គលសុចរិត(**២.៣.១**) និងការសម្របសម្រួលនូវការអនុវត្តប្រាតិភោគចលនវត្ថុរវាងក្រមរដ្ឋប្បវេណី និងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា(**២.៣.២**) ត្រូវតែបង្កើតឡើងដើម្បីបង្កើតនូវដំណោះស្រាយជារួមមួយសម្រាប់យកទៅអនុវត្ត។

### ២.៣.១. ការអនុវត្តបញ្ញត្តិរួមគ្នាក្នុងការការពារបុគ្គលសុចរិត

ការចុះបញ្ជីចលនវត្ថុនៅកម្ពុជាបច្ចុប្បន្ននៅមិនទាន់បានអនុវត្តគ្រប់ប្រភេទនៃចលនវត្ថុទេ ពោលគឺមានការចុះបញ្ជីសម្រាប់តែយានយន្តតែប៉ុណ្ណោះ ហើយនៅមិនទាន់បានមួយរយភាគរយសម្រាប់ជាការជូនដំណឹងអំពីស្ថានភាពគតិយុត្តជាសាធារណៈឲ្យបានគ្រប់គ្រាន់ឡើយ។ ហេតុដូច្នេះហើយចាំបាច់ណាស់ក្នុងការបង្កើតនូវវិធានពិសេស ក្នុងករណីដែលមានទំនាក់ទំនងផលប្រយោជន៍តាមផ្លូវច្បាប់របស់ជនសុចរិត ដូចជាករណីដែលជនសុចរិតបានទិញវត្ថុដែលជាកម្មវត្ថុនៃការដាក់ប្រាតិភោគ នាពេលដែលខ្លួនមិនបានដឹងថាវត្ថុនោះ គឺជាកម្មវត្ថុនៃប្រាតិភោគ ឬ ករណីដែលជនសុចរិតនោះបានទទួលដាក់ប្រាតិភោគនៃវត្ថុលួច ឬ វត្ថុបាត់ជាអាទិ៍។

ទោះជាយ៉ាងណាក៏ដោយ លទ្ធកម្មកម្មសិទ្ធិនូវចលនវត្ថុដោយសុចរិត និងការធ្វើអនុប្បទានវត្ថុលួច ឬ វត្ថុបាត់តាមក្រមរដ្ឋប្បវេណីនោះ ត្រូវបានអនុញ្ញាតដើម្បីការពារបុគ្គលសុចរិត។ ការកំណត់បែបនេះ ចង់ចង្អុលពីការការពារអនុប្បទានិកដែលទទួលកម្មវត្ថុពីបុគ្គលដែលគ្មានសិទ្ធិ។ មួយវិញទៀត ក្នុងករណីដែលប្រតិបត្តិការដែលត្រូវបានធ្វើឡើងដោយយោងតាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា និងប្រតិបត្តិការដែលបានធ្វើឡើងដោយយោងតាមក្រមរដ្ឋប្បវេណីត្រូវបានបង្កើតឡើងលើចលនវត្ថុតែមួយ ទោះជាប្រតិបត្តិការមុនមិនទាន់បានទទួលលក្ខខណ្ឌតតាំងនៅពេលប្រតិបត្តិការក្រោយបង្កើតឡើងក្តី បើសិនជាក្រោយមកទៀត ប្រតិបត្តិការមុនទើបតែទទួលបាននូវលក្ខខណ្ឌតតាំងមុនប្រតិបត្តិការក្រោយ នេះមិនមែនមានន័យថាប្រតិបត្តិការក្រោយជា

ការធ្វើលទ្ធកម្មពីបុគ្គលដែលគ្មានសិទ្ធិនោះទេ និងមិនមែនមានន័យថាការការពារបុគ្គលសុចរិតក្នុងករណីនេះមិនអាចអនុវត្តនោះដែរ។[137]

### ២.៣.១.១. អានុភាពតាមនៃសិទ្ធិប្រាតិភោគប្រត្យក្ស និងលទ្ធកម្មដោយសុចរិត

បញ្ញត្តិរួមតាមក្រមរដ្ឋប្បវេណីស្តីពីអានុភាពតាមនៃសិទ្ធិប្រាតិភោគប្រត្យក្ស ត្រូវបានយកអនុវត្តទៅលើសិទ្ធិប្រាតិភោគ ដោយគោលការណ៍នេះបានលើកឡើងថា ទោះបីជាវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគប្រត្យក្សត្រូវបានផ្ទេរក៏ដោយ ក៏សិទ្ធិប្រាតិភោគប្រត្យក្សនោះនៅតែមានអានុភាពចំពោះវត្ថុនោះ ទោះជានៅលើដៃអ្នកណាក៏ដោយ។[138] ក្នុងនោះដែរយើងសង្កេតឃើញ មាត្រា១៧ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាក៏បានទទួលស្គាល់គោលការណ៍នេះដែរ ដោយបញ្ញត្តថាសិទ្ធិប្រាតិភោគដែលភ្ជាប់នឹងទ្រព្យធានានៅតែមានអានុភាព ទោះបីជាមានការលក់ ការជួល ឬការដូរ តែបើភាគីព្រមព្រៀងគ្នាថាសិទ្ធិប្រាតិភោគនេះមិនមានអនុភាពតាមទេ នោះការព្រមព្រៀងបែបនេះគឺទទួលស្គាល់។ ទោះជាយ៉ាងណាក៏ដោយ អនុភាពតាមនេះបង្កើតឡើងដើម្បីប្រឆាំងនឹងបុគ្គលទុច្ចរិត ដែលបានធ្វើលទ្ធកម្មលើកម្មវត្ថុនៃការដាក់ធានាដោយទុច្ចរិត ក្នុងស្ថានភាពដែលគាត់បានដឹងថាទ្រព្យធានាមានជាប់នូវសិទ្ធិប្រាតិភោគ និងនៅក្រោយពេលដែលសិទ្ធិប្រាតិភោគបានធ្វើសុក្រឹតកម្ម។[139]

តែបើមើលទៅរូបភាពម្ខាងទៀត តាមនិយមន័យក្រមរដ្ឋប្បវេណី *"បុគ្គលដែលបានធ្វើលទ្ធកម្មនូវវត្ថុនៃសិទ្ធិប្រាតិភោគប្រត្យក្សដែលបង្កើតដោយកូនបំណុល ដើម្បីធានាកាតព្វកិច្ចរបស់ខ្លួនត្រូវហៅថា* ***តតិយជនដែលបានធ្វើលទ្ធកម្ម***"។[140] ឃ្លានេះបង្ហាញថាមានករណីតតិយជនដែលបានធ្វើលទ្ធកម្មនូវទ្រព្យដែលត្រូវបានបង្កើតសិទ្ធិប្រាតិភោគ ដែលទ្រព្យនេះជាទ្រព្យរបស់កូនបំណុលបានដាក់ប្រាតិភោគដើម្បីធានាកាតព្វកិច្ចរបស់ខ្លួន ប៉ុន្តែបែរជាម្ចាស់សិទ្ធិប្រាតិភោគប្រត្យក្ស បានធ្វើអនុប្បទានវត្ថុធានានោះ ទៅឲ្យតតិយជនទៅវិញ។ សំណួរនឹងកើតឡើងថា តើច្បាប់ត្រូវការពារតតិយជនដែលបានធ្វើលទ្ធកម្មនោះតាមរបៀបណា?

លក្ខខណ្ឌដែលតតិយជនដែលបានធ្វើលទ្ធកម្មនឹងត្រូវបានការពារ គឺយកមកអនុវត្តដូចគ្នាចំពោះស្ថានភាពតតិយជននោះបានគោរពលក្ខខណ្ឌមាត្រា១៩៣ (លទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិ

[137] មាត្រា ៧៧ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី

[138] មាត្រា ៧៧២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[139] មាត្រា ១៣(១) នៃប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

[140] មាត្រា ៧៦៦(២) នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

លើចលនវត្ថុ) តម្រូវឲ្យតតិយជនដែលបានធ្វើលទ្ធកម្មនៃវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគប្រត្យក្ស ត្រូវដែលជាជនដែលបានធ្វើលទ្ធកម្មដោយសុចរិត និងគ្មានកំហុស និងលក្ខខណ្ឌមួយទៀតគឺ ទាល់តែកម្មវត្ថុដែលបានធ្វើអនុប្បទាននោះមិនត្រូវបានបន្តការកាន់កាប់ដោយអនុប្បទាយីនោះទេ។ ឧទាហរណ៍៖ លោក **ក** បានយកចិញ្ចៀនពេជ្រទៅដាក់ប្រាតិភោគជាមួយលោក **ខ** ដើម្បីធានាសិទ្ធិលើបំណុលចំនួន១០,០០០ (មួយម៉ឺន) ដុល្លារអាមេរិក។ ប៉ុន្តែលោក **ខ** បែរជាលក់ចិញ្ចៀនពេជ្រនេះទៅឲ្យលោក **គ** ក្នុងតម្លៃ២០.០០០(ពីរម៉ឺន) ដុល្លាអាមេរិក ដោយអះអាងថាជាកម្មសិទ្ធិរបស់ខ្លួន។ ហេតុនេះបើលោក **គ** បានបំពេញលក្ខខណ្ឌស្របតាមមាត្រា១៩៣ នៃក្រមរដ្ឋប្បវេណី ច្បាប់នឹងការពារលោក **គ** បើកាលណាគាត់បានកំពុងតែកាន់កាប់ចិញ្ចៀននេះនឹងនឹងខ្លួន ហើយគាត់ជាបុគ្គលសុចរិត និងគ្មានកំហុសក្នុងការដឹងថាចិញ្ចៀននោះជាកម្មសិទ្ធិរបស់លោក **ក** ។

នៅក្រោមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ករណីទិញយានយន្តដែលមានលេខស៊េរី នោះអ្នកទិញត្រូវទទួលយានយន្តដោយជាប់សិទ្ធិប្រាតិភោគ ដោយសារតែខ្លួនមានលទ្ធភាពធ្វើការស្រាវជ្រាវពីលេខស៊េរីនៃយានយន្តនេះបញ្ជាក់នូវសិទ្ធិប្រាតិភោគ ដែលបានតម្កល់លិខិតជូនដំណឹងនៅក្នុងការិយាល័យតម្កល់ តែគាត់មានការធ្វេសប្រហែសមិនត្រួតពិនិត្យមើល ដូចនេះសន្មតថាគាត់គឺជាជនសុចរិត ក៏ប៉ុន្តែគាត់នៅតែមានកំហុសក្នុងការមិនបានដឹង ដូចនេះច្បាប់មិនអាចការពារបុគ្គលបែបនេះបានទេ។[141] ផ្ទុយទៅវិញបើអ្នកទិញក្នុងអាជីវកម្មធម្មតាពាក់ព័ន្ធនឹងទំនិញវិញ គាត់ត្រូវទទួលបានកម្មសិទ្ធិដោយគ្មានជាប់សិទ្ធិប្រាតិភោគនោះទេ ទោះជាគាត់ដឹងថាទំនិញដែលគាត់ទិញមានជាប់សិទ្ធិប្រាតិភោគ ឬបើសិទ្ធិប្រាតិភោគនេះបានធ្វើសុក្រឹតកម្មរួចហើយក្តី។[142]

### ២.៣.១.២. អនុប្បទានសិទ្ធិលើបំណុលដែលសិទ្ធិប្រត្យក្សត្រូវបានបង្កើតដោយម្ចាស់សិទ្ធិប្រាតិភោគទៅឲ្យតតិយជន

ជាគោលការណ៍ ម្ចាស់បំណុលអាចធ្វើអនុប្បទានសិទ្ធិលើបំណុលរបស់ខ្លួនបាន តាមតម្រូវការចាំបាច់ក្រោមរូបភាពដូចជា ការលក់សិទ្ធិលើបំណុល ប្រទានកម្ម អច្ច័យទានជាដើម។ ប៉ុន្តែចំពោះប្រភេទសិទ្ធិលើបំណុលមួយចំនួនមិនអនុញ្ញាតឲ្យម្ចាស់បំណុលធ្វើអនុប្បទាននោះទេ ដូចជាសិទ្ធិលើបំណុលរបស់និយោជកមានចំពោះនិយោជិតរបស់ខ្លួនជាដើម[143] ដែលត្រូវបានចាត់ចូលជាប្រភេទសិទ្ធិលើបំណុលដែលមានលក្ខណៈមិនអាចធ្វើអនុប្បទានបាន។ ចំណែកសិទ្ធិប្រាតិភោគប្រត្យក្រ

[141] មាត្រា ៥០ នៃប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

[142] មាត្រា ១៩(២) នៃប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

[143] មាត្រា ៥០១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ក៏ដូចគ្នា ព្រោះសិទ្ធិនេះកើតចេញពីសិទ្ធិលើបំណុល ដូចនេះវាអាចធ្វើអនុប្បទានបានតាមធម្មជាតិរបស់សិទ្ធិប្រត្យក្ស។ យើងដឹងហើយថាកាតព្វកិច្ចចម្បង គឺជាសិទ្ធិលើបំណុលដែលត្រូវបានអនុញ្ញាតឲ្យធ្វើអនុប្បទាន ដូចនេះគ្មានអ្វីចម្លែកទេដែលកាតព្វកិច្ចបន្ទាប់បន្សំដែលស្គាល់ថាជាសិទ្ធិប្រាតិភោគប្រត្យក្សក៏អាចក្លាយជាកម្មវត្ថុនៃការធ្វើអនុប្បទានបានដែរ។ សរុបមកវិញសិទ្ធិប្រាតិភោគដែលម្ចាស់សិទ្ធិមានទៅលើអ្នកបង្កើតសិទ្ធិអាចជាកម្មវត្ថុនៃការធ្វើអនុប្បទានផងដែរ។

ករណីនេះបញ្ជាក់ពីភាពអាចធ្វើអនុប្បទានបាននូវសិទ្ធិប្រាតិភោគប្រត្យក្ស ដោយការកំណត់ពីការគោលការណ៍ទូទៅនៃសិទ្ធិប្រាតិភោគប្រត្យក្សគឺ គោលការណ៍ស្តីពីភាពទៅជាមួយគ្នានៃសិទ្ធិប្រាតិភោគប្រត្យក្ស។[144] ក៏ប៉ុន្តែប្រសិនបើ ភាគីនៃប្រាតិភោគបានធ្វើការព្រមព្រៀងគ្នាជាពិសេសជាមុនថា "មិនអនុញ្ញាតឲ្យធ្វើអនុប្បទានសិទ្ធិប្រាតិភោគប្រត្យក្សនោះទេ" នោះសិទ្ធិប្រាតិភោគប្រត្យក្សមិនអាចធ្វើអនុប្បទាននោះទេ ក៏ប៉ុន្តែការសន្យាបែបនេះ គឺមិនមានអានុភាពយកទៅតតាំងនឹងតតិយជនសុចរិត និងគ្មានកំហុសដ៏ធ្ងន់ធ្ងរនោះដែរ។[145] មិនថាប្រភេទនៃសិទ្ធិប្រាតិភោគប្រត្យក្សប្រភេទណាទេ ក្នុងចំណោមសិទ្ធិប្រាតិភោគប្រត្យក្សចលនវត្ថុទាំងបីនេះ សុទ្ធតែតម្រូវឲ្យការពារតតិយដូចគ្នា។

ឧទាហរណ៍៖ លោក A បានយករថយន្តម៉ាកលេចស៊ីសទៅដាក់ប្រាតិភោគជាមួយលោក B ដើម្បីខ្ចីប្រាក់ចំនួន២០.០០០(ពីរម៉ឺន) ដុល្លាអាមេរិក។ ក្នុងកិច្ចសន្យារវាងលោក A និងលោក B បានបញ្ជាក់ថា "មិនអនុញ្ញាតឲ្យអនុប្បទានសិទ្ធិលើបំណុលរបស់លោក B ទៅតតិយជនណាទេ"។ ប៉ុន្តែដោយសារតែលោក B ជួបវិបត្តិហិរញ្ញវត្ថុក្នុងក្រុមហ៊ុន ដូច្នេះមុនកាលកំណត់សងមកដល់លោក B បានបង្ខំចិត្តលក់សិទ្ធិលើបំណុលនេះទៅឲ្យលោក C ហើយលោក C ក៏មិនបានដឹងអំពីការសន្យាពិសេសខាងលើដែរ។ ក្នុងករណីខាងលើលោក C បានទទួលសិទ្ធិលើបំណុលដែលបង្កើតឡើងដោយសិទ្ធិប្រាតិភោគប្រត្យក្សទៅលើរថយន្តនោះ។ ហេតុនេះលោក A ដែលជាកូនបំណុលមិនអាចអះអាងចំពោះលោក C អំពីការសន្យាពិសេសរបស់ខ្លួននោះទេ។

### ២.៣.១.៣. ការធ្វើអនុប្បទាននូវវត្ថុលួច ឬវត្ថុបាត់

ករណីដែលអ្នកបង្កើតសិទ្ធិប្រាតិភោគ បានធ្វើអនុប្បទានវត្ថុលួច ឬ វត្ថុបាត់តាមរូបភាពនៃការបញ្ចាំជាមួយម្ចាស់សិទ្ធិប្រាតិភោគ អ្នកដែលត្រូវគេលួច ឬ អ្នកដែលបានធ្វើបាត់វត្ថុនោះអាចទាមទារឲ្យអនុប្បទានិកនោះសងវត្ថុនោះមកវិញក្នុងកំឡុងពេល២ឆ្នាំ គិតពីពេលដែលបាត់ ឬត្រូវ

144 មាត្រា ៧៧០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

145 មាត្រា ៥០១ កថាខណ្ឌទី៣ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

បានគេលួច។[146] ប៉ុន្តែ បើអ្នកមានសិទ្ធិដើមបានបាត់បង់នូវការកាន់កាប់កម្មវត្ថុនោះ ដោយការឆបោក ការគៃបន្លំ ឬ ការគម្រាមកំហែង ម្ចាស់វត្ថុបាត់នេះមិនមានសិទ្ធិទាមទារវត្ថុនោះមកវិញទេ។ មាត្រានេះក៏ត្រូវបានយកមកអនុវត្តក្នុងករណីការបង្កើតសិទ្ធិប្រាតិភោគប្រត្យក្សដោយយកវត្ថុលួច ឬ វត្ថុបាត់ទៅដាក់ដើម្បីធានាកាតព្វកិច្ចផងដែរ។ បើសិនជាម្ចាស់សិទ្ធិមានភ័ស្តុតាងបង្ហាញពីភាពជាម្ចាស់សិទ្ធិលើចលនវត្ថុដែលម្ចាស់សិទ្ធិប្រាតិភោគកំពុងកាន់កាប់ដើម្បីធានាសិទ្ធិលើបំណុល នោះម្ចាស់សិទ្ធិមានសិទ្ធិក្នុងការទាមទារវិញក្នុងកំឡុងពេល២ឆ្នាំ គិតចាប់ពីពេលដែលខ្លួនបានបាត់ តែត្រូវសងនូវចំនួនទឹកប្រាក់ទៅម្ចាស់សិទ្ធិប្រាតិភោគ ដែលបានបង់ទៅអ្នកបង្កើតសិទ្ធិប្រាតិភោគដែលគ្មានសិទ្ធិនោះ។

## ២.៣.១.៤. ករណីឧបាទេសកម្មលើកម្មវត្ថុនៃសិទ្ធិប្រាតិភោគ

ឧបាទេសកម្ម គឺជាសិទ្ធិដើម្បីប្តូរនឹងតម្លៃនៃកម្មវត្ថុជាក់លាក់ណាមួយ។ ដូច្នេះហើយម្ចាស់សិទ្ធិប្រាតិភោគអាចអនុវត្តនូវសិទ្ធិលើការបញ្ចាំរបស់ខ្លួនចំពោះប្រាក់ ឬ វត្ថុផ្សេងទៀតដែលអ្នកបង្កើតសិទ្ធិប្រាតិភោគមានសិទ្ធិទទួល ដោយមូលហេតុនៃការលក់ ឬ ការបាត់បង់ ឬ ការខូចខាតកម្មវត្ថុនៃការបញ្ចាំ ព្រោះមូលហេតុទាំងនោះត្រូវបានគេចាត់ទុកជាការបំប្លែងនូវតម្លៃនៃចលនវត្ថុដែលជាប់ការបញ្ចាំ។ ប៉ុន្តែម្ចាស់សិទ្ធិប្រាតិភោគពុំអាចអនុវត្តសិទ្ធិប្រាតិភោគរបស់ខ្លួនបានឡើយ នៅក្រោយពេលដែលប្រាក់ត្រូវបានបង់ ឬ វត្ថុផ្សេងទៀត ត្រូវបានប្រគល់ទៅឲ្យអ្នកបង្កើតសិទ្ធិប្រាតិភោគនោះទេ។[147] ដោយសារតែសិទ្ធិលើការបញ្ចាំត្រូវបានបង្កើតឡើង និងអាចអនុវត្តបានតែចំពោះកម្មវត្ថុណាមួយជាក់លាក់តែប៉ុណ្ណោះ ដូច្នេះប្រាក់ ឬ វត្ថុផ្សេងទៀតមិនអាចត្រូវបានគេបែងចែកពីទ្រព្យសម្បត្តិផ្សេងទៀតបានទេ នៅក្រោយពេលដែលប្រាក់ ឬ វត្ថុផ្សេងទៀតនោះ ត្រូវបានប្រគល់ទៅឲ្យអ្នកបង្កើតសិទ្ធិលើការបញ្ចាំ។[148]

ឧទាហរណ៍៖ **ក** បានបង្កើតសិទ្ធិប្រាតិភោគនៅលើរថយន្តមួយគ្រឿងរបស់ខ្លួនទៅឲ្យ **ខ** ដើម្បីធានាបំណុលរបស់ខ្លួនចំនួន១០០០ដុល្លារ ប៉ុន្តែ **គ** បានធ្វើឲ្យរថយន្តនោះឆេះ។ ដូចនេះ **ខ** ដែលជាម្ចាស់សិទ្ធិប្រាតិភោគអាចប្តឹងទាមទារប្រាក់ដែលជាថ្លៃសំណងខូចខាតរថយន្តពី **គ** បានតាមរយៈឧបាទេសកម្មលើវត្ថុនៃម្ចាស់សិទ្ធិប្រាតិភោគលើរថយន្តដែលបានឆេះនោះ។ តែបើ **គ** បានផ្តល់ប្រាក់សំណងខូចខាតនៃរថយន្តនោះទៅឲ្យ **ក** រួចហើយ **ខ** មិនអាចប្តឹងទាមទារប្រាក់ពី **ក** តាមរយៈឧបាទេសកម្មលើវត្ថុបានទៀតទេ ព្រោះថាប្រាក់ដែលជាសំណងថ្លៃខូចខាតនៃរថយន្តដែល **ក** ទទួល

[146] មាត្រា ១៩៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[147] មាត្រា៨១៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[148] មាត្រា ១៩៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

បាននោះ នឹងក្លាយទៅជាទ្រព្យទូទៅរបស់ **ក** ហើយ។ ប៉ុន្តែ **ខ** នៅតែអាចទាមទារប្រាក់ជំពាក់ពី **ក** ក្នុងនាមជាម្ចាស់បំណុលធម្មតាបាន។

សំណួរចោទឡើងថា ប្រសិនបើក្លាយជាម្ចាស់បំណុលធម្មតាបែបនេះ តើបង្កើតសិទ្ធិលើបំណុលអាទិភាពដើម្បីអ្វី? ដើម្បីឆ្លើយសំណួរនេះយើងត្រូវយកមាត្រា៤២៣ (លក្ខខណ្ឌដើម្បីអនុវត្តសិទ្ធិឧបាទេសកម្ម) ដែលជាវិធានគតិយុត្តទូទៅសម្រាប់គ្រប់គ្រងរបបគតិយុត្តនៃសិទ្ធិលើបំណុលទាំងអស់មកបកស្រាយ។ ដូច្នេះដើម្បីអាចរក្សាស្ថានភាពនៃសិទ្ធិប្រាតិភោគរបស់ខ្លួន (**ខ** តាមឧទាហរណ៍ខាងលើ) ដោយថ្ងៃកំណត់សងមិនទាន់មកដល់នោះ **ខ** ត្រូវដាក់ពាក្យបណ្ដឹង ឬ ពាក្យសុំទៅតុលាការដើម្បីឲ្យតុលាការ[149] អនុញ្ញាតឲ្យ **ខ** បានក្លាយជាម្ចាស់បំណុលជំនួស **ក** (ម្ចាស់បំណុលឧបាទេសកម្ម) ដោយយក **គ** ជាកូនបំណុល។ ប៉ុន្តែប្រសិនបើមិនចង់ដាក់ពាក្យសុំ ឬ ពាក្យបណ្ដឹងក្នុងការសុំការអនុញ្ញាតពីតុលាការទេ **ខ** អាចដាក់ពាក្យបណ្ដឹងទាមទារប្រាក់សំណងការខូចខាត ដោយឲ្យតុលាការរក្សាប្រាក់នៃសំណងការខូចខាតនោះទុករហូតដល់ថ្ងៃកំណត់សងបានមកដល់។[150]

## ២.៣.២. ការសម្របសម្រួលការអនុវត្តប្រាតិភោគចលនវត្ថុ

ការសម្របសម្រួលនេះមានអត្ថិភាពឡើង ពីព្រោះថាច្បាប់ស្ដីពីការប្រតិបត្តិការដែលមានកិច្ចធានាត្រូវបានអនុម័តមុននឹងក្រមរដ្ឋប្បវេណីដាក់ឲ្យអនុវត្ត។ គោលបំណងគឺចង់ទទួលស្គាល់ប្រតិបត្តិការទាំងឡាយ ដែលបង្កើតដោយយោងច្បាប់ស្ដីពីប្រតិបត្តិការដែលមានកិច្ចធានា ដោយមិនចង់ឲ្យមានការធ្វើវិសោធនកម្មច្បាប់ស្ដីពីប្រតិបត្តិការដែលមានកិច្ចធានានោះទេ។ ក៏ប៉ុន្តែបើមានភាពផ្ទុយគ្នារវាងប្រតិបត្តិការដែលធ្វើឡើងយោងច្បាប់ស្ដីពីប្រតិបត្តិការដែលមានកិច្ចធានា និងប្រតិបត្តិការដែលយោងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី វាជាការចាំបាច់ដែលត្រូវមានបញ្ញត្តិសម្របសម្រួលដូចខាងក្រោម។

ក្រមរដ្ឋប្បវេណីមានសណ្ឋាន ជាលក្ខណៈច្បាប់ទូទៅនៃនីតិឯកជន គ្របដណ្ដប់លើសកម្មភាពតាមនីតិឯកជនទាំងអស់ ជាពិសេសការបង្កើតសិទ្ធិប្រាតិភោគ ចំណែកច្បាប់ស្ដីពីប្រតិបត្តិការដែលមានកិច្ចធានា កំណត់វិសាលភាពច្បាស់លាស់សម្រាប់ការអនុវត្តដែលមានចែងកំណត់នៅក្នុងកថាខណ្ឌទី១ មាត្រា២ នៃច្បាប់ស្ដីពីប្រតិបត្តិការដែលមានកិច្ចធានា។ ក៏ប៉ុន្តែបញ្ហានៅត្រង់ថា ច្បាប់ស្ដីពីប្រតិបត្តិការដែលមានកិច្ចធានាបានបញ្ញត្តផ្សេងពីការកំណត់ដោយ

[149] មាត្រា ៤២៣(២)(១) នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[150] មាត្រា ៤២៣ (២)(២) នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ក្រមរដ្ឋប្បវេណីចំពោះប្រាតិភោគចលនវត្ថុនេះ ដែលជាមូលហេតុចម្បងឆ្ពោះទៅរកការសម្របសម្រួល ជៀងវាងការអនុវត្តខុសគ្នាទៅតាមការយល់ឃើញរៀងៗខ្លួន។[151]

### ២.៣.២.១. អានុភាពនៃប្រតិបត្តិការដែលបង្កើតមុនកាលបរិច្ឆេទចូលជាធរមាននៃក្រមរដ្ឋប្បវេណី

ជាគោលការណ៍ ក្រមរដ្ឋប្បវេណីមិនអនុវត្តប្រតិសកម្មទេ គឺអនុវត្តចំពោះតែបញ្ហាណាដែលកើតឡើងក្រោយកាលបរិច្ឆេទអនុវត្តក្រមរដ្ឋប្បវេណីប៉ុណ្ណោះ បញ្ហាទាំងឡាយណាដែលកើតឡើងមុនកាលបរិច្ឆេទនេះ ត្រូវអនុលោមតាមបទប្បញ្ញត្តិដែលមានពីមុនមក។ ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីបានផ្តល់ជាជម្រើសរបស់ភាគីក្នុងការបន្តអានុភាពប្រតិបត្តិការរបស់ខ្លួន ទោះជាប្រតិបត្តិការប្រាតិភោគចលនវត្ថុបង្កើតឡើងយោងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា បានបង្កើតឡើងមុន ឬ ក្រោយកាលបរិច្ឆេទអនុវត្តរបស់ក្រមរដ្ឋប្បវេណីក៏ដោយ ត្រូវបន្តអនុភាពនៅក្រោយកាលបរិច្ឆេទនៃការអនុវត្តក្រមរដ្ឋប្បវេណី។[152] បើសិនជាមិនទទួលស្គាល់ដូច្នេះទេ មិនដឹងថាប្រតិបត្តិការដែលបង្កើតមុនក្រមរដ្ឋប្បវេណីចូលជាធរមាន នៅក្រោមរបបគតិយុត្តមួយណានោះទេ។

### ២.៣.២.២. ការផ្លាស់ប្តូររបបគតិយុត្តនៃប្រតិបត្តិការប្រាតិភោគចលនវត្ថុ

ប្រតិបត្តិការដែលមានកិច្ចធានា ដែលត្រូវបានបង្កើតឡើងមុនកាលបរិច្ឆេទនៃការអនុវត្តក្រមរដ្ឋប្បវេណី អាចធ្វើការផ្លាស់ប្តូរបានដោយគោរពតាមលក្ខខណ្ឌដែលសំខាន់ គឺឆន្ទៈរបស់ភាគីទាំងសងខាង[153] ក្នុងការប្តូររបបគតិយុត្តសម្រាប់ការគ្រប់គ្រងលើប្រតិបត្តិការប្រាតិភោគចលនវត្ថុរបស់ខ្លួនដោយប្តូរទៅជ្រើសរើសយកបញ្ញត្តិនៃក្រមរដ្ឋប្បវេណី។ បើមានស្ថានភាពការព្រមព្រៀងប្តូរប្រតិបត្តិការដូចនេះកើតឡើង ត្រូវចាត់ទុកថាភាគីបានធ្វើប្រតិបត្តិការប្រាតិភោគចលនវត្ថុនៅកាលបរិច្ឆេទនៃការអនុវត្តក្រមរដ្ឋប្បវេណីវិញ។ ក៏ប៉ុន្តែលុះត្រាតែប្រតិបត្តិការដែលបង្កើតឡើង បានបំពេញតាមលក្ខខណ្ឌដែលកំណត់នៅក្នុងក្រមរដ្ឋប្បវេណី និងមិនបង្កឲ្យមានការខូចខាតដល់ប្រយោជន៍ណាមួយរបស់តតិយជន បើមិនដូច្នេះទេមិនអនុញ្ញាតឲ្យប្តូរប្រតិបត្តិការនោះទេ។[154]

---

[151] មាត្រា ៧២ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១

[152] មាត្រា ៧២ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១

[153] សំដៅទៅលើការព្រមព្រៀងរវាងភាគីនៃកិច្ចសន្យាបង្កើតសិទ្ធិប្រាតិភោគ គឺម្ចាស់សិទ្ធិប្រាតិភោគ និងអ្នកបង្កើតសិទ្ធិប្រាតិភោគ។

[154] មាត្រា ៧៤ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី២០១១

ករណីខាងលើនេះ ទោះបីជាភាគីបានតម្កល់លិខិតជូនដំណឹងហើយក៏ដោយ បើសិនជាមានការបង្ហាញឆន្ទៈព្រមព្រៀងថាប្តូរប្រតិបត្តិការទៅយោងបញ្ញត្តិក្រមរដ្ឋប្បវេណីវិញ នោះតម្រូវឲ្យភាគីធ្វើការលុបចោលលិខិតជូនដំណឹងនោះ។[155] តាមរយៈការផ្លាស់ប្តូរខាងលើ នាំឲ្យបាត់បង់នូវអានុភាពទទួលស្គាល់ប្រតិបត្តិការ ដែលយោងតាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា។ ដូចនេះ មិនមានជាបញ្ហាទេ បើភាគីមានបំណងផ្លាស់ប្តូរមូលដ្ឋានគតិយុត្តក្នុងចំណោមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា និងក្រមរដ្ឋប្បវេណី ពោលដោយគ្រាន់តែគោរពតាមលក្ខខណ្ឌដែលតម្រូវសម្រាប់របបគតិយុត្តនីមួយៗតែប៉ុណ្ណោះ។

### ២.៣.២.៣. ការបែងចែកលក្ខណៈសម្គាល់រវាងប្រតិបត្តិការបង្កើតឡើងតាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា និងតាមក្រមរដ្ឋប្បវេណី

មានពេលខ្លះប្រតិបត្តិការដែលបង្កើតឡើងដោយភាគី ពិបាកក្នុងវិនិច្ឆ័យថាស្ថិតនៅក្រោមរបបគតិយុត្តមួយណា ដូចនេះនីតិនិពន្ធបានកំណត់ថា ប្រតិបត្តិការណាដែលត្រូវបានធ្វើឡើងនៅក្រោយកាលបរិច្ឆេទនៃការអនុវត្តក្រមរដ្ឋប្បវេណី បើសិនជាមានភាពមិនច្បាស់លាស់ មិនដឹងថាប្រតិបត្តិការនោះនៅក្រោមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ឬយោងបញ្ញត្តិក្រមរដ្ឋប្បវេណី ប្រតិបត្តិការនោះត្រូវសន្មតថាបង្កើតឡើងដោយយោងបញ្ញត្តិនៃក្រមរដ្ឋប្បវេណី។[156] ចូរចំណាំថា ការសន្មតប្រតិបត្តិការតាមមាត្រា៧៥ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ពាក់ព័ន្ធនឹងការសន្មតអត្ថិភាពនៃប្រតិបត្តិការនៅក្រោមក្រមរដ្ឋប្បវេណី មិនត្រូវបានគ្របដណ្តប់នោះទេ លុះត្រាតែភាគីបង្កើតប្រាតិភោគដោយគ្មានការតម្កល់លិខិតជូនដំណឹង។ បើមិនដូច្នេះទេ បញ្ញត្តិនៃការសន្មតនឹងត្រូវយកមកអនុវត្ត មានន័យថាប្រតិបត្តិការនោះត្រូវសន្មតថាធ្វើឡើងយោងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី។

លក្ខណៈសម្គាល់ដែលងាយគឺ បើសិនជាប្រតិបត្តិការនោះពិតធ្វើឡើងដោយយោងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ប្រតិបត្តិការនោះនឹងមានការចុះបញ្ជីតាមនីតិវិធីតម្កល់លិខិតជូនដំណឹងជាមិនខាន ព្រោះថាតាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា មាននីតិវិធីតម្កល់លិខិតជូនដំណឹងនៅក្រសួងពាណិជ្ជកម្ម ហើយបើសិនជាមិនបានអនុវត្តនិតិវិធីនេះទេ ប្រតិបត្តិការនោះប្រាកដជាប្រតិបត្តិការដោយផ្អែកលើក្រមរដ្ឋប្បវេណីជាប្រាកដ។

---

155 មាត្រា ៧៤ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី២០១១

156 មាត្រា ៧៥ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១

ជារួមកត្តាជាសត្យានុម័ត ដើម្បីយកបែងចែករវាងប្រតិបត្តិការទាំងពីរគឺៈ

⇒ ប្រតិបត្តិការដែលមានកិច្ចធានាគឺ មានការចុះបញ្ជីតាមនីតិវិធីតម្កល់លិខិតជូនដំណឹង។

⇒ ប្រតិបត្តិការតាមក្រមរដ្ឋប្បវេណីគឺ លក្ខខណ្ឌតតាំងនៃរបបធានានីមួយៗ អាស្រ័យលើរបបគតិយុត្តរបស់វា។

### ២.៣.២.៤. អាទិភាពនៃប្រតិបត្តិការពីរដែលបង្កើតលើចលនវត្ថុតែមួយ

ជាគោលការណ៍ ករណីដែលច្បាប់ពិសេស និងច្បាប់ទូទៅត្រូវគ្នា គឺយកច្បាប់ពិសេស។ តែជាអញ្ញត្រកម្មច្បាប់ស្តីពីប្រតិបត្តិដែលមានកិច្ចធានា គឺជាច្បាប់ពិសេស ប៉ុន្តែការអនុវត្តប្រតិបត្តិការជាន់គ្នាក្នុងករណីនេះ បែជាបញ្ញត្តពីការផ្តល់អាទិភាពទៅវិញ។ នេះបើមើលតាមគោលបំណងសំខាន់នៃការកំណត់អាទិភាព រវាងប្រតិបត្តិការពីរដែលជាន់គ្នាលើចលនវត្ថុតែមួយនេះ គឺដើម្បីបញ្ចៀសនូវការសន្មតថា កិច្ចសន្យាប្រាតិភោគដែលបង្កើតនៅក្រោមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាដែលជាន់នឹងចលនវត្ថុដដែល ដែលបានបង្កើតសិទ្ធិប្រាតិភោគតាមក្រមរដ្ឋប្បវេណីរួចហើយ ត្រូវបានមោឃៈដោយសារការបង្កើតជាន់គ្នានោះទេ។ ម្យ៉ាងវិញទៀត នីតិករចង់ឲ្យភាគីកូនបំណុល[157] ដែលជាភាគីទន់ខ្សោយជាងម្ចាស់បំណុល អាចយកចលនវត្ថុជាទ្រព្យរបស់ខ្លួនទៅបង្កើតសិទ្ធិប្រាតិភោគប្រត្យក្សបានច្រើនដង និងអស់លទ្ធភាពនូវតម្លៃនៃចលនវត្ថុនោះ ទោះជាការបង្កើតនេះគ្រប់គ្រងដោយរបបគតិយុត្តពីរខុសគ្នាក៏ដោយ។[158]

ចំពោះវត្ថុដែលជាកម្មវត្ថុតែមួយ ត្រូវបានធ្វើតាមប្រតិបត្តិការដែលមានកិច្ចធានាផង និងយោងបញ្ញត្តិនៃក្រមរដ្ឋប្បវេណីផង អាចមានករណីដែលប្រតិបត្តិការទាំងនេះមិនមានភាពព្រមព្រៀងគ្នា។ ដូច្នេះបើមិនសម្រេចពីវិសមិតភាពអាទិភាព រវាងប្រតិបត្តិការស្ថិតក្រោមរបបគតិយុត្តខុសគ្នាបែបនេះទេ មិនដឹងថាម្ចាស់បំណុលមួយណាអាចយកទៅតតាំងបានមុននោះទេ។ ដូច្នេះហើយទើបច្បាប់ស្តីពីការអនុវត្តក្រមមាត្រា៧៦ បានចង្អុលបង្ហាញថា នាពេលដែលកម្មវត្ថុតែមួយត្រូវបានបង្កើតឡើងក្រោមប្រតិបត្តិការពីរគឺ អាទិភាពរបស់ប្រតិបត្តិការនីមួយៗនោះ អាស្រ័យលើពេលវេលានៃការកាន់កាប់ ឬ ការតម្កល់លិខិតជូនដំណឹង ដើម្បីតតាំងនឹងតតិយជន។

បើសិនជាកម្មវត្ថុនៃការបង្កើតប្រាតិភោគ ដោយយោងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាបានបង្កើត និងទទួលលក្ខខណ្ឌតតាំងមុន ទើបកូនបំណុលដែលមានកិច្ចធានាយកវត្ថុនៃការដាក់ធានាទៅបង្កើតសិទ្ធិលើការបញ្ចាំទៀតដោយធ្វើការប្រគល់វត្ថុ នោះយើងអាចសន្មតបានថា

[157] អ្នកបង្កើតសិទ្ធិលើការបញ្ចាំ ឬកូនបំណុលដែលមានកិច្ចធានា

[158] ម្ចាស់សិទ្ធិលើការបញ្ចាំ ឬម្ចាស់បំណុលដែលមានកិច្ចធានា

កម្មវត្ថុតែមួយដែលបានធ្វើការតម្កល់លិខិតជូនដំណឹង មុនពេលដែលកូនបំណុលយកទៅបញ្ចាំនោះទទួលលក្ខខណ្ឌតតាំងមុន។ ឧទាហរណ៍៖ បើសិនជាប្រាតិភោគ ដោយយោងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា និងយោងក្រមរដ្ឋប្បវេណីផង ត្រូវបានបង្កើតលើចលនវត្ថុតែមួយ សួរថាតើអាទិភាពរវាងសិទ្ធិលើការបង្កើតប្រាតិភោគទាំងពីរនេះទៅជាយ៉ាងណា? ចម្លើយគឺ អាទិភាពរវាងសិទ្ធិលើការដាក់ប្រាតិភោគលើកម្មវត្ថុតែមួយនេះ ត្រូវសម្រេចដោយប្រៀបធៀបលិខិតជូនដំណឹងអំពីការបង្កើតប្រាតិភោគដោយយោងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ថាបានតម្កល់នូវការិយាល័យតម្កល់លិខិតជូនដំណឹងនៅថ្ងៃខែឆ្នាំណា ហើយមួយវិញទៀតត្រូវមើលទៅលើពេលវេលានៃការកាន់កាប់កម្មវត្ថុនៃសិទ្ធិលើការបញ្ចាំដោយម្ចាស់សិទ្ធិតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី។

ទោះជាយ៉ាងណាក៏ដោយ ការប្រើប្រាស់ការសម្របសម្រួលករណីមានវិសមិតភាពនេះ មិនយកទៅប្រើប្រាស់ទេ បើមានស្ថានភាពដែលមានតតិយជនធ្វើលទ្ធកម្មនូវវត្ថុដែលជាកម្មវត្ថុនៃប្រតិបត្តិការដែលមានកិច្ចធានា ដោយហេតុថាវាមិនអាចចាត់ទុកជាករណីប្រតិបត្តិការពីរមានវិសមិតភាពនឹងគ្នានោះទេ តែវាជាការចាត់ចែងរបស់ម្ចាស់បំណុល ឬ កូនបំណុលលើវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគទៅតតិយជនជាធម្មតាប៉ុណ្ណោះ។

# សេចក្ដីសន្និដ្ឋាន

ក្រៅពីការប្រើប្រាស់អចលនវត្ថុធ្វើជាទ្រព្យធានា ការប្រើប្រាស់ចលនវត្ថុជាទ្រព្យធានាជាបញ្ហាគប្បីត្រូវយកចិត្តទុកដាក់ផងដែរ ឲ្យមានភាពជិតស្និទ្ធិរវាងទ្រព្យដែលក្រុមហ៊ុនអាជីវកម្ម ឬសហគ្រាសមាន និងទ្រព្យធានាដែលស្ថាប័នផ្តល់ប្រាក់កម្ចីតម្រូវឲ្យដាក់ធានា។ ការប្រើប្រាស់ចលនវត្ថុធ្វើជាទ្រព្យធានា ពិតជាប្រភពមួយដ៏សំខាន់ ក្នុងការរួមចំណែកផ្តល់នូវហិរញ្ញប្បទានអាជីវកម្មក្រៅពីអចលនវត្ថុព្រោះ វាក៏ជាផ្នែកមួយជួយលើកស្ទួយកំណើនសេដ្ឋកិច្ចផងដែរ។ ប្រាតិភោគចលនវត្ថុ ដែលបានបង្កើតឡើងមានលក្ខខណ្ឌខុសពីប្រាតិភោគអចលវត្ថុខ្លះៗ ដែលមិនតម្រូវនីតិវិធីនៃការចុះបញ្ជីនៅក្រសួងដែនដីនគរូបនីយកម្ម ដូចជាការប្រើអចលនវត្ថុដាក់ជាប្រាតិភោគនោះទេ។ នេះជាចំណុចល្អមួយក្នុងការប្រើទ្រព្យសម្បត្តិជាចលនវត្ថុ ដែលប្រជាជន ឬអាជីវករគប្បីពិចារណាព្រោះវាមានភាពឆាប់រហ័ស និងងាយស្រួលក្នុងការអនុវត្ត។

ក្នុងនោះដែរពាក់ព័ន្ធនឹងប្រាតិភោគចលនត្ថុ គេសង្កេតឃើញប្រតិបត្តិការដែលមានកិច្ចធានាជាមូលដ្ឋានគតិយុត្តបន្ថែមទៅលើ របបគតិយុត្តដែលបានបញ្ញត្តនៅក្នុងក្រមរដ្ឋប្បវេណីនោះ ដែលដើរតួនាទីសម្រួលការប្រើប្រាស់របបគតិយុត្តនៃសិទ្ធិលើការបញ្ចាំ ដែលតម្រូវឲ្យមានការប្រគល់វត្ថុជាលក្ខខណ្ឌអានុភាព។ នេះជាការប្រសើរ ព្រោះសារពើភណ្ឌ និងឧបករណ៍ដើម្បីដំណើរការអាជីវកម្មពិតជាមានភាពចាំបាច់ណាស់សម្រាប់ចរាចរទំនិញ លំហូរសាច់ប្រាក់ និងផលិតកម្ម។ ដូចនេះបើសិនជាចលនវត្ថុទាំងនេះ មិនត្រូវបានប្រគល់ឲ្យទៅម្ចាស់បំណុលធ្វើការកាន់កាប់ ហើយកូនបំណុលនៅតែអាចបន្តសកម្មភាពអាជីវកម្ម វានឹងបញ្ឈប់បាននូវការកកស្ទះសកម្មភាពសេដ្ឋកិច្ច។ ប្រតិបត្តិការដែលមានកិច្ចធានានេះមានប្រសិទ្ធិភាពសំខាន់ ដោយសារវិសាលភាពនៃទ្រព្យធានាធំទូលាយព្រមទាំងផ្តល់នូវអាទិភាពតាមរយៈការចុះបញ្ជី ការផ្សព្វផ្សាយជាសាធារណៈដើម្បីធានាតម្លាភាពនៃសិទ្ធិប្រាតិភោគដែលបង្កើតលើចលនវត្ថុនានា។ ចំណែកឯ ការដាក់ចលនវត្ថុជាទ្រព្យធានាតាមសណ្ឋាននៃការបញ្ចាំវិញ គឺធានានូវការអនុវត្តសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលខ្ពស់ជាងគេព្រោះម្ចាស់បំណុលកាន់កាប់វត្ថុធានានូវនឹងដៃ តែកូនបំណុលត្រូវខាតបង់ប្រយោជន៍ទៅវិញដោយសារតែមិនបានកាន់កាប់ និងប្រើប្រាស់ទ្រព្យដែលធានាសិទ្ធិលើបំណុលនោះ។

ដោយឡែកចំពោះសញ្ញាណគតិយុត្តនៃប្រាតិភោគដោយអនុប្បទាន ផ្តល់សិទ្ធិជ្រើសរើសនូវការប្រគល់ចលនវត្ថុជាទ្រព្យធានាទៅម្ចាស់បំណុល ឬត្រូវរក្សាទុកជាមួយកូនបំណុល ដែលលក្ខណៈនេះហាក់ដូចជាមានភាពស្រដៀងគ្នានឹង ការបង្កើតការបញ្ចាំចលនវត្ថុតាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា។ ដូចនេះត្រលប់មកវិញ ដោយសារតែសញ្ញាណនីមួយៗនៃការបញ្ចាំចលនវត្ថុ

មានភាពប្រហាក់ប្រហែលគ្នានេះហើយ ទើបការបង្កើននូវការយល់ដឹងពីសញ្ញាណនៃរបបគតិយុត្ត ទាំងបីនេះ មានសារៈសំខាន់សម្រាប់អ្នកប្រើប្រាស់ ព្រោះកាលណាម្ចាស់បំណុល ឬកូនបំណុលដឹង ពីសញ្ញាណគតិយុត្តច្បាស់លាស់ គេអាចពិចារណាបានច្បាស់លាស់ថារបបមួយណាផ្តល់នូវផល ចំណេញច្រើនដល់អាជីវកម្មរបស់ខ្លួន ដោយការចំណាយតិច និងងាយស្រួលក្នុងការអនុវត្តសិទ្ធិ មានប្រសិទ្ធិភាព។ ប្រសិនបើម្ចាស់បំណុល និងកូនបំណុលបង្កើតនូវការបញ្ចាំចលនវត្ថុដោយមិន គោរពទៅតាមលក្ខខណ្ឌដែលច្បាប់កំណត់ទេ នោះសិទ្ធិរបស់ម្ចាស់បំណុលនឹងក្លាយទៅជាសិទ្ធិលើ បំណុលធម្មតា ដូច្នេះនៅពេលអនុវត្តដោយបង្ខំគាត់អាចនឹងពិបាករកទ្រព្យមកលក់ឡាយឡុងបាន ដោយហេតុថា ទ្រព្យដទៃទៀតដែលកូនបំណុលមានត្រូវបានដាក់ធានាទៅម្ចាស់បំណុលផ្សេងៗ។

ទោះបីជាមូលដ្ឋានគតិយុត្តមួយមានវត្តមានក្នុងច្បាប់ពិសេស និងមូលដ្ឋានគតិយុត្តមួយ ទៀតមានវត្តមានក្នុងច្បាប់ទូទៅ ក៏ប៉ុន្តែមូលដ្ឋានទាំងនេះចែករំលែកនូវគោលបំណងរួមគ្នា គឺដើម្បី បង្កើននូវចរាចរនៃការផ្តល់ប្រាក់កម្ចី តាមរយៈការអនុញ្ញាតឲ្យដាក់ចលនវត្ថុដើម្បីធានាកាតព្វកិច្ច។ ការប្រើប្រាស់របបគតិយុត្តណាមួយ សុទ្ធតែផ្តល់នូវគុណសម្បត្តិ និងគុណវិបត្តិចំពោះម្ចាស់បំណុល និងកូនបំណុល ដូចនេះវាអាស្រ័យលើការគិតរបស់បុគ្គលនីមួយៗប៉ុណ្ណោះ។ ដូចនេះ មិនគួរមើល រំលងនូវប្រតិបត្តិការចលនវត្ថុដែលកើតឡើងជារៀងរាល់ថ្ងៃនេះទេ ព្រោះថាអត្ថប្រយោជន៍នៃការ អនុញ្ញាតឲ្យដាក់ចលនវត្ថុជាទ្រព្យធានា អាចចូលរួមចំណែកក្នុងការបង្កើននូវការផ្តល់ឥណទាន ជួយបង្កើតនូវការប្រកួតប្រជែងក្នុងទីផ្សារ និ អភិវឌ្ឍផ្នែកឧស្សាហកម្មដូចជារោងចក្រ (លើកតម្កើង ការផ្តល់ឥណទានផ្សេងៗគ្នាទាំងចលនវត្ថុ និងអចលនវត្ថុ) លើសពីនេះបង្កើននូវសកម្មភាពសេដ្ឋកិច្ច កាន់តែខ្លាំងក្លានាំឲ្យកាត់បន្ថយបាននូវភាពក្រីក្រ។

សរុបសេចក្តីមក របបគតិយុត្តមួយណាក៏ផ្តល់នូវគុណសម្បត្តិ និងគុណវិបត្តិរួមគ្នាដែរដូច នេះហើយវាជាបញ្ហាសម្រាប់ម្ចាស់បំណុល និងកូនបំណុលប៉ុណ្ណោះ ដើម្បីធ្វើការថ្លឹងថ្លែងពីទម្ងន់នៃ ផលវិបាក និងផលប្រយោជន៍ របស់របបគតិយុត្តនីមួយៗ។ តាមការពិតទៅ វត្តមានដំបូងនៃច្បាប់ ទាំងពីរនេះមានបញ្ហាចម្រូងចម្រះមួយចំនួន មូលហេតុនោះគឺនៅពេលក្រមរដ្ឋប្បវេណីត្រូវបានគេ បង្កើតឡើងដោយសារតែខាងក្រុមការងារJICA និងក្រុមការងារក្រសួងពាណិជ្ជកម្ម មិនមានភាព ស្របគ្នាអំពីការលុបចោលច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ដោយសារតែច្បាប់ពិសេស នេះកើតឡើងមុនក្រមរដ្ឋប្បវេណី ដែលធ្វើឲ្យវាមានភាពស្រដៀងគ្នានឹងរបបគតិយុត្តប្រាតិភោគ ដោយអនុប្បទានទៅវិញ នេះជាមូលហេតុមួយ។

ចំណែកមូលហេតុផ្សេងទៀតគឺ ខាងក្រុមការងារក្រសួងយុត្តិធម៌គិតថា ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាមានលក្ខណៈអមនុស្សធម៌ទៅលើកូនបំណុល ដោយសារតែសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលមានទៅលើទ្រព្យធានាគ្រប់ពេល មិនគិតថាទ្រព្យធានានោះនៅក្នុងដៃអ្នកណានោះទេ។ម្យ៉ាងទៀត បើមើលពីលក្ខណៈរបស់ច្បាប់នេះ វាហាក់ដូចជាការពារអ្នកមានមូលធនខាងភាគីម្ចាស់បំណុល ជាជាងអ្នកទន់ខ្សោយផ្នែកហិរញ្ញវត្ថុដែលស្គាល់ថាជាកូនបំណុលនោះ។ នេះជាចំណោទបញ្ហាថ្មីសម្រាប់អ្នកសិក្សាក្រោយៗធ្វើការពិចារណា ថាតើគប្បីធ្វើការលុបចោលច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ដែលជាច្បាប់ពិសេសនេះដែរឬទេ? តើនឹងជួបផលវិបាកអ្វីខ្លះប្រសិនបើទៅអនាគតទៅនឹងមានការលុបចោល ច្បាប់ពិសេសដែលគ្រប់គ្រងប្រាតិភោគលើចលនវត្ថុបែបលក្ខណៈទំនើបកម្មនេះ ដោយធ្វើការអនុវត្តតាមបញ្ញត្តិក្រមរដ្ឋប្បវេណីតែមួយមុខ?

# អនុសាសន៍

តាមរយៈការស្រាវជ្រាវកន្លងមក ឃើញថាការប្រើប្រាស់ចលនវត្ថុធ្វើជាទ្រព្យធានាមិនបាន ធំទូលាយប៉ុន្មានទេ ពីព្រោះបញ្ហាសំខាន់គឺរបាំងនៃច្បាប់នេះឯងដែលមិនបានបង្កើតជាមធ្យោបាយ គ្រប់គ្រាន់សម្រាប់ការអនុវត្តកន្លងមក។ មូលហេតុដែលសំខាន់ផ្សេងទៀត គឺដោយសារតែភាពខ្វះ ខាតមួយចំនួនដូចជា ទីមួយគឺ មិនមានស្ថាប័នហិរញ្ញវត្ថុណាមានឆន្ទៈក្នុងការផ្តល់ឥណទាន ដោយ យកចលនវត្ថុធ្វើជាទ្រព្យធានានោះទេ។ ចំណែកបញ្ហាទីពីរគឺ មិនមានបញ្ញត្តិច្បាប់គ្រប់គ្រាន់ដោយសារ តែការរិតបន្តឹងលើប្រភេទនៃទ្រព្យដែលអាចដាក់ធានា ព្រមទាំងខ្វះនូវសិទ្ធិអាទិភាពច្បាស់លាស់ សម្រាប់ម្ចាស់បំណុលក៏ដូចជាបញ្ហានៃការអនុវត្តសិទ្ធិ។ ចំណុចទីបី គឺការចុះបញ្ជីសិទ្ធិប្រាតិភោគលើ ចលនវត្ថុមានដំណើរការមិនទាន់បានល្អ ដោយសារខ្វះនូវការផ្សព្វផ្សាយជាសាធារណៈបានទូលំទូ លាយ។ ចំណុចដែលសំខាន់គួរឲ្យកត់សម្គាល់ចុងក្រោយគឺ ប្រជាពលរដ្ឋ និងអាជីវករនេះឯង ដែល ជាអ្នកអនុវត្ត តែបែជាខ្វះនូវការយល់ដឹងពីលទ្ធភាពដែលចលនវត្ថុអាចយកធ្វើជាទ្រព្យធានា កាតព្វកិច្ចនេះតែម្តង។

ដូចនេះ គប្បីធ្វើការពិចារណាឡើងវិញដើម្បីកែតម្រូវនូវចំណុចមួយចំនួន ជាពិសេសចំពោះ ស្ថាប័នហិរញ្ញវត្ថុ ឬ ធនាគារគួរតែធ្វើការសម្របសម្រួលការប្រើប្រាស់ចលនវត្ថុធ្វើជាទ្រព្យធានា សម្រាប់ពាណិជ្ជករ និងអ្នកប្រើប្រាស់ឥណទាន។ ម្យ៉ាងទៀត គប្បីបង្កើតឲ្យមានភាពសកម្មលើការ ដាក់ធានានូវ គណនីធនាគារ សារពើភណ្ឌ ឧបករណ៍កសិកម្ម ឧស្សាហកម្ម ផលិតផលកសិកម្ម ដំណាំ ត្រីកសិដ្ឋាន សត្វចិញ្ចឹមជាអាទិ៍។ ដូចដែលឃើញស្រាប់ មិនមានប្រជាជនច្រើនទេដែលអាច ឈានទៅរកការប្រើប្រាស់ចលនវត្ថុធ្វើជាទ្រព្យធានា ព្រោះអ្នកឲ្យខ្ចីភាគច្រើនមិនចង់ឲ្យដាក់ចលនវត្ថុ ធ្វើជាទ្រព្យធានានោះទេ ដោយសារតែគិតថាអចលនវត្ថុមានតម្លៃខ្ពស់ និងអាចធានាបាននូវការសង ខ្ពស់ជាងចលនវត្ថុ។ ដូចនេះគប្បីណែនាំដល់អ្នកផ្តល់ប្រាក់កម្ចីនៅតាមបណ្តាស្ថាប័ននានា ឲ្យមាន ការយល់ដឹងពីដំណើរការនៃការដាក់ធានានូវចលនវត្ថុ ភាពរហ័សក្នុងការចុះបញ្ជី និងចំណេញពេល វេលាក្នុងការអនុវត្តសិទ្ធិទៀតផង។

ក្រៅពីនេះ អាជ្ញាធរគប្បីយកចិត្តទុកដាក់ផងដែរចំពោះការកំណត់ឲ្យបានច្បាស់លាស់ពី វិសាលភាពនៃប្រតិបត្តិការដែលមានកិច្ចធានា បង្កើននូវការយល់ដឹងអំពីប្រតិបត្តិការដែលមានកិច្ច ធានាតាមរយៈការផ្សព្វផ្សាយឲ្យមានភាពសកម្ម។ ជាពិសេស គប្បីបង្កើតនូវយន្តការឲ្យបាន ច្បាស់លាស់ក្នុងអនុវត្តសិទ្ធិប្រាតិភោគ ពោលគឺធ្វើយ៉ាងកុំឲ្យប្រើប្រាស់ផ្លូវតុលាការ តែបង្កើតនូវនិតិ វិធីអនុវត្តដោយឡែក ដោយធានានូវដំណើរការនីតិវិធីដែលឆាប់រហ័ស និងមានលក្ខណៈអាចបត់

បែនបានគ្រប់ពេល។ ជាពិសេសធ្វើការបណ្ដុះបណ្ដាលបុគ្គលិកធានាគារគឺ ជាបញ្ហាសំខាន់គួរយកចិត្តទុកដាក់ជាងគេ។ គប្បីការពិចារណាផងដែរ ក្នុងការអនុញ្ញាតឲ្យមានការផ្ដល់សេវាចុះបញ្ជីលិខិតជូនដំណឹងដោយក្រុមហ៊ុនឯកជន ដើម្បីប្រកួតប្រជែងជាមួយការចុះបញ្ជីលិខិតជូនដំណឹងដោយស្ថាប័នរដ្ឋ ធ្វើយ៉ាងណាបង្កើនការប្រើប្រាស់ចលនវត្ថុជាទ្រព្យធានា ដើម្បីធានាកាតព្វកិច្ចឲ្យកាន់តែមានភាពសកម្មដូចវិស័យអចលនវត្ថុសព្វថ្ងៃ និងអាចធានាបាននូវស្ថេរភាពប្រតិបត្តិការអាជីវកម្មជំនួយក្នុងស្ថានភាពប្រចាំថ្ងៃ។

លើសពីនេះ ដើម្បីពង្រឹងការអនុវត្តច្បាប់ស្ដីពីការប្រតិបត្តិការដែលមានកិច្ចធានា ឲ្យកាន់តែមានប្រសិទ្ធិភាពក៏ដូចជាលើកទឹកចិត្តឲ្យប្រតិបត្តិការជំនួញដំណើរការបានរលូន ក្រសួងមានសមត្ថកិច្ចមានដូចជា ក្រសួងពាណិជ្ជកម្ម និងក្រសួងយុត្តិធម៌ គប្បីពិចារណាតាក់តែងនិតិវិធីពិសេសនេះ ក្រោមរូបភាពជាច្បាប់ ឬ ប្រកាសអន្តរក្រសួងសម្រាប់ការណែនាំលើការអនុវត្តសិទ្ធិឲ្យកាន់តែច្បាស់លាស់ និងសមស្របទៅនឹងគោលគំនិតនៃការបង្កើតរបបគតិយុត្តនេះផងដែរ។ ជាក់ស្ដែង នៅពេលដល់កំណត់សងឲ្យអនុវត្តកាតព្វកិច្ច តាមច្បាប់ស្ដីពីប្រតិបត្តិការដែលមានកិច្ចធានា ពុំទាន់មានដំណោះស្រាយគតិយុត្ត អំពីនីតិវិធីនៃការរឹបអូសដើម្បីធ្វើការលក់ទ្រព្យធានានៅឡើយទេ មិនដូចការអនុវត្តសិទ្ធិប្រាតិភោគតាមក្រមរដ្ឋប្បវេណីនោះទេ។ ជាពិសេសនៅត្រង់មាត្រា៥១ នៃច្បាប់ស្ដីពីប្រតិបត្តិការដែលមានកិច្ចធានា មិនទាន់បានកំណត់ពីដីកាសម្រេចកិច្ចការប្រញាប់ថាជាអ្វីនោះទេ ហើយក៏គ្មាននីតិវិធីឲ្យអនុវត្តបែបណាដែរ ដែលនេះហើយជាចំណុចដែលគួរពិចារណា៕

# គន្ថនិទ្ទេស

## I. បទដ្ឋានគតិយុត្ត

១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។

២.ក្រឹត្យច្បាប់លេខ៣៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្នុងកិច្ចសន្យា ដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី ២៨ ខែតុលា ឆ្នាំ១៩៨៨ (ត្រូវបាននិរាសករណ៍ដោយផ្នែក ដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ប្រកាសឲ្យប្រើនៅថ្ងៃទី ៣១ខែឧសភា ឆ្នាំ ២០១១ ត្រង់មាត្រា៧៩)។

៣. ក្រមនីតិរដ្ឋប្បវេណី ប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១/ ចុះថ្ងៃទី០៦ កក្កដា ២០០៦។

៤. ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៧/០១២ចុះ ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៧។

៥. ក្រមរដ្ឋប្បវេណី ប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧។

៦. ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/ រគម/ ០៥០៧/ ០១២ ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០១១។

- ប្រសិនបើអ្នកជាបុគ្គលិករបស់ក្រុមហ៊ុន រឺស្ថាប័នហិរញ្ញវត្ថុ ដែលនឹងត្រូវតម្កល់លិខិតជូនដំណឹងនៃសិទ្ធិប្រាតិភោគជាប្រចាំ ក្រុមហ៊ុន រឺក៏ស្ថាប័ននោះគួរតែបង្កើតគណនីអតិថិជនមួយ ដែលនឹងអនុញ្ញាតអោយអ្នក និងអ្នកដែលត្រូវបានផ្តល់សិទ្ធិផ្សេងទៀតចូល(log in) ទៅកាន់វែបសាយសំរាប់តម្កល់លិខិតជូនដំណឹង និងស្នើសុំរបាយការណ៍ស្រាវជ្រាវដែលមានការបញ្ជាក់។ តំលៃក្នុងការតម្កល់ និងស្នើសុំរបាយការណ៍ស្រាវ ជ្រាវដែលមានការបញ្ជាក់ គឺត្រូវបានកើនឡើងដោយស្វ័យប្រវត្តិទៅក្នុងគណនីអតិថិជន ចំណែកឯ របាយការណ៍នឹងត្រូវបានបង្កើតសំរាប់អ្នកប្រើប្រាស់នៅរៀងរាល់ចុងខែនិមួយៗ។ ការបង់ប្រាក់ទៅអោយ ការិយាល័យតម្កល់ត្រូវបានធ្វើឡើងតាមរយៈសាខា រឺការិយាល័យ របស់ធនាគារ អេស៊ីលីដាដោយបញ្ចូលទៅ កាន់គណនីលេខ NNNNNNNNN។ ដើម្បីបង្កើតគណនីអតិថិជន សូមត្រលប់ទៅកាន់ទំព័រដើមហើយ ជ្រើសរើសពាក្យថា របៀបបង្កើតគណនីអតិថិជន។ ទំព័ររបៀបបង្កើតគណនីអតិថិជននឹងនាំអ្នកទៅកាន់ ការបំពេញទម្រង់បែបបទអំពីគណនីអតថិជនដែលអ្នកអាចបំពេញហើយបញ្ជូនទៅកាន់ការិយាល័យតម្កល់តាមរយៈវែបសាយនេះ។

- ប្រសិនបើអ្នក រឺក្រុមហ៊ុនរបស់អ្នកត្រូវការតម្កល់លិខិតជូនដំណឹង និងស្នើសុំរបាយការណ៍ស្រាវជ្រាវដែលមានការបញ្ជាក់តែមួយដង រឺមិនញឹកញាប់ អ្នកអាចតម្កល់លិខិតជូនដំណឹង និងស្រាវជ្រាវរកការស្នើសុំ របាយការណ៍ដែលមានការបញ្ជាក់តាមរយៈវែបសាយ ក៏ប៉ុន្តែអ្នកត្រូវតែបង់កម្រៃជាមុនសិន។ ដំបូងអ្នកគួរតែ កំនត់ថាតើអ្នកចង់តម្កល់លិខិតជូនដំណឹងចំនួនប៉ុន្មាន

និងស្នើសុំរបាយការណ៍ស្រាវជ្រាវដែលមានការ បញ្ជាក់ចំនួនប៉ុន្មាន។ បន្ទាប់មកសូមត្រលប់មកកាន់ទំព័រដើមហើយជ្រើសរើសពាក្យថា តំលៃ ដើម្បីបង្ហាញ តារាងតំលៃ។ សូមកំនត់តំលៃសរុបសំរាប់សេវាកម្មដែលអ្នកចង់បាន។ បន្ទាប់មកសូមទៅបង់ប្រាក់ទៅអោយ ការិយាល័យតម្កល់តាមរយៈសាខា រឺការិយាល័យរបស់ធនាគារអេស៊ីលីដាដែលនៅជិតលោកអ្នកគឺបង់ចូលគណនីលេខ NNNNNNNNN។ ធនាគារនឹងបញ្ចូលការបង់ប្រាក់ចូលទៅក្នុងប្រព័ន្ធរបស់ការិយាល័យតម្កលហើយនឹងផ្តល់ជូនអ្នកនូវបង្កាន់ដៃបង់ប្រាក់ដែលមានលេខសំគាល់។ បន្ទាប់មកអ្នកអាចចូល(log in)ទៅកាន់វែបសាយរបស់ការិយាល័យតម្កល់ដើម្បីតម្កល់លិខិតជូនដំណឹង និងស្នើសុំរបាយការណ៍ស្រាវជ្រាវដែលមានការបញ្ជាក់ដោយប្រើលេខសំគាល់នៅលើបង្កាន់ដៃបង់ប្រាក់នោះ។

## របៀបបង្កើតគណនីអតិថិជន

សំនួរដំបូងដែលអ្នកត្រូវតែឆ្លើយ គឺថាតើអ្នកត្រូវការបង្កើតគណនីអតិថិជនរឺអត់។ ប្រសិនបើអាជីវកម្មរបស់អ្នក រំពឹងថា នឹងតម្កល់លិខិតជូន ដំណឹងនៃសិទ្ធិប្រាតិភោគនៅក្នុងការិយាល័យតម្កល់ជាទៀងទាត់ លោកអ្នកនឹងមានភាពងាយ ស្រួលដោយបង្កើតនូវគណនីអតិថិជន។ ប៉ុន្តែប្រសិនបើលោកអ្នករំពឹងថានឹងតម្កល់លិខិតជូនដំណឹង រឺស្នើសុំ របាយការណ៍ស្រាវជ្រាវដែលមានការបញ្ជាក់តែម្តង រឺមិនញឹកញាប់ អ្នកមិនចាំបាច់បង្កើតគណនីអតិថិជនទេ អ្នកអាច កំនត់តំលៃ ដោយចុចលើប៊ូតុង តំលៃនៅលើទំព័រដើម និងធ្វើការបង់ប្រាក់ទៅកាន់សាខា នៃធនាគារអេស៊ីលីដាដែល នៅជិតអ្នកបំផុត។ ធនាគារនឹងផ្តល់ជូនអ្នកនូវបង្កាន់ដៃដែលមានលេខសំគាល់ដែលអ្នកនឹងបញ្ចូលលេខ សំគាល់នោះនៅពេលដែលអ្នកចូល(login) ទៅកាន់វែបសាយរបស់ការិយាល័យតម្កល់ដើម្បីតម្កល់លិខិតជូនដំណឹង រឺស្នើសុំរបាយការណ៍ ស្រាវជ្រាវដែលមានការបញ្ជាក់។ ប្រសិនបើក្រុមហ៊ុនអ្នកក្លាយជាអតិថិជននៃការិយាល័យតម្កល់ គណនីរបស់អ្នកអាចនឹងមានចំនួនអ្នកប្រើដែលមានការអនុញ្ញាតិផ្ទាល់ខ្លួនច្រើន (ឧទាហរណ៍ អ្នកគ្រប់គ្រង អ្នកផ្តល់កំចី រឺអ្នកផ្តល់ឥណទាន គណនេយ្យករ ។ល។ យ៉ាងហោចណាស់ម្នាក់ក្នុងចំនោមអ្នកប្រើ ដែលមានការអនុញ្ញាតិទាំងនោះនឹងត្រូវបានចាត់តាំងជាអ្នកគ្រប់គ្រងសុវត្ថិភាពអតិថិជន ដែលមានន័យថាអ្នកប្រើម្នាក់នោះមានសិទ្ធិលើស ពីអ្នកប្រើទូទៅផ្សេងៗទៀត។ សិទ្ធិទាំងនោះនឹងរួមបញ្ចូលទាំងសិទ្ធិបន្ថែម រឺ លុបអ្នកប្រើដែលមានការអនុញ្ញាតិ និង សិទ្ធិកែប្រែពត៌មានរបស់ គណនីអតិថិជន (ឧទាហរណ៍ ការផ្លាស់ប្តូរអាស័យដ្ឋាន)។ អ្នកប្រើទូទៅនឹងមានសិទ្ធិតម្កល់

លិខិតជូនដំណឹង ស្វែងរកលិខិតជូនដំណឹង និងផ្លាស់ប្តូរពាក្យសំងាត់របស់ខ្លួន។អតិថិជនត្រូវមានការទទួលខុសត្រូវលើ សុវត្ថិភាពរាល់ការប្រតិបត្តិនៃអ្នកប្រើប្រាស់របស់ខ្លួននិងសំរាប់គ្រប់ការគិតតំលៃនៃកិច្ចការដែលធ្វើឡើង ដោយអ្នកប្រើប្រាស់របស់ខ្លួន។ ការិយាល័យតម្កល់នឹងផ្តល់នូវរបាយការណ៍ប្រចាំខែជូនដល់អតិថិជននិមួយៗតាមរយៈវែបសាយរបស់ការិយាល័យ តម្កល់ ហើយនឹងផ្ញើរ អ៊ីមែលជូនដំណឹងដល់អតិថិជនអំពីរបាយការណ៍ដែលអាចរកបាននៅក្នុងវែបសាយនេះ។ មានតែអ្នកប្រើនៃគណនីអតិថិជនដែលមាន ការអនុញ្ញាតិទើបអាចមើលរបាយការណ៍បាន។ អតិថិជនត្រូវតែបង់ប្រាក់ក្នុងរយៈពេល៣០ថ្ងៃបន្ទាប់ពីការបរិច្ឆេទនៃរបាយការណ៍។ ប្រសិនបើអតិថិជនខកខានក្នុងការបង់ប្រាក់ ការិយាល័យ តម្កល់នឹងផ្អាកសិទ្ធិរបស់អតិថិជនដើម្បីគិតកម្រៃលើគណនីរហូតដល់ចំនួនទឹកប្រាក់ ត្រូវបានបង់។ អ្នកប្រើដែលមាន ការអនុញ្ញាតិ អាចមើលពត៌មានគណនីអតិថិជន សមតុលបច្ចុប្បន្ននិងរបាយការណ៍មុនៗនៅពេលណា ក៏បាន។ឥឡូវអ្នកអាច" បង្កើតគណនីអតិថិជន" រឺត្រលប់ទៅកាន់ " ទំព័រដើម " ។

## របៀបតម្កល់លិខិតជូនដំណឹង

ដើម្បីតម្កល់លិខិតជូនដំណឹងនៃសិទ្ធិប្រាតិភោគ អ្នកត្រូវតែចូល(login)ទៅកាន់វែបសាយក្នុងនាមជាអ្នកប្រើម្នាក់នៃ គណនីអតិថិជន រឺអ្នកប្រើប្រាស់ម្តងម្កាលដែលបានបង់កំរៃជាមុន។ នៅពេលចូលដល់ទំព័រដំបូងរបស់គណនីអតិថិជន អ្នកនឹងមានសិទ្ធិជ្រើសរើសសកម្មភាពផ្សេងៗដែលអ្នកចង់ធ្វើនៅលើទំព័រនោះ។ ប្រសិនបើអ្នកចង់តម្កល់លិខិតជូន ដំណឹងដំបូងនៃសិទ្ធិប្រាតិភោគ សូមជ្រើសរើសពាក្យថាតម្កល់លិខិតជូនដំណឹងថ្មី ដើម្បីភ្ជាប់ទៅកាន់ទំព័រតម្កល់លិខិត ជូនដំណឹងដំបូង។ ទំព័រតម្កល់មានលក្ខណៈសមញ្ញ និងងាយស្រួលប្រើប្រាស់។ ទំព័រតម្កល់លិខិតជូនដំណឹងដំបូងមានបួនផ្ទាំងដែលអ្នកអាចជ្រើសរើសតាមលំដាប់ណាក៏បាន។

- ផ្ទាំងទីមួយដែលត្រូវបានបង្ហាញនៅពេលដែលអ្នកបើកទំព័រគឺត្រូវបានបំពេញពត៌មានដោយស្វ័យប្រវត្តិអំពីខ្លួនអ្នក រឺក្រុមហ៊ុនអ្នក រឺស្ថាប័ន ហើយនឹងប្រភេទនៃលិខិតជូនដំណឹង។ មានប្រអប់ឆែកមួយ នៅខាងក្រោម ឈ្មោះ និង អាស័យដ្ឋាននៃភាគីតម្កល់ (អ្នក ឬ ក្រុមហ៊ុនរបស់អ្នក)ដែលអ្នកអាចឆែក បើភាគីតម្កល់គឺជា ភាគីមានការធានា។ បើអ្នកឆែកប្រអប់អ្នកអាចរំលងផ្ទាំងភាគីមានការធានា។
- ផ្ទាំងទីពីរគឺសំរាប់កូនបំណុល។ ផ្ទាំងនេះត្រូវបានប្រើសំរាប់បញ្ចូលទិន្នន័យរបស់កូនបំណុល

ម្នាក់ រឺច្រើននាក់ ដែលជាភាគីកូនបំណុលចំពោះកាតព្វកិច្ចនោះ។ ដើម្បីបន្ថែមកូនបំណុល ជាដំបូងសូមចុចប៊ូតុង "បន្ថែមកូនបំណុល" ដើម្បីបើកផ្ទាំងបន្ថែមកូនបំណុល។ ជ្រើសរើសប្រភេទកូនបំណុលដែលត្រូវបញ្ចូល។

- ប្រសិនបើកូនបំណុលជាក្រុមហ៊ុន រឺស្ថាប័ន សូមបញ្ចូលឈ្មោះពិតប្រាកដដូចដែលមាននៅលើឯកសាររបស់ក្រុមហ៊ុន រឺស្ថាប័ន ជាអក្សរឡាតាំងទៅក្នុងប្រអប់ដែលបានបញ្ជាក់។ ប្រសិនបើ កូនបំណុលជាក្រុមហ៊ុន អ្នកអាចទទួលបានឈ្មោះពិតប្រាកដពីបញ្ជីឈ្មោះក្រុមហ៊ុននៅក្នុងក្រសួង ពាណិជ្ជកម្ម។
- ប្រសិនបើកូនបំណុលជាជនជាតិខ្មែរ សូមបញ្ចូលលេខអត្តសញ្ញាណប័ណ្ណដែលមាននៅលើ ប័ណ្ណសំគាល់ខ្លួនរបស់កូនបំណុលទៅក្នុងប្រអប់ដែលបានបញ្ជាក់។
- ប្រសិនបើកូនបំណុលជាជនបរទេស សូមបញ្ចូលនាមត្រកូល និងនាមខ្លួនរបស់កូនបំណុល និងឈ្មោះប្រទេសដែលបានចេញលិខិតឆ្លងដែនដល់ឲ្យកូនបំណុល ទៅក្នុងប្រអប់ដែលបានបញ្ជាក់។ក្នុងករណីណាក៏ដោយ សូមផ្តល់អាស័យដ្ឋានរបស់កូនបំណុលទៅក្នុងប្រអប់អាស័យដ្ឋាន។ ប្រសិនបើមានកូនបំណុលពីរ រឺច្រើននាក់ អ្នកអាចបន្តបន្ថែមពួកគេទៀតបានបន្ទាប់ពីបានបំពេញ ពត៌មានកូនបំណុលមុនរួច ដោយចុចប៊ូតុង បន្ថែមកូនបំណុល។
- ផ្ទាំងទីបីគឺសំរាប់ភាគីមានការធានា។ ផ្ទាំងនេះត្រូវបានប្រើសំរាប់បញ្ចូលពត៌មានរបស់ភាគីមានការធានាម្នាក់ រឺច្រើននាក់ ដែលជាអ្នកដាក់កាតព្វកិច្ចលើលិខិតបំណុល។ សូមបញ្ចូលឈ្មោះនិងអាស័យដ្ឋានរបស់ភាគី មានការធានា ទៅក្នុងប្រអប់ដែលបានបញ្ជាក់។ ប្រសិនបើមានភាគីមានការធានាពីរ រឺច្រើននាក់ អ្នកអាចបន្ត បន្ថែមពួកគេទៀតបានបន្ទាប់ពីបានបំពេញពត៌មានភាគីមានការធានាមុនរួច ដោយជ្រើសរើសពាក្យថា "បន្ថែមភាគីមានការធានា"។
- ផ្ទាំងទីបួនគឺសំរាប់ទ្រព្យធានា។ ផ្ទាំងនេះត្រូវបានប្រើសំរាប់បញ្ចូលការពិពណ៌នាអំពីចលនទ្រព្យដែលជា ទ្រព្យធានាដែលធានាបំណុល។ ការពិពណ៌នាពីទ្រព្យធានាអាចមានលក្ខណៈទូទៅរឺជាក់លាក់ដើម្បីផ្តល់ ពត៌មានដល់អ្នកអានដែលចង់ដឹងថាតើទ្រព្យណាខ្លះដែលជាប់នៅក្នុងសិទ្ធិប្រាតិភោគ។ ប្រសិនបើទ្រព្យធានាជាយានយន្ត សូមបញ្ចូលលេខស៊េរីយានយន្តនោះទៅក្នុងប្រអប់ដែលបានបញ្ជាក់។ ប្រសិនបើមានយានយន្តត្រូវបន្ថែម អ្នកអាចបន្តបន្ថែមវាទៀតបានបន្ទាប់ពីបានបំពេញពត៌មានរបស់ លេខស៊េរីយានយន្តមុនរួច ដោយចុចប៊ូតុង "បន្ថែមលេខស៊េរីយានយន្ត"។

បន្ទាប់ពីផ្ទាំងបញ្ចូលទិន្នន័យទាំងអស់ត្រូវបានបំពេញពត៌មានរួចរាល់ហើយ សូមជ្រើសរើស ពាក្យថា ពិនិត្យ លិខិតជូនដំណឹងឡើងវិញ ដើម្បីបង្ហាញគ្រប់ពត៌មានទាំងអស់នៅក្នុងទំព័រតែមួយសំរាប់ត្រួតពិនិត្យឡើងវិញ។ ប្រសិនបើអ្នកឃើញថានៅមានកំហុសឆ្គង អ្នកអាចត្រលប់ទៅទំព័របញ្ចូលទិន្នន័យវិញដើម្បីធ្វើការកែតំរូវ ដោយជ្រើសរើសពាក្យថា កែតំរូវលិខិតជូនដំណឹង។ ប្រសិនបើគ្រប់ពត៌មានសុទ្ធតែត្រឹមត្រូវ សូមជ្រើសរើស ពាក្យថា "ដាក់ស្នើ" ដើម្បីបញ្ជូនពត៌មានទាំងនោះទៅរក្សាទុកនៅក្នុងឃ្លាំងផ្ទុកទិន្នន័យ (Database) ។ បន្ទាប់ពីលិខិតជូនដំណឹងដំបូង ត្រូវបានដាក់ស្នើដោយចុចប៊ូតុង "បញ្ជាក់" ប្រព័ន្ធនឹងផ្តល់អោយលិខិតជូនដំណឹង នោះនូវលេខតម្កល់ និងកំនត់ត្រានៃកាលបរិច្ឆេទ និងពេលវេលានៃការតម្កល់។ លិខិតជូនដំណឹងពេញលេញនឹង ត្រូវបានបង្ហាញដោយមានទាំងលេខតម្កល់ កាលបរិច្ឆេទ និងពេលវេលាដើម្បីអោយអ្នកអាចធ្វើការបោះពុម្ព រឺរក្សា ទុកជាភស្តុតាងក្នុងការតម្កល់។

## របៀបតម្កល់ការកែប្រែលិខិតជូនដំណឹង

ដើម្បីតម្កល់ការកែប្រែលិខិតជូនដំណឹងដែលមានស្រាប់ អ្នកត្រូវតែចូល (log in) ទៅកាន់វែបសាយក្នុងនាមជាអ្នកប្រើ ម្នាក់នៃគណនីអតិថិជន រឺអ្នកប្រើប្រាស់ម្តងម្កាលដែលបានបង់កំរៃជាមុន។ នៅពេលចូលដល់ទំព័រដំបូងរបស់គណនី អតិថិជន អ្នកនឹងមានសិទ្ធិជ្រើសរើសសកម្មភាពផ្សេងៗដែលអ្នកចង់ធ្វើនៅលើទំព័រនោះ។ ប្រសិនបើ អ្នកចង់ធ្វើការកែ តំរូវ បន្ត រឺបញ្ចប់លើលិខិតជូនដំណឹងដែលមានស្រាប់ សូមជ្រើសរើសពាក្យថា តម្កល់ការកែប្រែលិខិតជូនដំណឹង ដើម្បីភ្ជាប់ទៅកាន់ទំព័រតម្កល់ការកែប្រែលិខិតជូនដំណឹង។ ប្រសិនបើអ្នកជាកូនបំណុលដែលមានឈ្មោះនៅក្នុងលិខិតជូនដំណឹងដែលមានស្រាប់ហើយអ្នកចង់ជំទាស់ទៅនឹងអ្វីដែលមាននៅក្នុងលិខិតនោះសូមជ្រើសរើសពាក្យថា តម្កល់ការកែប្រែលិខិតជូនដំណឹង។

ទំព័រតម្កល់ការកែប្រែលិខិតជូនដំណឹងគឺត្រូវបានប្រើសំរាប់បន្ថែមលិខិតជូនដំណឹងដែលទាក់ទងទៅនឹងលិខិតជូន ដំណឹងដំបូងនៃសិទ្ធិប្រាតិភោគដែលមានស្រាប់។ ប្រភេទនៃការកែប្រែលិខិតជូនដំណឹងមានដូចជាលិខិតជូនដំណឹង វិសោធនកម្ម លិខិតសុំបន្ត លិខិតសុំបញ្ចប់ និងលិខិតសុំកែតំរូវ។ នៅក្នុងទំព័រតម្កល់ការកែប្រែលិខិតជូនដំណឹង អ្នកត្រូវតែផ្តល់លេខតម្កល់របស់លិខិតជូនដំណឹងដំបូងដែលទាក់ទងនឹងការផ្លាស់ប្តូរ និងជ្រើសរើសប្រភេទនៃការ កែប្រែលិខិតជូនដំណឹងដែលអ្នកចង់តម្កល់ បន្ទាប់មកចុចប៊ូតុង "បន្ទាប់" ដើម្បីបន្តប្រតិបត្តិការទំព័រទីពីរនៃការកែប្រែ លិខិតជូនដំណឹង ដែលនឹងបញ្ជាក់ពីប្រភេទនៃការកែប្រែលិខិតជូនដំណឹងដែលអ្នកបានបញ្ចូល។

- ចំពោះលិខិតជូនដំណឹងវិសោធនកម្ម ដំបូងពិនិត្យឈ្មោះនៃភាគីមានការធានានិមួយៗដែលអនុញ្ញាតលើការ វិសោធនកម្ម ដែលមាននៅទំព័រខាងក្រោម។ អ្នកអាច បន្ថែម លុប រឺផ្លាស់ប្តូរពត៌មានលើ កូនបំណុល ភាគីមានការធានា និងទ្រព្យធានា ដោយចុចលើប៊ូតុង "បន្ថែម" ដែលមាននៅទំព័រខាងលើ រឺដោយ ជ្រើសរើស ប្រភេទផ្ទាំងនៃពត៌មាន ដើម្បីបន្ថែម លុប រឺផ្លាស់ប្តូរ។
- ប្រសិនបើវិសោធនកម្ម បន្ថែមកូនបំណុល ភាគីមានការធានា រឺលេខស៊េរីយានយន្ត សូមចុចប៊ូតុង "បន្ថែម" ដែលត្រូវគ្នា។
- ប្រសិនបើវិសោធនកម្ម លុបកូនបំណុល ភាគីមានការធានា រឺលេខស៊េរីយានយន្ត ជ្រើសរើសផ្ទាំង ដែលត្រូវគ្នា និងចុច X ដែលនៅចំហៀងនៃពត៌មានដែលបានបញ្ចូលដើម្បីលុប។
- ប្រសិនបើវិសោធនកម្ម ផ្លាស់ប្តូរពត៌មានកូនបំណុល រឺភាគីមានការធានា ជ្រើសរើសផ្ទាំងដែលត្រូវ និងចុច "កែប្រែ"(រូបខ្មៅដៃ) ដែលនៅចំហៀងនៃពត៌មានដែលបានបញ្ចូលដើម្បីកែប្រែ។ ពត៌មាននឹងបង្ហាញនៅកន្លែងទំព័របន្ថែមដែលអ្នកអាចផ្លាស់ប្តូរពត៌មាន ហើយសូមចុចប៊ូតុង "កែប្រែ"។
- ប្រសិនបើវិសោធនកម្ម ផ្លាស់ប្តូរការពិពណ៌នានៃទ្រព្យធានា សូមចុចផ្ទាំងទ្រព្យធានា ហើយធ្វើការ ផ្លាស់ប្តូរការពិពណ៌នានៅក្នុងប្រអប់អត្ថបទ។
- ប្រសិនបើវិសោធនកម្ម ជំនួសការភ្ជាប់ឯកសារប្រភេទPDFក្នុងផ្ទាំងទ្រព្យធានា សូមចុចប៊ូតុង browseនិងជ្រើសរើសឯកសារថ្មី។ នៅពេលឈ្មោះឯកសារបង្ហាញនៅក្នុងប្រអប់ហើយ អ្នកប្រាកដថាជាឯកសារត្រឹមត្រូវ សូមចុចប៊ូតុង "បន្ថែមការភ្ជាប់"។ ឯកសារថ្មីនឹងត្រូវជំនួស ឯកសារចាស់។
- ចំពោះលិខិតសុំបន្ត ដំបូងពិនិត្យឈ្មោះនៃភាគីមានការធានានិមួយៗដែលអនុញ្ញាតលើការសុំបន្តដែលមាន នៅទំព័រខាងក្រោម។ មិនតម្រូវអោយមានការបញ្ចូលទិន្នន័យទៀតទេ ដូច្នេះអ្នកអាចចុចប៊ូតុង "ពិនិត្យឡើងវិញ" ហើយចុចប៊ូតុង "បញ្ជាក់" នៅក្នុងទំព័រពិនិត្យឡើងវិញ។ ប្រសិនបើការផ្លាស់ប្តូរត្រូវបានយល់ព្រមដោយប្រព័ន្ធសុពលភាពនៃលិខិតជូនដំណឹងនឹងបន្តរយៈពេល ប្រាំឆ្នាំទៀតដោយស្វ័យប្រវត្តិ។ ប្រសិនបើកាលបរិច្ឆេទបច្ចុប្បន្នមិនស្ថិតនៅក្នុងរយៈពេល៦ខែចុងក្រោយ មុនកាលបរិច្ឆេទផុតកំណត់នៃលិខិតជូនដំណឹងដំបូង ប្រព័ន្ធនឹងបដិសេធន៍ការបន្តសុពលភាពនៃលិខិត ជូនដំណឹង។
- ចំពោះលិខិតសុំបញ្ចប់ ដំបូងពិនិត្យឈ្មោះនៃភាគីមានការធានានិមួយៗដែលអនុញ្ញាតលើការ

សុំបញ្ចប់ ដែល មាននៅទំព័រខាងក្រោម។ មិនតម្រូវអោយមានការបញ្ចូលទិន្នន័យទៀតទេ ដូច្នេះអ្នកអាចចុចប៊ូតុង "ពិនិត្យឡើងវិញ" ហើយចុចប៊ូតុង "បញ្ជាក់" នៅក្នុងទំព័រពិនិត្យឡើងវិញ។ លិខិតសុំបញ្ចប់នឹងត្រូវបញ្ជូន ទៅទុកជាឯកសារ ហើយនឹងត្រូវបានបង្ហាញនៅក្នុង លទ្ធផលនៃការស្រាវជ្រាវរករួមទាំងលិខិតជូនដំណឹង ដំបូងរបស់វាផងដែរ។ មិនមានការផ្លាស់ប្តូរស្ថានភាពនៃលិខិតជូនដំណឹងដំបូងទេដូច្នេះលិខិតជូនដំណឹង ដំបូងនឹងត្រូវបាន រាយការណ៍ នៅក្នុងលទ្ធផលនៃការស្រាវជ្រាវរករហូតដល់កាលបរិច្ឆេទផុតកំណត់ធម្មតា នៃលិខិតជូនដំណឹងនោះ។

- ចំពោះលិខិតសុំកែតំរូវ ទំព័រទីពីរជាទំព័រលិខិតសុំកែតំរូវ។ ដំបូងអ្នកគួរតែពិនិត្យឈ្មោះនៃកូនបំណុលនិមួយៗ ដែលអនុញ្ញាតលើការ សុំកែតំរូវ ដែលមាននៅទំព័រខាងក្រោម។ សូមបញ្ចូលមូលហេតុនៃការធ្វើលិខិត សុំកែតំរូវនៅក្នុងប្រអប់បរិយាយ។ សូមចុចប៊ូតុង "ពិនិត្យឡើងវិញ" ហើយចុចប៊ូតុង "បញ្ជាក់" នៅក្នុងទំព័រ ពិនិត្យឡើងវិញ។ លិខិតសុំកែតំរូវមិនមានផលប៉ះពាល់តាមផ្លូវច្បាប់ចំពោះលិខិតជូនដំណឹងដំបូងទេ។

បន្ទាប់ពីលិខិតសុំកែតំរូវត្រូវបានដាក់ស្នើដោយចុចប៊ូតុង "បញ្ជាក់" ប្រព័ន្ធនឹងផ្តល់អោយលិខិតជូនដំណឹងនោះ នូវលេខ តម្កល់ និងកំនត់ត្រានៃកាលបរិច្ឆេទ និងពេលវេលានៃការតម្កល់។ លិខិតជូនដំណឹងពេញលេញនឹង ត្រូវបានបង្ហាញដោយមានទាំងលេខតម្កល់ កាលបរិច្ឆេទ និងពេលវេលា ដើម្បីអោយអ្នកអាចធ្វើការបោះពុម្ព រឺរក្សាទុកជាភស្តុតាងក្នុង ការតម្កល់។

## របៀបស្រាវជ្រាវរកលិខិតជូនដំណឹង

ប្រសិនបើអ្នកចង់ស្រាវជ្រាវរកលិខិតជូនដំណឹង ដែលមានការបញ្ជាក់ពីអត្តសញ្ញាណកូនបំណុលរឺលិខិតជូនដំណឹង ដែលមានលេខស៊េរីយានយន្តជាក់លាក់ណាមួយ រឺប្រសិនបើអ្នកចង់ស្រាវជ្រាវរកលិខិតជូនដំណឹងតាមរយៈលេខតម្កល់ អ្នកអាចជ្រើសរើសពាក្យថា "ស្រាវជ្រាវរក" នៅក្នុងទំព័រដោយមិនចាំបាច់ចូល(log in) រឺនៅក្នុងទំព័រដំបូង បន្ទាប់ពីអ្នកបានចូល(log in)។ ទោះជាយ៉ាងណាក៏ដោយប្រសិនបើអ្នកចង់ ស្រាវជ្រាវរករបាយការណ៍ស្រាវជ្រាវ ដែលមានការបញ្ជាក់ អ្នកត្រូវតែចូល(log in) ហើយជ្រើសរើសពាក្យថា "ស្រាវជ្រាវរបាយការណ៍ស្រាវជ្រាវដែល មានការបញ្ជាក់" នៅក្នុងទំព័រដំបូង ព្រោះថានឹងមានការគិតកំរៃចំពោះរបាយការណ៍ស្រាវជ្រាវដែលមានការបញ្ជាក់។ បន្ទាប់ពីអ្នកជ្រើសរើសពាក្យថា "ស្រាវជ្រាវរក" ទំព័រស្រាវជ្រាវរកនឹងត្រូវបានបើក។

- ទំព័រស្រាវជ្រាវរកមានប្រភេទផ្ទាំងផ្សេងៗនៃលក្ខខណ្ឌស្រាវជ្រាវដែលអ្នកអាចជ្រើសរើសទោះបីជាអ្នកបាន រឺមិនបានចូល (log in) ក៏ដោយ។
    - ប្រសិនបើអ្នកស្គាល់លេខតម្កល់របស់លិខិតជូនដំណឹងដំបូង សូមជ្រើសរើសផ្ទាំងលេខតម្កល់ បញ្ចូលលេខតម្កល់ទៅក្នុងប្រអប់លេខតម្កល់ដែលបានបង្ហាញហើយចុចប៊ូតុង "ដាក់ស្នើ"។
    - ប្រសិនបើអ្នកចង់ស្រាវជ្រាវរកលិខិតជូនដំណឹងដែលមានការបញ្ជាក់ពី អត្តសញ្ញាណកូនបំណុល សូមជ្រើសរើសផ្ទាំង កូនបំណុល។ ក្នុងផ្ទាំងកូនបំណុល ជ្រើសរើសប្រភេទកូនបំណុលដែលអ្នកចង់ ស្រាវជ្រាវ។
- ប្រសិនបើកូនបំណុលជាជនជាតិខ្មែរ សូមបញ្ចូលលេខអត្តសញ្ញាណប័ណ្ណទៅក្នុងប្រអប់ ដែលបានបង្ហាញ ហើយចុចប៊ូតុង "ដាក់ស្នើ"។
- ប្រសិនបើអ្នកស្រាវជ្រាវរកលិខិតជូនដំណឹងដែលមានកូនបំណុលជាក្រុមហ៊ុន រឺស្ថាប័នសូមបញ្ចូលឈ្មោះក្រុមហ៊ុន រឺស្ថាប័ននោះ ដូចដែលមាននៅលើ ឯកសាររបស់ក្រុមហ៊ុន រឺស្ថាប័នទៅក្នុងប្រអប់ដែលបានបង្ហាញ ហើយចុចប៊ូតុង "ដាក់ស្នើ"។
- ប្រសិនបើអ្នកស្រាវជ្រាវរកលិខិតជូនដំណឹងដែលមានកូនបំណុលជាជនបរទេសសូមបញ្ចូលនាមត្រកូលរបស់គាត់ទៅក្នុងប្រអប់ដែលបានបង្ហាញ ហើយចុចប៊ូតុង"ដាក់ស្នើ"។
    - ប្រសិនបើអ្នកស្វែងរកលិខិតជូនដំណឹងដែលទាក់ទងនឹងទ្រព្យធានាដែលមានលេខស៊េរីយានយន្តជាក់លាក់ណាមួយ សូមជ្រើសរើសផ្ទាំង លេខស៊េរីយានយន្ត និងបញ្ចូលលេខស៊េរីនោះទៅក្នុង ប្រអប់ដែលបានបង្ហាញ ហើយចុចប៊ូតុង "ដាក់ស្នើ"។
- នៅពេលដែលការស្រាវជ្រាវរកត្រូវបានដាក់ស្នើ ប្រព័ន្ធនឹងកំណត់យករាល់លិខិតជូនដំណឹងដែលត្រូវគ្នា ហើយនឹងបង្ហាញចេញនូវរាល់ពត៌មាននៃលិខិតជូនដំណឹងនិមួយៗទៅតាមលេខលំដាប់នៃលិខិតជូនដំណឹង ព្រមទាំងបង្ហាញនូវការកែប្រែលិខិតជូនដំណឹងទាំងឡាយណាដែលមានទំនាក់ទំនងជាមួយលិខិតជូនដំណឹង ដំបូងនិមួយៗ។
- ប្រសិនបើអ្នកបានចូល(log in) ទំព័រស្រាវជ្រាវរកនឹងអនុញ្ញាតអោយអ្នកស្នើសុំលទ្ធផលដែលមានការ បញ្ជាក់។ ប្រសិនបើអ្នកស្នើសុំរបាយការណ៍ស្រាវជ្រាវដែលមានការបញ្ជាក់លទ្ធផលនៃការស្រាវជ្រាវរកនឹងមានបន្ថែមនូវការបញ្ជាក់ជាមួយនឹងហត្ថលេខានៃការបញ្ជាក់របស់អាជ្ញាធរ។ លទ្ធផលក៏បានបង្ហាញ ផងដែរនូវលេខពិសេសសំរាប់សំគាល់របាយការណ៍នោះ ដែលលេខនេះនឹងអាចត្រូវបានប្រើសំរាប់ដកយក របាយការណ៍ពីមូលដ្ឋានផ្ទុកទិន្នន័យ(Database)នៃការិយាល័យ

តម្កល់ ប្រសិនបើអ្នកត្រូវការនៅពេលក្រោយ។ របាយការណ៍ស្រាវជ្រាវដែលមានការបញ្ជាក់គឺជាកំនត់ត្រាផ្លូវការនៃការិយាល័យតម្កល់ ហើយអ្នកអាចបោះពុម្ពរបាយការណ៍នោះយកមកធ្វើជាភស្តុតាងនៅក្នុងស្ថានភាពណាមួយដែលទាក់ទងទៅនឹងកំនត់ត្រា ក្នុងកំឡុងពេលនៃកាលបរិច្ឆេទនៃរបាយការណ៍នោះ។ ប្រសិនបើតុលាការបដិសេធមិនទទួលស្គាល់របាយការណ៍ស្រាវជ្រាវដែលមានការបញ្ជាក់នេះ អ្នកអាចស្នើសុំលិខិតបញ្ជាក់ពីយថាភាពរបស់អ្នកដែល មានចុះហត្ថលេខាក្នុងសំណៅដើមពីការិយាល័យតម្កល់ ដោយផ្តល់នូវលេខរបាយការណ៍ស្រាវជ្រាវដែល មានការបញ្ជាក់នោះ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

លេខ : ៧២៥ សហវ.ប្រក.៦២៣

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ ២០០៧

# ប្រកាសអន្តរក្រសួង

## ស្តីពី

## កម្រៃសេវាតម្កល់ និងស្រាវជ្រាវកំណត់ជូនដំណឹង នៃប្រតិបត្តិការដែលមានកិច្ចធានា

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

និង ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើ រដ្ឋធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៧/០១២ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៧ ប្រកាសអោយប្រើច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ ត្រូវបានកែប្រែដោយ ច្បាប់វិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសឱ្យប្រើដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/ ០៣៥ ចុះថ្ងៃ ទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៦ និង ប្រកាសលេខ ១៤០១ សហវ.ប្រក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនប្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសំរួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អនុវត្តតាមអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- អនុវត្តតាមបទបញ្ជារបស់រាជរដ្ឋាភិបាលកម្ពុជា លេខ ០៤ បប ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញប្រកាសរបស់ក្រសួងពាណិជ្ជកម្ម លេខ ១២៣ MOC/SM 2007 ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៧ ស្តីពីការបង្កើតការិយាល័យតម្កល់ប្រតិបត្តិការដែលមានកិច្ចធានា
- យោងតាមតម្រូវការចាំបាច់ដើម្បីអនុវត្តនូវមាត្រាទាំងឡាយនៅក្នុងជំពូកទី ៣ "ការតម្កល់លិខិតជូនដំណឹង" នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា

## <u>សម្រេច</u>

**ប្រការ ១:** អនុញ្ញាតឱ្យក្រសួងពាណិជ្ជកម្មយកកម្រៃលើសេវាតម្កល់ និងស្រាវជ្រាវលិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានាក្នុងគេហទំព័រ (វេបសាយ) របស់ការិយាល័យតម្កល់លិខិតជូនដំណឹងប្រតិបត្តិការដែលមានកិច្ចធានា នៃក្រសួងពាណិជ្ជកម្ម ។

**ប្រការ ២:** កម្រៃសេវាតម្កល់ និងស្រាវជ្រាវរកលិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានា ត្រូវបានកំណត់ ដូចខាងក្រោម :

| ល.រ | បរិយាយសេវា | កម្រៃសេវា |
|---|---|---|
| ១ | តម្កល់លិខិតជូនដំណឹងដំបូង លើសិទ្ធិប្រាតិភោគ ( សំរាប់រយៈពេល ៥ ឆ្នាំ) | ១០.000 រៀល |
| ២ | តម្កល់វិសោធនកម្មលើលិខិតជូនដំណឹង ( មួយដង ) | ១០.000 រៀល |
| ៣ | តម្កល់លិខិតសុំបន្ត ( សំរាប់រយៈពេល ៥ ឆ្នាំ) | ១០.000 រៀល |
| ៤ | តម្កល់លិខិតសុំកែតម្រូវ ( មួយដង ) | ១០.000 រៀល |
| ៥ | តម្កល់លិខិតសុំបញ្ចប់ ( មួយដង) | ១០.000 រៀល |
| ៦ | សេវារៀបចំរបាយការណ៍ស្រាវជ្រាវដែលមានការបញ្ជាក់ ( មួយដង ) | ១០.000 រៀល |

ដោយឡែក ចំពោះការសុំតម្កល់សិទ្ធិឃាត់ទុកពីសំណាក់ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល គឺមិនគិតកម្រៃឡើយ ។

**ប្រការ ៣:** ក- ការប្រមូលកម្រៃសេវា ពីសំណាក់អ្នកប្រើប្រាស់សេវារបស់ការិយាល័យតម្កល់លិខិតជូនដំណឹងប្រតិបត្តិការដែលមានកិច្ចធានាត្រូវធ្វើឡើងតាមរយៈធនាគារពាណិជ្ជ ដែលជ្រើសរើសដោយក្រសួងពាណិជ្ជកម្ម ។

ខ- ក្រសួងពាណិជ្ជកម្មត្រូវចុះកិច្ចសន្យាជាមួយធនាគារពាណិជ្ជ ដែលបានជ្រើសរើសសម្រាប់សេវានោះ ហើយត្រូវផ្សាយឈ្មោះធនាគារ នៅលើគេហទំព័រ (វេបសាយ) របស់ការិយាល័យតម្កល់លិខិតជូនដំណឹងប្រតិបត្តិការដែលមានកិច្ចធានា ។ ក្រសួងពាណិជ្ជកម្ម (ការិយាល័យតម្កល់លិខិតជូនដំណឹងប្រតិបត្តិការដែលមានកិច្ចធានា) ត្រូវបើកគណនីមួយនៅធនាគារដែលបានចុះកិច្ចសន្យាជាមួយដើម្បីទទួលប្រាក់កម្រៃពីសេវានេះ ដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

គ- ធនាគារពាណិជ្ជ ដែលបានចុះកិច្ចសន្យាជាមួយក្រសួងពាណិជ្ជកម្ម ត្រូវបង្វែរទឹកប្រាក់ចំណូលរៀងរាល់ ៣ (បី) ខែម្តង ពីគណនីរបស់ ការិយាល័យតម្កល់លិខិតជូនដំណឹងប្រតិបត្តិការដែលមានកិច្ចធានា នៃក្រសួងពាណិជ្ជកម្ម ទៅគណនីចរន្តថវិការដ្ឋជាប្រាក់រៀលលេខ 0100-39.1211-T001 របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅធនាគារជាតិនៃកម្ពុជា បន្ទាប់ពីបានកាត់កម្រៃសេវាធនាគាររួចហើយ ដូចមានចែងក្នុងកិច្ចសន្យា ។

**ប្រការ ៤ :** ចំណូលពីសេវានេះ ត្រូវកត់ត្រាទៅក្នុង ជំពូក ៧៣ គណនី ៧៣០ អនុគណនី ៧៣០៨ នៃមាតិកាថវិកាទូទៅរបស់រដ្ឋ ។ ក្រសួងពាណិជ្ជកម្មត្រូវផ្ញើរបាយការណ៍ចំណូលពីសេវានេះជារៀងរាល់ត្រីមាស មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ) ។

**ប្រការ ៥ :** ការផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្ត ចំពោះការគ្រប់គ្រងការប្រមូលចំណូលនេះ នឹងត្រូវរៀបចំប្រកាសអន្តរក្រសួងមួយដោយឡែក តាមគោលការណ៍សម្រេចរបស់រាជរដ្ឋាភិបាល។

**ប្រការ ៦ :** គ្រប់អង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងពាណិជ្ជកម្ម និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៧ :** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចាម ប្រសិទ្ធ

ចម្លងជូន :

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន និង សាលាខេត្ត-ក្រុង
  " ដើម្បីជូនជ្រាប និង ផ្សព្វផ្សាយ "
- ដូចប្រការ ៦
  "ដើម្បីអនុវត្ត"
- រាជកិច្ច " ដើម្បីចុះផ្សាយ "
- ឯកសារ និង កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

KINGDOM OF CAMBODIA

Nation - Religion - King

ក្រសួងពាណិជ្ជកម្ម

Ministry of Commerce

លេខ ៣០៤៤ ព.ណ.....ដ.ក.ក

ភ្នំពេញ, ថ្ងៃទី ២៧ ខែ ៩ ឆ្នាំ ២០០៧

## សេចក្តីជូនដំណឹង

### ស្តីពី

### ការតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានា និងការស្រាវជ្រាវរកកំណត់ត្រាតាមមធ្យោបាយអេឡិចត្រូនិច

អនុលោមតាមច្បាប់ស្តីពី ប្រតិបត្តិការដែលមានកិច្ចធានា ដែលប្រកាសឱ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម /០៥០៧/០១២ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៧ និង អនុលោមតាម ប្រកាសអន្តរក្រសួងស្តីពី កម្រៃសេវាតម្កល់ និងស្រាវជ្រាវលិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានា លេខ ៨២៥ សហវប្រក.ចមព ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០០៧ ។ ក្រសួងពាណិជ្ជកម្ម សូមប្រកាសជូនដំណឹងដល់សាធារណៈជនអោយបានជ្រាបថា: ការតម្កល់លិខិតជូនដំណឹង ជាមួយការិយាល័យតម្កល់លិខិតជូនដំណឹងនៃក្រសួងពាណិជ្ជកម្ម សាធារណៈជនអាចធ្វើតាមមធ្យោបាយអេឡិចត្រូនិចតាម រយៈគេហទំព័រ www.setfo.gov.kh ។

១. តាមរយៈគេហទំព័ររបស់ការិយាល័យតម្កល់លិខិតជូនដំណឹង សាធារណៈជនអាច :

- តម្កល់លិខិតជូនដំណឹងដំបូង
- តម្កល់វិសោធនកម្មលើលិខិតជូនដំណឹង
- តម្កល់លិខិតសុំបន្ត
- តម្កល់លិខិតសុំកែតម្រូវ
- តម្កល់លិខិតសុំបញ្ចប់

២. សាធារណៈជនអាចមកធ្វើការបញ្ជាក់លើកំណត់ត្រានៃការតម្កល់នៅការិយាល័យតម្កល់លិខិតជូនដំណឹងនៃនាយកដ្ឋាននីតិកម្ម ក្រសួងពាណិជ្ជកម្មបានរាល់ម៉ោងធ្វើការ ។

សេចក្តីជូនដំណឹងនេះត្រូវអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គឹម_ស៊ីថន

ចំលងជូន

- មន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង ដើម្បីផ្សព្វផ្សាយ
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០២៥ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១០

លិខិតចូល
ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ 2010

# ប្រកាស
# ស្តីពី
# ការផ្តល់អាជ្ញាបណ្ណអាជីវកម្មទទួលបញ្ញើ និងទិញ-លក់ទ្រព្យបញ្ញើ និង អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៤ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការចាត់តាំងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/១២០៨/០២០ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩
- បានឃើញ ក្រឹត្យច្បាប់លេខ ៣៨ ក្រ.ច ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៨៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៨
- បានឃើញ អនុក្រឹត្យលេខ ០៤ អនក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និង អនុក្រឹត្យលេខ ២០អនក្រ/បក ចុះថ្ងៃទី ២៩ ខែ មិនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និងការកែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ១៣៤.អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និង រដ្ឋាករ នាយកដ្ឋានពន្ធដារ និង រតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អោយទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ១០ ខែ មិនា ឆ្នាំ ២០០៩ លើលិខិតលេខ ១១៦៨ សហវ ចុះថ្ងៃទី ០៥ ខែ មិនា ឆ្នាំ ២០០៩ ស្តីពីការគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ
- យោងតាមចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១០ លើលិខិតលេខ ០៨២ សហវ ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១០ ស្តីពីការគ្រប់គ្រង ការត្រួតពិនិត្យ និងការផ្តល់អាជ្ញាប័ណ្ណអាជីវកម្ម ទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន
- បានឃើញ ប្រកាសលេខ ៥៨៤ សហវ.ប្រក ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៥ ស្តីពីការកែសម្រួល ការរៀបចំ និង ការប្រព្រឹត្តទៅនៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
- យោងតាមតំរូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

### ប្រការ១: គោលដៅ

ប្រកាសនេះមានគោលដៅអនុវត្តចំពោះប្រតិបត្តិការខ្ចីប្រាក់ដែលមានវត្ថុដាក់ធានាជាទ្រព្យផ្សេងៗ នៅកន្លែង អាជីវកម្មស្របច្បាប់ណាមួយដែលមានទីតាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រៅពីគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ ដែលស្ថិតនៅក្រោមច្បាប់ស្តីពី គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ ។

### ប្រការ២: គោលបំណង

ប្រកាសនេះមានគោលបំណងកំណត់នូវវិធានការជាមូលដ្ឋានគ្រឹះសម្រាប់គ្រប់គ្រងអាជីវកម្មដើម្បី :

-កែលំអ និងតំរង់ទិសដល់ប្រតិបត្តិការអាជីវកម្ម ឱ្យអនុវត្តបានត្រឹមត្រូវស្របតាមក្រមសីលធម៌វិជ្ជាជីវៈ ។

-ការដាក់បញ្ចាំ ឬដាក់ប្រាតិភោគដោយអនុប្បទានទ្រព្យសម្បត្តិ ឬរបស់របរ ឬទំនិញផ្សេងៗ ធ្វើឡើងតាម រយៈកន្លែងអាជីវកម្មដែលទទួលបានអាជ្ញាប័ណ្ណពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីងាយស្រួលដល់ការគ្រប់គ្រង និង កាត់បន្ថយបាននូវហានិភ័យមួយចំនួនដែលអាចកើតមានឡើងជាយថាហេតុ ។

-សំរួលដល់វិនិយោគិន និងប្រជាពលរដ្ឋដែលមានបំណងដាក់បញ្ចាំ ឬដាក់ប្រាតិភោគដោយអនុប្បទានទ្រព្យ សម្បត្តិ ឬរបស់របរ ឬទំនិញផ្សេងៗឱ្យទទួលបាននូវសេវាល្អប្រសើរ និងតំលៃមួយសមស្របតាមថ្លៃទីផ្សារ ។

-បង្កើនការគ្រប់គ្រងការពារសន្តិសុខសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គមតាមរយៈការត្រួតពិនិត្យ ការពារ អំពើចោរកម្មទ្រព្យសម្បត្តិ ។

-បង្កើនភាពជឿទុកចិត្តដល់អតិថិជន អាជីវករ និងអ្នកទិញទ្រព្យពីកន្លែងអាជីវកម្ម

-ធានាការទូទាត់ និងរក្សាទុកទ្រព្យដែលអាចទទួលយកបានរវាងអតិថិជន និងអាជីវករ

-បង្កើនប្រាក់ចំណូលជាតិតាមរយៈការយកពន្ធអាករ និងការបង់ថ្លៃសេវាផ្សេងៗ

ប្រការ៣: និយមន័យ

- **"ក្រសួង"** សំដៅដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- **"អាជីវកម្ម"** សំដៅដល់អាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ ឬ អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន។

- **"អាជីវករ"** សំដៅដល់អ្នកទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ ឬអ្នកទទួលប្រាតិភោគដោយអនុប្បទាន ដែលជារូបវ័ន្តបុគ្គល ឬនីតិបុគ្គលសញ្ជាតិខ្មែរដែលបានចុះបញ្ជីពាណិជ្ជកម្មស្របច្បាប់ ដើម្បីប្រកបអាជីវកម្មឱ្យខ្ចីប្រាក់ដោយយកទ្រព្យផ្សេងៗដាក់ធានា។

- **"បញ្ចាំ"** សំដៅទៅលើការណ៍ដែលអតិថិជនដាក់នូវចលនវត្ថុ ឯកសារបញ្ជាក់សិទ្ធិកាន់កាប់អចលនវត្ថុ ឬឯកសារផ្សេងៗ ជាមួយអាជីវករ ដើម្បីធានាដល់ការទូទាត់សងប្រាក់កម្ចី និងការប្រាក់។

- **"ប្រាតិភោគដោយអនុប្បទាន"** សំដៅទៅលើការណ៍ដែលអតិថិជនធ្វើអនុប្បទាននូវចលនវត្ថុរបស់ខ្លួនជាកំណត់ជាមួយអាជីវករ ដើម្បីធានាដល់ការទូទាត់សងប្រាក់កម្ចី និងការប្រាក់។

- **"អតិថិជន"** សំដៅដល់អ្នកដាក់បញ្ចាំ ឬអ្នកដាក់ប្រាតិភោគដោយអនុប្បទានដែលជា រូបវ័ន្តបុគ្គល ឬនីតិបុគ្គលដែលយកទ្រព្យសម្បត្តិ ឬរបស់របរ ឬទំនិញផ្សេងៗទៅដាក់ធានាជាមួយនឹងអាជីវករ ដើម្បីទទួលបានប្រាក់កម្ចី ។

- **"កិច្ចសន្យា"** សំដៅដល់កិច្ចសន្យាបញ្ចាំ ឬកិច្ចសន្យាប្រាតិភោគដោយអនុប្បទាន ដែលធ្វើឡើងរវាងអតិថិជនជាមួយនឹងអាជីវករលើការដាក់ទ្រព្យធានា ។

- **"កន្លែងអាជីវកម្ម"** សំដៅដល់ហាងទទួលបញ្ចាំ ឬក្រុមហ៊ុនទទួលបញ្ចាំ ឬហាងទទួលប្រាតិភោគដោយអនុប្បទាន ឬក្រុមហ៊ុនទទួលប្រាតិភោគដោយអនុប្បទានរួមមាន : អាគារ លំនៅដ្ឋាន ឃ្លាំង ឬទីកន្លែង អាជីវកម្មផ្សេងៗទៀតដែលត្រូវបានជ្រើសរើសដើម្បីធ្វើជាទីកន្លែងសម្រាប់ធ្វើអាជីវកម្ម ។

- **"ទ្រព្យ"** សំដៅដល់ទ្រព្យបញ្ចាំរួមមានចលនវត្ថុ ឬឯកសារបញ្ជាក់សិទ្ធិកាន់កាប់អចលនវត្ថុ និងឯកសារផ្សេងៗ ដែលជាកម្មវត្ថុយកមកដាក់បញ្ចាំ និង សំដៅដល់ទ្រព្យប្រាតិភោគដោយអនុប្បទានដែលមានចលនវត្ថុជាកម្មវត្ថុយកមកដាក់ធ្វើប្រាតិភោគដោយអនុប្បទាន។

- **"អាជ្ញាប័ណ្ណ"** សំដៅដល់លិខិតអនុញ្ញាតប្រកបអាជីវកម្មទទួលបញ្ចាំ ឬអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទានដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

- **"លោះ"** គឺជាការទទួលយកមកវិញនូវទ្រព្យ ដែលបានមកពីការសងប្រាក់កម្ចីរួមទាំងការប្រាក់របស់អតិថិជន ជូនទៅអាជីវករដូចដែលមានចែងនៅក្នុងកិច្ចសន្យា។

## ប្រការ៤: ការអនុញ្ញាតធ្វើអាជីវកម្ម

គ្មានរូបវ័ន្តបុគ្គល ឬនីតិបុគ្គលណាម្នាក់អាចធ្វើអាជីវកម្មបានទេ ប្រសិនបើគ្មានអាជ្ញាប័ណ្ណពីក្រសួង។

## ប្រការ៥: ការដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ

រូបវ័ន្តបុគ្គល ឬនីតិបុគ្គលទាំងអស់ដែលកំពុងធ្វើអាជីវកម្ម ឬមានបំណងចង់ធ្វើអាជីវកម្មត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណនៅក្រសួង ។

ពាក្យស្នើសុំអាជ្ញាប័ណ្ណ ត្រូវបានរៀបចំជូនដោយនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ប្រការ៦: ថ្លៃអាជ្ញាប័ណ្ណ

អាជីវករត្រូវបង់ថ្លៃអាជ្ញាប័ណ្ណដូចខាងក្រោម :

សំរាប់អាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ

| | | |
|---|---|---|
| -អាជ្ញាប័ណ្ណថ្មីចំនួន | ២.០០០.០០០ រៀល | (ពីរលានរៀល) |
| -បន្តអាជ្ញាប័ណ្ណចំនួន | ២.០០០.០០០ រៀល | (ពីរលានរៀល) |
| -អាជ្ញាប័ណ្ណសាខាចំនួន | ១.០០០.០០០ រៀល | (មួយលានរៀល) |
| -បន្តអាជ្ញាប័ណ្ណសាខាចំនួន | ១.០០០.០០០ រៀល | (មួយលានរៀល) |

សំរាប់អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន

| | | |
|---|---|---|
| -អាជ្ញាប័ណ្ណថ្មីចំនួន | ១.០០០.០០០ រៀល | (មួយលានរៀល) |
| -បន្តអាជ្ញាប័ណ្ណចំនួន | ១.០០០.០០០ រៀល | (មួយលានរៀល) |
| -អាជ្ញាប័ណ្ណសាខាចំនួន | ៥០០.០០០ រៀល | (ប្រាំសែនរៀល) |
| -បន្តអាជ្ញាប័ណ្ណសាខាចំនួន | ៥០០.០០០ រៀល | (ប្រាំសែនរៀល) |

អាជីវករត្រូវបង់ប្រាក់ថ្លៃអាជ្ញាប័ណ្ណដូចមានចែងខាងលើទៅអគ្គនាយកដ្ឋានរតនាគារជាតិ ឬធនាគារជាតិនៃកម្ពុជា តាមដីកាអមរបស់នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ប្រការ៧: សុពលភាព និងការបន្តសុពលភាពអាជ្ញាប័ណ្ណ

អាជ្ញាបណ្ណ័មានសុពលភាពរយៈពេល ០១ ឆ្នាំ (មួយឆ្នាំ) គិតចាប់ពីថ្ងៃចុះហត្ថលេខា ។

អ្នកកាន់អាជ្ញាប័ណ្ណត្រូវដាក់ពាក្យស្នើសុំបន្តសុពលភាពឱ្យបាន ៣០ ថ្ងៃ (សាមសិបថ្ងៃ) មុនពេលអាជ្ញាប័ណ្ណនោះអស់សុពលភាព ។

ក្រសួងមានសិទ្ធិបន្តអាជ្ញាប័ណ្ណដោយមានដាក់ ឬមិនមានដាក់លក្ខខណ្ឌ ឬមិនបន្តអាជ្ញាប័ណ្ណប្រសិនបើអ្នកកាន់អាជ្ញាប័ណ្ណមិនបានបំពេញទៅតាមលក្ខខណ្ឌតម្រូវណាមួយដែលក្រសួងបានកំណត់ ។

ក្នុងករណីអ្នកកាន់អាជ្ញាប័ណ្ណមិនបន្តសុពលភាពអាជ្ញាប័ណ្ណ ត្រូវជូនដំណឹងជាលាយល័ក្ខអក្សរដោយភ្ជាប់មកជាមួយ នូវឯកសារពាក់ព័ន្ធព្រមទាំងបញ្ជាក់អំពីមូលហេតុអោយបានត្រឹមត្រូវមកក្រសួងក្នុងរយៈពេល ៣០ ថ្ងៃ (សាមសិបថ្ងៃ) មុន ។

## ប្រការ៨: លក្ខខណ្ឌនៃការផ្តល់អាជ្ញាប័ណ្ណ

ក្រសួងនឹងផ្តល់អាជ្ញាប័ណ្ណ ជូនដល់អាជីវករទាំងឡាយណាដែលបានបំពេញលក្ខខណ្ឌដូចខាងក្រោម :

-ជារូបវ័ន្តបុគ្គលដែលមានសញ្ជាតិខ្មែរ ហើយមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ ឬនីតិបុគ្គលមានសញ្ជាតិខ្មែរដែលបានបំពេញបែបបទ និងចុះបញ្ជីត្រឹមត្រូវតាមច្បាប់

-លិខិតថ្កោលទោស ឬលិខិតបញ្ជាក់កិរិយាមាយាទដែលចេញដោយក្រសួងយុត្តិធម៌ ឬពីអាជ្ញាធរពាក់ព័ន្ធ

-បានចុះបញ្ជីពាណិជ្ជកម្មស្របច្បាប់នៅក្រសួងពាណិជ្ជកម្ម

-មានអាស័យដ្ឋានស្នាក់នៅច្បាស់លាស់ក្នុងព្រះរាជាណាចក្រកម្ពុជា

-ត្រូវបង្ហាញពីកន្លែងសុវត្ថិភាពដើម្បីធានាថែរក្សា និងការពារការខូចខាត ឬការបាត់បង់ទ្រព្យ

-សំរាប់អាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំត្រូវមានដើមទុនអាជីវកម្មអប្បបរមាចំនួន ៨០.០០០.០០០ រៀល (ប៉ែតសិបលានរៀល) និងដាក់ប្រាក់តំកល់ចំនួន ១០% នៃដើមទុនអាជីវកម្ម ឬប្រាក់តំកល់អតិបរមាចំនួន ៤០.០០០.០០០ រៀល (សែសិបលានរៀល) ទៅក្នុងគណនីរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលមានចែងនៅក្នុងសៀវភៅបន្ទុក ។

-សំរាប់អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន ត្រូវមានដើមទុនអាជីវកម្មអប្បបរមាចំនួន ៤០.០០០.០០០ រៀល (សែសិបលានរៀល) និងដាក់ប្រាក់តំកល់ចំនួន ១០% នៃដើមទុនអាជីវកម្ម ឬប្រាក់តំកល់អតិបរមាចំនួន ៤០.០០០.០០០ រៀល (សែសិបលានរៀល) ទៅក្នុងគណនីរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលមានចែងនៅក្នុងសៀវភៅបន្ទុក ។

-អាជីវករអាចដកប្រាក់តំកល់ខាងលើមកវិញបាន លុះត្រាតែមានការអនុញ្ញាតិពីក្រសួងដូចដែលមានចែងនៅក្នុងសៀវភៅបន្ទុក ។

-ត្រូវមានលិខិតបញ្ជាក់អាស័យដ្ឋានកន្លែងអាជីវកម្មអោយបានច្បាស់លាស់ពីអាជ្ញាធរមូលដ្ឋាន

-មានកិរិតវប្បធម៌ចាប់ពីថ្នាក់បរិញ្ញាបត្រ ឬប្រហាក់ប្រហែលផ្នែកសេដ្ឋកិច្ច ឬពាណិជ្ជកម្ម ឬនិតិសាស្ត្រ ឬវិញ្ញាបនប័ត្រផ្សេងៗទៀតដែលទាក់ទងនឹងអាជីវកម្ម ឬមានបទពិសោធន៍ពាក់ព័ន្ធទៅនឹងការគ្រប់គ្រងផ្នែកអាជីវកម្ម ឬធ្លាប់បំរើការងារផ្នែកនេះពីមុន ។

-មានសមត្ថភាពក្នុងការទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពទាំងការនិយាយ ការសរសេរ និងមានសមត្ថភាពក្នុងការរៀបចំរបាយការណ៍ដែលមានទំរង់បែបបទត្រឹមត្រូវ ។

-បង្ហាញពីម្ចាស់ភាគហ៊ុន នាយកក្រុមហ៊ុន អ្នកគ្រប់គ្រងផ្នែកផ្សេងៗ និងឈ្មោះបុគ្គលិកដែលបំរើការងារនៅក្នុងកន្លែងអាជីវកម្មអោយបានច្បាស់លាស់ ។

-បានបង់ថ្លៃអាជ្ញាប័ណ្ណដូចមានចែងក្នុងប្រការ ៦ នៃប្រកាសនេះ

-ភ្ជាប់គំរូស្លាកសញ្ញា និងត្រារបស់កន្លែងអាជីវកម្ម ព្រមទាំងហត្ថលេខារបស់អ្នកកាន់អាជ្ញាប័ណ្ណ

ការកំណត់លក្ខខណ្ឌផ្សេងទៀត អាចនឹងតម្រូវបន្ថែមដោយក្រសួង ។

## ប្រការ៩: លក្ខខណ្ឌនៃការមិនផ្តល់អាជ្ញាប័ណ្ណ

ក្រសួងមិនផ្តល់អាជ្ញាប័ណ្ណប្រកបអាជីវកម្មជូនអ្នកដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណទាំងឡាយណាដែលស្ថិតនៅក្នុងលក្ខខណ្ឌដូចខាងក្រោម :

-ផ្តល់ព័ត៌មានមិនពិតចំពោះចំណុចណាមួយដែលមានចែងក្នុងប្រការ ៨ នៃប្រកាសនេះ

-មិនបានផ្តល់ព័ត៌មានដែលខ្វះចន្លោះណាមួយដែលមានចែងក្នុងប្រការ៨ នៃប្រកាសនេះមកអោយក្រសួងក្នុង

រយៈពេល ១៥ថ្ងៃ (ដប់ប្រាំថ្ងៃ)បន្ទាប់ពីមានការស្នើសុំជាលាយលក្ខអក្សរពីក្រសួងដល់អ្នកដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ ។

**ប្រការ១០: ភារកិច្ចនានារបស់អាជីវករ (អ្នកកាន់អាជ្ញាប័ណ្ណ)**

អ្នកកាន់អាជ្ញាប័ណ្ណមានភារកិច្ចដូចតទៅ :

១-ត្រូវអនុវត្តគោរពតាមរាល់លិខិតបទដ្ឋានផ្សេងៗដែលចេញដោយក្រសួង

២-ត្រូវការពារ និងលើកកំពស់អត្ថប្រយោជន៍អតិថិជនរបស់ខ្លួន ហើយភារកិច្ចចំបងមួយទៀតគឺមិនត្រូវគេចវេសពីការទទួលខុសត្រូវចំពោះភាគីដទៃទៀតដែលពាក់ព័ន្ធក្នុងកិច្ចការអាជីវកម្មរបស់ខ្លួនឡើយ

៣-ត្រូវមានស្លាកសញ្ញាអាជីវកម្មនៅពីមុខកន្លែងធ្វើអាជីវកម្ម ហើយអាជ្ញាប័ណ្ណត្រូវរក្សានៅក្នុងហាង ឬក្រុមហ៊ុនដែលកំពុងប្រកបអាជីវកម្ម និងត្រូវដាក់តាំងនៅកន្លែងដែលងាយមើលឃើញ

៤-ត្រូវមានសៀវភៅចុះបញ្ជីទ្រព្យ សៀវភៅលោះទ្រព្យ និងសៀវភៅចំណូលចំណាយប្រចាំខែ និងឯកសារផ្សេងៗដែលពាក់ព័ន្ធ ។ ដោយទំរង់នៃសៀវភៅទាំងនោះនឹងមានបញ្ជាក់នៅក្នុងសៀវភៅបន្ទុក

៥-ត្រូវចេញកិច្ចសន្យាឱ្យទៅអតិថិជន ។ ទំរង់នៃកិច្ចសន្យានឹងមានបញ្ជាក់នៅក្នុងសៀវភៅបន្ទុក

៦-ត្រូវសរសេរជាលាយល័ក្ខអក្សរ ដើម្បីជៀសវាងការយល់ខុសពីគ្នាទៅវិញទៅមកនូវរាល់ការលើកលែងការសន្យា និងការធានាលើសេវាជាក់លាក់ណាមួយចំពោះអតិថិជន

៧-ត្រូវពិនិត្យអោយបានល្អិតល្អន់មុនពេលចុះហត្ថលេខាលើកិច្ចព្រមព្រៀងណាមួយ ដោយបញ្ជាក់ជូនទៅភាគីហត្ថលេខីអំពីភារកិច្ចដែលភាគីនីមួយៗត្រូវទទួលខុសត្រូវ

៨-ត្រូវរក្សាទុកទ្រព្យនៅកន្លែងមានសុវត្ថិភាព និងមិនត្រូវយកទ្រព្យនោះទៅប្រើប្រាស់ឡើយ

៩-អាជីវករត្រូវទទួលខុសត្រូវទាំងស្រុងចំពោះការខូចខាតលើទ្រព្យដែលកើតឡើងក្នុងអំឡុងពេលជាប់កិច្ចសន្យា

១០-ត្រូវផ្ដល់ជូនអតិថិជននូវសេវាប្រកបដោយការយកចិត្តទុកដាក់ខ្ពស់

១១-ត្រូវផ្ដល់ព័ត៌មានជាបន្ទាន់ឱ្យនគរបាល ឬសមត្ថកិច្ចពាក់ព័ន្ធ ក្នុងករណីមានការសង្ស័យបទល្មើសនៃអតិថិជន ឬទ្រព្យណាមួយ

១២-ត្រូវផ្ដល់ព័ត៌មាន ឬរាយការណ៍អំពីអត្តសញ្ញាណនៃអតិថិជន និងទ្រព្យ(សៀវភៅចុះបញ្ជីទ្រព្យ) ជូនប៉ុស្តិ៍នគរបាលរដ្ឋបាលសមត្ថកិច្ចដែលមានទីតាំងនៅជិតកន្លែងអាជីវកម្មយ៉ាងយូររយៈពេល ០៧ថ្ងៃ (ប្រាំពីរថ្ងៃ) បន្ទាប់ពីកាលបរិច្ឆេទទទួលទ្រព្យ

១៣-ត្រូវតាមដាននូវរាល់សភាពការណ៍ដែលអាចជះឥទ្ធិពលដល់លក្ខខណ្ឌទីផ្សារបច្ចុប្បន្ន ដើម្បីផ្ដល់ជាដំបូន្មានដល់អតិថិជនរបស់ខ្លួន និង/ឬដើម្បីជួយអតិថិជនក្នុងលក្ខណៈមួយដែលមានការទទួលខុសត្រូវ

១៤-ត្រូវធានាថារាល់ការព្រមព្រៀងដែលពាក់ព័ន្ធទៅនឹងកិច្ចសន្យា ត្រូវតែធ្វើឡើងជាលាយលក្ខអក្សរដោយប្រើប្រាស់ពាក្យពេចន៍ច្បាស់ៗ និងងាយយល់ ព្រមទាំងមានការបញ្ជាក់អោយបានច្បាស់លាស់នូវរាល់លក្ខខណ្ឌភារកិច្ច និង រាល់អនុសាសន៍ដែលភាគីពាក់ព័ន្ធបានព្រមព្រៀងគ្នា ។ រាល់កិច្ចសន្យាដែលបានពិនិត្យនិងចុះហត្ថលេខា ត្រូវតែថតចំលងដើម្បីចែកជូនដល់ភាគីដែលពាក់ព័ន្ធ

១៥-ត្រូវធានាថារាល់ការបង្ហាញនៅក្នុងការផ្សាយពាណិជ្ជកម្មគឺជាការពិត ហើយរាល់ការផ្សព្វផ្សាយអំពីទ្រព្យ

សម្បត្តិ ឬសេវាទាំងអស់ត្រូវតែមានបញ្ជាក់ពីអត្តសញ្ញាណរបស់កន្លែងអាជីវកម្ម និងឈ្មោះបុគ្គលដែលទទួលបានអាជ្ញាប័ណ្ណ

១៦-ត្រូវរក្សាទុកអោយបានល្អនូវសៀវភៅកត់ត្រា ឯកសារអាជីវកម្ម និងលិខិតស្នាមផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងប្រតិបត្តិការអាជីវកម្ម

១៧-ត្រូវបិទផ្សាយថ្ងៃ និងពេលវេលាម៉ោងធ្វើការរបស់ខ្លួន នៅនឹងច្រកទ្វារចេញ-ចូលនៃកន្លែងអាជីវកម្មឱ្យបានត្រឹមត្រូវ។ នៅថ្ងៃ ឬម៉ោងដែលប្រកាសបិទមិនធ្វើការនោះ មិនត្រូវទទួលបញ្ចាំ ឬទទួលប្រាតិភោគដោយអនុប្បទាន និងប្រមូលការប្រាក់ឡើយ ។ អាជីវករត្រូវជូនដំណឹងទៅក្រសួងអំពីការផ្លាស់ប្តូរពេលវេលាធ្វើការដែលបានបិទនៅលើច្រកទ្វារចេញ-ចូល

១៨-ត្រូវផ្តល់របាយការណ៍ពីប្រតិបត្តិការអាជីវកម្មដោយភ្ជាប់បញ្ជីទ្រព្យមកក្រសួងរៀងរាល់ខែ និងរៀងរាល់ដំណាច់ឆ្នាំ

១៩-មិនត្រូវផ្តល់ប្រាក់កម្ចីដល់អតិថិជន ០១ នាក់ ឬ ០១ ក្រុម លើសពី ២០% នៃដើមទុនអាជីវកម្មនោះឡើយ

២០-មិនត្រូវផ្តល់ប្រាក់កម្ចីលើសពី ២០.០០០.០០០ រៀល សំរាប់ឯកសារបញ្ជាក់សិទ្ធិកាន់កាប់អចលនវត្ថុ ឬឯកសារផ្សេងៗដែលជាកម្មវត្ថុយកមកដាក់បញ្ចាំ

២១-មិនត្រូវធ្វើអាជីវកម្មខុសពីឈ្មោះ ឬអាស័យដ្ឋានរបស់ខ្លួនដែលបានប្រើនៅក្នុងអាជ្ញាប័ណ្ណនោះទេ

២២-មិនត្រូវបង្កវាទប្បដិវាទក្នុងការធ្វើអាជីវកម្មជាមួយអាជីវករដទៃទៀតឡើយ

២៣-មិនត្រូវផ្តល់គំនិត ឬយោបល់ណាមួយដល់អតិថិជនក្រៅអំពីធុរៈកិច្ចនិងបទពិសោធន៍របស់ខ្លួនឡើយ

២៤-មិនអាចធ្វើការផ្លាស់ប្តូរទីកន្លែងធ្វើអាជីវកម្ម ដោយគ្មានការជូនដំណឹងជាមុនយ៉ាងតិច ៣០ថ្ងៃ (សាមសិបថ្ងៃ) ទៅក្រសួងបានឡើយ

២៥-មិនត្រូវទទួលយកទ្រព្យអ្វីមួយពីអនីតិជន ឬពីជនណាដែលកំពុងមានជាតិស្រវឹងជោគជាំក្នុងខ្លួន ឬពីជនណាដែលខ្លួនបានសង្ស័យថាជាចោរ ឬអ្នកទទួលផលចោរកម្ម។

២៦-មិនត្រូវឱ្យអតិថិជនផ្តិតមេដៃលើកិច្ចសន្យា ឬកំណត់ត្រាផ្សេងៗដែលមិនទាន់បានបំពេញត្រឹមត្រូវពេញលេញនោះឡើយ

២៧-មិនត្រូវធ្វើអាជីវកម្មដើម្បីបំរើដល់សកម្មភាពសំអាតប្រាក់ ឬបំរើផលប្រយោជន៍ដល់ភេរវករ ឬឧក្រិដ្ឋជនណាមួយឡើយ។ ក្នុងករណីដែលសង្កេតឃើញមានសកម្មភាពនេះ សាមីជនត្រូវរាយការណ៍ជាបន្ទាន់មកក្រសួង ឬអាជ្ញាធរមានសមត្ថកិច្ច

២៨-នៅពេលមានការស្នើសុំអោយផ្តល់យោបល់ ឬវាយតំលៃវត្ថុអ្វីមួយ អាជីវករត្រូវគិត និងធ្វើការវិភាគឱ្យបានល្អិតល្អន់នូវរាល់កត្តាដែលអាចជះឥទ្ធិពលដល់តំលៃវត្ថុត្រូវដាក់បញ្ចាំ ឬដាក់ប្រាតិភោគដោយអនុប្បទាន មុននឹងជំរាបជូនដល់អតិថិជនរបស់ខ្លួន។

## ប្រការ១១: ការផ្ទេរអាជ្ញាប័ណ្ណ

អាជ្ញាប័ណ្ណមិនអាចផ្ទេរទៅអោយអ្នកផ្សេងបានឡើយ លុះត្រាតែមានការអនុញ្ញាតពី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ១២: ការផ្អាកសកម្មភាពអាជីវកម្ម និងការបញ្ឈប់អាជីវកម្ម**

ក្នុងករណីផ្អាក ឬបញ្ឈប់សកម្មភាពអាជីវកម្ម អ្នកកាន់អាជ្ញាប័ណ្ណត្រូវដាក់សំណើជាលាយល័ក្ខអក្សរដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធ ព្រមទាំងបញ្ជាក់អំពីមូលហេតុអោយបានត្រឹមត្រូវមកក្រសួងក្នុងរយៈពេល ៣០ថ្ងៃ (សាមសិបថ្ងៃ) មុនអាជីវកម្មត្រូវបានផ្អាក ឬបញ្ឈប់សកម្មភាពជាស្ថាពរ។ ការសំរេចលើការផ្អាក ឬបញ្ឈប់សកម្មភាពអាជីវកម្មជាសិទ្ធិរបស់ក្រសួង។

ក្រោយពីបញ្ឈប់អាជីវកម្មហើយ អ្នកកាន់អាជ្ញាប័ណ្ណត្រូវប្រគល់អាជ្ញាប័ណ្ណមកក្រសួងវិញ ។

**ប្រការ១៣: ការព្យួរ ឬដកហូតអាជ្ញាប័ណ្ណ**

ក្រសួងមានសិទ្ធិព្យួរ ឬដកហូតអាជ្ញាប័ណ្ណមកវិញ នៅពេលដែលអ្នកកាន់អាជ្ញាប័ណ្ណបានប្រព្រឹត្តដូចករណីណាមួយដូចខាងក្រោម :

-ពុំបានអនុវត្តអោយបានត្រឹមត្រូវទៅតាមខ្លឹមសារនៃប្រកាសនេះឬលិខិតបទដ្ឋានផ្សេងៗទៀតដែលចេញដោយក្រសួង

-ក្រោយពីទទួលបានការណែនាំពីក្រសួងព្រមទាំងទទួលពិន័យរដ្ឋបាលហើយ អ្នកកាន់អាជ្ញាប័ណ្ណនៅតែបន្តប្រព្រឹត្តល្មើសទៅនឹងលក្ខខណ្ឌទាំងឡាយដែលមានចែងក្នុងប្រកាសនេះ

-អ្នកកាន់អាជ្ញាប័ណ្ណខកខានមិនបានបំពេញកាតព្វកិច្ចហិរញ្ញវត្ថុរួមមាន កាតព្វកិច្ចបង់ពន្ធ និងចំណូលផ្សេងៗជូនរដ្ឋ ចាប់ពី ០២ ខែ (ពីរខែ) ជាប់គ្នា

-ករណីកន្លែងអាជីវកម្មក្ស័យធន ឬប្រព្រឹត្តិបទល្មើសក្នុងការធ្វើអាជីវកម្មណាមួយ ក្រសួងនឹងជូនដំណឹងជាលាយលក្ខ័អក្សរ ៣០ថ្ងៃ (សាមសិបថ្ងៃ) មុន ចំពោះកន្លែងអាជីវកម្មដែលនឹងត្រូវដកហូតអាជ្ញាប័ណ្ណ និងចុះផ្សាយអោយសាធារណៈជនបានជ្រាប ឬអាចស្នើទៅតុលាការដើម្បីរឹបអូស ឬឃាត់ទុកវត្ថុដែលដាក់បញ្ចាំ ឬដាក់ប្រាតិភោគដោយអនុប្បទាន ។

**ប្រការ១៤: ការចាត់ចែងលើទ្រព្យ**

-ក្នុងករណីអតិថិជនពុំមានលទ្ធភាពសងប្រាក់កម្ចី និងការប្រាក់តាមការកំណត់នៅពេលកិច្ចសន្យាដល់កាលវសាន្ត ការចាត់ចែងលើទ្រព្យមានដូចខាងក្រោម:

+សំរាប់អាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ ទ្រព្យបញ្ចាំនឹងត្រូវចាត់ចែងតាមនីតិវិធីច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

+សំរាប់អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន ទ្រព្យប្រាតិភោគដោយអនុប្បទាននឹងត្រូវចាត់ចែងតាមលទ្ធភាពជាក់ស្តែង ឬនីតិវិធីច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

-ក្នុងករណីអតិថិជនបានសងប្រាក់កម្ចី និងការប្រាក់គ្រប់ចំនួនដូចមានចែងក្នុងកិច្ចសន្យា នោះអាជីវករត្រូវប្រគល់ទ្រព្យទៅឱ្យអតិថិជនវិញភ្លាម ។

អាជីវករមិនមានសិទ្ធិលក់ ផ្ទេរ ឬប្រគល់សិទ្ធិកាន់កាប់ទ្រព្យអោយទៅអ្នកផ្សេងក្នុងកំឡុងពេលដែលទ្រព្យនេះកំពុងជាប់កិច្ចសន្យា លុះត្រាតែមានការឯកភាពពីអតិថិជន។

**ប្រការ១៥: ការកំណត់អត្រាការប្រាក់ និង រយៈពេលបញ្ចាំ**

-អត្រាការប្រាក់ត្រូវបានកំណត់តាមការព្រមព្រៀងរវាងអាជីវករ និងអតិថិជន។ ប៉ុន្តែការព្រមព្រៀងលើអត្រាការប្រាក់នេះមិនត្រូវអោយផ្ទុយពីច្បាប់កំណត់នោះឡើយ ។

-កិច្ចសន្យាមានរយៈពេលយ៉ាងយូរត្រឹម ០៤ ខែ (បួនខែ) ចាប់ពីថ្ងៃបរិច្ឆេទនៃការដាក់ទ្រព្យ និងអាចបន្តសុពលភាពបាន ។

**ប្រការ១៦: ការបង់ពន្ធលើអាជីវកម្ម**

អាជីវករត្រូវបង់ពន្ធទៅអគ្គនាយកដ្ឋានរតនាគារជាតិ តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ១៧: ការបង្កើតសាខា**

អាជីវករអាចបង្កើតសាខាបាន លុះត្រាតែមានការអនុញ្ញាតពីក្រសួង ហើយត្រូវសុំអាជ្ញាប័ណ្ណសម្រាប់សាខាអាជីវកម្មដោយបំពេញលក្ខខណ្ឌទាំងឡាយដូចមានចែងនៅក្នុងប្រការ ៨ នៃប្រកាសនេះ។

**ប្រការ១៨: របាយការណ៍អាជីវកម្មប្រចាំខែ**

អាជីវករត្រូវផ្តល់ស្ថិតិ និងរបាយការណ៍អាជីវកម្មប្រចាំខែមកក្រសួងមិនអោយលើសពី ១៥ថ្ងៃ នៃខែ បន្ទាប់។ ស្ថិតិ និងរបាយការណ៍នោះត្រូវបញ្ជាក់ថាពិត និងត្រឹមត្រូវដោយអ្នកកាន់អាជ្ញាប័ណ្ណ ។

**ប្រការ១៩: របាយការណ៍អាជីវកម្មប្រចាំឆ្នាំ**

ក្នុងរយៈពេល ០៣ ខែ (បីខែ) ក្រោយពីបញ្ចប់ឆ្នាំនីមួយៗ អាជីវករត្រូវផ្តល់ឱ្យក្រសួងនូវរបាយការណ៍អាជីវកម្ម នៃឆ្នាំសារពើពន្ធកន្លងមក ។

**ប្រការ២០: ការត្រួតពិនិត្យបញ្ជី**

ក្រសួងអាចចាត់មន្ត្រីជំនាញ ដើម្បីចុះត្រួតពិនិត្យឯកសារផ្សេងៗដែលពាក់ព័ន្ធទៅនឹងការធ្វើអាជីវកម្មតាមការចាំបាច់ ។ អាជីវករត្រូវសហការ និងបង្កលក្ខណៈងាយស្រួលដល់មន្ត្រីរបស់ក្រសួង ។

**ប្រការ២១: ការផាកពិន័យរដ្ឋបាល**

អាជីវករទាំងឡាយណាដែលល្មើសទៅនឹងបទប្បញ្ញត្តិ និងលក្ខខណ្ឌនានាដែលមានចែងក្នុងប្រកាសនេះនឹងត្រូវទទួលទណ្ឌកម្មដូចជា ទទួលការផាកពិន័យ ការព្យួរ ឬការដកហូតអាជ្ញាប័ណ្ណ ដូចមានចែងនៅក្នុងសៀវភៅបន្ទុក។ ក្នុងករណីចាំបាច់ក្រសួងមានសិទ្ធិប្តឹងទៅតុលាការដើម្បីអនុវត្តទណ្ឌកម្មខាងលើ ។

**ប្រការ២២: ការអនុវត្តតាមសៀវភៅបន្ទុក**

អ្នកកាន់អាជ្ញាប័ណ្ណត្រូវអនុវត្តរាល់លក្ខខណ្ឌដែលមានចែងនៅក្នុងសៀវភៅបន្ទុក ស្តីពីលក្ខខណ្ឌអនុវត្តអាជ្ញាប័ណ្ណសំរាប់អាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន។

**ប្រការ២៣: អវសានប្បញ្ញត្តិ**

បទប្បញ្ញត្តិ ឬ លិខិតបទដ្ឋានទាំងឡាយណាដែលផ្ទុយពីប្រកាសនេះត្រូវទុកជានិរាករណ៍ ។

## ប្រការ២៤: ការអនុវត្តប្រកាស

អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងគ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កន្លែងអាជីវកម្ម និងបុគ្គលដែលពាក់ព័ន្ធ ត្រូវអនុវត្ត និងប្រតិបត្តិតាមខ្លឹមសារនៃប្រកាសនេះអោយមានប្រសិទ្ធិភាពខ្ពស់ ។

## ប្រការ២៥: សុពលភាពនៃការអនុវត្តប្រកាស

ប្រកាសនេះមានតំលៃអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

**ចំលងជូន :**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- សាលារាជធានី ខេត្ត

  "ដើម្បីជូនជ្រាប និងសហការអនុវត្ត"
- ដូចមានក្នុងប្រការ ២៤

  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ